សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université royale de droit et des sciences économiques

Royal University of Law and Economic


## សារណាបញ្ចប់ការសិក្សា

# សិទ្ធិរបស់ទណ្ឌិតនៅក្នុងពន្ធនាគារ នៃព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្ន

ស្រាវជ្រាវ ពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣


រៀបរៀងដោយ

និស្សិតឈ្មោះ កញ្ញា **យ៉េង មួយណេង**

កញ្ញា **ណាន់ ម៉ារ៉ា**

ណែនាំដោយ

លោក **រុន ពណ្ណារិទ្ធ**



ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ

ជំនាន់ទី ២៣

ឆ្នាំចូលសិក្សា ២០១៩

ឆ្នាំសរសេរសារណា ២០២៣

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université royale de droit et des sciences économiques

Royal University of Law and Economic


**សារណាបញ្ចប់ការសិក្សា**

# សិទ្ធិរបស់ទណ្ឌិតនៅក្នុងពន្ធនាគារ នៃព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្ន

ស្រាវជ្រាវ ពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣


រៀបរៀងដោយ

និស្សិតឈ្មោះ កញ្ញា **យ៉េង មួយលេង**

កញ្ញា **ណាន់ ម៉ារ៉ា**

ណែនាំដោយ

លោក **រុន ពន្លឺរ៉ាវិទ្ធ**


ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ

ជំនាន់ទី ២៣

ឆ្នាំចូលសិក្សា ២០១៩

ឆ្នាំសរសេរសារណា ២០២៣

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **យ៉េង មួយឈេង** និង **ឈាន់ ម៉ារ៉ា** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ជំនាន់ទី២៣ ឆ្នាំសិក្សា២០២២-២០២៣ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

**យើងខ្ញុំសូមលំឱនកាយសម្តែងនូវកត្តញ្ញូតាធម៌យ៉ាងជ្រាលជ្រៅ និងខ្ពង់ខ្ពស់ជាទីបំផុតចំពោះ**

| | | | |
|---|---|---|---|
| លោកឪពុក | **អែម មុយយ៉េង** | លោកឪពុក | **ឈាន់ ឡាំបុង** |
| អ្នកម្តាយ | **ម៉ុក ចាន់ធឿន** | អ្នកម្តាយ | **ភន្ទេង នុត** |

អ្នកមានគុណទាំងពីរដែលបានផ្តល់កំណើត ចិញ្ចឹម បីបាច់ថែរក្សា អប់រំប្រៀនប្រដៅ ប្រកបដោយព្រហ្មវិហារធម៌ទាំង៤ និងបានលះបង់អស់ពីកម្លាំងកាយចិត្ត ដើម្បីធ្វើយ៉ាងណាឱ្យយើងខ្ញុំមានឱកាសបានសិក្សារៀនសូត្ររហូតដល់ថ្នាក់បរិញ្ញាបត្រ។ យើងខ្ញុំនៅតែចងចាំជាប់ជានិច្ច មិនអាចបំភ្លេចបានពីគុណនូបការៈរបស់អ្នកមានគុណទាំងទ្វេព្រមទាំងលោកគ្រូ និងអ្នកគ្រូដែលបានបង្ហាត់បង្រៀនផ្តល់នូវពុទ្ធិទាំងចរិយាមាយាទតាំងពីថ្នាក់បឋមរហូតមកដល់សាកលវិទ្យាល័យ។

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ៖

- សាកលវិទ្យាធិការ **លុយ ចណ្ណា** សាកលវិទ្យាធិការរង ព្រឹទ្ធបុរស លោក លោកស្រីសាស្ត្រាចារ្យ បណ្ណារក្ស និងបុគ្គលិកទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែលបានខិតខំអស់ពីសមត្ថភាពដើម្បីគ្រប់គ្រង និងពង្រឹងនូវការអប់រំនៅថ្នាក់ឧត្តមសិក្សានេះ ព្រមទាំងបានចែករំលែកចំណេះដឹង និងបទពិសោធន៍ល្អៗដល់រូបយើងខ្ញុំ។
- ជាពិសេសសូមគោរព និងថ្លែងអំណរគុណជាទីបំផុតចំពោះ លោកគ្រូណែនាំ **រុន ពណ្ណារិទ្ធ** ជាលោកគ្រូណែនាំក្នុងការសរសេរសារណាបញ្ចប់ការសិក្សារនេះឡើងដោយលោកបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការណែនាំ និងផ្តល់យោបល់ទាក់ទងនឹងខ្លឹមសារនៃប្រធានបទសារណានេះ។

ជាទីបញ្ចប់ យើងខ្ញុំសូមបួងសួងដល់អស់វត្ថុស័ក្តិសិទ្ធិ និងទេពតារក្សាជម្ពូទ្វីបនេះ សូមប្រសិទ្ធិពរជ័យដល់អ្នកមានគុណទាំងអស់ ឱ្យជួបប្រទះតែសេចក្តីសុខសុភមង្គល និងប្រកបដោយពុទ្ធពរទាំងប្រាំប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ និង បដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ជាការពិតណាស់ អ្វីៗទាំងអស់អាចសម្រេចទៅបានអាស្រ័យលើការខិតខំ ប្រឹងប្រែង និងព្យាយាមកសាងឡើង។ ឆ្លៀតក្នុងឱកាសនេះ យើងខ្ញុំពិតជាមានអារម្មណ៍ត្រេកអរណាស់ដែលយើងខ្ញុំមានឱកាសបានសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ តាមការកំណត់របស់ការិយាល័យស្រាវជ្រាវនៃសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែលនេះគឺជាស្នាដៃសមិទ្ធផលនៃការខិតខំប្រឹងប្រែងរៀនសូត្រនៃថ្នាក់ឧត្តមសិក្សាចាប់តាំងពីថ្នាក់សិក្សាឆ្នាំមូលដ្ឋានរហូតមកដល់ថ្នាក់បញ្ចប់បរិញ្ញាបត្រនេះដែលមានប្រធានបទស្ដីពី "**សិទ្ធិរបស់ទណ្ឌិតនៅក្នុងពន្ធនាគារនៃព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្ន**" មកធ្វើជាកម្មវត្ថុនៃការស្រាវជ្រាវក្នុងការបញ្ចប់ឆ្នាំសិក្សានេះ។ ក្នុងសារណាមួយច្បាប់នេះ យើងខ្ញុំទាំងពីរនាក់បានស្រាវជ្រាវ និងដកស្រង់ចេញពីបណ្ដាឯកសារមួយចំនួនដែលពាក់ព័ន្ធនៅក្នុងបណ្ណាល័យព្រមទាំងប្រភពឯកសារផ្សេងៗទៀតដែលអាចជាគំនិត និងប្រាប់ពីចំណុចសំខាន់ៗដែលទាក់ទងនឹងប្រធានបទនេះ។ ជាពិសេសយើងខ្ញុំក៏បានទទួលនូវការណែនាំយ៉ាងយកចិត្តទុកដាក់ពីសំណាក់លោកគ្រូណែនាំ **រុន ពណ្ណារិទ្ធ** ដែលលោកជាអ្នកដឹកនាំក្នុងការស្វែងរកនូវឯកសារក៏ដូចជាផ្ដល់ជាគំនិតយោបល់ចំពោះប្រធានបទខាងលើ។

យ៉ាងណាមិញ ចំពោះសារណាដែលយើងខ្ញុំបានធ្វើយើងខ្ញុំជឿជាក់ថា វានឹងក្លាយជាឯកសារមួយដែលអាចជំនួយដល់មិត្តអ្នកអាន ក្នុងការយល់ដឹងបន្ថែមពីសិទ្ធិទូទៅរបស់ទណ្ឌិតនៅក្នុងអំឡុងពេលអនុវត្តទោស សិទ្ធិទទួលបានការដោះលែងដោយមានលក្ខខណ្ឌ និងការបន្ធូរបន្ថយ ឬលើកលែងទោស សិក្សាឈ្វេងយល់ពីសិទ្ធិក្នុង។ ម៉្យាងវិញទៀត ក្រោយពីបានសិក្សាស្រាវជ្រាវ និងចងក្រងអត្ថបទនេះរួច យើងខ្ញុំក៏បានយល់ដឹងថែមមួយកម្រិតទៀតនូវចំណុចសំខាន់ៗនូវសិទ្ធិ កាតព្វកិច្ច និងការកំណត់អំពីកម្រិតដែលអាចធ្វើការដោះលែង និងបន្ធូរបន្ថយលើកលែងទោសបានដែលអាចជួយឱ្យយើងខ្ញុំបានដើរទៅតាមអ្វីដែរច្បាប់បានចង្អុលបង្ហាញ និងបានស្វែងយល់ពីវាផង។

ទោះជាយ៉ាងណាក៏ដោយ ការសរសេរសារណាមួយនេះរមែងមានកំហុសត្រង់ប្រការណាមួយដោយជៀសពុំផុតឡើយលើអត្ថន័យខ្លឹមសារ និងអក្ខរាវិរុទ្ធ ហេតុដូច្នេះយើងខ្ញុំសូមអភ័យទោសទុកជាមុនហើយរង់ចាំទទួលយកនូវការរិះគុណដើម្បីស្ថាបនាក៏ដូចជាការណែនាំបំពេញបន្ថែមពីសំណាក់សាស្ត្រាចារ្យ សិស្ស និស្សិត និងអ្នកសិក្សាទាំងអស់ដោយក្ដីសោមនស្សរីករាយ។

# មាតិកា

ទំព័រ

**មាតិកា** ........................................................................................ i

**សេចក្តីផ្តើម** ........................................................................................ ១

## ជំពូកទី១

## សិទ្ធិរបស់ទណ្ឌិតទូទៅក្នុងពន្ធនាគារ

**ផ្នែកទី១. ពន្ធនាគារ** ........................................................................................ ៥

១.១. រចនាសម្ព័ន្ធគ្រប់គ្រង និងមុខងាររបស់ពន្ធនាគារកម្ពុជា........................................................................................ ៥

១.១.១. រចនាសម្ព័ន្ធគ្រប់គ្រង និងការរៀបចំ ........................................................................................ ៥

១.១.២. មុខងាររបស់ពន្ធនាគារ ........................................................................................ ១០

១.១.២.១. ការអប់រំ ........................................................................................ ១០

១.១.២.២. ការបណ្តុះបណ្តាលវិជ្ជាជីវៈ ........................................................................................ ១២

១.១.២.៣. តម្លាភាព ........................................................................................ ១២

១.១.២.៤. ការជ្រើសរើសកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈសមរម្យ ........................................................................................ ១៣

១.២. ស្ថានភាពទូទៅរបស់ពន្ធនាគារកម្ពុជា ........................................................................................ ១៤

១.២.១. ស្ថានភាពទូទៅរបស់ទណ្ឌិតនៅក្នុងពន្ធនាគារ ........................................................................................ ១៤

១.២.២. ស្ថានភាពនៃការឃុំឃាំង ........................................................................................ ១៦

១.២.២.១. កំណើននៃអាត្រាជនជាប់ឃុំ........................................................................................ ១៧

១.២.២.២. កត្តារួមផ្សំបណ្តាលឱ្យមានភាពចង្អៀតណែនក្នុងពន្ធនាគារ........................................................................................ ១៩

**ផ្នែកទី២. សិទ្ធិរបស់ទណ្ឌិតជាទូទៅក្នុងអំឡុងពេលអនុវត្តទោស** ........................................................................................ ២០

១.១. សិទ្ធិក្នុងការរស់នៅ ........................................................................................ ២០

១.១.១. សិទ្ធិទទួលបាននូវសម្លៀកបំពាក់ និងសម្ភារៈប្រើប្រាស់ចាំបាច់........................................................................................ ២១

១.១.២. សិទ្ធិទទួលបានអាហារ និងទឹក ........................................................................................ ២២

១.១.៣ សិទ្ធិទទួលបានផ្នែកសេវាសុខាភិបាល........................................................................................ ២៣

១.១.៤. សិទ្ធិទទួលបានរបបជីវភាព ........................................................................................ ២៤

១.១.៥. សិទ្ធិរក្សាទុក និងប្រើប្រាស់ទ្រព្យសម្បត្តិផ្ទាល់ខ្លួន........................................................................................ ២៥

១.២. សិទ្ធិខាងវប្បធម៌........................................................................................ ២៥

១.២.១. សិទ្ធិខាងជំនឿសាសនា ........................................................................................ ២៦

១.២.២. សិទ្ធិខាងចូលរួមកម្មវិធីសិក្សាអប់រំ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ........................................ ២៦

១.៣. សិទ្ធិខាងព័ត៌មាន ........................................ ២៧

១.៣.១. សិទ្ធិទទួលបានព័ត៌មាន និងស្វ័យសិក្សា ........................................ ២៧

១.៣.២. សិទ្ធិទទួលបានការប្រាស្រ័យទាក់ទង ........................................ ២៨

១.៤. សិទ្ធិខាងសេរីភាព ........................................ ២៩

១.៤.១. សិទ្ធិរបស់ទណ្ឌិតប្ដឹងតវ៉ាចំពោះអំពើរំលោភរបស់ទណ្ឌិតដូចគ្នា និងមន្ត្រីពន្ធនាគារ ........................................ ២៩

១.៤.២. សិទ្ធិរួចផុតពីការធ្វើទារុណកម្ម ........................................ ២៩

១.៤.៣. សិទ្ធិរួចផុតពីការដាក់ខ្នោះ ........................................ ៣០


## ជំពូកទី២

## សិទ្ធិរបស់ទណ្ឌិតក្នុងលក្ខខណ្ឌពិសេសក្នុងពន្ធនាគារ


**ផ្នែកទី១. សិទ្ធិរបស់ទណ្ឌិតជាអនីតិជន** ........................................ ៣២

១.១. សិទ្ធិទទួលបានការបែងចែងគ្រប់គ្រងអនីតិជនក្នុងមណ្ឌលឃុំនីតិសម្បទា ........................................ ៣២

១.២. សិទ្ធិទទួលបានសេវាសម្រាប់អនីតិជនក្នុងមណ្ឌលឃុំនីតិសម្បទា ........................................ ៣៣

១.៣. សិទ្ធិទទួលបានការដោះលែងដោយមានលក្ខខណ្ឌ ........................................ ៣៣

១.៤. សិទ្ធិទទួលបានការផ្ដល់ និងការមាននីតិសម្បទាឡើងវិញ ........................................ ៣៤

១.៤.១. លក្ខខណ្ឌលើរយៈពេលទាក់ទងនឹងពាក្យសុំឱ្យមានការផ្ដល់នីតិសម្បទាឡើងវិញតាមផ្លូវតុលាការ... ៣៤

១.៤.២. ការមាននីតិសម្បទាឡើងវិញដោយពេញលក្ខណៈច្បាប់ ........................................ ៣៤

**ផ្នែកទី២. សិទ្ធិរបស់ទណ្ឌិតជាស្ត្រីមានគភ៌ ម្ដាយបំបៅកូនដោយទឹកដោះ និងម្ដាយរស់នៅជាមួយកូនក្នុងពន្ធនាគារ** ........................................ ៣៤

**ផ្នែកទី៣. សិទ្ធិរបស់ទណ្ឌិតជាជនបរទេស** ........................................ ៣៦


## ជំពូកទី៣

## សិទ្ធិផ្សេងៗទៀតរបស់ទណ្ឌិត


**ផ្នែកទី១. សិទ្ធិទទួលបានការដោះលែងដោយមានលក្ខខណ្ឌ** ........................................ ៣៨

១.១. លក្ខខណ្ឌទាក់ទងនឹងគំនិតមាយាទ ........................................ ៣៨

១.២. លក្ខខណ្ឌទាក់ទងនឹងថិរវេលានៃទោសដែលត្រូវបានទទួលរួចរាល់ហើយ ........................................ ៣៨

១.៣. សមត្ថកិច្ច និងសេចក្ដីសម្រេចសម្រាប់ផ្ដល់ការដោះលែងដោយមានលក្ខខណ្ឌ ........................................ ៣៨

១.៤. ការដោះលែងដោយភ្ជាប់លក្ខខណ្ឌជាកាតព្វកិច្ច ........................................ ៣៩

១.៥. វិធានការឃ្លាំមើល តាមដាន និងត្រួតពិនិត្យការអនុវត្តដីកាសម្រេច ........................................ ៤០

**ផ្នែកទី២. សិទ្ធិទទួលបានការលើកលែងទោស ឬ ការបន្ធូរបន្ថយទោស** ........ ៤១
២.១. លក្ខខណ្ឌសម្រាប់ធ្វើការលើកលែងទោស និងបន្ធូរបន្ថយទោស ........ ៤១
២.១.១. លក្ខខណ្ឌទូទៅនៃការបន្ធូរបន្ថយទោស និងការលើកលែងទោស ........ ៤១
២.១.២. លក្ខខណ្ឌដោយឡែកនៃការបន្ធូរបន្ថយទោស........ ៤២
២.១.៣. លក្ខខណ្ឌដោយឡែកនៃការលើកលែងទោស........ ៤៣
២.២. រយៈពេលនៃការបន្ធូរបន្ថយទោស ........ ៤៣
២.៣. ឱកាសនៃការលើកលែងទោស និងបន្ធូរបន្ថយទោស ........ ៤៤
២.៤. នីតិវិធីនៃការស្នើសុំលើកលែងទោស និងបន្ធូរបន្ថយទោស........ ៤៤
២.៤.១. គណៈកម្មការដែលរៀបចំដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ........ ៤៤
២.៤.២. គណៈកម្មការដែលរៀបចំដោយអគ្គនាយនៃអគ្គនាយកដ្ឋានពន្ធនាគារនៃក្រសួងមហាផ្ទៃ ........ ៤៥
២.៤.៣. គណៈកម្មការថ្នាក់ជាតិរៀបចំដោយរាជរដ្ឋាភិបាល........ ៤៥
២.៤.៤. ការលើកលែងទោសដោយបុព្វសិទ្ធិ........ ៤៦
២.៥. ការអនុវត្តព្រះរាជក្រឹត្យបន្ធូរបន្ថយទោស និងលើកលែងទោស ........ ៤៦
**សេចក្ដីសន្និដ្ឋាន** ........ ៤៧
**អនុសាសន៍** ........ ៤៩
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំនៃការស្រាវជ្រាវ

នៅក្នុងសង្គមបច្ចុប្បន្ននេះ មនុស្សមួយចំនួនបានប្រព្រឹត្តអំពើល្អធ្វើឱ្យសង្គមមានការរីកចម្រើនចំណែកឯមនុស្សខ្លះទៀត បានប្រព្រឹត្តនូវទង្វើមិនល្អដែលធ្វើឱ្យប៉ះពាល់ទៅដល់ផលប្រយោជន៍អ្នកដទៃបង្កព្យសនកកម្មក្នុងសង្គមបានបង្កឱ្យមានភាពរីករវដោយសារសកម្មភាពផ្ទុយច្បាប់របស់ពួកគេ។ ជាក់ស្តែងនៅក្នុងទំនាក់ទំនងជីវភាពរស់នៅប្រចាំថ្ងៃមនុស្សគ្រប់រូបបានព្យាយាមគ្រប់មធ្យោបាយធ្វើយ៉ាងណាដើម្បីឱ្យខ្លួនទទួលបាននូវផលប្រយោជន៍ ដែលជាតម្រូវការរបស់ខ្លួន យ៉ាងណាមិញនូវរាល់គ្រប់មធ្យោបាយទាំងនោះតែងតែឆ្លុះបញ្ចាំពីទង្វើក៏ដូចជាទំនាក់ទំនងមួយចំនួនដែលបង្កជាបញ្ហាជាច្រើនដែលអាចកើតមកពីអំពើផ្ទុយច្បាប់មានដូចជា អំពើកេងប្រវ័ញ្ច លួច រំលោភសេពសន្ថវៈ ឆបោក ឬការប្រើប្រាស់នូវអំពើហិង្សាជាដើមដែលជាហេតុបង្កឱ្យមានវិវាទរវាងភាគីជាអ្នកប្រព្រឹត្ត និងភាគីជាអ្នករងគ្រោះ។

អំពើទាំងអស់នេះវាមិនត្រឹមតែធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍ដល់មនុស្សគ្រប់រូបតែប៉ុណ្ណោះទេ ប៉ុន្តែវាបានធ្វើឱ្យប៉ះពាល់សង្គមទាំងមូល។ ជារួម ដើម្បីធ្វើការដោះស្រាយនូវរាល់អស្ថេរភាពទាំងអស់នេះកម្ពុជាបានបង្កើតឱ្យមាននរបាំងការពារសង្គមដែលជាបទដ្ឋានគតិយុត្តដែលចាប់បង្ខំឱ្យបុគ្គលគ្រប់រូបនៅក្នុងសង្គមធ្វើការអនុវត្តឱ្យបានខ្ជាប់ខ្ជួន។ ប៉ុន្តែទោះបីជាមានច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាច្រើនត្រូវបានកំណត់ និងផ្សព្វផ្សាយជាសាធារណៈ អំពើបញ្ហាទាំងអស់នេះយ៉ាងណាក៏ដោយនៅតែមានបុគ្គលមួយចំនួននៅតែធ្វើការប្រព្រឹត្តបទល្មើសដែលផ្ទុយនឹងស្ថេរភាព សណ្តាប់ធ្នាប់ សាធារណៈដែលជាបទល្មើសប្រឆាំងនឹងបុគ្គល បទល្មើសប្រឆាំងនឹងទ្រព្យសម្បត្តិ និងប្រព្រឹត្តបទល្មើសប្រឆាំងនឹងជាតិ។ រាល់គ្រប់អំពើផ្ទុយនឹងបទដ្ឋានគតិយុត្តទាំងអស់នោះ ជាបទល្មើលព្រហ្មទណ្ឌដែលមានចែងនៅក្នុងច្បាប់សារធាតុ និងបទដ្ឋានគតិពាក់ព័ន្ធផ្សេងៗទៀត។ បន្ទាប់ពីមានបទល្មើសណាមួយកើតឡើងភាគីដែលជាជនរងគ្រោះនៅក្នុងអំពើនោះនឹងធ្វើការប្តឹងទាមទារយុត្តិធម៌ទៅតុលាការដែលមានសមត្ថកិច្ច ដើម្បីទាមទារសិទ្ធិ និងការសំណងនៃការខូចខាតដែល ជនល្មើសបានប្រព្រឹត្តនោះ។

សមត្ថកិច្ចក្នុងការស្វែងរកយុត្តិធម៌ជូនជនរងគ្រោះពីអំពើផ្ទុយច្បាប់នោះ តាមផ្លូវច្បាប់ត្រូវធ្វើការឆ្លងកាត់តាមនីតិវិធីនៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលមានជាធរមាននៅក្នុងព្រះរាជាណាចក្រកម្ពុជាដែលជាសមត្ថកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌ សាលាដំបូង សាលាឧទ្ធរណ៍ និងតុលាការកំពូល ដើម្បីស្វែងរកយុត្តិធម៌ជូនដល់ជនរងគ្រោះ និងធ្វើការកាត់ទោសទៅលើជនដែលបានប្រព្រឹត្តផ្ទុយនឹងច្បាប់មានជាធរមានទៅតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

ជាទូទៅនៅក្នុងសង្គមបច្ចុប្បន្នមនុស្សទាំងឡាយមានការយល់ដឹង និងទំនាក់ទំនងគ្នាក្នុងគោលដៅស្វែងរកនូវផលចំណេញរៀងៗខ្លួនពាក់ព័ន្ធទៅនឹងជីវភាពរស់នៅប្រចាំថ្ងៃ សកម្មភាពទាំងអស់នោះអាចជាសកម្មភាពសុចរិត និងសកម្មភាពទុច្ចរិតជាដើម។ ប្រសិនបើអំពើនោះជាអំពើទុច្ចរិតវានឹងបង្កឱ្យសង្គមមានភាពចលាចល ដោយសារតែបុគ្គលដែលប្រព្រឹត្តផ្ទុយនឹងច្បាប់ទាំងអស់នោះ បុគ្គលទាំងនោះត្រូវបានកំណត់ដោយច្បាប់ថាជាជនល្មើសហើយ

តុលាការនឹងស្វែងរកពិរុទ្ធភាពរបស់ជនល្មើសនោះ ដើម្បីធ្វើការកាត់ទោសទៅតាមស្ថានទម្ងន់នៃទោស និងប្រភេទនៃបទល្មើសដែលជននោះបានប្រព្រឹត្តស្របតាមគោលការណ៍ឯកត្តកម្មនៃទោសដែលមានចៅក្រមជាអ្នកសម្រេចសេចក្ដីតាមរយៈសាលក្រមជាស្ថាពរដែលជាសេចក្ដីចុងក្រោយក្នុងការកាត់ទោសទៅលើជនដែលបានប្រព្រឹត្តផ្ទុយនឹងច្បាប់ទាំងនោះគេហៅថាជា "**ទណ្ឌិត**" ។

បន្ទាប់ពីការសម្រេចទោសចូលជាស្ថាពររួចរាល់នោះ នីតិវិធីបន្ទាប់គឺជាការអនុវត្តទោសទៅលើជនជាទណ្ឌិតនោះទៅតាមសេចក្ដីសម្រេចរបស់តុលាការ។ ថ្វីត្បិតតែទណ្ឌិតបានប្រព្រឹត្តល្មើសនឹងច្បាប់ដែលមានជាធរមានក៏ពិតមែនប៉ុន្តែយើងសង្កេតឃើញថាមានលិខិតបទដ្ឋានជាតិ និងអន្តរជាតិមួយចំនួនបានចែងអំពីសិទ្ធិរបស់ទណ្ឌិតត្រូវទទួលបានដែលមានកំណត់ដូចជា រដ្ឋធម្មនុញ្ញ លិខិតបទដ្ឋានគតិយុត្តិអន្តរជាតិ ច្បាប់ជាតិ និងច្បាប់ពាក់ព័ន្ធមួយចំនួនទៀតដែលមានជាធរមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ២. ចំណោទបញ្ហា

ជាទូទៅ មនុស្សគ្រប់រូបត្រូវបានច្បាប់ផ្ដល់សិទ្ធិសេរីភាពស្មើៗគ្នា ទាំងសិទ្ធិនៅចំពោះមុខច្បាប់ សិទ្ធិមានសេរីភាព និងករណីយកិច្ចដូចៗគ្នាដោយមិនធ្វើការប្រកាន់នូវពូជសាសន៍ ពណ៌ សម្បុរ ភេទ ជាតិ ភាសា ជំនឿសាសនា និន្នាការនយោបាយ ដើមកំណើត និងស្ថានភាពឯទៀតនោះទេ តែក្នុងការប្រើប្រាស់សិទ្ធិ សេរីភាពទាំងអស់នោះ ជនគ្រប់រូបមិនត្រូវធ្វើឱ្យប៉ះពាល់ដល់សិទ្ធិ និងសេរីភាពអ្នកដទៃនោះទេ ដោយការប្រើប្រាស់សិទ្ធិរបស់ខ្លួននោះត្រូវធ្វើឡើងត្រឹមតែព្រំដែនដែលច្បាប់បានកំណត់តែប៉ុណ្ណោះ ប្រសិនបើមានការអនុវត្តសិទ្ធិរបស់ខ្លួនលើសពីអ្វីដែលច្បាប់បានចែងទុកនោះ វាបង្កឱ្យកើតជាបទល្មើសដែលត្រូវដាក់ទណ្ឌកម្មតាមច្បាប់។

ជាក់ស្តែង ដូចជាជនជាទណ្ឌិតទោះបីខ្លួនបានប្រព្រឹត្តបទល្មើសដែលបង្កឱ្យមានការខូចខាតដល់សង្គម សណ្ដាប់ធ្នាប់សារធារណៈ និងបុគ្គលដទៃទៀតយ៉ាងណាក៏ដោយក៏ច្បាប់បានផ្ដល់សិទ្ធិ និងការពារទៅលើជនជាទណ្ឌិតទាំងអស់នោះដែរ។ ថ្វីត្បិតតែទណ្ឌិតបានប្រព្រឹត្តល្មើសច្បាប់ក៏ពិតមែនប៉ុន្តែ ទណ្ឌិតក៏ជាមនុស្សម្នាក់ និងជាប្រជាពលរដ្ឋម្នាក់ដែលរស់នៅក្នុងសង្គម មានសតិសម្បជញ្ញៈ និងមានអាយុជីវិតម្នាក់ ទោះបីជាបានប្រព្រឹត្តនូវអំពើដែលល្មើសច្បាប់ក៏ពិតមែនតែច្បាប់ជឿជាក់ថា បុគ្គលទាំងអស់នោះអាចនឹងយល់ដឹងអំពីកំហុសរបស់ខ្លួនបន្ទាប់ពីបានធ្វើការអនុវត្តទោសដែលទណ្ឌិតនោះបានប្រព្រឹត្ត។

**១. ហេតុអ្វីបានជាទណ្ឌិតដែលបានប្រព្រឹត្តផ្ទុយនឹងច្បាប់យ៉ាងណាក៏ដោយក៏នៅតែទទួលសិទ្ធិមួយចំនួនទៀត?**

**២. តើសិទ្ធិ និងលក្ខខណ្ឌនៃការរស់នៅអ្វីខ្លះដែលទណ្ឌិតត្រូវទទួលបានអំឡុងពេលនៅក្នុងពន្ធនាគារ?**

## គ. គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រធានបទនេះ គឺជាការសិក្សាទៅលើសិទ្ធិរបស់ទណ្ឌិតដែលបានប្រព្រឹត្តបទល្មើស ហើយត្រូវបានតុលាការធ្វើការចេញសាលក្រមជាស្ថាពរសម្រេចសេចក្ដីឱ្យជាប់ពន្ធនាគារក្នុងរយៈពេលកំណត់ណាមួយ

ទៅតាមស្ថានទម្ងន់ដែលបុគ្គលជាទណ្ឌិតនោះបានប្រព្រឹត្ត។ ក្នុងនោះដែរ ប្រធានបទនេះយើងនឹងសិក្សាឱ្យកាន់តែច្បាស់លាស់អំពីស្ថានភាពជាក់ស្តែងនៅក្នុងពន្ធនាគារដែលជាទូទៅសាមញ្ញជនទូទៅ និងអ្នកសិក្សាស្រាវជ្រាវតែងតែមានចម្ងល់អំពីការអនុវត្តសិទ្ធិរបស់ទណ្ឌិតនៅក្នុងពន្ធនាគារត្រូវអនុវត្តបែបណា បើទណ្ឌិតត្រូវបានកំពុងតែឃុំឃាំងមិនឱ្យមានសេរីភាពនៅក្នុងពន្ធនាគារផងនោះ។ ដើម្បីធ្វើការស្រាយចម្ងល់ទាំងអស់នេះ ប្រធានបទនេះនឹងធ្វើការពិភាក្សាអំពីសិទ្ធិរបស់ទណ្ឌិតជាមូលដ្ឋានមានចែងទាំងនៅក្នុងច្បាប់ជាតិ និងច្បាប់អន្តរជាតិដែលជាមូលដ្ឋានក្នុងការអនុវត្តជាក់ស្តែងនៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។

ម្យ៉ាងវិញទៀត គោលគំនិតសំខាន់ផ្សេងទៀតនោះ ប្រធានបទនេះនឹងធ្វើការបង្ហាញអំពីគោលការណ៍នឹងបទបញ្ញត្តិមួយចំនួនដែលទណ្ឌិតបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ប៉ុន្តែជននោះនៅតែទទួលបានសិទ្ធិក្នុងការដោះលែងដោយមានលក្ខខណ្ឌ និងសិទ្ធិការលើកលែង និងបន្ធូរបន្ថយទោសដើម្បីឱ្យទណ្ឌិតវិលចូលទៅរស់ក្នុងសង្គមវិញអាចធ្វើការបម្រើការងារ និងទទួលបានភាពថ្លៃថ្នូររបស់ខ្លួនមកវិញបន្ទាប់ពីខ្លួនបានអនុវត្តទោសចំពោះការប្រព្រឹត្តល្មើស ទៅតាមលក្ខខណ្ឌច្បាប់បានកំណត់រួចរាល់នោះ។

រួមសេចក្តីមក ប្រធានបទនេះនឹងលើកយកមកធ្វើការសិក្សាស្រាវជ្រាវស៊ីជម្រៅ តម្លាភាព និងសុក្រឹតភាព។

## ៤. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

ការលើកយកនូវប្រធានបទស្តីពី "**ទណ្ឌិតនៅក្នុងពន្ធនាគាររបស់ព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្ន**" នេះឡើងដោយយល់ឃើញថាប្រធានបទនោះមានសារៈសំខាន់នូវក្នុងការកំណត់អំពីសិទ្ធិរបស់ទណ្ឌិតនៅក្នុងរឿងក្តីព្រហ្មទណ្ឌ លើសពីនេះទៅទៀត ប្រធានបទនេះក៏នឹងលើកយកពីសិទ្ធិមួយចំនួនដែលទណ្ឌិតមាននៅអំឡុងពេលអនុវត្តទោសដែលមានដូចជា សិទ្ធិក្នុងការរស់នៅ សិទ្ធិខាងវប្បធម៌ សិទ្ធិខាងព័ត៌មាន សិទ្ធិខាងសេរីភាព សិទ្ធិពិសេសរបស់ទណ្ឌិតដែលជាស្ត្រីភេទ អនីតិជន ជនបរទេស ក្នុងនោះក៏មានការទទួលបានការដោះលែងដោយមានលក្ខខណ្ឌ និងការបន្ធូរបន្ថយទោសនៅអំឡុងពេលអនុវត្តទោសផងដែរ។

## ៥. វិធីសាស្ត្រស្រាវជ្រាវ

ក្នុងការសិក្សាស្រាវជ្រាវនូវប្រធានបទនេះ ការស្រាវជ្រាវឯកសារ គឺជាកត្តាសំខាន់បំផុតក្នុងការតាក់តែងមកធ្វើជាឯកសារគោលយោងនៅក្នុងប្រធានបទ និងធ្វើការអត្ថាធិប្បាយក្នុងសារណាបញ្ចប់ការសិក្សាមួយនេះ។ ប្រធានបទនេះបានដកស្រង់ចេញពីអត្ថបទច្បាប់ដែលជាមូលដ្ឋានគ្រឹះដ៏សំខាន់ប្រកបដោយសុក្រឹតភាពដែលពាក់ព័ន្ធមានដូចជាឯកសារ រដ្ឋធម្មនុញ្ញ លិខិតបទដ្ឋានគតិយុត្តិជាអន្តរជាតិមាន សន្ធិសញ្ញា អនុសញ្ញា គោលការណ៍អន្តរជាតិ ច្បាប់ វិធានព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងឯកសារពាក់ព័ន្ធផ្សេងៗទៀតដែលទាក់ទងជាមួយនឹងប្រធានបទនេះ។

មួយវិញទៀត ប្រធានបទនេះបាននឹងធ្វើការបង្ហាញអំពីទិដ្ឋភាពជាក់ស្តែងមួយចំនួនដែលមនុស្សទូទៅអាចធ្វើការវិភាគ យល់ដឹងពីគំនិត និងការពិចារណាលើប្រធានបទនេះជាងនេះទៅទៀតប្រធានបទបានឆ្លុះបញ្ចាំងពីការខិតខំ

សហាការក្នុងស្វាស់ស្វែងរកឯកសារដើម្បីតាក់តែង និងការស្រាវជ្រាវពីគ្រប់មជ្ឈដ្ឋាននានាដែលមានឯកសារពាក់ព័ន្ធក្នុងការដាក់បញ្ចូលក្នុងប្រធានបទឱ្យកាន់តែមានអត្ថន័យ និងខ្លឹមសារដើម្បីជាឯកសារមួយដែលមានតម្លៃសម្រាប់តម្កល់ទុកឱ្យអ្នកស្រាវជ្រាវបានយល់ដឹងបន្ថែមពីមូលដ្ឋានក្នុងការស្រាវជ្រាវរកប្រភពឯកសារពីប្រធានបទនេះផងដែរ។

## ៦. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

នៅក្នុងទំហំនៃការសិក្សានៃប្រធានបទសារណានេះ ដើម្បីបង្កជាលក្ខណៈងាយស្រួល និងច្បាស់លាស់អំពីសិទ្ធិរបស់ទណ្ឌិតនៅក្នុងប្រធានបទនេះ យើងខ្ញុំបាននឹងធ្វើការបែងចែកនូវរចនាសម្ព័ន្ធនៃប្រធានបទដូចជា៖

**ជំពូកទីទី១. សិទ្ធិរបស់ទណ្ឌិតទូទៅនៅក្នុងពន្ធនាគារ** ដែលនឹងធ្វើការបកស្រាយទៅលើរចនាសម្ព័ន្ធគ្រប់គ្រង ការរៀបចំប្រព្រឹត្តទៅ និងមុខងារ រួមទាំងស្ថានភាពទូទៅរបស់ជនជាប់ឃុំ និងទណ្ឌិតនៅក្នុងពន្ធនាគាររបស់ព្រះរាជាណាចក្រ-កម្ពុជា និងសិទ្ធិរបស់ទណ្ឌិតជាទូទៅនៅក្នុងអំឡុងពេលអនុវត្តទោស។

**ជំពូកទី២. សិទ្ធិរបស់ទណ្ឌិតក្នុងលក្ខខណ្ឌពិសេសក្នុងពន្ធនាគារ** ដែលនឹងធ្វើការបកស្រាយពីសិទ្ធិពិសេសមួយចំនួនរបស់ទណ្ឌិតអនីតិជន ទណ្ឌិតជាស្ត្រីមានគភ៌ ម្តាយបំបៅកូនដោយទឹកដោះ និងម្តាយរស់នៅជាមួយកូន។

**ជំពូកទី៣. សិទ្ធិផ្សេងៗទៀតរបស់ទណ្ឌិត** ដែលនឹងត្រូវធ្វើការបកស្រាយអំពីការសិទ្ធិទទួលបានការដោះលែងដោយមានលក្ខខណ្ឌ និងការលកលែងទោស ឬបន្ធូរបន្ថយទោសចំពោះទណ្ឌិត។

# ជំពូកទី១
# សិទ្ធិរបស់ទណ្ឌិតទូទៅ
# ក្នុងពន្ធនាគារ

# ជំពូកទី១.

# សិទ្ធិរបស់ទណ្ឌិតទូទៅក្នុងពន្ធនាគារ

## ផ្នែកទី១. ពន្ធនាគារ

### ១.១. រចនាសម្ព័ន្ធគ្រប់គ្រង និងមុខងាររបស់ពន្ធនាគារកម្ពុជា

ក្រសួងមហាផ្ទៃជាស្ថាប័នដែលមានសមត្ថកិច្ចក្នុង ការគ្រប់គ្រងពន្ធនាគារ និងមណ្ឌលអប់រំកែប្រែ ទូទាំងរាជនីខេត្តនៃព្រះរាជាណាចក្រកម្ពុជាហើយដែលមានអគ្គនាយកដ្ឋានពន្ធនាគារជាសេនាធិការឲ្យក្រសួងមហាផ្ទៃក្នុងការគ្រប់គ្រង។ ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋានពន្ធនាគារត្រូវកំណត់ដោយអនុក្រឹត្យ។ ក្រសួងមហាផ្ទៃត្រូវធ្វើប្រតិភូកម្មមុខងារឲ្យរដ្ឋបាល រាជធានី ខេត្ត ក្នុងការគ្រប់គ្រងពន្ធនាគារ និងមណ្ឌលអប់រំកែប្រែ រាជធានី ខេត្ត។ ពន្ធនាគារ និងមណ្ឌលអប់រំកែប្រែ រាជធានី ខេត្ត ស្ថិតក្រោមការគ្រប់គ្រងរបស់គណៈអភិបាលរាជធានី ខេត្ត។ មន្ត្រីពន្ធនាគារត្រូវស្ថិតក្រោមលក្ខន្តិកៈដោយឡែកដែលត្រូវកំណត់ដោយព្រះរាជក្រឹត្យស្របតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រ-កម្ពុជា។ មន្ត្រីពន្ធនាគារមានឯកសណ្ឋាន សញ្ញាសក្តិ គ្រឿងបំពាក់ ឧបករណ៍ និងសម្ភារៈការពារសមស្រប។

ដើម្បីឲ្យពន្ធនាគារ ឬមណ្ឌលអប់រំកែប្រែ ប្រព្រឹត្តមកបានរហូតមកដល់នាពេលបច្ចុប្បន្នអាស្រ័យដោយមានការគ្រប់គ្រងពីមន្ត្រីមានមុខងារនៅក្នុងពន្ធនាគារ ឬមណ្ឌលអប់រំកែប្រែដែលមន្ត្រីទាំងនោះធ្វើការទៅតាមជំនាញរៀងៗខ្លួន។ ក្នុងពន្ធនាគារ ឬមណ្ឌលអប់រំកែប្រែមានរចនាសម្ព័ន្ធគ្រប់គ្រងដូចតទៅ ៖

#### ១.១.១. រចនាសម្ព័ន្ធគ្រប់គ្រង និងការរៀបចំ

ក្រសួងមហាផ្ទៃត្រូវទទួលខុសត្រូវរាល់ការបង្កើត ការគ្រប់គ្រង និងការផ្តល់ធនធានដល់ពន្ធនាគារ និងមណ្ឌលអប់រំកែប្រែទាំងអស់ឱ្យមានប្រសិទ្ធិភាព។ អគ្គនាយកដ្ឋានពន្ធនាគារ ជាសេនាធិការឱ្យក្រសួងមហាផ្ទៃក្នុងការគ្រប់គ្រងពន្ធនាគារ ឬមណ្ឌលអប់រំកែប្រែដែលមានរចនាសម្ព័ន្ធគ្រប់គ្រងដូចខាងក្រោម៖

ពន្ធនាគារ សំដៅដល់កន្លែងប្រើប្រាស់សម្រាប់ធ្វើការឃុំឃាំងជនជាប់ឃុំតាមលិខិតឃុំខ្លួនចេញដោយអាជ្ញាធរតុលាការ រួមមានមណ្ឌលឃុំខ្លួន និងមណ្ឌលអប់រំកែប្រែផងដែរ[1]។

នៅក្នុងពន្ធនាគារ និងមណ្ឌលអប់រំកែប្រែ ជាទូទៅតែងតែមានប្រធាន ០១ (មួយ) រូប ជាអ្នកគ្រប់គ្រង ហើយក្រៅពីប្រធានក៏នៅមានចំនួន ០៣ (បី) ការិយាល័យទៀតដើម្បីការប្រព្រឹត្តទៅរបស់ពន្ធនាគារ ឬមណ្ឌអប់រំកែប្រែដែល

[1] ប្រការ១ នៃប្រកាសស្តីពីការគ្រប់គ្រងពន្ធនាគារ ឆ្នាំ១៩៩៣

មានដូចជា ការិយាល័យប្រតិបត្តិ ការិយាល័យមធ្យោបាយ ការិយាល័យអប់រំកែប្រែ[2]។ ក្នុងការិយាល័យនីមួយៗមានប្រធាន និងអនុប្រធាន និងមន្ត្រីក្រោមឱវាទ។

ប្រធានមណ្ឌលអប់រំកែប្រែ ឬពន្ធនាគារ និងការិយាល័យទាំងបីខាងលើនេះមានមុខនាទីទទួលខុសៗគ្នាដូចខាងក្រោម ៖

យោងតាមប្រកាសស្តីពីការគ្រប់គ្រងពន្ធនាគារឆ្នាំ១៩៩៣ បានចែងថា ប្រធានពន្ធនាគារគឺជាអ្នកដែលទទួលបន្ទុកផ្នែករដ្ឋបាល និងកិច្ចប្រតិបត្តិការការងារប្រចាំថ្ងៃក្នុងពន្ធនាគារ[3]។ ប្រធានមណ្ឌលអប់រំកែប្រែ ឬពន្ធនាគារ ត្រូវទទួលខុសត្រូវដោយផ្ទាល់ក្នុងការគ្រប់គ្រងមណ្ឌលអប់រំកែប្រែ ឬពន្ធនាគារឲ្យបានត្រឹមត្រូវតាមនីតិវិធី និងបទបញ្ជាផ្ទៃក្នុងដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ។ ប្រធានមណ្ឌលអប់រំកែប្រែ ឬពន្ធនាគារត្រូវរាយការណ៍ជាបន្ទាន់ទៅព្រះរាជអាជ្ញា គណៈអភិបាលរាជធានី ខេត្ត និងអគ្គនាយកដ្ឋានពន្ធនាគារ អំពីព័ត៌មាន ឬឧប្បត្តិហេតុទាំងឡាយណាដែលគំរាមកំហែង ឬដែលអាចគំរាមកំហែងដល់សន្តិសុខ សុវត្ថិភាពមណ្ឌល ឬពន្ធនាគារ។ ប្រធាន មណ្ឌលអប់រំកែប្រែ ឬពន្ធនាគារអាចអនុញ្ញាតឲ្យមន្ត្រីពន្ធនាគារដែលបានបណ្តុះបណ្តាលហ្វឹកហាត់ត្រឹមត្រូវឲ្យប្រើប្រាស់អាវុធ និងឧបករណ៍បច្ចេកទេសដើម្បីធានាសន្តិសុខ សុវត្ថិភាពក្នុងកិច្ចប្រតិបត្តិការរបស់មណ្ឌលអប់រំកែប្រែ ឬពន្ធនាគារហើយទទួលខុសត្រូវក្នុងការគ្រប់គ្រងអាវុធ និងឧបករណ៍បច្ចេកទេសឲ្យមានសុវត្ថិភាព។

ការិយាល័យទាំង០៣ (បី) ខាងលើមានតួនាទី និងការទទួលខុសត្រូវដូចជា៖

**ក. ការិយាល័យអប់រំកែប្រែ**

ការិយាល័យអប់រំកែប្រែទទួលខុសត្រូវលើផ្នែកចំនួន ០៣ (បី)[4] គឺ ៖

**ក១. ផ្នែកសុខាភិបាល**

ផ្នែកសុខាភិបាលនេះ មានភារកិច្ចមួយចំនួនដូចជា៖

- ធ្វើកំណត់ហេតុជម្ងឺ (ធ្វើចំពោះជនជាប់ឃុំដែលចូលមកថ្មី) ដើម្បីឲ្យដឹងពីស្ថានភាពសុខភាពជនជាប់ឃុំនោះ និងដើម្បីងាយស្រួលការពារទុកជាមុន។
- គ្រប់គ្រងការប្រើប្រាស់ឱសថ និងបើកឱសថជូនជនជាប់ឃុំជាដើម។
- ចុះស្រាវជ្រាវពីស្ថានភាពជនជាប់ឃុំថាមានជម្ងឺដែរឬទេ។
- ចុះអប់រំជនជាប់ឃុំពីបញ្ហាអនាម័យនៅក្នុងការរស់នៅក្នុងមណ្ឌលអប់រំកែប្រែ ឬពន្ធនាគារ។

[2] មាត្រា១ នៃប្រកាសលេខ៨០៤ ប្រក ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០០៧ ស្តីពីតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់នាយកដ្ឋាន លេខាធិការដ្ឋាន មណ្ឌលអប់រំកែប្រែ និងពន្ធនាគារ ខេត្ត ក្រុង ចំណុះអគ្គនាយកដ្ឋានពន្ធនាគារ ក្រសួងមហាផ្ទៃ

[3] ប្រការ១ នៃប្រកាសស្តីពីការគ្រប់គ្រងពន្ធនាគារ ឆ្នាំ១៩៩៣

[4] ប្រសាសន៍របស់លោក ព្រំ សុផល ជាប្រធានការិយាល័យអប់រំកែប្រែមណ្ឌលអប់រំកែប្រែទី២ កាលពីឆ្នាំ២០១២ (សារណាស្តីពីស្ថានភាពជនជាប់ឃុំក្នុងពន្ធនាគារឆ្នាំ២០១២ របស់និស្សិត ស.ភ.វ.ន.ស)

- ព្យាបាលជនជាប់ឃុំដែលមានជម្ងឺ។
- បញ្ជូនជនជាប់ឃុំដែលមានជម្ងឺធ្ងន់ធ្ងរទៅមន្ទីរពេទ្យខាងក្រៅព្យាបាល ក្នុងករណីដែលមន្ត្រីផ្នែកសុខាភិបាលគ្មានលទ្ធភាពក្នុងការព្យាបាល។
- ចូលរួមក្នុងការធ្វើចំណាត់ថ្នាក់សន្តិសុខដល់ជនជាប់ឃុំ។

**ក២. ផ្នែកអប់រំកែប្រែស្តារនីតិសម្បទា**

ផ្នែកអប់រំកែប្រែស្តារនីតិសម្បទានេះ មានភារកិច្ចមួយចំនួនដូចជា ៖

- រៀបចំបទបញ្ញាផ្ទៃក្នុង និងណែនាំដល់ជនជាប់ឃុំទាំងអស់ឲ្យបានដឹង និងយល់នូវខ្លឹមសារនៃបទបញ្ញាផ្ទៃក្នុងនេះ។
- ធ្វើការណែនាំពីការទទួលខុសត្រូវពីការទទួលខុសត្រូវពេលអនុវត្តន៍។
- ធ្វើការណែនាំពីផលប៉ះពាល់នានានៅពេលដែលប្រព្រឹត្តអំពើអបាយមុខ និងការប្រព្រឹត្តអំពើអ្វីមួយដែលខុសច្បាប់។
- ចូលរួមធ្វើចំណាត់ថ្នាក់សន្តិសុខដល់ជនជាប់ឃុំ។
- មានការអប់រំជាបុគ្គលក្នុងករណីមានបញ្ហាជម្លោះ ឬវិវាទនានាដែលកើតមានឡើងក្នុងមណ្ឌលអប់រំកែប្រែ ឬពន្ធនាគារដោយកើតឡើងដោយសារជនជាប់ឃុំណាមួយ។
- ធ្វើការដាក់វិន័យដល់ជនជាប់ឃុំដែលបានប្រព្រឹត្តកំហុសនៅក្នុងមណ្ឌលអប់រំកែប្រែ ឬពន្ធនាគារ។
- គ្រប់គ្រងលើជនជាប់ឃុំ។
- គ្រប់គ្រងបណ្ណាល័យ (ចាត់ចែងជនជាប់ឃុំឲ្យបានអានសៀវភៅ)។
- ធ្វើការអប់រំដល់ជនជាប់ឃុំដែលនៅក្នុងនោះមានទាំងការអប់រំផ្នែកផ្លូវចិត្តផងដែរ។
- ចាត់ចែងឲ្យមានប្រធានសម្រាប់បន្ទប់ឃុំឃាំងនីមួយៗ។

**ក៣. បណ្តុះបណ្តាលវិជ្ជាជីវៈ និងការងារផលិតកម្ម**

ផ្នែកបណ្តុះបណ្តាលវិជ្ជាជីវៈ និងការងារផលិតកម្មនេះ មានភារកិច្ចមួយចំនួនដូចជា ៖

- ការបង្រៀនជំនាញវិជ្ជាជីវៈ និងចំណេះដឹងផ្សេងៗមានដូចជាបង្រៀនផ្នែកអេឡិចត្រូនិច
- ការកាត់សក់ ការជួសជុលម៉ូតូ ភាសាអង់គ្លេស និងមេរៀនបំណិនជីវិតដល់ជនជាប់ឃុំ
- តាមមណ្ឌលអប់រំកែប្រែ ឬពន្ធនាគារមួយចំនួនមានបង្រៀនផ្នែកចំណេះដឹងទូទៅជាភាសាខ្មែរផងដែរ
- បង្រៀនពីការដាំបន្លែ និងធ្វើកសិកម្មកាត់ដេរ ប៉ាក់ខិន ត្បាញ (ពីមុនមានតែឥឡូវត្រូវបានបិទដោយសារអង្គការពលកម្មអន្តរជាតិប្តឹង)
- ធ្វើក្រណាត់សម្រាប់ជូតឡាន។

**ខ. ការិយាល័យមធ្យោបាយ**

ការិយាល័យមធ្យោបាយនេះទទួលខុសត្រូវលើ០៣ (បី) ផ្នែកដែលមានដូចជា[5]៖

**ខ១. រដ្ឋបាលសរុប**

ផ្នែករដ្ឋបាលសរុប មានភារកិច្ចមួយចំនួនដូចខាងក្រោម ៖

- ទទួលរាល់លិខិតស្នាមចេញ និងចូល
- ធ្វើរបាយការណ៍ និងបូកសរុបរបាយការណ៍ដែលមានដូចជា ៖
  - របាយការណ៍ប្រចាំខែ
  - របាយការណ៍ប្រចាំត្រីមាស
  - របាយការណ៍ប្រចាំឆមាស
  - របាយការណ៍ប្រចាំឆ្នាំ។
- ធ្វើលិខិតបទដ្ឋាននានាបញ្ជូនទៅស្ថាប័ន និងអង្គភាពពាក់ព័ន្ធ
- បំពេញបែបបទឲ្យសាច់ញាតិបានជួបជនជាប់ឃុំ
- ទទួលជនជាប់ឃុំចូលថ្មី
- ទំនាក់ទំនងជាមួយអង្គការ ស្ថាប័នជាតិ និងអន្តរជាតិ។

**ខ២. ផ្នែកភស្តុភា**

ផ្នែកភស្តុភាមានតួនាទី និងភារកិច្ចដូចជា ៖

- ចាត់ចែងការទិញម្ហូបអាហារសម្រាប់មណ្ឌល ឬពន្ធនាគារ
- ចាត់ចែងម្ហូបអាហារសម្រាប់ជនជាប់ឃុំ
- ចាត់ចែងលើសម្ភារៈប្រើប្រាស់របស់ជនជាប់ឃុំ
- គ្រប់គ្រងការប្រើប្រាស់សម្ភារៈនានាក្នុងមណ្ឌល ឬពន្ធនាគារ។

**ខ៣. ផ្នែកគណនេយ្យ**

ផ្នែកគណនេយ្យ មានតួនាទី និងភារកិច្ចដូចជា ៖

- បែងចែករបបហូបចុក និងសម្ភារៈប្រើប្រាស់ដល់ជនជាប់ឃុំ
- រៀបចំវេនដល់ជនជាប់ឃុំសម្រាប់ធ្វើម្ហូបអាហារ
- បញ្ជូនម្ហូបអាហារដាក់តាមបន្ទប់របស់ជនជាប់ឃុំ។

[5] ប្រសាសន៍របស់លោក គង់ សំអុន ជាប្រធានការិយាល័យមធ្យោបាយមណ្ឌលអប់រំកែប្រែទី២ កាលពីឆ្នាំ២០១២ (សារណាស្តីពីស្ថានភាពជនជាប់ឃុំក្នុងពន្ធនាគារឆ្នាំ២០១២ របស់និស្សិត ស.ភ.វ.ន.ស)

**គ. ការិយាល័យប្រតិបត្តិ**

ការិយាល័យប្រតិបត្តិ មានការទទួលខុសត្រូវលើការងារ០២ (ពីរ) ផ្នែកមានដូចជា[6]៖

**គ១. ផ្នែកស៊ើបការអប់រំ**

ផ្នែកស៊ើបការអប់រំគ្រប់គ្រងលើផ្នែកចំនួនពីរទៀត គឺសន្តិសុខ និងអាគារនុរក្សដូចតទៅ៖

**គ១.១ សន្តិសុខ**

ផ្នែកសន្តិសុខ មានតួនាទី និងភារកិច្ចដូចជា ៖

- យាមតាមគោលដៅ (ប៉ុស្តិ៍) នាំទណ្ឌិតទៅធ្វើការខាងក្រៅបន្ទប់ឃុំឃាំង
- នាំជនត្រូវចោទ ឬជនជាប់ចោទឡើងតុលាការ
- នាំជនជាប់ឃុំទៅមន្ទីរពេទ្យករណីឈឺធ្ងន់ធ្ងរ និងឃ្លាំមើលរាល់សកម្មភាពរបស់ជនជាប់ឃុំ
- អន្តរាគមន៍ដោះស្រាយបញ្ហាដែលកើតមានក្នុងពន្ធនាគារដូចជា ការធ្វើបាតុកម្ម កូដកម្ម និងវិវាទរវាងជនជាប់ឃុំ និងជនជាប់ឃុំ។

**គ១.២. អាគារនុរក្ស**

អាគារនុរក្ស មានតួនាទី និងភារកិច្ចដូចជា ៖

- ចាក់សោរបញ្ចេញ និងបញ្ចូលជនជាប់ឃុំពីបន្ទប់ឃុំឃាំង
- ផ្តល់កម្លាំងជនជាប់ឃុំឲ្យផ្នែកនីមួយៗដើម្បីជួយធ្វើការនៅក្នុងមណ្ឌល ឬពន្ធនាគារ
- ឈរនៅគោលដៅគ្រប់អាគារនីមួយៗ
- ត្រួតពិនិត្យបន្ទប់ឃុំឃាំងនីមួយៗដូចជាការពិនិត្យ ដំបូល ទ្វារបង្អួច និងបន្ទប់ទឹកជាដើម
- បញ្ចេញជនជាប់ឃុំទៅរៀនវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈ និងការសិក្សាអប់រំ
- បញ្ចេញជនជាប់ឃុំឡើងសវនការ
- ទប់ស្កាត់ជនជាប់ឃុំធ្វើកូដកម្ម បាតុកម្មផ្សេងៗ។

**គ២. ផ្នែកសំណុំរឿង**

ផ្នែកសំណុំរឿង មានតួនាទី និងភារកិច្ច ៖

- គ្រប់គ្រងសំណុំឯកសារពាក់ព័ន្ធនឹងជនជាប់ឃុំ
- ធ្វើសាវតាជាតិរបស់ជនជាប់ឃុំ
- ថតរូបជនជាប់ឃុំដែលទើបមកថ្មី

[6] ប្រសាសន៍របស់លោក ហេង សំណាង ជាអនុប្រធានការិយាល័យមធ្យោបាយមណ្ឌលអប់រំកែប្រែទី២ កាលពីឆ្នាំ២០១២ (សារណាស្តីពីស្ថានភាពជនជាប់ឃុំក្នុងពន្ធនាគារឆ្នាំ២០១២ របស់និស្សិត ស.ភ.វ.ន.ស)

- ផ្តល់លេខកូដដល់ជនជាប់ឃុំ
- ធ្វើរបាយការណ៍ផ្ញើទៅអគ្គនាយកដ្ឋានពន្ធនាគារ សាលាដំបូងរាជធានីខេត្ត និងបណ្តាស្ថាប័នពាក់ព័ន្ធ
- រៀបចំធ្វើលិខិតស្នើសុំដោះលែងជនជាប់ឃុំ
- កសាងកម្លាំងសម្ងាត់ជាជនជាប់ឃុំក្នុងមណ្ឌល ឬពន្ធនាគារនៅតាមបន្ទប់នីមួយៗ
- អប់រំដល់ជនជាប់ឃុំណាដែលបង្កបញ្ហានៅក្នុងមណ្ឌលឬពន្ធនាគារ ចូលរួមធ្វើចំណាត់ថ្នាក់សន្តិសុខ
- រៀបចំធ្វើលិខិតស្នើសុំបន្ធូរបន្ថយទោស និងលើកលែងទោសដល់ជនជាប់ឃុំ
- ធ្វើរបាយការណ៍ពាក់ព័ន្ធគ្រឿងញៀនទៅអង្គភាពប្រឆាំងគ្រឿងញៀន
- ធ្វើរបាយការណ៍ស្តីពីការឃុំខ្លួនជនត្រូវចោទលើសនីតិវិធីច្បាប់ទៅតុលាការ។

### ១.១.២. មុខងាររបស់ពន្ធនាគារ

ពន្ធនាគារ សំដៅដល់កន្លែងប្រើសម្រាប់ធ្វើការឃុំឃាំងជនជាប់ឃុំតាមលិខិតឃុំខ្លួនចេញដោយអាជ្ញាធរតុលាការ រួមមានមណ្ឌលឃុំខ្លួន និងមណ្ឌលអប់រំកែប្រែផង[7]។ មុខងាររបស់មណ្ឌលអប់រំកែប្រែ និងពន្ធនាគារគឺមានគោលដៅជាសារវន្តនៃការគ្រប់គ្រងជនជាប់ឃុំដែលមានទណ្ឌិតជាដើមនេះ គឺការអប់រំ កែប្រែ និងការស្តារនីតិសម្បទារបស់ជនជាប់ឃុំដែលជាស្នូលនៃក្របខ័ណ្ឌគោលនយោបាយកំណែទម្រង់ពន្ធនាគារ និងមណ្ឌលអប់រំកែប្រែ។ ការដាក់វិន័យទៅលើជនជាប់ឃុំត្រូវធ្វើឡើងក្នុងកម្រិតអប្បបរមាដែលចាំបាច់ដើម្បីធានាសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់ប៉ុណ្ណោះ។ លើសពីនេះទៅទៀតគេសង្កេតឃើញមានមុខងារចំនួនពីរទៀត គឺការអប់រំ និងការបណ្តុះបណ្តាល។

#### ១.១.២.១. ការអប់រំ

ការអប់រំចំពោះទណ្ឌិតនេះ គឺបានតែសម្រាប់ជនជាទណ្ឌិតណាដែលគណៈកម្មការផ្នែកធ្វើចំណាត់ថ្នាក់សន្តិសុខវាយតម្លៃថាជនជាប់ឃុំនោះ គឺស្ថិតនៅក្នុងចំណាត់ថ្នាក់សន្តិសុខទាប ឬមធ្យមតែប៉ុណ្ណោះ។ ប៉ុន្តែចំណែកឯជនជាទណ្ឌិតដែលស្ថិតនៅក្នុងចំណាត់ថ្នាក់សន្តិសុខខ្ពស់ក៏អាចទទួលបានការអប់រំបណ្តុះបណ្តាលបានផងដែរ បើសិនជាជនជាទណ្ឌិតនោះចេះកែខ្លួនបានប្រព្រឹត្តល្អក្នុងពេលដែលខ្លួនកំពុងជាប់ឃុំហើយដែលត្រូវបានគណៈកម្មការខាងលើនេះវាយតម្លៃថាល្អ។ ចំពោះការអប់រំនេះយើងផ្តោតជាសំខាន់ទៅលើស្ត្រី និងកុមារ។ ស្ត្រីជាម្តាយរស់នៅក្នុងពន្ធនាគារជាមួយកូនដែលមានអាយុជាង ០៤ (បួន) ឆ្នាំ សង្កេតឃើញថាខ្វះការអប់រំ គឺជាបញ្ហាដ៏ធំបំផុតដែលកុមារប្រឈមមុខនៅក្នុងពន្ធនាគារ។ ស្ត្រីជាម្តាយភាគច្រើននៅក្នុងពន្ធនាគារ គឺជាមនុស្សមិនចេះអក្សរ បើមិនដូច្នោះទេក៏មិនអាចបង្រៀន និងអប់រំកូនបានដែរ។ ខណៈដែលកុមារជិតដល់អាយុចូលរៀនការទទួលបានការអប់រំ និងពេលវេលាលេងកម្សាន្តនៅ

[7] មាត្រា៤ នៃច្បាប់ស្តីពីពន្ធនាគារ ឆ្នាំ២០១១

ក្នុងពន្ធនាគារក្លាយជាកត្តាកំណត់មួយយ៉ាងសំខាន់ ថាតើស្ត្រីជាម្តាយជ្រើសរើសយកការរក្សាទុកកូននៅក្នុងពន្ធនាគារ ឬមណ្ឌលអប់រំកែប្រែជាមួយពួកគេឬទេ[8]។

យ៉ាងតិចណាស់ មានកុមារ ៨២ នាក់ កំពុងតែរស់នៅក្នុងពន្ធនាគារជាមួយម្តាយដែលជាប់ទោសហើយនឹងមានស្ត្រី និងក្មេងស្រី ៣០ នាក់ ផ្សេងទៀត កំពុងតែមានផ្ទៃពោះនៅក្នុងពន្ធនាគារ គិតត្រឹមខែមេសា ឆ្នាំ២០២៣នេះ[9]។ ជារឿយៗការអប់រំត្រូវបានបញ្ជាក់ថាជាមូលហេតុសម្រាប់ឲ្យកុមារចាកចេញពីពន្ធនាគារ អាស្រ័យដោយពុំមានកម្មវិធីអប់រំនៅក្នុងពន្ធនាគារសម្រាប់កុមារបណ្តាលឱ្យស្ត្រីជាម្តាយទាំងឡាយត្រូវបង្ខំចិត្តជ្រើសរើសរវាងការបញ្ជូនកូនចេញក្រៅពន្ធនាគាររស់នៅជាមួយមិត្តភក្តិ សាច់ញាតិ អង្គការមិនមែនរដ្ឋាភិបាល ឬមណ្ឌលកុមារកំព្រាដើម្បីបានទៅរៀននៅក្រៅពន្ធនាគារ ឬបន្តទុកកូននៅក្នុងពន្ធនាគារដោយពុំទទួលបានការសិក្សាសោះ។ នេះគឺជាបញ្ហាស្មុគស្មាញមួយដែលស្ត្រីទាំងនោះពិបាកធ្វើសេចក្តីសម្រេចចិត្ត ដោយហេតុថាគ្មានការធានាណាមួយថាកុមារនឹងបានចូលរៀនទេនៅពេលចេញពីពន្ធនាគារម្តាយមួយចំនួនបានលើកឡើងថាប្រសិនបើកូនៗ របស់ពួកគេត្រូវបានអនុញ្ញាតឲ្យទៅសាលារៀនខាងក្រៅពន្ធនាគារនៅពេលថ្ងៃ ហើយយប់ត្រឡប់មកវិញរស់នៅជាមួយពួកគាត់ក្នុងពន្ធនាគារវិញនោះនឹងអាចកាត់បន្ថយនូវបញ្ហាបានមួយភាគធំ ម្តាយមួយចំនួនទៀតក៏បានលើកឡើងថាពួកគេចង់ឲ្យកូនទៅរៀន ប៉ុន្តែពុំមានលទ្ធភាពសម្រាប់ទិញសម្ភារៈសិក្សាឲ្យកូនទេ។ កង្វះមធ្យោបាយធ្វើដំណើរជាការលំបាកមួយដល់កុមារដែលត្រូវបានមិនអនុញ្ញាតឲ្យទៅសាលានៅក្រៅពន្ធនាគារអាចទៅរៀនបានទៀតទាត់រាល់ថ្ងៃទេដោយសាលានៅឆ្ងាយពីពន្ធនាគារ[10]។

ស្ត្រីជាម្តាយភាគច្រើនមិនអាចអប់រំកូនរបស់ខ្លួនអំពីជីវិតនៅក្រៅពន្ធនាគារបាននោះទេ។ លើសពីនេះទៅទៀតកុមារដែលធំដឹងក្តីឡើងនៅក្នុងពន្ធនាគារជៀសមិនផុតពីការខ្វះចំណេះដឹងទូទៅឡើយ។ ជាធម្មតាកុមារដែលរស់នៅក្នុងស្ថាប័នណាមួយច្រើនតែជួបប្រទះនូវការខ្វះចំណេះដឹងទូទៅអំពីសង្គម ហើយការសិក្សាបានផ្សារភ្ជាប់បញ្ហានេះជាមួយកង្វះលទ្ធភាពក្នុងការស្វែងរកទីកន្លែងឲ្យបានសមរម្យនៅក្នុងសង្គមនៅពេលកុមារពេញវ័យ។ អនុសញ្ញាស្តីពីសិទ្ធិកុមារបានផ្តល់កុមារនូវសិទ្ធិចូលរួមក្នុងវប្បធម៌សង្គមរបស់ខ្លួន។ កុមារតូចៗរស់នៅក្នុងពន្ធនាគារពុំអាចមានលទ្ធភាពក្នុងការចូលរួមបែបនេះទេ ហើយបញ្ហានេះអាចជាប់ពាក់ព័ន្ធជាមួយនឹងអនាគតរបស់ពួកគេក្នុងរយៈពេលយូរអង្វែងផងដែរ។

ចំពោះបញ្ហាអប់រំបញ្ហាផ្លូវចិត្ត គឺជាបញ្ហាមួយដែលមានការស្មុគស្មាញពីព្រោះថាយើងពុំទាន់មានគ្រូក្នុងការអប់រំច្បាស់លាស់នៅឡើយហើយភាគច្រើនការអប់រំផ្លូវចិត្ត គឺត្រូវបានបណ្តាអង្គការក្រៅរដ្ឋាភិបាលមួយចំនួនបានចុះ

[8] របាយការណ៍អង្គការលីកាដូស្តីពីគម្រោងជំនួយដល់កុមាររស់នៅជាមួយម្តាយក្នុងពន្ធនាគារ ខែមិថុនា ឆ្នាំ២០១០

[9] សេចក្តីថ្លែងការណ៍ស្តីពី សូមបញ្ឈប់ការឃុំខ្លួនដែលមិនចាំបាច់លើកុមារនៅក្នុងពន្ធនាគារដ៏ចង្អៀតណែន ចេញផ្សាយថ្ងៃទី០១ ខែមិថុនា ឆ្នាំ ២០២៣

[10] របាយការណ៍សង្ខេបរបស់អង្គការលីកាដូស្តីពីគម្រោងផ្តល់ជំនួយដល់កុមាររស់នៅជាមួយម្តាយក្នុងពន្ធនាគារ ខែមិថុនា ឆ្នាំ២០១០

មកធ្វើការអប់រំផងដែរ[11]។ ទណ្ឌិតដែលមានបញ្ហាផ្លូវចិត្តភាគច្រើនជាទណ្ឌិតចំណូលថ្មីដែលខ្វល់ខ្វាយច្រើនពីគ្រួសារ និងទោសកំហុសដែលខ្លួនបានប្រព្រឹត្ត។ ការខ្វល់ខ្វាយពីគ្រួសារមានន័យថាពួកគេខ្វល់ពីស្ថានភាពគ្រួសាររបស់ពួកគេ ដោយគ្រួសារពួកគេពឹងផ្អែកលើការធ្វើការរបស់ពួកគេដើម្បីចិញ្ចឹមជីវិត ហើយប្រសិនបើគ្មានពួកគេតើគ្រួសាររបស់ពួកគេនឹងទៅជាយ៉ាងណាគ្រួសារពួកគេរស់នៅយ៉ាងដូចម្តេច។ ចំណែកការខ្វាយខ្វល់ពីទោសកំហុស គឺមានន័យថា ពួកគេដឹងកំហុសរបស់ខ្លួន និងសួរខ្លួនឯងថាហេតុអ្វីបានជាធ្លាក់ខ្លួនប្រព្រឹត្តបទល្មើសយ៉ាងដូច្នេះ។

**១.១.២.២. ការបណ្តុះបណ្តាលវិជ្ជាជីវៈ**

យើងក៏បានសង្កេតឃើញថា អង្គការលីកាដូបានគាំទ្រចំពោះផែនការរបស់អគ្គនាយកដ្ឋានពន្ធនាគារក្នុងការផ្លាស់ប្តូរពីពន្ធនាគារដាក់ទណ្ឌកម្មទៅជាពន្ធនាគារស្តារនីតិសម្បទាវិញ[12]។ ការបណ្តុះបណ្តាលជំនាញ គឺជាផ្នែកមួយដ៏សំខាន់នៅក្នុងគ្រប់កិច្ចប្រឹងប្រែងស្តារនីតិសម្បទាទាំងអស់។ លើសពីនេះទៅទៀតការបញ្ចេញជនជាប់ឃុំទៅក្រៅអាគារឃុំឃាំងដើម្បីធ្វើហត្ថកម្ម ពលកម្ម ឬផ្តល់ការបណ្តុះបណ្តាលខាងវិជ្ជាជីវៈ គឺជាតម្រូវការយ៉ាងខ្លាំងនៃផ្នែកសុខភាពរបស់ជនជាប់ឃុំ។

ទោះជាយ៉ាងណាក៏ដោយក៏កម្មវិធីស្តារនីតិសម្បទាទាំងនេះអាចដំណើរការទៅដោយជោគជ័យបាន គឺពឹងផ្អែកលើការរៀបចំគម្រោងការងារលម្អិត និងជាក់ច្បាស់។ ដោយហេតុថាការទទួលព័ត៌មានអំពីគម្រោងស្តារនីតិសម្បទានេះនៅមានកម្រិតនៅឡើយ ហើយក៏មានការព្រួយបារម្ភអំពីការប្រើប្រាស់កម្លាំងពលកម្មជនជាប់ឃុំដែរ។

**១.១.២.៣. តម្លាភាព**

មកដល់ពេលនេះគេបានដឹងតិចតួចបំផុតអំពីការរៀបចំលំអិតនៃកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈនៅក្នុងមណ្ឌលអប់រំកែប្រែទី៤ នេះដោយសារតែគម្រោងស្ថិតនៅក្នុងដំណាក់កាលអភិវឌ្ឍដំបូងរបស់ខ្លួន ប៉ុន្តែនៅពេលដែលគម្រោងនេះមានការរីកចម្រើនគេក៏បានឃើញមានអង្គការលីកាដូសុំស្នើឲ្យអគ្គនាយកដ្ឋានពន្ធនាគារចាត់វិធានការជាជំហានៗដើម្បីធានាឲ្យបាននូវតម្លាភាព និងប្រសិទ្ធិភាពរបស់កម្មវិធីបណ្តុះបណ្តាលដូចខាងក្រោម ៖

១. ផ្សព្វផ្សាយរបាយការណ៍សាធារណៈឲ្យបានទៀងទាត់ស្តីពីប្រភេទការងារដែលជនជាប់ឃុំកំពុងធ្វើ។

២. ផ្សព្វផ្សាយឲ្យបានទៀងទាត់នូវរបាយការណ៍ស្តីពីហិរញ្ញវត្ថុរបស់កម្មវិធី ដោយរួមមានគណនេយ្យលម្អិតស្តីពីចំណូល ចំណាយ និងចំណូលដែលត្រូវបានយកទៅវិនិយោគសារឡើងវិញ។

[11] ប្រសាសន៍របស់លោក ព្រុំ សុផល ជាប្រធានការិយាល័យអប់រំកែប្រែមណ្ឌលអប់រំកែប្រែទី២ កាលពីឆ្នាំ២០១២ (សារណាស្តីពីស្ថានភាពជនជាប់ឃុំក្នុងពន្ធនាគារឆ្នាំ២០១២ របស់និស្សិត ស.ភ.រ.ន.ស)

[12] របាយការណ៍សង្ខេបរបស់អង្គការលីកាដូស្តីពីគុកធំ ចង្អៀតខ្លាំង (ភាពចង្អៀតណែនរបស់អ្នកទោសនៅកម្ពុជា និងក្តីស្រមៃនៃមណ្ឌលអប់រំកែប្រែទី៥) ខែកក្កដា ឆ្នាំ២០១០

៣. ផ្សព្វផ្សាយនូវគណនេយ្យទៀងទាត់ស្តីពីការប្រើប្រាស់ផលិតផលម្ហូបអាហារ។ ឧទាហរណ៍ៈ តើម្ហូបអាហារទាំងនោះត្រូវបានប្រើប្រាស់នៅតាមពន្ធនាគារកម្ពុជានានា ឬត្រូវបានលក់នៅឯផ្សារដើម្បីទទួលបានប្រាក់ចំណូលទៅវិញ។

៤. ផ្សព្វផ្សាយបញ្ជីឈ្មោះអង្គការ ឬក្រុមហ៊ុនដៃគូទាំងឡាយទាំងអ្នកទទួលធ្វើ លក់បន្ត ឬអនីតិជន (ដោយមានព័ត៌មានលម្អិតនៃកិច្ចការវិនិយោគនៅក្នុងគម្រោងរបស់ដៃគូទាំងនោះផង) ប្រសិនបើមាន។

៥. ផ្សព្វផ្សាយជាផ្លូវការនូវគោលនយោបាយទាំងឡាយស្តីអំពីតម្លៃពលកម្ម ដែលជនជាទណ្ឌិតនឹងទទួលបានពីការងារដែលខ្លួនធ្វើ ហើយអនុវត្តប្រព័ន្ធមួយដើម្បីកត់ត្រាលម្អិតអំពីការបើកប្រាក់ឲ្យជនជាទណ្ឌិត និងម៉ោងធ្វើការងារ។

៦. អនុញ្ញាតឲ្យអង្គការមិនមែនរដ្ឋាភិបាល និងអង្គការឃ្លាំមើលអំពីស្ថានភាពពលកម្មធ្វើការពិនិត្យអំពីស្ថានភាពការងាររបស់ជនជាប់ឃុំ។

៧. អនុម័តនូវយន្តការគ្រប់គ្រងលម្អិតរួមគ្នាដើម្បីគ្រប់គ្រងកម្មវិធីរួមមាន វិធាននានាដើម្បីធានាឲ្យបាននូវការអនុវត្តជំហានខាងលើ។

### ១.១.២.៤. ការជ្រើសរើសកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈសមរម្យ

ជាការព្រួយបារម្ភពីការបណ្តុះបណ្តាលវិជ្ជាជីវៈដល់ជនជាប់ឃុំ គឺបណ្តុះបណ្តាលទៅលើវិស័យកសិកម្មដែលកម្មវិធីនេះ គឺកម្មវិធីធម្មតាសម្រាប់ជនជាប់ឃុំពីព្រោះថាបើតាមការប៉ាន់ប្រមាណបានឲ្យដឹងថាប្រជាពលរដ្ឋកម្ពុជាប្រមាណ ៨០% គឺជាកសិករ។ កត្តានេះនាំឲ្យមានបញ្ហាពីរនៅពេលដែលនិយាយអំពីការបណ្តុះបណ្តាលអាចត្រួតគ្នាជាមួយជំនាញដែលពួកគេធ្លាប់មានស្រាប់ ។ ផ្នែកខ្លះក្នុងវិស័យកសិកម្មត្រឹមតែមានជំនាញសមល្មមក៏អាចប្រើការបាន។

ជាក់ស្តែងនៅមណ្ឌលអប់រំកែប្រែទី២ គឺមានការបណ្តុះបណ្តាលវិជ្ជាជីវៈដល់ជនជាប់ឃុំដែលមានដូចជាខាងអេឡិចត្រូនិច កាត់សក់ អង់គ្លេស ជួសជុលម៉ូតូ និងបំណិនជីវិត (សម្រាប់ស្ត្រី) ក្រៅពីការងារដែលមានទាំងអស់នេះមណ្ឌលពីមុនមានការបង្រៀន ដេរប៉ាក់ ត្បាញ ផងដែរ ហើយការដេរប៉ាក់នេះ គឺឈ្មួញដែលយកមកឲ្យជនជាប់ឃុំធ្វើនេះបានយកនាំចេញនូវការដេរប៉ាក់សំលៀកបំពាក់នេះទៅធ្វើពាណិជ្ជកម្មទៅក្រៅប្រទេស ក្រោយមកក៏ត្រូវបានអង្គការពលកម្មអន្តរជាតិ (ILO) ប្តឹងទាក់ទងនឹងការប្រើប្រាស់កម្លាំងពលកម្មរបស់ជនជាប់ឃុំហើយរាជរដ្ឋាភិបាលក៏បានចេញប្រកាសជាអន្តរក្រសួងស្តីពីហាមប្រាមចំពោះការប្រើប្រាស់កម្លាំងជនជាប់ឃុំទាក់ទងនឹងការផលិតនូវផលិតផលមួយចំនួនដែលលក់ចេញទៅក្រៅប្រទេសដោយឥឡូវនេះនៅសល់តែការបណ្តុះបណ្តាលប៉ុន្មានខាងលើតែប៉ុណ្ណោះ។ គ្រូដែលមកបណ្តុះបណ្តាលនូវជំនាញខាងលើ គឺជាគ្រូដែលមកពីបណ្តាអង្គការនានាដូចជា អង្គការសម្ព័ន្ធមេត្រីភាពពន្ធនាគារជាដើម និងខាងសង្គមកិច្ចមួយចំនួន។ ក៏ដូចគ្នាផងដែរសម្រាប់មណ្ឌលអប់រំកែប្រែទី១

តែត្រូវបានកំណត់ចំនួនសិស្សដែលជាជនជាប់ឃុំចូលរៀនមិនបានគ្រប់ចំនួននោះទេដោយការសិក្សាវគ្គជំនាញនេះគឺរើសយកទណ្ឌិតណាដែលមានទោសជាប់ពន្ធនាគារចាប់ពី ០១ (មួយ) ឆ្នាំកន្លះឡើងទៅ និងក្រោម០៣ (បី) ឆ្នាំ[13]។

## ១.២. ស្ថានភាពទូទៅរបស់ពន្ធនាគារកម្ពុជា

### ១.២.១. ស្ថានភាពទូទៅរបស់ទណ្ឌិតនៅក្នុងពន្ធនាគារ

អគ្គនាយកដ្ឋានពន្ធនាគារបានរាយការណ៍កាលពីខែមីនា ឆ្នាំ២០២៣ កន្លងបានថ្លែងថានៅក្នុងឆ្នាំ២០២២ ជនជាប់ឃុំបានថយចុះ 0.៦% ខណៈជនជាប់ឃុំភាគច្រើនពាក់ព័ន្ធបទល្មើសគ្រឿងញៀន ដោយស្ថានភាពជនជាប់ឃុំគិតត្រឹម ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២២ មានចំនួនសរុប ៣៧,៨៤០ នាក់ ( ស្ត្រី ២,៣៧៤ នាក់) បើធៀបនឹងឆ្នាំ២០២១ មានការថយចុះប្រមាណ 0.៦% ស្មើនឹងចំនួន ២៣០ នាក់ដែលជាចំនួនតិចតួចប៉ុណ្ណោះ បើធៀបនឹងឆ្នាំ២០២១ ដែលមានចំនួនជនជាប់ឃុំចំនួន ៣៨ ០៧០ នាក់[14]។ ជនជាប់ឃុំទទួលថ្មីក្នុងឆ្នាំ២០២២ មានចំនួន ២០,១៤២ នាក់ និងបានអនុវត្តដីកាឱ្យដោះលែងមានចំនួន ២០,០៧៥ នាក់។ ជនជាប់ឃុំភាគច្រើនពាក់ព័ន្ធបទល្មើសគ្រឿងញៀនស្មើនឹង ៥២.៨២% ជនជាប់ឃុំជាទណ្ឌិតមានចំនួន ១១,៥០៧ នាក់ (ភាគច្រើនស្ថិតក្នុងនីតិវិធីតុលាការ) ជនជាប់ឃុំជាអនីតិជនមានចំនួន ១,៦៤៥ នាក់ ក្នុងនោះបានបញ្ជូនទៅក្រោមការគ្រប់គ្រងរបស់មណ្ឌលយុវនីតិសម្បទាមានចំនួន ២៣០ នាក់។ តាមសេចក្ដីថ្លែងសន្និបាតផ្សព្វផ្សាយទិសដៅការងារក្នុងឆ្នាំ២០២៣ របស់ក្រសួងមហាផ្ទៃលទ្ធផលការងារឆ្នាំ ២០២២ និងលើកទិសដៅឆ្នាំ២០២៣ របស់អគ្គនាយកពន្ធនាគារបានឱ្យដឹងថាក្នុងចំណោមជនជាប់ឃុំទាំង ៣៧,៨៤០ នាក់ មានជនបរទេស ១,៧៧១ នាក់ ( ស្ត្រី ២៣៨ នាក់ ) អនីតិជន ១,៦៤៥ នាក់ ( ស្ត្រី ៥៥ នាក់ ) ស្ត្រីមានផ្ទៃពោះ ២៦ នាក់ កូនតាមម្ដាយមានចំនួន ១០៩ នាក់ និងពិការ ៤៤២ នាក់។ ក្នុងនោះដែរ ក្នុងចំណោមជនជាប់ឃុំសរុបខាងលើត្រូវបានបែងចែកជាប្រភេទរួមមាន ជនត្រូវចោទ ៦,១៣៧ នាក់ ជនជាប់ចោទ ៤,៥០៣ នាក់ ពិរុទ្ធជន ១៥,៦៩៣ នាក់ និងទណ្ឌិត ១១,៥០៧ នាក់។ យ៉ាងណាមិញ ជនជាប់ឃុំទាំងនោះភាគច្រើនពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀនដែលស្មើនឹង ៥២.៨២% បទល្មើសលួចមានស្ថានទម្ងន់ទោស ១០.១៥ % បទល្មើសលួច ៨.២ % រំលោភសេពសន្ថវៈ ៦.១៧ % បទល្មើសឃាតកម្ម ៥.៧៥ % និងបទល្មើសផ្សេងៗ ១៦.៨៦ %[15]។

តែបើយើងធ្វើការប្រៀបធៀបចំនួនជនជាប់ឃុំនៅឆ្នាំ២០២២ ទៅនឹងជនជាប់ដែលមាននៅក្នុងឆ្នាំ២០១១ តាមរយៈរបាយការណ៍របស់អង្គការលីកាដូឆ្នាំ២០១២ ដែលមានជនជាប់ឃុំចំនួន ១៥,៤០៤[16] នាក់ វិញ គេសង្កេតឃើញថា

[13] បទសម្ភាសន៍ជាមួយលោកព្រំ សុផល ជាប្រធាន ការិយាល័យអប់រំកែប្រែមណ្ឌលអប់រំកែប្រែទី ២ (ឯកសារយោងពីសារណាឆ្នាំ ២០១២ ប្រធានបទស្ដីពីស្ថានភាពជនជាប់ឃុំក្នុងពន្ធនាគារ)

[14] ប្រសាសន៍របស់ឯកឧត្តម ប៉ាវ ហាមផាន ក្នុងកម្មវិធីបើកសន្និបាតផ្សព្វផ្សាយ លទ្ធផលការងារឆ្នាំ២០២១ និងលើកទិសដៅការងារឆ្នាំ២០២២ និងផែនការសកម្មភាពឆ្នាំ២០២២ របស់អគ្គនាយដ្ឋានពន្ធនាគារ ថ្ងៃទី២៥ ខែមិនា ឆ្នាំ២០២២

[15] ប្រសាសន៍របស់ឯកឧត្តមអគ្គានុរក្សថ្នាក់លេខ១ ឆែម សាវុធ អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារក្នុងសន្និបាតផ្សព្វផ្សាយទិសដៅការងារឆ្នាំ២០២៣ នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៣

[16] របាយការណ៍លីកាដូឆ្នាំ២០១២

ចំនួននៃជនជាប់ឃុំមានកើនឡើងរហូតដល់ចំនួន ២២,៤៣៦ នាក់ ស្មើប្រមាណជាង ៥៩.២៩% ដែលចំនួននេះធៀបនឹងរបាយការណ៍របស់អគ្គនាយដ្ឋានពន្ធនាគារក្នុងឆ្នាំ២០២២ ចំនួនអ្នកជាប់ឃុំមានការកើនឡើងយ៉ាងខ្លាំង ដែលជាចំនួនមួយដ៏ច្រើនលើសលប់ពីព្រោះពន្ធនាគារនៃព្រះរាជាណាចក្រកម្ពុជាត្រូវបានរបាយការណ៍របស់អង្គការលីកាដូ និងអង្គការលើកលែងទោសអន្តរជាតិធ្វើការប៉ាន់ប្រមាណថា អាចផ្ទុកចំនួនមនុស្សបានចំនួនជាង ២៦,៥៩៣ នាក់ តែប៉ុណ្ណោះ។ ការកើនឡើងនៃចំនួនអ្នកជាប់ឃុំនេះ គឺបន្ទាប់ពីយុទ្ធនាការបង្ក្រាបគ្រឿងញៀន និងដោយសារការកើនឡើងច្រើនហួសហេតុនៃការឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការជំនុំជម្រះក្តីបញ្ហានេះបានបង្កើតឱ្យមានប្រព័ន្ធនៃការឃុំខ្លួនដ៏ធំសម្បើម ដែលជិត ៧០ % នៃជនជាប់ឃុំទាំងនោះនៅមិនទាន់ទទួលបានការជំនុំជម្រះក្តីនៅឡើយទេ។ តួយ៉ាងរដ្ឋាភិបាលកម្ពុជាក៏មានការព្រួយបារម្ភនូវស្ថានភាពពន្ធនាគារចំពោះការកើនឡើងគួរឱ្យកត់សម្គាល់នេះផងដែរ ក្នុងនោះដែររាជរដ្ឋាភិបាលបានកំពុងតែចាត់វិធានការនានាចំពោះបញ្ហាពន្ធនាគារ ដោយបានដាក់បញ្ហាឱ្យអាជ្ញាធរពាក់ព័ន្ធឱ្យចូលរួមក្នុងការដោះស្រាយចំពោះបញ្ហាចង្អៀតណែនក្នុងពន្ធនាគារនេះ ដោយការពន្លឿនការដោះស្រាយសំណុំរឿងដែលកកស្ទះ និងការដោះលែងជនជាប់ឃុំដែលប្រព្រឹត្តបទល្មើសស្រាលៗ។

ពន្ធនាគារបន្តចង្អៀតណែន ដោយសារបទល្មើសកើនឡើងជាពិសេសបញ្ហាគ្រឿងញៀន និងរដ្ឋាភិបាលមិនទាន់បានលទ្ធភាពពង្រីកអគារពន្ធនាគារបន្ថែមទៀត។ ទោះបីជាយ៉ាងណាក៏ដោយ កាលពីឆ្នាំ២០១៩ កន្លងទៅនេះមានការរីករាលដាលឆ្លងជម្ងឺកូវីដ១៩ ជនជាទណ្ឌិតនៅក្នុងពន្ធនាគារបានប្រឈមមុខជាងគេនឹងការឆ្លងនៃជម្ងឺដ៏កាចសាហាវនេះដោយស្ថានភាពនៃការជាប់របស់ទណ្ឌិតទាំងអស់នោះមានលក្ខណៈចង្អៀតណែនដោយសារមណ្ឌលឃុំឃាំងមានចំនួនតិច ហើយបញ្ហាអនាម័យនៅក្នុងពន្ធនាគារក៏មិនទាន់មានលក្ខណៈល្អប្រសើរនៅឡើយ។

អគ្គនាយកដ្ឋានពន្ធនាគារនៃក្រសួងមហាផ្ទៃក៏បានដាក់ចេញនូវវិធានការសុខាភិបាល និងវិធានការសន្តិសុខដោយញែកជនជាប់ឃុំខាងក្នុងពន្ធនាគារជាច្រើនផ្នែកដើម្បីសុវត្ថិភាព និងសុខភាពរបស់ជនជាប់ឃុំ ជាពិសេសអាជ្ញាធរពន្ធនាគារបានយកចិត្តទុកដាក់ទប់ស្កាត់ជម្ងឺកូវីដ១៩ និងព្យាបាលអ្នកឆ្លងជម្ងឺកូវីដ១៩ ប៉ុន្តែបញ្ហាប្រឈម គឺពន្ធនាគារមានភាពចង្អៀត និងសភាពទ្រុឌទ្រោម ដោយត្រូវការថវិកា និងធនធានក្នុងការពង្រីកអគារទាំងអស់នោះឱ្យបានទូលំទូលាយ និងទីតាំងសុវត្ថិភាព។ ដោយរយៈពេលកន្លងទៅសង្កេតឃើញថាមានប្រទេសមួយចំនួនដែលជាប្រទេសផ្តល់ជំនួយដូចជាអូស្ត្រាលីជាដើមបានផ្តល់ជាជំនួយដើម្បីសាងសង់អគារពន្ធនាគារថ្មីៗធ្វើយ៉ាងណារក្សាឱ្យបាននូវសុវត្ថិភាពជូនជនជាប់ឃុំ ធ្វើយ៉ាងណាអនុវត្តវិធានការសុខាភិបាលទៅលើជនជាប់ឃុំទាំងអស់នោះ ដើម្បីការពារកុំឱ្យជម្ងឺកូវីដ១៩ រីករាលលដាលក្នុងពន្ធនាគារ។ យោងតាមពីអគ្គនាយកដ្ឋានពន្ធនាគារ ក្នុងឆ្នាំ២០២២ បានលើកឡើងថាអគ្គនាយកដ្ឋានពន្ធនាគារបានកំពុងបន្តពិនិត្យសិក្សា រៀបចំក្របខ័ណ្ឌនានា សម្រាប់គាំទ្រដល់ការបង្កើតមណ្ឌលគ្រប់ទណ្ឌិតពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន នៅស្រុកតាលោសែនជ័យ ខេត្តពោធិ៍សាត់ គម្រោងសាងសង់ពន្ធនាគារខេត្ត

កណ្តាលថ្មីនៅស្រុងស្អាង និងគម្រោងពន្ធនាគារថ្មីខេត្តស្វាយរៀង ព្រមទាំងបន្តពង្រឹងកិច្ចការពារសន្តិសុខ សណ្តាប់ធ្នាប់ និងសុវត្ថិភាពពន្ធនាគារ[17]។

### ១.២.២. ស្ថានភាពនៃការឃុំឃាំង

ស្ថានភាពនៃការឃុំឃាំង មានភាពចង្អៀតណែននៃមន្ទីរឃុំឃាំងដែលស្ទើរតែរកកន្លែងដាក់អ្នកថ្មីលែងបានទៅហើយនោះ គឺជាភស្តុតាងបញ្ជាក់ថាជំងឺសង្គមពិតជាបញ្ហាដែលមិនអាចមើលរំលងបានឡើយ។ មានមូលហេតុច្រើនយ៉ាងដែលធ្វើឲ្យពន្ធនាគារទូទាំងប្រទេសកាន់តែចង្អៀតឡើងៗពីមួយថ្ងៃទៅមួយថ្ងៃ។ ការស្រុតចុះនៃសីលធម៌សង្គមគឺជាមូលហេតុចម្បងជាងគេមួយ បច្ចុប្បន្ននេះមនុស្សមួយចំនួនហាក់ដូចជាធ្វើខ្លួនឲ្យងាយប្រព្រឹត្តបទល្មើសយ៉ាងខ្លាំង។ ជាក់ស្តែង សូម្បីតែរឿងបន្តិចបន្តួចសោះក៏គេអាចបង្កឲ្យទៅជាបទល្មើសធំមួយបានដែរហើយពេលខ្លះក៏ឈានដល់បទឧក្រិដ្ឋសម្លាប់មនុស្សក៏មាន។ អំពើឃាតកម្ម លួច ប្លន់ កាប់ចាក់ បាញ់ប្រហារ រំលោភ គ្រឿងញៀន ឬអំពើឆបោកជាដើម គឺជារឿងដែលកើតមានស្ទើរតែរៀងរាល់ថ្ងៃ។ អ្នកប្រព្រឹត្តល្មើសទាំងនេះឯងដែលជាកម្មវត្ថុនៃការចាប់ខ្លួនបញ្ជូនទៅមន្ទីរឃុំឃាំង។ ស្របពេលដែលសង្គមកំពុងកើតមានបញ្ហាជាច្រើនបែបនេះ ប្រព័ន្ធយុត្តិធម៌ក៏នៅទន់ខ្សោយយ៉ាងខ្លាំងដែរនេះក៏ជាមូលហេតុមួយទៀតដែលនាំឲ្យមនុស្សងាយនឹងជាប់ពន្ធនាគារដែរមានន័យថាអ្នកជាប់ពន្ធនាគារមួយចំនួនមិនប្រាកដថាពួកគេប្រព្រឹត្តល្មើសនោះទេតែក៏មានជនរងគ្រោះដោយអំពើអយុត្តិធម៌នៅក្នុងពន្ធនាគារដែរ ដោយអយុត្តិធម៌ដែលកើតឡើងដោយសារអំពើពុករលួយ និងការប្រើអំណាចបំពានជាដើម។

*តើមានមនុស្សប៉ុន្មាននាក់ដែលកំពុងជាប់ពន្ធនាគារដោយអំពើអយុត្តិធម៌នេះ?*

គ្មានអ្នកណាអាចផ្តល់ចម្លើយជាក់លាក់បាននៅឡើយទេ ប៉ុន្តែមានសំណុំរឿងជាច្រើនមកហើយដែលជាភស្តុតាងបង្ហាញថាពិតជាមានអ្នករងគ្រោះជាប់ពន្ធនាគារដោយសារអំពើអយុត្តិធម៌មែន។ ជនជាប់ចោទមួយចំនួនទៀតត្រូវបានគេឃុំខ្លួនលើសកាលកំណត់ខណៈដែលខ្លះទៀតត្រូវបានតុលាការបញ្ជាឱ្យឃុំខ្លួនទោះបីជាពួកគេមិនបានប្រព្រឹត្តកំហុសធ្ងន់ធ្ងរដែលគួរតែអាចនៅក្រៅឃុំបណ្តោះអាសន្នបានក៏ដោយ ផ្ទុយពីអ្នកខ្លះដែលគួរតែជាប់ពន្ធនាគារតែបែរជារស់នៅមានសេរីភាពទៅវិញ។ ទាំងអស់នេះសុទ្ធតែជារឿងរ៉ាវពិតៗដែលកំពុងកើតមាននៅក្នុងសង្គមបច្ចុប្បន្ន។ ជាការពិតណាស់មានទ្រឹស្តីពីរផ្ទុយគ្នាដែលគេធ្លាប់បានឮនៅក្នុងប្រព័ន្ធយុត្តិធម៌។ ទ្រឹស្តីទី១ «សូវចាប់ខ្លួនមនុស្សច្រឡំកុំឲ្យតែដោះលែងច្រឡំ» ទ្រឹស្តីនេះត្រូវបានគេអនុវត្តនៅក្នុងរបបកុំម្មុយនិស្តផ្តាច់ការដូចជារបបខ្មែរក្រហមជាដើម។ ការអនុវត្តបែបប្រមាថជីវិតមនុស្សនេះហើយដែលធ្វើឲ្យរបបនេះសម្លាប់មនុស្សគ្មានញញើតដោយគ្រាន់តែការសង្ស័យ ចំណែកទ្រឹស្តីទី២ វិញមានន័យផ្ទុយពីនេះ៖ «សូវដោះលែងមនុស្សច្រឡំ កុំឲ្យតែដាក់ទោសមនុស្សខុស»។ ទ្រឹស្តីនេះត្រូវបានគេអនុវត្តក្នុងបណ្តាប្រទេសប្រជាធិបតេយ្យជឿនលឿនដែលយកគោលការណ៍គោរពសិទ្ធិមនុស្សជាធំវាមានន័យ

[17] ប្រសាសន៍របស់ឯកឧត្តមអគ្គានុរក្សថ្នាក់លេខ១ ឆែម សាវុធ អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារក្នុងសន្និបាតផ្សព្វផ្សាយទិសដៅការងារឆ្នាំ ២០២៣

ស្មើនឹងភាសាច្បាប់ដែលថា «វិមតិសង្ស័យនឹងបានជាប្រយោជន៍ដល់ជនជាប់ចោទ»។ ទ្រឹស្តីទី២នេះ មានសារៈសំខាន់ណាស់សម្រាប់កម្ពុជាប្រសិនបើប្រទេសនេះចង់ដើរនៅលើគន្លងប្រជាធិបតេយ្យមែននោះ។

ក្នុងនោះដែរ យើងសង្កេតឃើញថា បច្ចុប្បន្នមានកំណើននៃការប្រព្រឹត្តបទល្មើសគ្រឿងញៀន ដែលបញ្ជាក់ឱ្យឃើញកាន់តែច្បាស់ថាប្រជាជនមួយចំនួនមិនទាន់មានការយល់ដឹងទៅលើបញ្ហាសុខភាពដែលបង្កមកពីការប្រើប្រាស់គ្រឿងញៀននៅឡើយ។ ជាពិសេស ចំពោះអនីតិជនដែលជាវ័យចឹងដឹង ចង់ឮ ចង់សាកនូវអ្វីថ្មី ដោយកង្វះការណែនាំ និងវិធានការផ្សព្វផ្សាយជាសាធារណៈនៅក្នុងសង្គមដែលបញ្ហានេះបង្កជាហានិភ័យដ៏ធំសម្រាប់សង្គមដែលមានជនជាប់ឃុំជាអ្នកប្រើប្រាស់ និងចែកចាយគ្រឿងញៀនច្រើននៅក្នុងសង្គម។

សរុបមកវិញ ដើម្បីដោះស្រាយបញ្ហាកំណើនអ្នកជាប់ឃុំក្នុងពន្ធនាគារមានកិច្ចការច្រើនយ៉ាងដែលត្រូវធ្វើ។ ជាបឋមការលើកកម្ពស់សីលធម៌សង្គមចេញនូវវិធានការផ្សព្វផ្សាយ និងទប់ស្កាត់ គឺជាកិច្ចការដ៏ចម្បងបំផុតដែលត្រូវគិតគូរ។ នៅពេលដែលមនុស្សមានសីលធម៌ខ្ពស់ ចេះយល់អធ្យាស្រ័យល្អរវាងគ្នា និងយល់ដឹងពីផលប៉ះពាល់នៃការប្រព្រឹត្តបទល្មើសនឹងច្បាប់ដោយមិន ខុសដៃយកដៃ ខុសជើងយកជើង និងមិនប្រព្រឹត្តអំពើល្មើសនោះ ជម្លោះប្តឹងផ្តល់នឹងត្រូវបានកាត់បន្ថយ។ ទន្ទឹមនឹងនោះ ការពង្រឹងប្រព័ន្ធយុត្តិធម៌ និងនីតិរដ្ឋក៏ជាកិច្ចការដ៏សំខាន់មួយទៀតដែរពោលគឺតុលាការត្រូវតែឯករាជ្យ និងជាយន្តការផ្តល់យុត្តិធម៌ដែលជាទីទុកចិត្តរបស់ពលរដ្ឋ។ ឥឡូវនេះមេរោគដែលបណ្តាលឲ្យមានជំងឺសង្គមត្រូវបានគេមើលឃើញអស់ហើយ ដូច្នេះវានៅសល់តែសុឆន្ទៈ និង សមត្ថភាពក្នុងការព្យាបាលបំបាត់មេរោគសង្គមទាំងនោះតែប៉ុណ្ណោះដែលអ្នកដឹកនាំ និងអ្នកតម្រង់ទិសសង្គមទាំង ឡាយត្រូវបង្ហាញ។ ពលរដ្ឋខ្មែរគ្រប់គ្នាក៏មានចំណែកសំខាន់ណាស់ដែរក្នុងការចូលរួមលើកកម្ពស់សីលធម៌សង្គម ក៏ដូចជាលើកកម្ពស់ការគោរពច្បាប់។ ប្រសិនបើគេអាចធ្វើឲ្យសង្គមមានភាពសុខដុមរមនាជាសះស្បើយពីជំងឺទាំងអស់នេះ ចំនួនអ្នកជាប់ពន្ធនាគារប្រាកដជានឹងថយចុះជាស្វ័យប្រវត្តិ។

#### ១.២.២.១. កំណើននៃអត្រាជនជាប់ឃុំ

បើយើងទិន្នន័យកាលពីឆ្នាំ២០១១ ចំនួនជនជាប់ឃុំ មានចំនួនត្រឹមតែ ១៥,៤០៤[18] នាក់តែប៉ុណ្ណោះ លុះដល់ឆ្នាំ២០២២ ចំនួនជនជាប់ឃុំមានការកើនឡើងទ្វេដងគឺមានចំនួនរហូតដល់ទៅ ៣៧,៨៤០ នាក់។

នៅក្នុងកំឡុងពេលពីខែធ្នូ ឆ្នាំ២០១១ និងខែធ្នូ ឆ្នាំ២០២២ ចំនួនអ្នកទោសកើនឡើងដល់ទៅ ២២, ៤៣៦ នាក់ ដែលចំនួនជនជាប់ឃុំនេះនឹងបានបន្តកើនឡើងទ្វេដងក្នុងរយៈពេលត្រឹមតែ ១១ ឆ្នាំតែប៉ុណ្ណោះ ប្រមាណណជា ៥៩.២៩%។

អត្រាជនជាប់ឃុំទូទាំងប្រទេសកព្រះរាជាណាចក្រកម្ពុជាធៀបទៅនឹងចំនួនប្រជាពលរដ្ឋទូទាំងប្រទេសក្នុងរយៈពេល ១១ ឆ្នាំ យើងឃើញថាកាលពីឆ្នាំ២០១១ ចំនួនប្រជាជនសរុបទូទាំងព្រះរាជាណាចក្រកម្ពុជាមានចំនួន

[18] របាយការណ៍អង្គការលីកាដូ ខែកក្កដា ឆ្នាំ២០១២

១៤,៣៦៥,២២៤ នាក់[19] ដែលក្នុងនោះមានចំនួនជនជាប់ឃុំចំនួន ១៥,៤០៤ នាក់។ លុះមកដល់ឆ្នាំ ២០២២ ចំនួនប្រជាជនទូទាំងព្រះរាជាណាចក្រកម្ពុជាមានចំនួន ១៥,២៨៨,៤៨៩ នាក់ ក្នុងនោះមានជនជាប់ឃុំរហូតដល់ទៅចំនួន ៣៧,៨៤០នាក់។ តាមទិន្នន័យនេះ គេសង្កេតឃើញថាចំនួនប្រជាជននៅទូទាំងប្រទេសមានការកើនឡើងត្រឹមតែចំនួន ៩២៤,២៦៥ នាក់ ស្មើនឹងប្រមាណ ៦.០៤៥% តែប៉ុណ្ណោះបើធៀបនឹងឆ្នាំ២០២២ ចំណែកឯចំនួននៃជនជាប់ឃុំនៅទូទាំងប្រទេសមានរហូតដល់ទៅ ៥៩.២៩% នេះជាចំនួនកើនឡើងដល់ច្រើនត្រឹមតែរយៈពេល ១១ ឆ្នាំតែប៉ុណ្ណោះ។

***សំគាល់៖*** ទិន្នន័យនៅឆ្នាំ២០១១ ឃើញថាកំណើនប្រជាពលរដ្ឋកំណើន ៦.០៤៥ នាក់ ប៉ុន្តែកំណើនអ្នកទោសមានរហូតដល់ ៥០.២៩ %។ ទិន្នន័យជនជាប់ឃុំក្នុងឆ្នាំ២០១១ នេះសម្រាប់តែពន្ធនាគារដែលអង្គការលីកាដូឃ្លាំមើលតែប៉ុណ្ណោះ។

ផែនការដើម្បីរក្សាពន្ធនាគារឱ្យស្ថិតនៅក្រោមចំណុះនៅពេលអនាគតហាក់ដូចជាមិនសូវមានសង្ឃឹមច្រើនទេ ប្រសិនបើពន្ធនាគារទាំងអស់នៅតែរក្សាកំណើនត្រឹម ៥៩.២៩% ក្នុងរយៈពេល ១១ ឆ្នាំនោះនៅកម្ពុជានឹងត្រូវការកសាងពន្ធនាគារថ្មីៗបន្ថែមដែលមានទំហំស្មើមណ្ឌលអប់រំកែប្រែទី៤ ឱ្យបានយ៉ាងហោចណាស់មួយជារៀងរាល់ឆ្នាំ។ ទោះជាបែបនេះក៏ដោយវានៅតែមិនទាន់ឆ្លើយតបទៅនឹងបរិមាណអ្នកទោសដែលចេះតែកើនឡើងឥតឈប់ឈរនេះឡើយ។ ឧបមាថានេះជាករណីដ៏អាក្រក់នៃការបន្តកើនឡើងជាង ៥៩.២៩% ក្នុងរយៈពេល ១១ ឆ្នាំកន្លងទៅបូករួមទាំងការបន្ថែមបន្ទប់សម្រាប់អ្នកទោស ៤០០ នាក់ ក្នុងមួយឆ្នាំជាមធ្យមនោះប្រទេសកម្ពុជាអាចក្លាយជាពន្ធនាគារចង្អៀតជាងគេបំផុតលើពិភពលោកនៅឆ្នាំ២០៤០។

តួលេខ "បច្ចុប្បន្ន" គឺផ្អែកលើលទ្ធភាព និងចំនួនអ្នកទោសនៅក្នុងពន្ធនាគារទាំងអស់ដែលមាននៅក្នុងរបាយការណ៍របស់អគ្គនាយកដ្ឋានពន្ធនាគារនាខែមីនា ឆ្នាំ២០២២ កន្លងទៅ។ កម្ពុជាពុំអាចកសាងពន្ធនាគារឱ្យលឿនទាន់នឹងល្បឿនកំណើនអ្នកទោសដែលចេះតែកើនឡើងនាពេលបច្ចុប្បន្ននេះទេ ម្យ៉ាងទៀតថវិកាសម្រាប់សាងសង់ពន្ធនាគារនៅមានកម្រិតនៅឡើយ។ ការកសាងពន្ធនាគារ និងការឃុំឃាំងអ្នកទោសឱ្យបានសមស្របតាមលក្ខខណ្ឌ និងស្តង់ដាអន្តរជាតិចាំបាច់ត្រូវចំណាយច្រើនណាស់ហើយមកដល់ពេលនេះ យោងតាមមន្ត្រីដែលផ្តល់សម្ភាសន៍ជាមួយលីកាដូបានឱ្យដឹងថា នៅពេលនេះពន្ធនាគារជួបប្រទះនូវកង្វះខាតថវិកាក្នុងការកសាងមណ្ឌលអប់រំកែប្រែទី៤ ហើយកាលពីឆ្នាំ២០១១។ ម្យ៉ាងវិញទៀត វាជាករណីកម្រណាស់នាពេលកន្លងមកដែលពន្ធនាគារថ្មីណាមួយអាចបញ្ចប់គម្រោងសាងសង់ដោយថវិការដ្ឋ។ តាមធម្មតាសាងសង់ពន្ធនាគារថ្មីបែបនេះច្រើនតែត្រូវបានជួយកសាងបង្ហើយ និងកែលំអរដោយអង្គការមិនមែនរដ្ឋាភិបាលជាតិ ឬអន្តរជាតិ។

[19] របាយការណ៍ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩ របស់វិទ្យាស្ថានជាតិស្ថិតិក្រសួងផែនការខែមិថុនា ឆ្នាំ២០១៩

### ១.២.២.២. កត្តារួមផ្សំបណ្តាលឱ្យមានភាពចង្អៀតណែនក្នុងពន្ធនាគារ

បញ្ហាចង្អៀត គឺជាលទ្ធផលនៃកត្តារួមផ្សំជាច្រើនប៉ុន្តែអ្វីដែលសំខាន់នោះ គឺការពឹងផ្អែកលើសលប់លើពន្ធនាគារតែម្យ៉ាងដើម្បីដោះស្រាយបញ្ហានេះ។ បច្ចុប្បន្ននេះប្រព័ន្ធយុត្តិធម៌កម្ពុជា គឺផ្តោតការយកចិត្តទុកដាក់ស្ទើរតែទាំងស្រុងលើការឃុំឃាំងទាំងទណ្ឌិត និងពិរុទ្ធជនដែលរង់ចាំសវនាការ។ ការផ្តន្ទាទោសស្ទើរតែគ្រប់បទល្មើសទាំងអស់ គឺត្រូវដាក់ពន្ធនាគារសូម្បីតែបទល្មើសស្រាលក៏ដោយហើយច្រើនតែជាប់ក្នុងរយៈពេលមួយយូរទៀតផង។ ដូចគ្នានេះដែរ ការដាក់ឱ្យជនត្រូវចោទនៃបទល្មើសព្រហ្មទណ្ឌឱ្យនៅក្រៅឃុំរង់ចាំសវនាការ គឺជាករណីកម្រណាស់ភាគច្រើនត្រូវឃុំឃាំងបណ្តោះអាសន្នរង់ចាំការបើកសវនាការជំនុំជម្រះក្តី។ ទ្រឹស្តីមួយបានលើកឡើងថា"ប្រសិនបើពន្ធនាគារទាំងអស់នៅតែរក្សាកំណើននោះនៅកម្ពុជានឹងត្រូវកសាងពន្ធនាគារថ្មីៗបន្ថែមដែលមានទំហំស្មើមណ្ឌលអប់រំកែប្រែទី៤ ឱ្យបានយ៉ាងហោចណាស់មួយជារៀងរាល់ឆ្នាំ។ ទោះជាបែបនេះក៏ដោយ វានៅតែមិនទាន់ឆ្លើយតបទៅនឹងបរិមាណអ្នកទោសដែលចេះតែកើនឡើងឥតឈប់ឈរនេះឡើយ"។

កន្លងមក អង្គការលីកាដូបានកត់ត្រានូវករណីជាច្រើនដែលត្រូវឃុំឃាំងលើសថេរវេលាកំណត់នៃច្បាប់។ ការឃុំឃាំងមនុស្សម្នាក់ហើយម្នាក់ទៀត ក្នុងនោះមានករណីខ្លះគួរពិចារណាលើការដាក់ឱ្យនៅក្រៅឃុំបណ្តោះអាសន្ន ប៉ុន្តែការសម្រេចចិត្តភាគច្រើនរបស់ចៅក្រមមិនបានគិតថាពន្ធនាគារស្ទើរតែប្រេះថ្មេរបែកធ្លាយទៅហើយដោយសារតែចំនួនកំណើននៃអ្នកទោសជាប់ឃុំនៅក្នុងពន្ធនាគារនៅក្នុងព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្ននោះទេ។

បុគ្គលដែលជាប់ឃុំឃាំងទាំងនោះមានដូចជា៖

- ពិរុទ្ធជនដែលជាប់ឃុំឃាំងបណ្តោះអាសន្នរង់ចាំសវនាការលើសថេរវេលាកំណត់ដោយច្បាប់[20]។
- ទណ្ឌិតដែលត្រូវបានឃុំឃាំងលើសថេរវេលាកំណត់នៃទោស បញ្ហានេះអាចកើតឡើងដោយសារតែមានការយឺតយ៉ាវនូវនីតិវិធីរដ្ឋបាលក្នុងការរៀបចំឯកសារដោះលែងអាចជាឧបសគ្គដោយសារមន្ត្រីពន្ធនាគារក្នុងការរៀបចំឯកសារ ឬដោយសារតែបញ្ហាទាំងពីរខាងលើ។
- ពិរុទ្ធជនដែលជាប់ឃុំឃាំងបណ្តោះអាសន្ន ត្រូវឃុំលើសកម្រិតអតិបរមានៃទោសក្នុងបទល្មើសដែលត្រូវបានចោទប្រកាន់។
- ពិរុទ្ធជនជាប់បណ្តឹងឧទ្ធរណ៍ហើយជាប់នៅក្នុងឃុំលើសកម្រិតអតិបរមានៃទោសដែលត្រូវបានកំណត់ករណីដ៏កំសត់បំផុតនោះ គឺជនត្រូវចោទដែលត្រូវបានលើកលែងការចោទប្រកាន់ហើយនាពេលសវនាការសាលាដំបូង ប៉ុន្តែត្រូវជាប់ឃុំតទៅទៀតដោយសារតែជាប់បណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា[21]។

[20] មាត្រា២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[21] មាត្រា៣៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

- ការផ្តោតតែទៅលើការបញ្ជូនជនត្រូវចោទទៅដាក់ពន្ធនាគារជាអាទិភាពនោះ វាជាការវិបាកមួយដែលមិនអាចចៀសផុតបាននៃការដែលមានកំណើនអ្នកទោសឥតឈប់ឈរដែលនេះហើយ គឺជាមូលហេតុនៃការចង្អៀតណែនណពន្ធនាគារនោះ។

## ផ្នែកទី២. សិទ្ធិរបស់ទណ្ឌិតជាទូទៅក្នុងអំឡុងពេលអនុវត្តទោស

ជាទូទៅទោស គឺជាទណ្ឌកម្មដែលត្រូវផ្តន្ទាដោយសង្គមតាមរយៈច្បាប់ទៅលើជន ឬបុគ្គលទាំងឡាយណាដែលបានប្រព្រឹត្តបទល្មើស និងទណ្ឌិតជាជនដែលត្រូវបានសាលក្រមចេញដីកាឃុំខ្លួនជាស្ថាពរ។ អំឡុងពេលអនុវត្តទោសទណ្ឌិតមានសិទ្ធិជាច្រើនក្នុងការរស់នៅប្រចាំថ្ងៃទោះបីជាត្រូវដកហូតសិទ្ធិសេរីភាពរបស់ពួកគេយ៉ាងណាក៏ដោយ។ បន្ទាប់ពីទទួលយកជនជាប់ឃុំចូលក្នុងពន្ធនាគារ មន្ត្រីពន្ធនាគារត្រូវណែនាំដល់ជនជាប់ឃុំអំពីច្បាប់ បទបញ្ជាផ្ទៃក្នុងពន្ធនាគារ សិទ្ធិស្វែងរកអ្នកតំណាងផ្លូវច្បាប់ សិទ្ធិផ្តល់ដំណឹងទៅគ្រួសារ ឬសាច់ញាតិ ឬស្ថាប័នពាក់ព័ន្ធផ្សេងៗអំពីការជាប់ពន្ធនាគារ និងទីតាំងនៃពន្ធនាគារព្រមទាំងសិទ្ធិ និងករណីយកិច្ចផ្សេងៗទៀតដូចមានចែងក្នុងច្បាប់នេះ។ ក្នុងករណីជនជាប់ឃុំជាជនបរទេស ប្រធានពន្ធនាគារត្រូវអនុញ្ញាតឲ្យជនជាប់ឃុំជូនដំណឹងទៅស្ថានទូត ឬស្ថានកុងស៊ុល ឬស្ថានតំណាងរបស់ខ្លួន។ ប្រសិនបើជនជាប់ឃុំមិនមានលទ្ធភាពជូនដំណឹងបាន ប្រធានពន្ធនាគារត្រូវធ្វើកិច្ចការនេះ។ ក្រោយពីបានទទួលការណែនាំនេះជនជាប់ឃុំត្រូវផ្តិតម្រាមដៃនិងបិទ ឬល្ខោនរូបថតបញ្ចូលក្នុងកុំព្យូទ័រ ដើម្បីរក្សាទុកជាអចិន្ត្រៃយ៍ក្នុងសំណុំឯកសារ។

### ១.១. សិទ្ធិក្នុងការរស់នៅ

ជនជាទណ្ឌិតដែលត្រូវបានឃុំខ្លួនក្នុងពន្ធនាគារត្រូវទទួលបានសិទ្ធិទទួលបាននូវបន្ទប់ឃុំឃាំងដែលខ្លួនរស់នៅត្រូវមាន ពន្លឺគ្រប់គ្រាន់ មានខ្យល់ធម្មជាតិ មានបន្ទប់អនាម័យ មានប្រព័ន្ធផ្គត់ផ្គង់ទឹក និងអគ្គិសនីសម្រាប់ប្រើប្រាស់។[22] អ្នកទោសត្រូវបានដាក់អ្នកទោសបុរស និងអ្នកទោសស្ត្រីឱ្យនៅដាច់ដោយឡែកពីគ្នា។ អ្នកទោសដែលមានអាយុក្រោម ១៨ ឆ្នាំដាក់ឱ្យឡែកពីអ្នកទោសពេញវ័យ។ ក្នុងនោះដែរ អ្នកទោសដែលជាពិរុទ្ធជនត្រូវដាក់ដោយឡែកពីទណ្ឌិត អ្នកទោសដែលបានរត់គេចពីពន្ធនាគារ ឬបានប្រព្រឹត្តអ្វីមួយផ្ទុយពីសន្តិសុខ និងសណ្តាប់ធ្នាប់ល្អរបស់ពន្ធនាគារ។[23] អ្នកទោសកម្រិតធ្ងន់ដាក់ឱ្យនៅដោយឡែកពីអ្នកទោសកម្រិតស្រាល ឬអ្នកទោសមធ្យម ចំណែកអ្នកទោសដែលមានរោគប្រចាំកាយ ឬមានជម្ងឺសរសៃប្រសាទមានរបួសធ្ងន់ធ្ងរដែលប៉ះពាល់ដល់សុខភាពសាមីខ្លួន និងដល់អ្នកដទៃទៀត និងការការពារអ្នកទោសពីការវាយប្រហារផ្សេងទៀត។[24]

ប្រសិនបើជនជាប់ឃុំដេកក្នុងបន្ទប់រួមគ្នា គេត្រូវជ្រើសយកតែជនជាប់ឃុំប្រភេទណាដែលអាចរស់នៅជាមួយគ្នាបានឲ្យនៅក្នុងបន្ទប់ជាមួយគ្នាហើយត្រូវឲ្យមានការត្រួតពិនិត្យមើលឲ្យបានទៀងទាត់នៅវេលាយប់អាស្រ័យទៅតាម

---

[22] មាត្រា១១ នៃច្បាប់ស្តីពីពន្ធនាគារឆ្នាំ២០១១

[23] មាត្រា ២៦ នៃច្បាប់ស្តីពីពន្ធនាគារឆ្នាំ២០១១

[24] នីតិវិធីលេខ៣ នៃនីតិវិធីពន្ធនាគាររបស់អគ្គនាយដ្ឋានពន្ធនាគារ ឆ្នាំ២០០៣

ប្រភេទនៃពន្ធនាគារ។ គ្រប់កន្លែងស្នាក់នៅដែលប្រើសម្រាប់ដាក់ជនជាប់ឃុំ និងជាពិសេសកន្លែងដេកទាំងអស់ត្រូវស្របទៅតាមតម្រូវការផ្នែកសុខភាពពោល គឺយកចិត្តទុកដាក់ទៅលើលក្ខណៈធាតុអាកាស និងជាពិសេសគឺត្រូវមានខ្យល់ដកដង្ហើមគ្រប់គ្រាន់ មានទំហំផ្ទៃរាបសមល្មម មានពន្លឺ កំដៅ និងខ្យល់អាកាសចេញចូលគ្រប់គ្រាន់។

នៅគ្រប់ទីកន្លែងណាដែលគេតម្រូវឲ្យជនជាប់ឃុំនៅផងហើយធ្វើការផងគេត្រូវមានបង្អួចទូលំទូលាយ ដើម្បីឲ្យជនជាប់ឃុំអាចធ្វើការ ឬអានសៀវភៅបានដោយពន្លឺថ្ងៃហើយឲ្យមានច្រកចំហធំៗដើម្បីឲ្យខ្យល់បក់បានគ្រប់គ្រាន់ទោះជាមាន ឬគ្មានកង្ហារបក់ខ្យល់ក៏ដោយ។

បង្គន់ត្រូវឲ្យមានគ្រប់គ្រាន់សម្រាប់សេចក្តីត្រូវការរបស់ជនជាប់ឃុំគ្រប់ពេលវេលាហើយត្រូវឲ្យមានភាពស្អាត និងសមរម្យផងដែរ។ ប្រដាប់ប្រើប្រាស់ក្នុងបន្ទប់ទឹកក៏ត្រូវឲ្យមានគ្រប់គ្រាន់ត្រូវឲ្យមានទឹកសម្រាប់សេចក្តីត្រូវការចាំបាច់របស់ជនជាប់ឃុំដោយយោងទៅតាមលក្ខខណ្ឌអនាម័យទូទៅប្រចាំរដូវកាល និងទៅតាមលក្ខណ្ឌតំបន់ភូមិសាស្ត្រ និងគ្រប់ផ្នែកនៃពន្ធនាគារដែលសម្រាប់ឱ្យជនជាប់ឃុំប្រើប្រាស់ជានិច្ចជាកាលត្រូវថែទាំសម្អាតឲ្យបានត្រឹមត្រូវ និងយ៉ាងហ្មត់ចត់គ្រប់ពេលវេលា[25]។

### **១.១.១. សិទ្ធិទទួលបាននូវសម្លៀកបំពាក់ និងសម្ភារៈប្រើប្រាស់ចាំបាច់**

មន្ត្រីទទួលបន្ទុកយកអ្នកទោសចូលក្នុងពន្ធនាគារត្រូវធនាគារថា នៅពេលទទួលយកអ្នកទោសចូលក្នុងពន្ធនាគារត្រូវផ្តល់នូវឯកសណ្ឋាន និងសម្ភារៈបរិក្ខាសម្រាប់បំពេញតម្រូវការនៃការរស់នៅប្រចាំថ្ងៃរបស់អ្នកទោសមានដូចជា អាវអំបោះពណ៌ខៀវឆ្នូតសពីឈុត ស្បែកជើងផ្ទាត់មួយសម្រាប់ ក្រមាមួយ ខោខ្លីអំបោះពណ៌ខៀវពីរ អ្នកទោសស្ត្រីត្រូវទទួលមានសារុងមួយផងដែរ មុងមួយ កន្ទេលដេកមួយ ភួយមួយ ខ្នើយកើយមួយ កន្ត្ទោរមួយ បើសិនជាអ្នកទោសគ្មានបង្គន់ ចានសម្លរមួយ ចានបាយមួយ ស្លាបព្រា ដបទឹកប្លាស្ទិចមួយ សាប៊ូមួយដុំ ថ្នាំដុសធ្មេញ ច្រាសដុសធ្មេញ ក្រាសសិតសក់ អ្នកទោសស្ត្រីអាចទទួលបានសម្ភារៈអានាម័យ និងទទួលបានក្រណាត់កៅស៊ូភ្លៀងសម្រាប់អ្នកទោសធ្វើពលកម្ម[26]។

លើសពីនេះទៅទៀត ជនជាប់ទោសនៅក្នុងមណ្ឌលអប់រំកែប្រែ ឬពន្ធនាគារមានសិទ្ធិក្នុងការទទួលបាននូវ សម្ភារៈ និងសម្ភារៈប្រើប្រាស់ដូចខាងក្រោម ៖

១. រាល់ជនជាប់ឃុំណាដែលមិនអនុញ្ញាតឲ្យស្លៀកពាក់សម្លៀកបំពាក់ផ្ទាល់ខ្លួនរបស់គេទេនោះពួកគេត្រូវតែបានគេផ្តល់ឲ្យនូវសម្លៀកបំពាក់ណាមួយដែលសមស្របទៅនឹងធាតុអាកាស និងគ្រប់គ្រាន់ដើម្បីរក្សាពួកគេឲ្យមានសុខភាពល្អ។ សម្លៀកបំពាក់នេះទៀតក៏មិនត្រូវធ្វើឲ្យមានលក្ខណៈបន្ថោកបន្ទាប ឬអាប់ឱនដល់ជនជាប់ឃុំឡើយ។

---

[25] វិធាន ១២ ដល់ ១៧ នៃវិធានអង្គការសហប្រជាជាតិស្តីពីបទដ្ឋានអប្បបរមាសម្រាប់ការប្រព្រឹត្តទៅលើជនជាប់ឃុំ (វិធាននែលសាន់ម៉ាន់ដឺលា) ឆ្នាំ២០១៥

[26] នីតិវិធីលេខ៥ នៃនីតិវិធីពន្ធនាគាររបស់អគ្គនាយកដ្ឋានពន្ធនាគារ ឆ្នាំ២០០៣

២. សម្លៀកបំពាក់ទាំងអស់ត្រូវតែឲ្យស្អាតហើយឲ្យមានលក្ខណៈសមរម្យជានិច្ច។ សម្លៀកបំពាក់ក្នុងត្រូវផ្លាស់ប្តូរ និងបោកសំអាតឲ្យបានញឹកញាប់តាមការចាំបាច់ ដើម្បីរក្សាអនាម័យប្រចាំកាយ។

៣. តាមកាលៈទេសៈពិសេសខ្លះ នៅពេលណាគេយកជនជាប់ឃុំចេញទៅក្រៅពន្ធនាគារក្នុងគោលបំណងណាមួយដែលមានការអនុញ្ញាតតាមច្បាប់ជនជាប់ឃុំ ត្រូវតែបានអនុញ្ញាតឱ្យស្លៀកពាក់សម្លៀកបំពាក់ផ្ទាល់ខ្លួនរបស់គេ ឬក៏សម្លៀកបំពាក់ផ្សេងៗដែលពុំមានលក្ខណៈលេចធ្លោខុសគេខុសឯងពេក។[27]

ចំណាត់ការបែបនេះត្រូវផ្តើមធ្វើចាប់តាំងពីថ្ងៃដែលជនជាប់ឃុំចូលមកដល់ពន្ធនាគារ។ យោងទៅតាមកម្រិតរស់នៅប្រចាំតំបន់ ឬប្រចាំប្រទេសទាំងមូល ជនជាប់ឃុំគ្រប់ៗរូបត្រូវតែមានគ្រែដេកម្នាក់មួយ និងសម្ភារៈដេកដោយឡែកពីជនជាប់ឃុំឯទៀតហើយត្រូវឲ្យស្អាត និងត្រូវផ្លាស់ប្តូរឲ្យបានញឹកញាប់ដើម្បីរក្សាភាពស្អាតបាត។[28]

**១.១.២. សិទ្ធិទទួលបានអាហារ និងទឹក**

ជនជាប់ឃុំ ឬទណ្ឌិតគ្រប់រូបត្រូវតែបានទទួលម្ហូបអាហារដែលផ្តល់ឲ្យដោយរដ្ឋតាមពេលម៉ោងធម្មតា។ ម្ហូបអាហារនោះត្រូវមានគុណភាព និងជីវជាតិអាហារគ្រប់គ្រាន់ដើម្បីសុខភាព និងកម្លាំងពលំ រស់ជាតិទទួលយកបាន និងត្រូវបានចម្អិនបានល្អ។ ទឹកសម្រាប់ផឹកត្រូវឲ្យមានគ្រប់គ្រាន់សម្រាប់នៅពេលណាជនជាប់ឃុំម្នាក់ៗត្រូវការ[29]។

អ្នកទោសទាំងអស់ត្រូវបានផ្តល់អាហារដែលមានជីវជាតិសមល្មមអាចថែរក្សានូវសុខភាពនិងរូបរាងកាយ។ ជនជាទណ្ឌិតត្រូវបានផ្តល់ឱ្យនូវការយកចិត្តទុកដាក់គិតគូអំពីអាហារតមស្របតាមតម្រូវការខាងសុខភាពដែលបញ្ជាក់ពីមន្ត្រីពេទ្យពន្ធនាគារ ឬស្របតាមតម្រូវការខាងសាសនារបស់ពួកគេ។ លើសពីនេះទៀត ជនជាប់ឃុំអាចទទួលបាន ឬទិញអាហារដោយថវិកាផ្ទាល់ខ្លួនពីប្រភពខាងក្រៅបានតែអាហារទាំងនេះត្រូវបានត្រួតពិនិត្យពីមន្ត្រីពន្ធនាគារ[30]។ ប្រធានពន្ធនាគារត្រូវកំណត់ពេលវេលាដែលត្រូវផ្តល់ម្ហូបអាហារ ប៉ុន្តែជាទូទៅគួរផ្តល់ម្ហូបអាហារពេលព្រឹកនៅម៉ោង ១០:៣០ នាទី និងពេលល្ងាចនៅម៉ោង ៤:៣០ នាទី ជារៀងរាល់ថ្ងៃ។

អ្នកទោសទាំងឡាយដែលចូលរួមក្នុងការងារពលកម្ម ត្រូវបានផ្តល់ឱ្យនូវអាហារបន្ថែមដែលកំណត់ដោយប្រធានពន្ធនាគារចំពោះអ្នកទោសដែលមានកូននៅក្នុងពន្ធនាគារត្រូវផ្តល់ម្ហូបអាហារតាមលក្ខណៈសមរម្យសម្រាប់ថែទាំសុខភាព និងរូបរាងកាយរបស់កូន។ ម្យ៉ាងទៀត ចំពោះអ្នកទោសទាំងអស់នឹងទទួលបានរបបអាហារបន្ថែម

[27] នីតិវិធីលេខ៥.២ នៃនីតិវិធីពន្ធនាគាររបស់អគ្គនាយកដ្ឋានពន្ធនាគារ ឆ្នាំ២០០៣

[28] វិធាន ១៩ ដល់ ២១ នៃវិធានអង្គការសហប្រជាជាតិស្តីពីបទដ្ឋានអប្បបរមាសម្រាប់ការប្រព្រឹត្តទៅលើជនជាប់ឃុំ (វិធាននែលសាន់ម៉ាន់ដឺលា) ឆ្នាំ ២០១៥

[29] វិធាន ២២ នៃវិធានអង្គការសហប្រជាជាតិស្តីពីបទដ្ឋានអប្បបរមាសម្រាប់ការប្រព្រឹត្តទៅលើជនជាប់ឃុំ ( វិធាននែលសាន់ម៉ាន់ដឺលា) ឆ្នាំ ២០១៥

[30] មាត្រា ៣៤ នៃច្បាប់ស្តីពីពន្ធនាគារឆ្នាំ២០១១

លើរបបប្រចាំថ្ងៃធម្មតា មួយជាពី នៅក្នុងថ្ងៃបុណ្យដូចជា ថ្ងៃបុណ្យចូលឆ្នាំខ្មែរ ថ្ងៃបុណ្យ ៧ មករា ថ្ងៃបុណ្យភ្ជុំបិណ្ឌ និងថ្ងៃបុណ្យចូលឆ្នាំសកល[31]។

### ១.១.៣ សិទ្ធិទទួលបានផ្នែកសេវាសុខាភិបាល

ជនជាប់ឃុំដែលមាជម្ងឺត្រូវបានទទួលសេវាថែទាំសុខភាពប្រចាំថ្ងៃដោយមន្ត្រីពន្ធនាគារ[32]។ ការផ្តល់សេវាថែទាំសុខភាពដល់ជនជាប់ឃុំ គឺជាការទទួលខុសត្រូវរបស់រដ្ឋ។ ជនជាប់ឃុំត្រូវទទួលបានការថែទាំសុខភាពតាមស្តង់ដារដូចគ្នានឹងសេវាសុខភាពខាងក្រៅពន្ធនាគារដូច្នេះដែរ និងត្រូវមានលទ្ធភាពទទួលបានសេវាថែទាំសុខភាពដោយឥតគិតថ្លៃ និងមិនរើសអើងដោយសារស្ថានភាពផ្លូវច្បាប់របស់ពួកគេ។ សេវាថែទាំសុខភាពត្រូវបានចាត់ចែងដោយសហការជិតស្និតជាមួយប្រព័ន្ធសុខាភិបាលសាធារណៈទូទៅ និងធានាឱ្យមាននិរន្តរភាពនៃការព្យាបាល និងថែទាំរួមទាំងមេរោគអេដស៍ របេង និងជំងឺឆ្លងផ្សេងៗទៀតក៏ដូចជាចំពោះរោគញៀនផងដែរ។

ប្រធានពន្ធនាគារត្រូវធានាឱ្យមានទីកន្លែងសមស្រប ដើម្បីឱ្យមន្ត្រីពេទ្យពន្ធនាគារផ្តល់សេវាសុខភាពទៅឱ្យអ្នកទោស និងមន្ត្រីពន្ធនាគារ ទីកន្លែងត្រូវមានសុវត្ថិភាព និងត្រូវផ្តល់សន្តិសុខឱ្យបានសមស្របសម្រាប់ដាក់ឱសថ និងឯកសារប្រវត្តិជម្ងឺ។ ពន្ធនាគារទាំងអស់ ត្រូវធានាការទទួលការទទួលភ្លាមៗនូវការថែទាំវេជ្ជសាស្ត្រក្នុងករណីបន្ទាន់។ ជនជាប់ឃុំដែលត្រូវការព្យាបាលពិសេស ឬការវះកាត់ត្រូវបញ្ជូនទៅស្ថាប័នជំនាញ ឬទៅមន្ទីរពេទ្យទូទៅនៅខាងក្រៅ។ ពន្ធនាគារមានមន្ទីរពេទ្យខ្លួនឯង ត្រូវមានបុគ្គលិក និងបំពាក់បរិក្ខារគ្រប់គ្រាន់ ដើម្បីព្យាបាល និងថែទាំជនជាប់ឃុំដែលត្រូវទទួលសេវាសុខាភិបាល។ មានតែអ្នកជំនាញការផ្នែកថែទាំងសុខភាពប៉ុណ្ណោះដែលអាចធ្វើការសម្រេចចិត្តទាក់ទងនឹងការព្យាបាលដោយមិនត្រូវបានបំពានដោយ ឬមិនអើពើពីមន្ត្រីពន្ធនាគារដែលមិនមែនជាមន្ត្រីពេទ្យឡើយ។

គ្រូពេទ្យ ឬមន្ត្រីជំនាញផ្នែកថែទាំសុខភាពទោះជាត្រូវ ឬមិនតម្រូវឱ្យរាយការណ៍ជូនគ្រូពេទ្យក៏ត្រូវតែមើលពិភាក្សានិងពិនិត្យជនជាប់ឃុំម្នាក់ៗឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន បន្ទាប់ពីទទួលជនជាប់ឃុំចូលក្នុងពន្ធនាគារ និងពិនិត្យនាពេលក្រោយមកទៀតតាមតម្រូវការចាំបាច់។ ត្រូវយកចិត្តទុកដាក់ជាពិសេស ចំពោះ៖

(ក) ការកំណត់តម្រូវការការថែទាំសុខភាព និងការចាត់វិធានការចាំបាច់ទាំងអស់សម្រាប់ការព្យាបាល។

(ខ) ការពិនិត្យមើលលក្ខណៈដែលស្តែងចេញពីការធ្វើបាបផ្សេងៗមកលើជនជាប់ឃុំមុនពេលបញ្ជូនមកពន្ធនាគារ។

(គ) ការកំណត់រោគសញ្ញាជំងឺផ្លូវចិត្ត ឬភាពតានតឹងផ្សេងដែលបណ្តាលមកពីការជាប់ពន្ធនាគាររួមមានហានិភ័យនៃការធ្វើអត្តឃាត ឬការបង្កអន្តរាយដល់ខ្លួនឯង និងរោគសញ្ញាផ្សេងៗដែលបណ្តាលមកពី

[31] នីតិវិធីលេខ៦.២ នៃនីតិវិធីពន្ធនាគាររបស់អគ្គនាយកដ្ឋានពន្ធនាគារ ឆ្នាំ២០០៣

[32] មាត្រា៣៨ នៃច្បាប់ស្តីពីពន្ធនាគារឆ្នាំ២០១១

ការសេពគ្រឿងញៀន ការប្រើឱសថ ឬគ្រឿងស្រវឹង និងបន្ទាប់មកត្រូវចាត់រាល់វិធានការ ឬការព្យាបាលជាក់ស្តែងទៅតាមស្ថានភាពជនជាប់ឃុំម្នាក់ៗ។

(ឃ) ក្នុងករណីជនជាប់ឃុំសង្ស័យមានជំងឺឆ្លងត្រូវរៀបចំដាក់ជនជាប់ឃុំដោយឡែក និងផ្តល់ការព្យាបាលត្រឹមត្រូវក្នុងអំឡុងពេលដែលមានជំងឺឆ្លង។

(ង) ការកំណត់ពីកាយសម្បទាជនជាប់ឃុំសម្រាប់ធ្វើការងារលំហាត់ប្រាណ និងចូលរួមសកម្មភាពផ្សេងៗតាមលទ្ធភាពជាក់ស្តែង។

គ្រូពេទ្យត្រូវរាយការណ៍ជូនប្រធានពន្ធនាគារនៅពេលណាខ្លួនបានដឹងថា សុខភាពផ្លូវកាយ ឬផ្លូវចិត្តរបស់ជនជាប់ឃុំបានទទួលរង ឬនឹងត្រូវទទួលរងរបួសធ្ងន់ធ្ងរបណ្តាលមកពីការនៅក្នុងពន្ធនាគារ ឬលក្ខខណ្ឌណាមួយនៃការរស់នៅក្នុងពន្ធនាគារ។ ក្នុងអំឡុងពេលពិនិត្យជនជាប់ឃុំពេលបញ្ជូនមកដល់ពន្ធនាគារ ឬក្នុងពេលផ្តល់ការថែទាំព្យាបាលនៅពេលបន្ទាប់មកទៀត ប្រសិនបើមន្ត្រីជំនាញវេជ្ជសាស្ត្រស្រាប់តែដឹងពីសញ្ញានៃការធ្វើទារុណកម្ម ឬអំពើឃោរឃៅ អំពើអមនុស្សធម៌ ឬអំពើបន្ថោកបន្ទាប ឬទណ្ឌកម្មផ្សេងទៀតពួកគេត្រូវចងក្រងជាឯកសារ និងរាយការណ៍នេះទៅអាជ្ញាធរសុខាភិបាល រដ្ឋបាល ឬតុលាការ[33]។

**១.១.៤. សិទ្ធិទទួលបានរបបជីវភាព**

ជនជាប់ឃុំគ្រប់រូបត្រូវទទួលបានរបបជីវភាពដែលត្រូវកំណត់ដោយអនុក្រឹត្យ[34]។ ក្នុងនោះដែរ របបជីវភាពដែលជនជាប់ឃុំមានសិទ្ធិទទួលបាន គ្រូពេទ្យ ឬស្ថាប័នសុខភិបាលសាធារណៈមានសមត្ថកិច្ចត្រូវពិនិត្យ និងប្រឹក្សាយោបល់ដល់ប្រធានពន្ធនាគារឱ្យបានទៀងទាត់ អំពី៖

(ក) បរិមាណ គុណភាព ការរៀបចំ និងសេវាអាហារ។

(ខ) អនាម័យ និងភាពស្អាតរបស់ស្ថាប័ន និងរបស់ជនជាប់ឃុំ។

(គ) អនាម័យបរិស្ថាន សីតុណ្ហភាព ពន្លឺ និងខ្យល់ចេញចូលក្នុងពន្ធនាគារ។

(ឃ) ភាពសមស្រប និងភាពស្អាតនៃសម្លៀកបំពាក់ និងកន្លែងដេករបស់ជនជាប់ឃុំ។

(ង) ការគោរពតាមវិធាននានាទាក់ទងនឹងការអប់រំកាយ និងកីឡាក្នុងករណីមិនមានអ្នកបច្ចេកទេសទទួលខុសត្រូវចំពោះសកម្មភាពទាំងនេះ[35]។

[33] វិធាន២៤ និង២៧ និងវិធាន៣០ ដល់ ៣៤ នៃវិធានអង្គការសហប្រជាជាតិស្តីពីបទដ្ឋានអប្បបរមាសម្រាប់ការប្រព្រឹត្តទៅលើជនជាប់ឃុំ (វិធាននែលសាន់ម៉ាន់ដឺលា) ឆ្នាំ២០១៥

[34] មាត្រា៣៣ នៃច្បាប់ស្តីពីពន្ធនាគារឆ្នាំ២០១១

[35] វិធាន៣៥ នៃវិធានអង្គការសហប្រជាជាតិស្តីពីបទដ្ឋានអប្បបរមាសម្រាប់ការប្រព្រឹត្តទៅលើជនជាប់ឃុំ (វិធាននែលសាន់ម៉ាន់ដឺលា) ឆ្នាំ២០១៥

### ១.១.៥. សិទ្ធិរក្សាទុក និងប្រើប្រាស់ទ្រព្យសម្បត្តិផ្ទាល់ខ្លួន

ជនជាប់ឃុំ អាចត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ថវិកាផ្ទាល់ខ្លួន ដើម្បីទិញសម្ភារៈប្រើប្រាស់ ឬទទួលសម្ភារៈប្រើប្រាស់ពីគ្រួសារ ញាតិមិត្ត ឬពីប្រភពផ្សេងទៀត ប្រសិនបើមានការយល់ព្រម និងការត្រួតពិនិត្យពីប្រធានពន្ធនាគារ។ ក្នុងនោះដែរ ជនជាប់ឃុំមិនត្រូវបានអនុញ្ញាតឱ្យទិញ ឬផ្តល់ ឬឱ្យខ្ចី ឬលក់សម្ភារៈទៅឱ្យជនជាប់ឃុំផ្សេងទៀតបានឡើយ[36]។

នៅដែលជនជាប់ឃុំចូលមកដល់ពន្ធនាគារភ្លាម ប្រាក់កាស គ្រឿងអលង្ការ សម្លៀកបំពាក់ និងសម្ភារៈផ្សេងៗទៀតដែលត្រូវហាមឃាត់ដោយបទបញ្ជាផ្ទៃក្នុងពន្ធនាគារ ត្រូវដកហូតហើយរក្សាទុកនៅកន្លែងដែលមានសុវត្ថិភាព និងមានការកត់ត្រាត្រឹមត្រូវ ក្នុងសៀវភៅបញ្ជី និងរក្សាទុកបញ្ជីពន្ធនាគារ ឬត្រូវប្រគល់ជូនក្រុមគ្រួសារ ញាតិមិត្តរក្សាទុកប្រសិនបើមានការយល់ព្រមពីជនជាប់ឃុំ ដោយត្រូវមានហត្ថលេខា ឬស្នាមម្រាមដៃរបស់ជនជាប់ឃុំរូបនោះ[37]។ ដល់ថ្ងៃដែលជនជាប់ឃុំចេញពីពន្ធនាគារ ទ្រព្យសម្បត្តិ និងប្រាក់កាសត្រូវតែប្រគល់ឲ្យទៅម្ចាស់គេវិញទាំងអស់ លើកលែងតែប្រាក់កាសទាំងនោះកន្លងមកត្រូវបានគេអនុញ្ញាតឲ្យចាយវាយអស់ ឬទ្រព្យសម្បត្តិទាំងនោះត្រូវបានផ្ញើទៅក្រៅពន្ធនាគារ ឬក៏សម្លៀកបំពាក់ខ្លះដែលគេយល់ឃើញថាជាចាំបាច់ត្រូវតែកម្ទេចចោលដោយសារហេតុផលអនាម័យ ជនជាប់ឃុំត្រូវចុះហត្ថលេខាលើលិខិតប្រគល់ទ្រព្យសម្បត្តិ និងប្រាក់កាសទាំងនោះ។ ប្រសិនបើជនជាប់ឃុំណាម្នាក់មានថ្នាំសង្កូវជាប់មកជាមួយគ្រូពេទ្យត្រូវសម្រេចថាតើថ្នាំណាខ្លះដែលអាចអនុញ្ញាតឲ្យប្រើបាន[38] ។

## ១.២. សិទ្ធិខាងវប្បធម៌

ពន្ធនាគារត្រូវមានកន្លែងសម្រាប់គោរពជំនឿសាសនា មានបណ្ណាល័យ និងអគារអប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈ[39]។

អ្នកតំណាងសាសនាដែលត្រូវបានតែងតាំង ឬយល់ព្រម ត្រូវបានអនុញ្ញាតឱ្យធ្វើការបានទៀងទាត់ និងជួយប្រៀនប្រដៅជនជាប់ឃុំតាមមាគ៌ាសាសនារបស់ជនជាប់ឃុំទៅតាមពេលវេលាដ៏សមគួរ។ មិនត្រូវហាមឃាត់ជនជាប់ឃុំមិនឲ្យជួបអ្នកតំណាងសាសនារបស់ពួកគេឡើយ។ ផ្ទុយទៅវិញ ប្រសិនបើជនជាប់ឃុំណាម្នាក់ពុំមានឆន្ទៈចង់ជួបអ្នកតំណាងសាសនាទេនោះគេត្រូវគោរពតាមឆន្ទៈរបស់ជនជាប់ឃុំជានិច្ច[40]។

---

[36] មាត្រា៣៥ នៃច្បាប់ស្តីពីពន្ធនាគារឆ្នាំ២០១១

[37] មាត្រា៣៦ នៃច្បាប់ស្តីពីពន្ធនាគារឆ្នាំ២០១១

[38] វិធាន៦៧ នៃវិធានអង្គការសហប្រជាជាតិស្តីពីបទដ្ឋានអប្បបរមាសម្រាប់ការប្រព្រឹត្តទៅលើជនជាប់ឃុំ ( វិធាននែលសាន់ម៉ាន់ដឺលា) ឆ្នាំ២០១៥

[39] មាត្រា១៣ នៃច្បាប់ស្តីពីពន្ធនាគារឆ្នាំ២០១១

[40] វិធាន៦៥ នៃវិធានអង្គការសហប្រជាជាតិស្តីពីបទដ្ឋានអប្បបរមាសម្រាប់ការប្រព្រឹត្តទៅលើជនជាប់ឃុំ ( វិធាននែលសាន់ម៉ាន់ដឺលា) ឆ្នាំ២០១៥

### ១.២.១. សិទ្ធិខាងជំនឿសាសនា

អ្នកទោសមានសិទ្ធិប្រតិបត្តិសាសនាតាមជំនឿរបស់ខ្លួន និងមិនត្រូវបានបង្ខិតបង្ខំ ឱ្យប្រតិបត្តិសាសនាណាមួយឡើយ[41]។ អ្នកទោសអាចប្រកាន់យកសាសនាតាមផ្លូវជម្រើសរបស់ខ្លួន ហើយពួកគេត្រូវបានផ្តល់ឱ្យនូវសម្ភារៈសមស្របសម្រាប់ធ្វើសក្ការៈផ្នែកសាសនារបស់ខ្លួន ប្រសិនបើប្រធានពន្ធនាគារយល់ឃើញថាវាមិនប៉ះពាល់ដល់សន្តិសុខ និងសណ្តាប់ធ្នាប់ល្អក្នុងពន្ធនាគារ[42] ។

បើអាចអនុវត្តទៅបានជនជាប់ឃុំគ្រប់រូបត្រូវតែបានអនុញ្ញាត ដើម្បីបំពេញនូវសេចក្តីត្រូវការនៃជីវិតខាងផ្លូវសាសនារបស់គេតាមរយៈការចូលរួមក្នុងពិធីផ្សេងៗដែលអនុញ្ញាតឲ្យមាននៅក្នុងពន្ធនាគារ និងអនុញ្ញាតឲ្យរក្សាទុកនូវឯកសារ ឬសៀវភៅនានាដែលស្តីពីការប្រៀនប្រដៅ និងការគោរពបូជាតាមមាគ៌ានិកាយសាសនារបស់គេ[43]។

ប្រសិនបើនៅក្នុងពន្ធនាគារណាមួយមានជនជាប់ឃុំដែលគោរពសាសនាដូចគ្នាច្រើនគ្រប់គ្រាន់ត្រូវតែងតាំង ឬយល់ព្រមឲ្យមានតំណាងសាសនាដែលមានគុណសម្បត្តិគ្រប់គ្រាន់ម្នាក់សម្រាប់សេចក្តីត្រូវការរបស់ជនជាប់ឃុំទាំងនោះ។ អ្នកទោសត្រូវបានអនុញ្ញាតិឱ្យមានជាគម្ពី សៀវភៅគម្ពី និងគ្រឿងសក្ការៈសាសនាផ្សេងៗដែលចាំបាច់សម្រាប់ការប្រតិបត្តិខាងសាសនារបស់ពួកគេហើយដែលវាមិនប៉ះពាល់ដល់សន្តិសុខ និងសណ្តាប់ធ្នាប់ល្អក្នុងពន្ធនាគារ[44] ។

### ១.២.២. សិទ្ធិខាងចូលរួមកម្មវិធីសិក្សាអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

ទណ្ឌិតត្រូវបានផ្តល់មធ្យោបាយដើម្បីចូលរួមកម្មវិធីបណ្តុះបណ្តាលចំណេះដឹងទូទៅ និងកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈក្នុងពន្ធនាគារ។ កម្មវិធីសិក្សាអប់រំ និងកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈនៅក្នុងពន្ធនាគារត្រូវធ្វើសមាហរណកម្មជាមួយប្រព័ន្ធអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈរបស់ជាតិត្រូវសហការជាមួយក្រសួងមហាផ្ទៃរៀបចំកម្មវិធី និងដំណើរការអនុវត្តកម្មវិធីសិក្សាអប់រំ និងកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈដល់ទណ្ឌិតនៅក្នុងពន្ធនាគារ។

ទណ្ឌិតត្រូវបានផ្តល់ឱ្យនូវកម្មវិធីការងារ ការអប់រំ និងការបណ្តុះបណ្តាលវិជ្ជាជិវៈដែលមានប្រយោជន៍នៅក្នុងពន្ធនាគារដើម្បីផ្តល់ និងកែលម្អ នូវជំនាញ និងលើកស្ទួយជីវភាពរស់នៅ និងការស្តារនីតិសម្បទា ក្នុងការរៀបចំសម្រាប់ឱ្យពួកគេវិលត្រឡប់ទៅរស់នៅក្នុងសហគបន៍វិញ[45]។ ដោយឡែកចំពោះទណ្ឌិតជាអនីតិជនត្រូវបានយកចិត្តទុកដាក់ដោយឡែកទាក់ទង និងតម្រូវការសិក្សាអប់រំ ការបណ្តុះបណ្តាលលេខនព្វន្ត និងអក្សរសាស្ត្រ ការស្តារនីតិសម្បទា និងសមាហរណកម្មដោយធ្វើការសហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងអប់រំ យុវជន និងកីឡា ។ សម្រាប់កម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈកម្មវិធីឧស្សាហកម្ម សិប្បកម្ម កសិកម្មពន្ធនាគារត្រូវបានរៀបចំនៅ

[41] មាត្រា២៩ នៃច្បាប់ស្តីពីពន្ធនាគារឆ្នាំ២០១១

[42] មាត្រា១៣ នៃច្បាប់ស្តីពីពន្ធនាគារឆ្នាំ២០១១

[43] វិធាន៦៦ នៃវិធានអង្គការសហប្រជាជាតិស្តីពីបទដ្ឋានអប្បបរមាសម្រាប់ការប្រព្រឹត្តទៅលើជនជាប់ឃុំ ( វិធាននែលសាន់ម៉ាន់ដឺលា) ឆ្នាំ២០១៥

[44] នីតិវិធី៧ នៃនីតិវិធីពន្ធនាគាររបស់អគ្គនាយកដ្ឋានពន្ធនាគារ ឆ្នាំ២០០៣

[45] នីតិវិធីទី១១.១ នៃនីតិវិធីពន្ធនាគាររបស់អគ្គនាយកដ្ឋានពន្ធនាគារ ឆ្នាំ២០០៣

តាមពន្ធនាគារនីមួយៗដើម្បីផ្តល់ឱកាសឱ្យទណ្ឌិតគ្រប់រូបមានសមត្ថភាពក្នុងការប្រកបរបរចិញ្ចឹមជីវិតរបស់ខ្លួន បន្ទាប់ពីបានអនុវត្តទោសរបស់ខ្លួនរួចរាល់ហើយនោះ។ អ្នកទោសដែលមានជំនាញ ឬសមត្ថភាពដោយឡែកត្រូវបានចាត់ឱ្យទៅធ្វើការផ្នែកទាំងឡាយណាដែលពួកគេអាចប្រើប្រាស់ជំនាញរបស់ពួកគេ[46]។ នៅរាល់មណ្ឌលអប់រំកែប្រែ និងពន្ធនាគារនៅក្នុងព្រះរាជាណាចក្រកម្ពុជាទាំងអស់ត្រូវបង្កើតឱ្យមានមុខជំនាញសម្រាប់ផ្តល់ជាចំណេះដឹងដល់ទណ្ឌិតគ្រប់រូបនៅពេលដែលពួកគេកំពុងតែអនុវត្តទោសហើយពួកគេត្រូវទទួលបានការផ្តល់ការអប់រំកែប្រែជាប្រចាំពីសំណាក់អនុរក្សពន្ធនាគារតាមចំណេះ និងជំនាញរបស់ទណ្ឌិតម្នាក់ចង់ធ្វើការស្វែងយល់។

ចំពោះអនីតិជនដែលមានអាយុលើសពីអាយុដែលត្រូវចូលរៀន ហើយមានបំណងចង់បន្តការសិក្សារបស់ពួកគេគួរត្រូវបានអនុញ្ញាត និងលើកទឹកចិត្តឱ្យបន្តទទួលបាននៅអប់រំ ដើម្បីផ្តល់ឱ្យពួកគេនូវឱកាសទទួលបានការអប់រំមួយយ៉ាងសមស្រប។

## ១.៣. សិទ្ធិខាងព័ត៌មាន

ជនជាប់ឃុំមានសិទ្ធិទទួលបានដំណឹង ឬព័ត៌មានសំខាន់ៗយ៉ាងទៀងទាត់ពេល គឺត្រូវអនុញ្ញាតឲ្យជនជាប់ឃុំអានកាសែត អានសៀវភៅ ឬអត្ថបទផ្សព្វផ្សាយ ឬស្តាប់ព័ត៌មានបច្ចេកវិជ្ជាទូរគមនាគមន៍ឥតខ្សែ ឬស្តាប់បាចកថា ឬមធ្យោបាយនានាដែលអនុញ្ញាត ឬគ្រប់គ្រងដោយរដ្ឋបាលពន្ធនាគារ។ ម្យ៉ាងវិញទៀត ជនជាប់ឃុំមានសិទ្ធិក្នុងការទទួលបានការជូនដំណឹងទាក់ទងនឹងជម្ងឺ ឬមរណភាពរបស់ជនជាប់ឃុំ ឬរបស់គ្រួសារជនជាប់ឃុំឱ្យបានដឹងទៅវិញទៅមកផងដែរ[47]។

### ១.៣.១. សិទ្ធិទទួលបានព័ត៌មាន និងស្វ័យសិក្សា

ជនជាប់ឃុំត្រូវបានអនុញ្ញាតឱ្យទទួលដំណឹ ឬព័ត៌មានសំខាន់ៗតាមរយៈកម្មវិធីផ្សព្វផ្សាយរបស់វិទ្យុ ទូរទស្សន៍ ទស្សនាវដ្តី សារព័ត៌មាន និងទំនាក់ទំនងទូរស័ព្ទជាមួយក្រុមគ្រួសារ ដែលរៀបចំដោយពន្ធនាគារ ។ ជនជាប់ឃុំមានសិទ្ធិក្នុងការចូលសិក្សាស្រាវជ្រាវក្នុងបណ្ណាល័យពន្ធនាគារ ឬអាចអនុញ្ញាតឱ្យខ្ចីសៀវភៅទៅសិក្សានៅបន្ទប់ឃុំឃាំងដើម្បីចំណេះដឹង។ គ្រប់ពន្ធនាគារទាំងអស់ត្រូវមានបណ្ណាល័យសម្រាប់សេចក្តីត្រូវការរបស់ជនជាប់ឃុំគ្រប់ប្រភេទសៀវភៅច្រើនបរិបូណ៌ទាំងសៀវភៅផ្នែកកំសាន្ត និងសៀវភៅសិក្សា ហើយត្រូវណែនាំជនជាប់ឃុំទាំងអស់ឲ្យអានសៀវភៅឲ្យបានច្រើនបំផុត[48]។

ជាក់ស្តែង យោងតាមរបាយការណ៍របស់អគ្គនាយកដ្ឋានពន្ធនាគាក្នុងឆ្នាំ២០២២ ចំនួនជនជាប់ឃុំដែលក្នុងនោះមានទណ្ឌិតជផងដែរ បានចូលបណ្ណាល័យពន្ធនាគាមានចំនួន ជនជាប់ឃុំចូលរួមចំនួន ១៧៩,១២១ (ស្ត្រី ១២,៤៣៤ នាក់)

[46] នីតិវិធីលេខ១១.៣ នៃនីតិវិធីពន្ធនាគាររបស់អគ្គនាយកដ្ឋានពន្ធនាគារ ឆ្នាំ២០០៣

[47] មាត្រា៣៧ នៃច្បាប់ស្តីពីពន្ធនាគារឆ្នាំ២០១១

[48] វិធាន៦៤ នៃវិធានអង្គការសហប្រជាជាតិស្តីពីបទដ្ឋានអប្បបរមាសម្រាប់ការប្រព្រឹត្តទៅលើជនជាប់ឃុំ ( វិធាននែលសាន់ម៉ាន់ដឺលា) ឆ្នាំ ២០១៥

ក្នុងនោះផ្ញើអំណាននៅបណ្ណាល័យ ៦៤,៦៧១ លើក (ស្ត្រី ៣,៦៣២ លើក) និងបានខ្ចីសៀវភៅអាន ១១៤,៤៥០ លើក (ស្ត្រី ៨,៨០៣ លើក) ។ ចំណែកឯ ជនជាប់ឃុំចូលរួមកម្មវិធីអប់រំកែប្រែ មានចំនួន ២៤០,៣៦៩ នាក់ (ស្ត្រី ១,៣០៥ នាក់) មានជាអាទិ៍ បទបញ្ជាផ្ទៃក្នុងពន្ធនាគារ រៀនអក្ខរកម្ម ថ្នាក់សមមូល ភាសាបរទេស សីលធម៌ ព្រះធម៌ ចូលរួមកម្មវិធីហាត់ប្រាណ កម្មវិធីបំណិនជីវិត និងចលនាប្រឡងប្រណាំងកែប្រែខ្លួនទណ្ឌិត[49]។

### ១.៣.២. សិទ្ធិទទួលបានការប្រាស្រ័យទាក់ទង

ជនជាប់ឃុំទាំងអស់មានសិទ្ធិទទួលការប្រាស្រ័យទាក់ទងសួរសុខទុក្ខពីក្រុមគ្រួសារ ឬមិត្តភក្តិ យ៉ាងតិចបំផុតបាន ១ ម៉ោង ក្នុង ១ សប្តាហ៍ទៅតាមពេលវេលាកំណត់ក្នុងបទបញ្ជាផ្ទៃក្នុង ដែលរៀបចំដោយប្រធានពន្ធនាគារ[50]។ ក្នុងនោះដែរ ជនជាប់ឃុំមានសិទ្ធិក្នុងការជួបសួរសុខទុក្ខពីមេធាវី ឬអ្នកតំណាងរបស់ខ្លួនក្នុងនាមអ្នកតំណាងស្របតាមផ្លូវច្បាប់នៅក្នុងម៉ោងធ្វើការ។ យ៉ាងណាមិញ ជនជាប់ឃុំ មានសិទ្ធិទទួល និងធ្វើលិខិតឆ្លងឆ្លើយ ដោយលិខិតឆ្លងឆ្លើយរបស់ជនជាប់ឃុំត្រូវបើកនៅចំពោះមុខមន្ត្រីពន្ធនាគារដែលត្រូវបានប្រគល់សិទ្ធិ លើកលែងតែលិខិតរបស់មេធាវី[51]។

ម្យ៉ាងទៀត ចំពោះវិធានអង្គការសហប្រជាជាតិស្តីពីបទដ្ឋានប្បរមាសម្រាប់ការប្រព្រឹត្តទៅលើជនជាប់ឃុំ (វិធាននែលសាន់ម៉ាន់ដឺឡា) បានចែងថាជនជាប់ឃុំអាចប្រាស្រ័យទាក់ទងបានដោយគោរពតាមក្រោមការឃ្លាំមើល ក្នុងករណីចាំបាច់ជនជាប់ឃុំត្រូវបានអនុញ្ញាតឱ្យមានទំនាក់ទំនងជាមួយគ្រួសារ និងមិត្តភក្តិរបស់ពួកគេនៅចន្លោះពេលទៀងទាត់ ៖

(ក) តាមរយៈលិខិតឆ្លើយឆ្លង និងតាមរយៈមធ្យោបាយទូរគមនាគមន៍ អេឡិចត្រូនិច ឌីជីថល និងតាមរយៈមធ្យោបាយផ្សេងទៀត ប្រសិនបើមាន និង

(ខ) តាមរយៈការសួរសុខទុក្ខ។

ក្នុងករណីមានការអនុញ្ញាតឱ្យមានការសួរសុខទុក្ខក្នុងឋានៈជាប្តីប្រពន្ធ សិទ្ធិនេះត្រូវបានអនុវត្តដោយគ្មានការរើសអើងហើយស្ត្រីជាជនជាប់ឃុំត្រូវប្រើសិទ្ធិនេះស្មើនឹងបុរសដែរ។ ត្រូវមាននីតិវិធីគ្រប់គ្រាន់ និងមានទីកន្លែងដើម្បីធានាការទទួលបានសុវត្ថិភាព និងសេចក្តីថ្លៃថ្នូរដោយយុត្តិធម៌ និងស្មើភាពគ្នា។ ការអនុញ្ញាតឱ្យអ្នកសួរសុខទុក្ខចូលពន្ធនាគារគឺអាស្រ័យលើការយល់ព្រមរបស់អ្នកសួរសុខទុក្ខ ចំពោះការឆែកឆេរ[52] ។

---

[49] សារព័ត៌មានហ្វ្រេសញូវ (Fresh News) ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៣ ស្តីពីរបាយការណ៍ឆ្នាំ២០២២ មានជនជាប់ឃុំចូលបណ្ណាល័យពន្ធនាគារ និងមណ្ឌលអប់រំកែប្រែ

[50] នីតិវិធីលេខ៨.១ នៃនីតិវិធីពន្ធនាគា របស់អគ្គនាយកដ្ឋានពន្ធនាគារឆ្នាំ២០០៣

[51] មាត្រា៣២ នៃច្បាប់ស្តីពីពន្ធនាគារឆ្នាំ២០១១

[52] វិធាន៥៨ និង ៦០ នៃវិធានអង្គការសហប្រជាជាតិស្តីពីបទដ្ឋានអប្បបរមាសម្រាប់ការប្រព្រឹត្តទៅលើជនជាប់ឃុំ (វិធាននែលសាន់ម៉ាន់ដឺលា) ឆ្នាំ ២០១៥

## ១.៤. សិទ្ធិខាងសេរីភាព

### ១.៤.១. សិទ្ធិរបស់ទណ្ឌិតប្តឹងតវ៉ាចំពោះអំពើរំលោភរបស់ទណ្ឌិតដូចគ្នា និងមន្ត្រីពន្ធនាគារ

ទណ្ឌិតមានសិទ្ធិប្តឹងតវ៉ាទៅប្រធានពន្ធនាគារ ឬទៅអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ ឬព្រះរាជអាជ្ញា ឬ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ពីអំពើរំលោភរបស់ទណ្ឌិតដូចគ្នា ឬអពើរំលោភរបស់មន្ត្រីពន្ធនាគារ។

ពាក្យបណ្តឹងតវ៉ារបស់ទណ្ឌិតត្រូវធ្វើឡើងតាមរយៈមន្ត្រីពន្ធនាគារ ឬអ្នកសួរសុខទុក្ខផ្លូវការ ឬអ្នកសួរសុខទុក្ខសាច់ញាតិ ឬមេធាវីរបស់ជនជាប់ឃុំ ឬតំណាងអយ្យការ។ រាល់បណ្តឹងតវ៉ាត្រូវបានដោះស្រាយ និងឆ្លើយតបក្នុងរយៈពេលសមស្របសម្រាប់ទណ្ឌិត។ គ្មានទណ្ឌិតណាម្នាក់ត្រូវបានដាក់ទណ្ឌកម្ម ឬត្រូវបានរើសអើងដោយសារការដាក់ពាក្យបណ្តឹង ឬការដាក់ពាក្យស្នើសុំនោះឡើយ[53]។

យ៉ាងណាមិញ នៅក្នុងវិធានទី៥៧ របស់អង្គការសហប្រជាជាតិស្តីពីបទដ្ឋានអប្បបរមាសម្រាប់ការប្រព្រឹត្តទៅលើជនជាប់ឃុំ (វិធាននែលសាន់ម៉ាន់ដឺលា) ឆ្នាំ២០១៥ បានចែងថារាល់សំណើ និងបណ្តឹងតវ៉ាត្រូវបានដោះស្រាយ និងឆ្លើយតបជាបន្ទាន់ដោយមិនពន្យាពេល។ ប្រសិនបើសំណើ ឬបណ្តឹងតវ៉ាត្រូវបានបដិសេធ ឬក្នុងករណីពន្យាពេលយូរហួសហេតុពេកនោះអ្នកដាក់ពាក្យបណ្តឹងមានសិទ្ធិនាំយកបណ្តឹងនេះទៅចំពោះមុខអាជ្ញាធរតុលាការ ឬអាជ្ញាធរផ្សេងទៀត។ ក្នុងនោះដែរ ការចោទប្រកាន់ថាមានការធ្វើទារុណកម្ម ឬអំពើឃោរឃៅ អំពើអមនុស្សធម៌ ឬអំពោះបន្ថោកបន្ទាប ឬទណ្ឌកម្ម ផ្សេងទៀតមកលើជនជាប់ឃុំ ឬទណ្ឌិត ត្រូវបានដោះស្រាយជាបន្ទាន់ និងធ្វើការស៊ើបអង្កេតភ្លាមៗដោយមិនលំអៀង ដោយអាជ្ញាធរជាតិឯករាជ្យមួយ[54]។

### ១.៤.២. សិទ្ធិរួចផុតពីការធ្វើទារុណកម្ម

ច្បាប់រ៉ាប់រងមិនឱ្យមានការរំលោភបំពានលើរូបរាងកាយបុគ្គលណាមួយឡើយ។ ការបង្ខិតបង្ខំ ការធ្វើបាបលើរូបរាងកាយ ឬប្រព្រឹត្តិកម្មណាមួយដែលបន្ថែមទម្ងន់ទណ្ឌកម្មអនុវត្តចំពោះជនជាប់ឃុំឃាំង ឬជាប់ពន្ធនាគារត្រូវហាមឃាត់មិនឱ្យធ្វើឡើយ[55]។

អនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាបដែលចូលជាធរមាននៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៨៧ បានចែងថា រដ្ឋភាគីត្រូវធានាថា ការអប់រំ និងព័ត៌មានស្តីពីការហាមប្រាមទារុណកម្ម ត្រូវបានដាក់បញ្ចូលឱ្យបានពេញលេញក្នុងការបណ្តុះបណ្តាលមន្ត្រីប្រតិបត្តិច្បាប់ បុគ្គលិកស៊ីវិល ឬយោធា បុគ្គលិកពេទ្យ មន្ត្រីសាធារណៈ និងជនផ្សេងទៀតដែលដាក់ឱ្យអន្តរាគមន៍ ការឃុំខ្លួន

[53] មាត្រា២៨ នៃច្បាប់ស្តីពីពន្ធនាគារ ឆ្នាំ២០១១

[54] វិធាន៥៧ នៃវិធានអង្គការសហប្រជាជាតិស្តីពីបទដ្ឋានអប្បបរមាសម្រាប់ការប្រព្រឹត្តទៅលើជនជាប់ឃុំ ( វិធាននែលសាន់ម៉ាន់ដឺលា) ឆ្នាំ២០១៥

[55] មាត្រា៣៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

ការសួរចម្លើយ ឬការប្រព្រឹត្តទៅលើបុគ្គលណាដែលស្ថិតក្រោមការចាប់ខ្លួន ឃុំខ្លួន ឬការដាក់ពន្ធនាគារតាមបែបណាមួយក៏ដោយ។[56]

យ៉ាងណាមិញ រដ្ឋបាលពន្ធនាគារត្រូវធានាសមាមាត្ររវាងទណ្ឌកម្មវិន័យ និងការបំពានវិន័យដែលត្រូវបានប្រព្រឹត្តឡើង និងត្រូវរក្សាកំណត់ត្រាទណ្ឌកម្មវិន័យទាំងអស់ឱ្យបានត្រឹមត្រូវ។ មុននឹងដាក់ទណ្ឌកម្មវិន័យ រដ្ឋបាលពន្ធនាគារ ត្រូវពិចារណាថាតើជំងឺផ្លូវចិត្ត ឬអសមត្ថភាពផ្នែក ការអភិវឌ្ឍ អាចជាកត្តារួមចំណែកដល់ការប្រព្រឹត្តរបស់ពួកគេដែរឬទេ ឬរួមចំណែកដល់អំពើដែលបណ្តាលឱ្យមានការចោទប្រកាន់ផ្នែកវិន័យដែរឬទេ ហើយប្រសិនបើមានតើវាកើតឡើងដោយរបៀបណា។ រដ្ឋបាលពន្ធនាគារ មិនត្រូវដាក់ទណ្ឌកម្មចំពោះការប្រព្រឹត្តណាមួយរបស់ជនជាប់ឃុំដែលបណ្តាលមកពីជំងឺផ្លូវចិត្ត ឬ អសមត្ថភាពផ្នែកបញ្ញារបស់គេឡើយ[57]។

បើយោងតាមវិធានអង្គការសហប្រជាជាតិស្តីពីបទដ្ឋានអប្បបរមានសម្រាប់ការប្រព្រឹត្តទៅលើជនជាប់ឃុំ (វិធាននែលសាន់ម៉ាន់ដឺឡា) ទោះក្នុងស្ថានភាពណាក៏ដោយការរឹតបន្តឹង ឬការដាក់ទណ្ឌកម្មវិន័យមិនត្រូវធ្វើឡើងក្នុងន័យធ្វើ ទារុណកម្ម ឬអំពើឃោរឃៅ អំពើអមនុស្សធម៌ ឬអំពើបន្ថោកបន្ទាប ឬទណ្ឌកម្មផ្សេងទៀតឡើយ។ ជាពិសេស ទង្វើខាងក្រោមត្រូវបានហាមឃាត់[58] ៖

(ក) ការដាក់ឃុំខ្លួនដាច់តែឯងដោយមិនមានពេលកំណត់

(ខ) ការចេះតែបន្តដាក់ឃុំខ្លួនដាច់តែឯង

(គ) ការដាក់ជនជាប់ឃុំក្នុងបន្ទប់ងងឹត ឬបន្ទប់ភ្លឺចាំងរហូត

(ឃ) ការដាក់ទណ្ឌកម្មលើរាងកាយ ឬការកាត់បន្ថយរបបអាហារ ឬទឹក

(ង) ការដាក់ទណ្ឌកម្មជាសមូហភាព។

### ១.៤.៣. សិទ្ធិរួចផុតពីការដាក់ខ្នោះ

ខ្នោះដៃ គឺគ្រាន់តែជាឧបករណ៍ដែលគេប្រើសម្រាប់បង្ខាំអ្នកទោស ហើយមិនត្រូវប្រើប្រាស់ក្នុងទម្រង់ណាមួយនៃការដាក់ទណ្ឌកម្មឡើយ។

នៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានរ៉ាប់រងមិនឱ្យមានការរំលោភបំពានលើរូបរាងកាយណាមួយជាងនេះទៅទៀត រដ្ឋធម្មនុញ្ញបានការពារសិទ្ធិរបស់ជនជាប់ឃុំឃាំង ឬជាប់ពន្ធនាគារពីការបង្ខិតបង្ខំ ការធ្វើបាបលើរូបរាងកាយ ឬប្រព្រឹត្តិកម្មណាមួយដែលបន្ថែមទម្ងន់ទណ្ឌកម្មអនុវត្តចំពោះពួកគេត្រូវបានហាមឃាត់មិនឱ្យធ្វើឡើយ[59]។

[56] អនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមលើខ្លួន ឬទណ្ឌឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ឆ្នាំ១៩៨៧

[57] វិធាន៣៩ នៃវិធានអង្គការសហប្រជាជាតិស្តីពីបទដ្ឋានអប្បបរមាសម្រាប់ការប្រព្រឹត្តទៅលើជនជាប់ឃុំ ( វិធាននែលសាន់ម៉ាន់ដឺលា) ឆ្នាំ ២០១៥

[58] វិធាន៤៣ នៃវិធានអង្គការសហប្រជាជាតិស្តីពីបទដ្ឋានអប្បបរមាសម្រាប់ការប្រព្រឹត្តទៅលើជនជាប់ឃុំ ( វិធាននែលសាន់ម៉ាន់ដឺលា) ឆ្នាំ ២០១៥

[59] មាត្រា៣៧ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

យ៉ាងណាមិញ នៅក្នុងច្បាប់ស្តីពីពន្ធនាគារ ឆ្នាំ២០១១ ការពារសិទ្ធិរបស់ជនជាប់ឃុំ និងទណ្ឌិតបន្ថែមទៀតគឺរាល់ការធ្វើទារុណកម្ម ទង្វើអមនុស្សធម៌ ឬការប្រើប្រាស់ឧបករណ៍ផ្សេងៗក្នុងការដាក់ទណ្ឌកម្មដល់ជនជាប់ឃុំត្រូវហាមឃាត់ លើកលែងតែខ្នោះដៃដែលត្រូវបានអនុញ្ញាតក្នុងករណីដូចជា ៖

- ពេលមានចលចលក្នុងពន្ធនាគារ
- ពេលផ្ទេរ ឬបញ្ជូន ឬនាំខ្លួនចេញពីពន្ធនាគារ
- ពេលមានហេតុផលខាងពេទ្យ
- ដើម្បីការពារជនជាប់ឃុំកុំឱ្យបង្ករបួសស្នាមដោយខ្លួនឯង ឬបង្ករបួសស្នាមដល់អ្នកដទៃ ឬបង្កការខូចខាតទ្រព្យសម្បត្តិអ្នកដទៃ។
- ដើម្បីការពារជនជាប់ឃុំកុំឱ្យបង្ករបួសស្នាមដោយខ្លួនឯង ឬបង្ករបួសស្នាមដល់អ្នកដទៃ ឬបង្កការខូចខាតទ្រព្យសម្បត្តិអ្នកដទៃ[60]។

ទណ្ឌិតមិនត្រូវបានប្រើប្រាស់ខ្នោះដៃសម្រាប់រយៈពេលយូរជាងសេចក្តីត្រូវការជាចាំបាច់ ហើយត្រូវធ្វើការត្រួតពិនិត្យយ៉ាងទៀតទាត់ ដើម្បីធានាថាខ្នោះដៃទាំងនោះមានសុវត្ថិភាពហើយអ្នកទោសមិនទទួលការឈឺចាប់ដោយការប្រើប្រាស់ខ្នោះដៃនោះទេ[61]។

[60] មាត្រា៥០ នៃច្បាប់ស្តីពីពន្ធនាគារឆ្នាំ២០១១

[61] ចំណុច២៥ នៃប្រកាស៤ នៃប្រកាសស្តីពីការគ្រប់គ្រងពន្ធនាគារ ឆ្នាំ១៩៩៣

# ជំពូកទី២

# សិទ្ធិរបស់ទណ្ឌិត

# ក្នុងលក្ខខណ្ឌពិសេស

# ក្នុងពន្ធនាគារ

# ជំពូកទី២.

# សិទ្ធិរបស់ទណ្ឌិតក្នុងលក្ខខណ្ឌពិសេសក្នុងពន្ធនាគារ

## ផ្នែកទី១. សិទ្ធិរបស់ទណ្ឌិតជាអនីតិជន

ការឃុំខ្លួនអនីតិជនធ្វើឡើងក្នុងគោលបំណងស្តារនីតិសម្បទាជាអាទិ៍ ការបណ្តុះបណ្តាលការព្យាបាល ការថែទាំ ការការពារ ការអប់រំ និងផ្តល់ជំនាញវិជ្ជាជីវៈក្នុងទស្សនៈជួយអនីតិជនឱ្យក្លាយទៅជាពលរដ្ឋសុចរិត និងមានប្រយោជន៍ដល់សង្គមជាតិ[62]។

ជនជាប់ឃុំដែលជាអនីតិជនទាំងអស់ត្រូវបានទទួលសិទ្ធិជាមូលដ្ឋានដូចជា៖

- សិទ្ធិទទួលបានការសិក្សាអប់រំ
- សិទ្ធិរួចផុតពីការធ្វើទារុណកម្ម អំពើឃោរឃៅ អមនុស្សធម៌ បន្ទាបបន្ថោក ការដាក់ទណ្ឌកម្មលើរូបកាយ និងផ្លូវចិត្ត ឬប្រើប្រាស់ទម្រង់ផ្សេងៗសម្រាប់ធ្វើទណ្ឌកម្ម រួមមានការដាក់ឱ្យនៅឯការ ការដាក់កំហិត ឬបដិសេធមិនឱ្យមានការប្រាស្រ័យទាក់ទងជាមួយក្រុមគ្រួសារ ការកាត់បន្ថយចំណីអាហា និងពលកម្មដោយបង្ខំ
- សិទ្ធិទទួលបានវិធានការដាក់វិន័យដែលស្របតាមសេចក្តីថ្លៃថ្នូររបស់អនីតិជន
- សិទ្ធិទទួលបានការណែនាំអំពីបទបញ្ជាផ្ទៃក្នុង អំពីសិទ្ធិ និងកាតព្វកិច្ច
- សិទ្ធិផ្តល់ដំណឹងអំពីការឃុំខ្លួន ការផ្ទេរ ការដោះលែងទៅអ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុង និងមេធាវី
- សិទ្ធិទទួលបានការការពារ ការពិនិត្យសុខភាព និងការព្យាបាលជម្ងឺ ឬរបួស និងផ្តល់ដំណឹងទៅអ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុង និងមេធាវី
- សិទ្ធិទទួលបានការអនុញ្ញាតឱ្យមានការសួរសុខទុក្ខជាលក្ខណៈឯកជនពីសំណាក់សមាជិកគ្រួសារ ឬមិត្តភក្តិ
- សិទ្ធិទទួលបានយន្តការបណ្តឹងប្រកបដោយប្រសិទ្ធភាព និងរក្សាការសម្ងាត់ទាក់ទងនឹងលក្ខខណ្ឌ និងការប្រព្រឹត្តទៅមកលើខ្លួនក្នុងពេលឃុំខ្លួន
- សិទ្ធិផ្សេងទៀតដែលទទួលស្គាល់ដោយបទដ្ឋានគតិយុត្តជាធរមាន[63]។

### ១.១. សិទ្ធិទទួលបានការបែងចែងគ្រប់គ្រងអនីតិជនក្នុងមណ្ឌលយុវនីតិសម្បទា

ការគ្រប់គ្រងអនីតិជនក្នុងមណ្ឌលយុវនីតិសម្បទាត្រូវបែងចែងជា៣ (បី) ផ្នែកដាច់ដោយឡែកពីគ្នា ៖

- ផ្នែកសម្រាប់ឃុំខ្លួនអនីតិជនបណ្តោះអាសន្ន
- ផ្នែកសម្រាប់ឃុំខ្លួន ទណ្ឌិតជាអនីតិជនដើម្បីទទួលបានកម្មវិធីស្តារនីតិសម្បទា

---

[62] មាត្រា៧៩ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជនឆ្នាំ២០១៦

[63] មាត្រា៨០ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

- ផ្នែកសម្រាប់ត្រៀមដោះលែងអនីតិជន ដើម្បីទទួលកម្មវិធីសមាហរណកម្ម។

ចំពោះបែបបទនៃការគ្រប់គ្រងអនីតិជនក្នុងមណ្ឌលយុវនីតិសម្បទាដែលត្រូវជាប់ឃុំត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច រដ្ឋមន្ត្រីមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌[64]។

### ១.២. សិទ្ធិទទួលបានសេវាសម្រាប់អនីតិជនក្នុងមណ្ឌលយុវនីតិសម្បទា

អាជ្ញាធរមមានសមត្ថកិច្ចទទួលបន្ទុកមណ្ឌលយុវនីតិសម្បទាទាំងអស់ ត្រូវផ្តល់សេវាដល់អនីតិជនដែលកំពុងជាប់ឃុំដូចខាងក្រោមនេះ៖

- ការពារ ថែទា និងផ្តល់រាល់តម្រូវការចាំបាច់ផ្ទាល់ខ្លួនដោយស្របតាមបុគ្គលិកលក្ខណៈ ជំនឿ សាសនា ភេទ និងអាយុរបស់អនីតិជន
- ស្នាក់នៅជាក្រុម ឬជាឯកត្តបុគ្គល
- សិក្សាអប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈ សិល្បៈ កីឡា កម្សាន្ត និងសម្រាកពីការងារ
- សុខភាពផ្លូវកាយ និងផ្លូវចិត្តសមស្រប
- ពិនិត្យវាយតម្លៃសុខភាពដោយមន្ទីរពេទ្យត្រូវកត់បញ្ចូលទៅក្នុងសំណុំរឿងអនីតិជនជាប់ឃុំនៃព័ត៌ មានអំពីរបួសស្នាម ជម្ងឺផ្លូវចិត្ត ពិការភាពផ្នែកកាយសម្បទា ឬព័ត៌មានពាក់ព័ន្ធផ្សេងទៀត
- សេវាផ្សេងទៀតដែលលើកស្ទួយសុខភាព និងមោទនភាពចំពោះខ្លួនឯង លើកទឹកចិត្តឱ្យមានគំនិតទទួលខុសត្រូវលើកទឹកចិត្តឱ្យមានអាកប្បកិរិយា និងជំនាញដែលនឹងជួយអនីតិជនក្នុងការអភិវឌ្ឍសក្តានុពលរបស់ខ្លួនក្លាយជាពលរដ្ឋល្អម្នាក់នៅក្នុងសង្គម និងជួយឱ្យពួកគេវិលត្រឡប់មកក្នុងសង្គមវិញបន្ទាប់ពីបានដោះលែង[65]។

### ១.៣. សិទ្ធិទទួលបានការដោះលែងដោយមានលក្ខខណ្ឌ

ការដោះលែងដោយមានលក្ខខណ្ឌចំពោះអនីតិជន អាចត្រូវផ្តល់ឱ្យដល់ទណ្ឌិតជាអនីតិជនដែលទទួលរងទោស ក្នុងមណ្ឌលយុវនីតិសម្បទាដូចជា ៖

- ចំនួនមួយភាគបី នៃទោស ប្រសិនបើទោសតិចជាង ឬស្មើ ១(មួយ) ឆ្នាំ
- ចំនួនពាក់កណ្តាលនៃទោស ក្នុងករណីផ្សេងទៀត[66]។

- បុគ្គលមានសិទ្ធិស្នើសុំដោះលែងដោយមានលក្ខខណ្ឌមានដូចជា ៖
  - ទណ្ឌិតដែលជាអនីតិជន ឬមេធាវីរបស់ជននោះ
  - អ្នកតំណាងដែលច្បាប់បានកំណត់
  - ប្រធានមណ្ឌលយុវនីតិសម្បទា

---

[64] មាត្រា៧៧ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[65] មាត្រា៨១ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[66] មាត្រា៧២ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

- ភ្នាក់ងារសង្គមកិច្ចដែលពាក់ព័ន្ធនឹងរឿងក្តីអនីតិជននោះ
- បេសកម្មការទូត ឬកុងស៊ុលបរទេស ក្នុងករណីអនីតិជនជាជនបរទេស[67]។

## ១.៤. សិទ្ធិទទួលបានការផ្តល់ និងការមាននីតិសម្បទាឡើងវិញ

### ១.៤.១. លក្ខខណ្ឌលើរយៈពេលទាក់ទងនឹងពាក្យសុំឱ្យមានការផ្តល់នីតិសម្បទាឡើងវិញតាមផ្លូវតុលាការ

ពាក្យសុំឱ្យមាននីតិសម្បទាឡើងវិញអាចនឹងដាក់ជូនសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ពិនិត្យបាន លុះត្រាតែផុតរយៈពេលដូចតទៅ[68]៖

- ២ (ពីរ) ឆ្នាំ ចំពោះបទឧក្រិដ្ឋ
- ៦ (ប្រាំមួយ) ខែ ចំពោះបទមជ្ឈិម
- ១ (មួយ) ខែ ចំពោះបទលហុ។

រយៈពេលនេះចាប់ផ្តើមគិតពីការអនុវត្តទោសរួច ឬនៅពេលទោសត្រូវផុតអាជ្ញាយុកាល។

ពាក្យសុំអាចត្រូវបានធ្វើឡើងដោយ ៖

- ទណ្ឌិតជានីតិជនដែលបានប្រព្រឹត្តបទល្មើសនៅពេលខ្លួនជាអនីតិជន
- អ្នកតំណាងដែលច្បាប់បានកំណត់ ក្នុងករណីទណ្ឌិតជាអនីតិជន។

### ១.៤.២. ការមាននីតិសម្បទាឡើងវិញដោយពេញលក្ខណៈច្បាប់

នីតិសម្បទាត្រូវមានឡើងវិញដោយពេញលក្ខណៈច្បាប់នៅពេលផុតរយៈពេល[69] ៖

- ៣ (បី) ឆ្នាំ ចំពោះបទឧក្រិដ្ឋ
- ១ (មួយ) ឆ្នាំ ចំពោះបទមជ្ឈិម
- ៣ (បី) ខែ ចំពោះបទលហុ។

រយៈពេលនេះចាប់ផ្តើមគិតពិការអនុវត្តទោសរួច ឬនៅពេលទោសត្រូវផុតអាជ្ញាយុកាល។

## ផ្នែកទី២. សិទ្ធិរបស់ទណ្ឌិតជាស្ត្រីមានគភ៌ ម្តាយបំបៅកូនដោយទឹកដោះ និងម្តាយរស់នៅជាមួយកូនក្នុងពន្ធនាគារ

ទណ្ឌិតជាស្ត្រីត្រូវបានបំបែកពីទណ្ឌិតជាបុរស ដាក់ស្តែងនៅក្នុងមណ្ឌលអប់រំកែប្រែទី១សម្រាប់ឃុំខ្លួនជនជាប់ឃុំ ឬទណ្ឌិជាបុរស ចំណែកឯមណ្ឌលអប់រំកែប្រែទី២ សម្រាប់ឃុំឃាំងជនជាប់ឃុំជាស្ត្រី។ តួយ៉ាងក្នុងយុទ្ធសាស្ត្រគ្រប់គ្រងពន្ធនាគារតាមគោលការណ៍សិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិសិទ្ធិមនុស្សការិយាល័យឧត្តមស្នងការកម្ពុជាឆ្នាំ

---

[67] មាត្រា៧៣ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[68] មាត្រា៧៤ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[69] មាត្រា៧៥ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

២០១២ ការដាក់ដោយឡែកពីគ្នារវាងអ្នកទោសជាស្ត្រីភេទ និងអ្នកទោសជាបុរសនេះដើម្បីធានានូវសុវត្ថិភាពរាងកាយរបស់ស្ត្រី គួរទទួលបានការធានាក្នុងអំឡុងពេលជាប់ឃុំឃាំង និងផ្តល់សុវត្ថិភាពដល់ជនជាប់ឃុំស្ត្រី ជនជាប់ឃុំស្ត្រីគួរឃុំខ្លួនដាច់ដោយឡែកពីជនជាប់ឃុំបុរសហើយមិនគួរឱ្យមានមន្ត្រីពន្ធនាគារបុរសធ្វើជាអ្នកត្រួតពិនិត្យលើស្ត្រីជនជាប់ឃុំឡើយ[70]។ ស្ត្រីជាទណ្ឌិតក្នុងពន្ធនាគារត្រូវបានផ្តល់ឱ្យនូវឱកាសជាច្រើនដើម្បីអនុវត្ត និងអភិវឌ្ឍន៍នូវការទទួលខុសត្រូវជាមាតា ព្រមទាំងភារកិច្ច និងជំនាញដើម្បីបង្កើននូវសក្តានុពលសម្រាប់ការអភិវឌ្ឍន៍ដ៏ត្រឹមត្រូវរបស់កូន និងកាត់បន្ថយនូវការប្រព្រឹត្តបទល្មើសជាថ្មីឡើងវិញរបស់ម្តាយ។

បើសិនជាអ្នកទោសជាស្ត្រីមានផ្ទៃពោះ ច្បាប់បានផ្តល់សិទ្ធិដល់ពួកគេលើសពីជនជាទណ្ឌិតដទៃទៀត ដូចជាទណ្ឌិតដែលផ្ទៃពោះ៖

- ត្រូវបានផ្តល់កិច្ចឧបត្ថម្ភពិសេស ដើម្បីថែទាំសុខភាពរបស់ស្ត្រីនោះ មុន និងក្រោយពេលសម្រាលកូន។
- ត្រូវបានអនុញ្ញាតឱ្យអ្នកទោសសម្រាលកូននៅមន្ទីរពេទ្យខាងក្រៅពន្ធនាគារ។
- បើសិនជាអ្នកទោសសម្រាលកូននៅពន្ធនាគារ អ្នកថែទាំសុខភាពម្នាក់ ត្រូវចូលរួមពិនិត្យសុខភាពអ្នកទោសជាម្តាយ និងកូននោះយ៉ាងឆាប់ដែលអាចធ្វើទៅបាន បន្ទាប់ពីសម្រាលកូនរួច។
- បើសិនជាទារកកើតនៅក្នុងពន្ធនាគារ ទីកន្លែងកំណើត មិនត្រូវចុះនៅក្នុងសំបុត្រកំណើតថា ទារកនោះកើតនៅក្នុងពន្ធនាគារឡើយ[71]។

ប្រធានពន្ធនាគាត្រូវធ្វើយ៉ាងណាឱ្យមានវិធានការសមស្របដើម្បីធានាដល់សុខភាព និងសុខុមាលភាពរបស់អ្នកទោស និងទារកក្នុងអំឡុងពេលមានផ្ទៃពោះ និងក្រោយពេលសម្រាលទារក។ វិធានការទាំងនេះរួមមាន[72] ៖

- ផ្តល់អាហារឱ្យមានតុល្យភាព (រួមមាន នៅពេលបំបៅកូនដោយទឹកដោះម្តាយ)។
- ជួយផ្តល់សេវាពិនិត្យសុខភាព
- ឱ្យម្តាយសម្រាលទារកក្នុងមន្ទីរពេទ្យខាងក្រៅ
- ផ្តល់សម្លៀកបំពាក់បានសមស្របសម្រាប់ទារក។

ស្ត្រីជាទណ្ឌិតមានគភ៌ត្រូវពិនិត្យតាមដានសុខភាពរបស់អ្នកទោសដែលមានផ្ទៃពោះជាប្រចាំខែ ក្នុងករណីមានការព្រួយបារម្ភដល់សុខភាពធ្ងន់ធ្ងរណាមួយ ត្រូវរាយការណ៍ជូនប្រធានពន្ធនាគារដើម្បីធានាផ្តល់កាព្យាបាលសុខភាពនៅពេលចាំបាច់។ ក្នុងនោះដែរ ទណ្ឌិតជាស្ត្រីមានគ៌ភ និងមានកូននៅជាមួយត្រូវទទួលបានការឃ្លាំមើលដោយអ្នកជំនាញ

[70] យុទ្ធសាស្ត្រលេខ១៨ ស្តីពីជនជាប់ឃុំស្ត្រី របស់អង្គការសហប្រជាជាតិសិទ្ធិមនុស្សការិយាល័យឧត្តមស្នងការកម្ពុជា ឆ្នាំ២០១២

[71] ចំណុចទី១៨ នៃប្រការ៤ នៃប្រកាសស្តីពីការគ្រប់គ្រងពន្ធនាគារ ឆ្នាំ១៩៩៣

[72] នីតិវិធីលេខ៣៤ នៃនីតិវិធីពន្ធនាគារ របស់អគ្គនាយកដ្ឋានពន្ធនាគារ ឆ្នាំ២០០៣

សុខាភិបាលមួយរូប ទទួលបានអាហារគ្រប់គ្រាន់ និងទៀងទាត់ពេលវេលា បរិស្ថានសុខភាព និងការធ្វើលំហាត់ប្រាណទៀងទាត់ និងត្រូវផ្ដល់ជូនដោយឥតគិតថ្លៃដល់ស្ត្រី មានគភ៌ ទារក កុមារ និងម្ដាយដែលបំបៅដោះកូនដោយទឹកដោះ។

ក្នុងនោះដែរ កូនអាចរស់នៅជាមួយម្ដាយក្នុងពន្ធនាគារបាន រហូតដល់ពួកគេមានអាយុ ៦ ឆ្នាំ។ ក្នុងអំឡុងពេលនោះម្ដាយត្រូវទទួលខុសត្រូវក្នុងការថែទាំសុវត្ថិភាពកូន។ នាយកដ្ឋានពន្ធនាគារត្រូវផ្ដល់ម្ហូបអាហារ ថ្នាំសង្កូវដល់កុមារទាំងនោះនៅពេលដែលពួកគេរស់នៅក្នុងពន្ធនាគារ។ បើសិនជាគេអនុញ្ញាតឱ្យកុមារទាំងនោះ រស់នៅក្នុងពន្ធនាគារត្រូវអនុញ្ញាតឱ្យពួកគេចេញចូលតាមបទបញ្ជាផ្ទៃក្នុងរបស់ពន្ធនាគារ។ ក្នុងករណីដែរក្មេងទាំងនោះ មិនអាចរស់នៅក្នុងពន្ធនាគារបាន ឧទាហរណ៍៖ នៅពេលម្ដាយមានជម្ងឺធ្ងន់ មិនអាចថែទាំពួកគេបាន ដើម្បីផលប្រយោជន៍ល្អប្រសើរដល់ក្មេងទាំងនោះ ប្រធានពន្ធនាគារត្រូវទំនាក់ទំនងជាមួយក្រសួងមានសមត្ថកិច្ចទទួលខុសត្រូវ ឬគ្រួសារ សាច់ញាតិ ដើម្បីឱ្យគេទទួលយកក្មេងទាំងនោះ ទៅបីបាច់ថែរក្សានៅក្រៅពន្ធនាគារ រួចហើយត្រូវរាយការណ៍ជូននាយកដ្ឋានពន្ធនាគារ។

យ៉ាងណាមិញ ការសម្រេចអនុញ្ញាតឱ្យកុមារស្នាក់នៅជាមួយម្ដាយរបស់ខ្លួនក្នុងពន្ធនាគារ ត្រូវផ្អែកលើឧត្ដមប្រយោជន៍របស់កុមារ។ កុមារក្នុងពន្ធនាគារជាមួយម្ដាយ មិនត្រូវបានគេប្រព្រឹត្តមកលើខ្លួនដូចជនជាប់ឃុំឡើយ។ ចំពោះកុមារដែលកំពុងនៅជាមួយម្ដាយក្នុងពន្ធនាគារត្រូវផ្ដល់នូវសេវាគាំពារ សុខភាពប្រចាំថ្ងៃហើយការរីកលូតលាស់របស់ពួកគេត្រូវបានតាមឃ្លាំមើលដោយអ្នកឯកទេសដោយសហការជាមួយសេវាសុខភាពសហគមន៍។ បរិស្ថានដែលបានផ្ដល់សម្រាប់ចិញ្ចឹមបីបាច់អប់រំកូន ដូចនេះត្រូវមានសភាពដូចទៅនឹងកុមារដែលនៅខាងក្រៅពន្ធនាគារតាមដែលអាចធ្វើទៅបាន។

ម្យ៉ាងទៀត ទណ្ឌិតជាស្ត្រីមានគ៌ភ និងមានកូនដែលជាប់នៅក្នុងពន្ធនាគារត្រូវទទួលបានសិទ្ធិក្នុងការលើកលែងទោសសម្រាប់ពួកគាត់ ដោយរាជរដ្ឋាភិបាលបានសេចក្ដីសម្រេចបង្កើតក្រុមការងារពិនិត្យ ស្រង់ស្ថិតិ និងរៀបចំបែបបទដើម្បីធ្វើការលើកលែងទោសស្ត្រីមានគ៌ភ និងមានកូនដែលជាប់ពន្ធនាគារ ដើម្បីធ្វើការពិនិត្យ ស្រាវជ្រាវ ផ្ទៀងផ្ទាត់ស្ថិតិ និងរៀបចំបែបបទក្នុងការលើកលែងទោសសជនជាប់ឃុំជាស្ត្រីមានគ៌ភ និងមានកូនដែលជាប់ពន្ធនាគារ[73]។

## ផ្នែកទី៣. សិទ្ធិរបស់ទណ្ឌិតជាជនបរទេស

ជនជាប់ឃុំ ឬទណ្ឌិត មិនត្រូវមានការប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា មតិនយោបាយ ឬមតិដទៃទៀត ដើមកំណើតជាតិ ឬសង្គម ទ្រព្យសម្បត្តិ ស្ថានភាពកំណើត ឬស្ថានភាពដទៃទៀតឡើយ[74]។ ក្នុងករណីទណ្ឌិតជាជនបរទេស ទណ្ឌិតមានសិទ្ធិអនុញ្ញាតឱ្យធ្វើការជូនដំណឹងទៅស្ថានទូត ឬស្ថានកុងស៊ុល ឬស្ថានតំណាងរបស់ខ្លួនប្រសិនបើជនជាប់ឃុំមិនមានលទ្ធភាពជូនដំណឹងបាន ប្រធានពន្ធនាគារត្រូវធ្វើកិច្ចការនេះ[75]។

---

[73] មាត្រា២ នៃសេចក្ដីសម្រេចស្ដីពីការបង្កើតក្រុមការងារពិនិត្យ ស្រង់ស្ថិតិ និងរៀបចំបែបបទដើម្បីធ្វើការលើកលែងទោសស្ត្រីមានគ៌ភ និងមានកូនដែលជាប់ពន្ធនាគារ

[74] វិធាន៦ នៃវិធានអង្គការសហប្រជាជាតិស្ដីពីបទដ្ឋានអប្បបរមាសម្រាប់ការប្រព្រឹត្តទៅលើជនជាប់ឃុំ ( វិធាននៃលសាន់ម៉ាន់ដឺលា) ឆ្នាំ២០១៥

[75] មាត្រា២០ នៃច្បាប់ស្ដីពីពន្ធនាគារឆ្នាំ២០១១

មន្ត្រីស្ថានទូត ឬស្ថានកុងស៊ុល ឬស្ថានតំណាងដែលមានបំណងចូលជួបសួរសុខទុក្ខជនជាប់ឃុំជាពលរដ្ឋរបស់ខ្លួន ឬពលរដ្ឋដែលខ្លួនធ្វើជាតំណាងត្រូវជូនដំណឹងជាមុនទៅអគ្គនាយកដ្ឋានពន្ធនាគារ។ គ្រួសារ ឬញាតិមិត្តជាជនបរទេសដែលមានបំណងចូលជួបសួរសុខទុក្ខជនជាប់ឃុំត្រូវស្នើសុំអគ្គនាយកដ្ឋានពន្ធនាគារ តាមរយៈស្ថានទូត ឬស្ថានកុងស៊ុល ឬស្ថានតំណាងរបស់ខ្លួន។ ជាពិសេសយោងតាមវិធាន៣៨ នៃវិធានបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងជនជាប់ឃុំបានចែងថា៖ ជនជាប់ឃុំជនបរទេសត្រូវបានអនុញ្ញាតតាមមធ្យោបាយណាមួយដែលសមស្របដើម្បីប្រាស្រ័យទាក់ទងជាមួយស្ថានទូត ឬកុងស៊ុលប្រចាំប្រទេសរបស់ខ្លួន។ ចំពោះជនជាប់ឃុំជនបរទេសដែលគ្មានតំណាងទូត ឬកុងស៊ុលប្រចាំនៅក្នុងប្រទេសដែលខ្លួនជាប់ឃុំឃាំងទេនោះ ឬជាជនភៀសខ្លួន ឬជាជនដែលគ្មានប្រទេសពិតប្រាកដត្រូវបានអនុញ្ញាតតាមមធ្យោបាយណាមួយឱ្យសមស្របដើម្បីប្រាស្រ័យទាក់ទងជាមួយតំណាងទូតនៃប្រទេសដែលទទួលខុសត្រូវផលប្រយោជន៍របស់ខ្លួនដែលមានភារកិច្ចការពារជនជាប់ឃុំទាំងនោះបាន[76]។

ចំពោះជនជាប់ឃុំ ឬទណ្ឌិតបរទេសជាស្ត្រីភាគច្រើនជាស្ត្រីដែលមកពីគ្រួសារមានស្ថានភាពលំបាក ដូចជាស្ត្រីដែលត្រូវបានបញ្ចុះបញ្ចូលឱ្យរត់ពន្ធគ្រឿងញៀនមកពីប្រទេសផ្សេងៗជាដើម។ ស្ត្រីទាំងនោះ ជាញឹកញាប់ត្រូវបានផ្តន្ទាទោសឱ្យជាប់ពន្ធនាគាររយៈពេលយូរហើយអាចទទួលរងទុក្ខវេទនា ជាពិសេសដោយសារតែការនៅឃ្លាតឆ្ងាយពីកូនៗរបស់ខ្លួន។ ដូច្នេះជនជាប់ឃុំ ឬទណ្ឌិតជាស្ត្រីគួរត្រូវបានរៀបចំដើម្បីបំពេញតម្រូវកកការរបស់ស្ត្រីទាំងនេះ និងជួយរក្សាទំនាក់ទំនងរវាងម្តាយ និងកូនៗរបស់ពួកគេ។

ទណ្ឌិតជាជនបរទេស ប្រសិនបើមានកិច្ចព្រមព្រៀងពាក់ព័ន្ធទ្វេភាគី ឬពហុភាគីការផ្ទេរជនជាប់ឃុំបរទេសជាស្ត្រីពីប្រទេសមិនមែនដើមកំណើតទៅកាន់ប្រទេសខ្លួនវិញ គេត្រូវធ្វើការពិចារណាឱ្យបានឆាប់តាមដែលអាចធ្វើបាននៅក្នុងអំឡុងពេលពួកគាត់កំពុងជាប់ពន្ធនាគារ ដោយមានការដាក់ពាក្យ ឬផ្តល់ព័ត៌មានយល់ព្រមពីជនជាប់ឃុំបរទេសជាស្ត្រីដែលពាក់ព័ន្ធនោះទេ។ ប្រសិនបើមានកុមាររស់នៅជាមួយនឹងស្ត្រីជាជនជាប់ឃុំបរទេសនោះដែលពន្ធនាគារមិនមែនជាប្រទេសដើមកំណើតខ្លួន កុមារដែលត្រូវបាននាំចេញពីពន្ធនាគារនោះ គេត្រូវពិចារណាអំពីការរៀបចំបញ្ជូនកុមារនោះទៅប្រទេសកំណើតរបស់ខ្លួនដោយគិតគូរអំពីឧត្តមប្រយោជន៍របស់កុមារ និងដោយមានការពិគ្រោះយោបល់ស្ត្រីជាម្តាយ[77]។

[76] វិធាន៣៨ នៃវិធានអង្គការសហប្រជាជាតិស្តីពីបទដ្ឋានអប្បបរមាសម្រាប់ការប្រព្រឹត្តទៅលើជនជាប់ឃុំ ( វិធាននែលសាន់ម៉ាន់ដឺលា) ឆ្នាំ ២០១៥

[77] យុទ្ធសាស្ត្រលេខ១២ ស្តីពីជនជាប់ឃុំបរទេស របស់អង្គការសហប្រជាជាតិសិទ្ធិមនុស្សការិយាល័យឧត្តមស្នងការកម្ពុជា ឆ្នាំ២០១២

# ជំពូកទី៣
# សិទ្ធិផ្សេងៗទៀត
# របស់ជនជាប់ចោទ

# ជំពូកទី៣.
# សិទ្ធិផ្សេងៗទៀតរបស់ទណ្ឌិត

## ផ្នែកទី១. សិទ្ធិទទួលបានការដោះលែងដោយមានលក្ខខណ្ឌ

ការដោះលែងដោយមានលក្ខខណ្ឌ គឺជាសមត្ថកិច្ចរបស់ប្រធានសាលាដំបូងនៃទីកន្លែងឃុំខ្លួនទណ្ឌិត។ ប្រធានសាលាដំបូងសម្រេចអំពីការដោះលែងដោយមានលក្ខខណ្ឌ តាមដីកាសម្រេច ដោយមានសំអាងហេតុ បន្ទាប់ពីទទួលបានការយោបល់ពីគណៈកម្មការជាតិដោះលែងដោយមានលក្ខខណ្ឌស្របតាមមាត្រាក្រមនីតិវិធីព្រហ្មទណ្ឌ[78]។

### ១.១. លក្ខខណ្ឌទាក់ទងនឹងគំនិតមាយាទ

គ្រប់ទណ្ឌិតដែលត្រូវបានទទួលទោសពន្ធនាគារមួយ ឬច្រើនអាចត្រូវបានដោះលែងដោយមានលក្ខខណ្ឌ ប្រសិនបើទណ្ឌិតនេះបានបង្ហាញឱ្យឃើញថាខ្លួនមានគំនិតមារយាទល្អក្នុងរយៈពេលជាប់ឃុំ និងមានសម្បទាដែលអាចបញ្ជូនខ្លួនទៅក្នុងសង្គមវិញបាន[79]។

### ១.២. លក្ខខណ្ឌទាក់ទងនឹងថិរវេលានៃទោសដែលត្រូវបានទទួលរួចរាល់ហើយ

ការដោះលែងដោយមានលក្ខខណ្ឌ អាចត្រូវបានផ្តល់ឱ្យទណ្ឌិតដែលទទួលរងទោសជាប់ពន្ធនាគារ ៖

- ចំនួនពាក់កណ្តាលនៃទោស ប្រសិនបើទោសនោះតិចជាង ឬស្មើ ១ (មួយ) ឆ្នាំ
- ចំនួនពីរភាគបីនៃទោសក្នុងករណីផ្សេងទៀត។

ទណ្ឌិតដែលត្រូវជាប់ពន្ធនាគារអស់មួយជីវិត អាចទទួលការដោះលែងដោយមានលក្ខខណ្ឌ ប្រសិនបើទណ្ឌិតបានទទួលទោសជាប់ពន្ធនាគារយ៉ាងតិចបំផុត ២០ (ម្ភៃ) ឆ្នាំរួចមកហើយ[80]។

### ១.៣. សមត្ថកិច្ច និងសេចក្តីសម្រេចសម្រាប់ផ្តល់ការដោះលែងដោយមានលក្ខខណ្ឌ

ការដោះលែងដោយមានលក្ខខណ្ឌ ត្រូវផ្តល់ឱ្យដោយប្រធានតុលាការជាន់ដំបូងនៃទីកន្លែងឃុំខ្លួន។ ប្រធានតុលាការនៃតុលាការនោះសម្រេចក្រោយពីបានទទួលយោបល់ធ្វើជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុពីគណៈកម្មការជាតិដែលត្រូវប្រជុំនៅក្រសួងយុត្តិធម៌[81]។

ចំពោះសេចក្តីសម្រេចក្នុងការដោះលែដោយមានលក្ខខណ្ឌនេះ តុលាការសម្រេចតាមដីកាដោយមានសំអាងហេតុរបស់គណៈកម្មាការជាតិ។ សេចក្តីសម្រេចនេះ កំណត់រយៈពេលសាកល្បងដែលមិនអាចលើសពីថិរវេលានៃទោសដែលនៅសល់មិនទាន់បានទទួលរងឡើយ[82]។

[78] ប្រការ២ នៃប្រកាសលេខ០៩០កយ.ប្រក/២១ ស្តីពីបែបបទនៃការឃ្លាំមើលតាមដាន ការត្រួតពិនិត្យ និងការបញ្ជូនទៅក្នុងសង្គមវិញនៃទណ្ឌិតដែលត្រូវបានដោះលែងដោយមានលក្ខខណ្ឌ ឆ្នាំ២០២១

[79] មាត្រា៥១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[80] មាត្រា៥១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[81] មាត្រា៥១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[82] មាត្រា៥១៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ក្រសួងយុត្តិធម៌ អាចប្រគល់ឱ្យស្ថាប័នសារធារណៈ ឬឯកជននូវការយកចិត្តទុកដាក់ធានារ៉ាប់រងលើការបញ្ចូលទណ្ឌិតទៅក្នុងសង្គមនេះវិញ[83]។

## ១.៤. ការដោះលែងដោយភ្ជាប់លក្ខខណ្ឌជាកាតព្វកិច្ច

ក្នុងដីកាសម្រេចដោះលែងដោយមានលក្ខខណ្ឌ ប្រធានសាលាដំបូងត្រូវកំណត់អំពីបែបបទនៃការអនុវត្ត និងរយៈពេលនៃការសាកល្បងដែលមិនអាចលើសពីថិរវេលានៃទោសដែលនៅសល់មិនទាន់បានទទួលរងឡើយ។

ប្រធានសាលាដំបូងសម្រេចដោះលែងទណ្ឌិត ដោយមានភ្ជាប់លក្ខខណ្ឌជាកាតព្វកិច្ចមួយ ឬច្រើនដូចខាងក្រោម[84]៖

- បំពេញសកម្មភាពខាងវិជ្ជាជីវៈ។
- ទទួលការបង្ហាត់បង្រៀន ឬទទួលការបណ្ដុះបណ្ដាលវិជ្ជាជីវៈ។
- រស់នៅក្នុងទីកន្លែងណាមួយជាកំណត់។
- ទទួលឱ្យពេទ្យធ្វើការពិនិត្យ ឬការព្យាបាល។
- បញ្ជាក់អំពីការចូលរួមចំណែកក្នុងការចិញ្ចឹមបីបាច់គ្រួសារ។
- ធ្វើការជួសជុលការខូចខាតដែលបណ្ដាលមកពីបទល្មើស តាមលទ្ធភាពនៃធនធានរបស់ខ្លួន។
- បញ្ជាក់អំពីការបានបង់ប្រាក់ជូនរដ្ឋបន្ទាប់ពីការផ្ដន្ទាទោស តាមលទ្ធភាពធនធានរបស់ខ្លួន។
- មិនត្រូវធ្វើសកម្មភាពខាងវិជ្ជាជីវៈ ឬសង្គមដែលសម្រួលដល់ការប្រព្រឹត្តបទល្មើស។ ក្នុងករណីនេះ តុលាការត្រូវបញ្ជាក់អំពីសកម្មភាពដែលហាមឃាត់។
- មិនត្រូវមានវត្តមាននៅទីកន្លែងមួយចំនួនដែលត្រូវបានហាមឃាត់។ ក្នុងករណីនេះ តុលាការត្រូវបញ្ជាក់អំពីទីកន្លែងដែលត្រូវបានហាមឃាត់។
- មិនត្រូវសេពគប់ជាមួយបុគ្គលខ្លះ ពិសេស ចារី សហចារី អ្នកផ្ដើមគំនិត អ្នកសមគំនិត ឬជនរងគ្រោះនៃបទល្មើស។ ក្នុងករណីនេះ តុលាការបញ្ជាក់អំពីបុគ្គលដែលមិនត្រូវសេពគប់ជាមួយ។
- មិនត្រូវកាន់កាប់ ឬយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ។

ក្រៅពីការអនុវត្តកាតព្វកិច្ចខាងលើ ទណ្ឌិតអាចត្រូវដាក់ឱ្យស្ថិតក្រោមវិធានការត្រួតពិនិត្យរបស់អាជ្ញាធរមានសមត្ថកិច្ច ដោយត្រូវគោរពកាតព្វកិច្ចមួយ ឬច្រើន ដូចខាងក្រោម៖

- ត្រូវគោរពតាមដីកាកោះរបស់ព្រះរាជអាជ្ញា ឬការកោះហៅរបស់បុគ្គលដែលព្រះរាជអាជ្ញាបានប្រគល់អំណាចឱ្យ។

---

[83] មាត្រា៥២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[84] ប្រការ៣ នៃប្រកាសលេខ០៩០កយ.ប្រក/២១ ស្ដីពីបែបបទនៃការឃ្លាំមើលតាមដាន ការត្រួតពិនិត្យ និងការបញ្ជូនទៅក្នុងសង្គមវិញនៃទណ្ឌិតដែលត្រូវបានដោះលែងដោយមានលក្ខខណ្ឌ ឆ្នាំ២០២១

- ត្រូវមកទទួលនូវការពិនិត្យមើលរបស់បុគ្គលដែលព្រះរាជអាជ្ញាបានប្រគល់អំណាចឱ្យ។
- ត្រូវប្រគល់ដល់ព្រះរាជអាជ្ញា ឬដល់បុគ្គលដែលព្រះរាជអាជ្ញាបានប្រគល់អំណាចឱ្យនូវឯកសារសម្រាប់ធ្វើការផ្ទៀតផ្ទាត់លើការបញ្ជូនឱ្យទៅរួមរស់នៅក្នុងសង្គមវិញ។
- ត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញា អំពីការផ្លាស់ប្តូរអាសយដ្ឋានរបស់ខ្លួន។
- ត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញា អំពីការផ្លាស់ប្តូរមុខរបររបស់ខ្លួន។
- ត្រូវមានការអនុញ្ញាតពីព្រះរាជអាជ្ញា មុនពេលធ្វើដំណើរទៅបរទេស។

ក្នុងករណីទណ្ឌិតមិនអនុវត្តតាមដីកាសម្រេចដោះលែងដោយមានលក្ខខណ្ឌ ប្រធានសាលាដំបូងអាចដកហូតដីកាសម្រេចនោះ និងអាចបង្គាប់ឱ្យចាប់ខ្លួនទណ្ឌិតនោះមកអនុវត្តទោសដែលនៅសេសសល់។

### ១.៥. វិធានការឃ្លាំមើល តាមដាន និងត្រួតពិនិត្យការអនុវត្តដីកាសម្រេច

ព្រះរាជអាជ្ញានៃសាលាដំបូងដែលបានចេញដីកាសម្រេចដោះលែងដោយមានលក្ខខណ្ឌ ប្រើប្រាស់សិទ្ធិអំណាចរបស់ខ្លួនតាមច្បាប់ ដើម្បីធានាដល់ការអនុវត្តដីកាសម្រេចដោះលែងដែលមានលក្ខខណ្ឌ ព្រមទាំងអាចចាត់វិធានការចាំបាច់នានា ដើម្បីឃ្លាំមើល តាមដាន និងត្រួតពិនិត្យការអនុវត្តដីកាសម្រេចនោះ។ ព្រះរាជអាជ្ញាដែលមានសមត្ថកិច្ចដែនដីពាក់ព័ន្ធ ត្រូវផ្តល់កិច្ចសហការចាំបាច់នានា ដើម្បីធានាដល់ការអនុវត្តដីកាសម្រេចដោះលែងដោយមានលក្ខខណ្ឌ។

ព្រះរាជអាជ្ញាដែលមានសមត្ថកិច្ច ត្រូវដឹកនាំសម្របសម្រួលអាជ្ញាធរដែនដី និងមន្ត្រីនគរបាលយុត្តិធម៌ ក្នុងការអនុវត្តដីកាសម្រេចដោះលែងដោយមានលក្ខខណ្ឌឱ្យមានប្រសិទ្ធិភាព។ ក្នុងករណីចាំបាច់ ព្រះរាជអាជ្ញាដែលមានសមត្ថកិច្ច អាចចាត់តាំងបុគ្គល ឬអង្គភាពនៅមូលដ្ឋាននៃទីកន្លែងដែលទណ្ឌិតនឹងទៅរស់នៅ ឬទៅបំពេញការងារ ឬទៅបំពេញកាតព្វកិច្ច ដើម្បីឃ្លាំមើល តាមដាន និងត្រួតពិនិត្យការអនុវត្តកាតព្វកិច្ចរបស់ទណ្ឌិតនោះ[85]។

បុគ្គលដែលអាចត្រូវបានចាត់តាំង រួមមាន មន្ត្រីនគរបាលយុត្តិធម៌ នគរបាល កងរាជអាវុធហត្ថ មេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ មេភូមិ មន្ត្រីសង្គមកិច្ច និងមន្ត្រីទទួលបន្ទុកអប់រំ និងស្តារនីតិសម្បទា។ បុគ្គលទាំងអស់នេះ ត្រូវបានចាត់តាំងដោយព្រះរាជអាជ្ញា ត្រូវបំពេញកាតព្វកិច្ចដូចខាងក្រោម[86]៖

- គ្រប់គ្រង និងតាមដានការបំពេញកាតព្វកិច្ចរបស់ទណ្ឌិត
- ណែនាំទណ្ឌិតដែលត្រូវបានដោះលែង អំពីកាតព្វកិច្ចដែលត្រូវអនុវត្តដូចមានកំណត់ក្នុងដីកាសម្រេចដោះលែងដោយមានលក្ខខណ្ឌ

[85] ប្រការ៤ នៃប្រកាសលេខ០៩០កយ.ប្រក/២១ ស្តីពីបែបបទនៃការឃ្លាំមើលតាមដាន ការត្រួតពិនិត្យ និងការបញ្ជូនទៅក្នុងសង្គមវិញនៃទណ្ឌិតដែលត្រូវបានដោះលែងដោយមានលក្ខខណ្ឌ ឆ្នាំ២០២១

[86] ប្រការ៥នៃ នៃប្រកាសលេខ០៩០កយ.ប្រក/២១ ស្តីពីបែបបទនៃការឃ្លាំមើលតាមដាន ការត្រួតពិនិត្យ និងការបញ្ជូនទៅក្នុងសង្គមវិញនៃទណ្ឌិតដែលត្រូវបានដោះលែងដោយមានលក្ខខណ្ឌ ឆ្នាំ២០២១

- អប់រំទណ្ឌិតឲ្យយលចិត្តទុកដាក់ កែប្រែ និងកសាងខ្លួនដើម្បីធ្វើសមាហរណកម្មចូលទៅរួមរស់នៅក្នុងសង្គមវិញ
- រាយការណ៍ ឬធ្វើរបាយការណ៍អំពីសកម្មភាពរបស់ទណ្ឌិតដែលត្រូវបានដោះលែងដោយមានលក្ខខណ្ឌ ជូលដល់ព្រះរាជអាជ្ញា។

## ផ្នែកទី២. សិទ្ធិទទួលបានការលើកលែងទោស ឬ ការបន្ធូរបន្ថយទោស

ការលើកលែងទោស និងការបន្ធូរបន្ថយទោស ជាសិទ្ធិមួយដែលជនជាទណ្ឌិតត្រូវទទួលបាននៅអំឡុងពេលខ្លួនកំពុងត្រូវបានអនុវត្តទោសនៅក្នុងពន្ធនាគារ។ យ៉ាងណាមិញ ការលើកលែងទោស និងការបន្ធូរបន្ថយទោសនេះជាវិធានការមួយក្នុងការកាត់បន្ថយភាពចង្អៀតណែនក្នុងពន្ធនាគារដែលមានចំនួនជនជាប់ឃុំចំនួនច្រើនដោយសារការកកស្ទះសំណុំរឿងដោយការឃុំខ្លួនជាបណ្តោះអាសន្នជាដើម និងជាការផ្តល់ឱកាសឱ្យជនជាទណ្ឌិតដែលបានទទួលស្គាល់នូវកំហុសរបស់ខ្លួនហើយត្រឡប់មកបានប្រព្រឹត្តអាកប្បកិរិយាល្អ និងមានឆន្ទៈក្នុងការកែប្រែខ្លួនឯងដើម្បីចូលរួមទៅរស់ក្នុងសង្គមវិញ។ ម៉្យាងវិញទៀត វិធានការនេះក៏ជាផ្នែកមួយដែលជំរុញលើកទឹកចិត្តឱ្យទណ្ឌិតម្នាក់ខិតខំក្នុងការកែប្រែគំនិត មាយាទ សកម្មភាព និងការប្រព្រឹត្តអំពើល្អរបស់ខ្លួន ដែលស្របទៅនឹងវិធានការរបស់ពន្ធនាគារដែលបង្កើតឱ្យមានការប្រកួតប្រជែងរបស់ទណ្ឌិតផ្នែកចំណេះដឹង និងសកម្មភាពវិជ្ជាជីវៈនៅក្នុងពន្ធនាគារ ដើម្បីឱ្យទណ្ឌិតមានបំពេញនូវលក្ខណសម្បត្តិគ្រប់គ្រាន់ដែលជាមូលដ្ឋាននៃការវិនិច្ឆ័យថាទណ្ឌិតអាចទទួលបាននូវការបន្ធូរបន្ថយទោស និងលើកលែងទោសក្នុងការធ្វើសមាហរណកម្ម ទណ្ឌិតចូលទៅក្នុងសង្គមវិញធ្វើជាប្រជាពលរដ្ឋល្អមួយរូប។ បើយោងតាមច្បាប់ស្តីពន្ធនាគារនៃព្រះរាជាណាចក្រកម្ពុជាដែលប្រកាសប្រើនៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ បានចែងពីអ្នកដែលមានសមត្ថកិច្ចនៅក្នុងការពិនិត្យ និងវាយតម្លៃអំពីកម្រិតនៃការកែប្រែរបស់ទណ្ឌិត ក្នុងអំឡុងពេលនៃការឃុំខ្លួននៅក្នុងពន្ធនាគាររបស់ទណ្ឌិត ដោយមានគណៈកម្មាធិការក្នុងការធ្វើបញ្ជីពិនិត្យលក្ខណសម្បត្តិក្នុងការស្នើសុំបន្ធូរបន្ថយទោស និងលើកលែងទោស និងគណៈកម្មាការជាតិនៅមុនថ្ងៃកំណត់នៃពិធីបុណ្យដែលបន្ធូរបន្ថយទោសនីមួយៗ។

### ២.១. លក្ខខណ្ឌសម្រាប់ធ្វើការលើកលែងទោស និងបន្ធូរបន្ថយទោស

ការលើកលែងទោស និងការបន្ធូរបន្ថយទោស ត្រូវគោរពតាមលក្ខខណ្ឌដូចខាងក្រោម ៖

#### ២.១.១. លក្ខខណ្ឌទូទៅនៃការបន្ធូរបន្ថយទោស និងការលើកលែងទោស

ការទទួលបានការបន្ធូរបន្ថយទោស និងការលើកលែងទោសមិនមែនជាសិទ្ធិរបស់ទណ្ឌិតនោះទេ លុះត្រាតែទណ្ឌិតនោះបានបំពេញតាមលក្ខខណ្ឌដែលច្បាប់បានកំណត់ នោះទើបទណ្ឌិតអាចទទួលបានការអនុគ្រោះទោសជាការបន្ធូរបន្ថយទោស និងការលើកលែងទោសបាន។ ការបន្ធូរបន្ធយទោស និងការលើកទោសអាចអនុវត្តបានតែចំពោះទណ្ឌិតដែលបានផ្តន្ទាទោសដាក់ពន្ធនាគារដោយសាលក្រម ឬសាលដីកាស្ថាពរតែប៉ុណ្ណោះ[87]។

[87] មាត្រា៤ នៃព្រះរាជក្រឹត្យស្តីពីការបន្ធូរបន្ថយទោស និងការលើកលែងទោស ឆ្នាំ២០២១

ការបន្ធូរបន្ថយទោស និងការលើកលែងទោស អាចអនុវត្តបានចំពោះទណ្ឌិតដែលត្រូវបានបំពេញលក្ខខណ្ឌដូចខាងក្រោម ៖

- ទណ្ឌិតបានភ្ញាក់រលឹក និងខិតខំកែប្រែគំនិត អត្តចរិត មាយាទ ដើម្បីក្លាយខ្លួនជាពលរដ្ឋល្អក្នុងការធ្វើសមាហរណកម្មចូលក្នុងសង្គមវិញ។
- ទណ្ឌិតបានគោរពប្រតិបត្តិបានយ៉ាងហ្មត់ចត់ និងត្រឹមត្រូវតាមបទបញ្ជាផ្ទៃក្នុងរបស់ពន្ធនាគារ និងជាគំរូល្អដល់ទណ្ឌិត និងជនជាប់ឃុំដទៃទៀត។
- ទណ្ឌិតបានចូលរួមយ៉ាងសកម្ម និងបានយ៉ាងទៀងទាត់កនូវកម្មវិធីអប់រំកែប្រែ កម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ និងកម្មវិធីសមាហរណកម្មដែលបានរៀបចំដោយពន្ធនាគារ។
- ទណ្ឌិតដែលបានគោរពប្រតិបត្តិបានយ៉ាងហ្មត់ចត់ និងត្រឹមត្រូវតាមសេចក្តីណែនាំផ្សេងទៀតរបស់ពន្ធនាគារ[88]។

ចំពោះលក្ខណៈសម្បត្តិរៀបរាប់ខាងលើនេះ ប្រធានពន្ធនាគារត្រូវធ្វើបញ្ជីពិនិត្យលក្ខណៈសម្បត្តិក្នុងការវាយតម្លៃ និងបញ្ជាក់អំពីការបំពេញលក្ខខណ្ឌខាងលើរបស់ទណ្ឌិតដែលត្រូវធ្វើការបន្ធូរបន្ថយទោស លើកលែងទោសដោយបញ្ជូនគណៈកម្មាការរាជធានីខេត្ត និងគណៈកម្មាការវាយតម្លៃរបស់ក្រសួងមហាផ្ទៃដើម្បីធ្វើការពិនិត្យ និងវាយតម្លៃអំពីកម្រិតនៃការកែប្រែរបស់ទណ្ឌិត។ ប្រធានពន្ធនាគារត្រូវធ្វើការបញ្ជាក់អំពីការបំពេញលក្ខខណ្ឌតាមស្ថានភាពនីមួយៗរបស់ទណ្ឌិតដូចមានចែងក្នុងកថាខណ្ឌខាងលើ ដើម្បីធ្វើការរៀបចំបញ្ជីឈ្មោះរបស់ទណ្ឌិតដែលត្រូវធ្វើការស្នើសុំទៅកាន់គណៈកម្មាការរាជធានី ខេត្ត និងកម្មាការក្រសួងមហាផ្ទៃ។

ការបន្ធូរបន្ថយទោស និងការលើកលែងទោសអាចអនុវត្តផងដែរ ក្នុងហេតុផលមនុស្សធម៌ចំពោះទណ្ឌិតដែលមានវ័យចាស់ជរា មានជម្ងឺរ៉ាំរ៉ៃធ្ងន់ធ្ងរ ស្ត្រីមានគ៌ភ ឬមានកូន វិបល្លាសស្មារតី ពិការភាពដោយមានលិខិតបញ្ជាក់ពីគ្រូពេទ្យដែលទទួលស្គាល់ដោយក្រសួងមានសមត្ថកិច្ច[89]។

ក្នុងនោះដែរ ប្រធានពន្ធនាគារត្រូវធ្វើការបញ្ជាក់អំពីការបំពេញលក្ខខណ្ឌតាមស្ថានភាពនីមួយៗរបស់ទណ្ឌិតដូចមានចែងក្នុងកថាខណ្ឌខាងលើ ដើម្បីរៀបចំបញ្ជីឈ្មោះទណ្ឌិតដែលត្រូវស្នើសុំទៅគណៈកម្មការរាជធានី ខេត្ត និងគណៈកម្មការក្រសួងមហាផ្ទៃ។

### ២.១.២. លក្ខខណ្ឌដោយឡែកនៃការបន្ធូរបន្ថយទោស

ទណ្ឌិតដែលបានបំពេញលក្ខខណ្ឌតាមបញ្ញត្តិនៃមាត្រា៥ នៃព្រះរាជក្រឹត្យស្តីពីការបន្ធូរបន្ថយទោស និងការលើកលែងទោស អាចទទួលការបន្ធូរបន្ថយទោសបានលុះត្រាតែ ៖

- ទណ្ឌិតនោះបានទទួលរងទោស ១/៣ (មួយភាគបី) នៃទោសដាក់ពន្ធនាគារដែលតុលាការបានកំណត់
- ទណ្ឌិតត្រូវទទួលរងទោស ១០ (ដប់) ឆ្នាំជាមុនសិនចំពោះទោសដាក់ពន្ធនាគារអស់មួយជីវិត[90]។

---

[88] មាត្រា៥ នៃព្រះរាជក្រឹត្យស្តីពីការបន្ធូរបន្ថយទោស និងការលើកលែងទោស ឆ្នាំ២០២១

[89] មាត្រា៦ នៃព្រះរាជក្រឹត្យស្តីពីការបន្ធូរបន្ថយទោស និងការលើកលែងទោស ឆ្នាំ២០២១

[90] មាត្រា៧ នៃព្រះរាជក្រឹត្យស្តីពីការបន្ធូរបន្ថយទោស និងការលើកលែងទោស ឆ្នាំ២០២១

#### ២.១.៣. លក្ខខណ្ឌដោយឡែកនៃការលើកលែងទោស

ទណ្ឌិតនៅក្នុងពន្ធនាគារត្រូវបានលើកលែងទោស និងបន្ធូរបន្ថយទោសផងដែរក្នុងករណីដែលទណ្ឌិតនោះបានអនុវត្តទោសរបស់ខ្លួននៅក្នុងពន្ធនាគារបាន ៖

- ចំនួន ២/៣ (ពីរភាគបី) នៃទោស
- ទណ្ឌិតដែលត្រូវបានទទួលរងទោសដាក់ពន្ធនាគារអស់មួយជីវិត អាចទទួលការលើកលែងទោសប្រសិនបើទណ្ឌិតនោះបានអនុវត្តទោសយ៉ាងតិច ២០ (ម្ភៃ) ឆ្នាំ ឬ៣០ (សាមសិប) ឆ្នាំ ក្នុងករណីមានការបន្ធូរបន្ថយទោស[91]។

### ២.២. រយៈពេលនៃការបន្ធូរបន្ថយទោស

រយៈពេលនៃការបន្ធូរបន្ថយទោសត្រូវកំណត់ដូចខាងក្រោម ៖

- ទោសដាក់ពន្ធនាគារកំណត់ពី ១ (មួយ) ឆ្នាំ ដល់ក្រោម ៥ (ប្រាំ) ឆ្នាំ អាចនឹងបន្ថយរយៈពេលពេលជាប់ពន្ធនាគាររយៈពេល ៣ (បី) ខែ។
- ទោសដាក់ពន្ធនាគារកំណត់ពី ៥ (ប្រាំ) ឆ្នាំ ដល់ក្រោម ១០ (ដប់) ឆ្នាំ អាចនឹងបន្ថយរយៈពេលជាប់ពន្ធនាគារចំនួន ៦ (ប្រាំមួយ) ខែ ឬ៣ (បី) ខែ។
- ទោសដាក់ពន្ធនាគារកំណត់ពី ១០ (ដប់) ឆ្នាំ ដល់ក្រោម ២០ (ម្ភៃ) ឆ្នាំ អាចនឹងបន្ថយរយៈពេលជាប់ពន្ធនាគារចំនួន ១២ (ដប់ពីរ) ខែ ឬ៩ (ប្រាំបួន) ខែ ឬ៦ (ប្រាំមួយ) ខែ ឬ៣ (បី) ខែ។
- ទោសដាក់ពន្ធនាគារអស់មួយជីវិត អាចនឹងបន្ថយទោសលើកទី១ មកនៅត្រឹម ៣០ (សាមសិប) ឆ្នាំ[92]។

ទណ្ឌិតអាចទទួលការបន្ធូរបន្ថយទោសបានតែម្តងគត់ក្នុងរយៈពេល ១២ (ដប់ពីរ) ខែ។ ទណ្ឌិតអាចទទួលការបន្ធូរបន្ថយទោស និងលើកលែងទោសច្រើនដងបាន លុះត្រាតែទណ្ឌិតនោះបានទទួលរងទោសពាក់កណ្តាលនៃទោសដាក់ពន្ធនាគារដែលតុលាការបានកំណត់ ប៉ុន្តែត្រូវគោរពតាមលក្ខខណ្ឌដូចមានចែងនៅក្នុងរយៈពេលនៃការបន្ធូរបន្ថយទោសដែលបានកំណត់ខាងលើ[93]។

ចំពោះទណ្ឌិតដែលត្រូវបានកំណត់ទោសដាក់ពន្ធនាគារអស់មួយជីវិតក្រោយពីបានបន្ថយមកនៅត្រឹម ៣០ (សាមសិប) ឆ្នាំ អាចនឹងបានទទួលការបន្ធូរបន្ថយទោសច្រើនដងទៀតបាន។ ប៉ុន្តែ ទោះជាទណ្ឌិតនោះបានទទួលការបន្ធូរបន្ថយទោសច្រើនដងក៏ដោយក៏រយៈពេលនៃការទទួលរងទោសទាំងអស់ត្រូវបាន យ៉ាងតិច ២០ (ម្ភៃ) ឆ្នាំ[94]។

[91] មាត្រា១០ នៃព្រះរាជក្រឹត្យស្តីពីការបន្ធូរបន្ថយទោស និងការលើកលែងទោស ឆ្នាំ២០២១

[92] មាត្រា៨ នៃព្រះរាជក្រឹត្យនៃការបន្ធូរបន្ថយទោស និងការលើកលែងទោស ឆ្នាំ២០២១

[93] មាត្រា៨ នៃព្រះរាជាក្រឹត្យនៃការបន្ធូរបន្ថយទោស និងការលើកលែងទោស ឆ្នាំ២០២១

[94] មាត្រា៩ នៃព្រះរាជក្រឹត្យនៃការបន្ធូរបន្ថយទោស និងការលើកលែងទោស ឆ្នាំ២០២១

### ២.៣. ឱកាសនៃការលើកលែងទោស និងបន្ធូរបន្ថយទោស

ពិធីបុណ្យដែលអាចស្នើសុំបន្ធូរបន្ថយទោស និងការលើកលែងទោសចំពោះទណ្ឌិត ត្រូវកំណត់ ៥ (ប្រាំ) ដង ក្នុងមួយឆ្នាំដូចតទៅ ៖

១. ទិវាជ័យជម្នះលើរបបប្រល័យពូជសាសន៍

២. ពិធីបុណ្យចូលឆ្នាំប្រពៃណីជាតិ

៣. ពិធីបុណ្យវិសាខបូជា

៤. ពិធីបុណ្យឯករាជ្យជាតិ

៥. ព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក។

ការបន្ធូរបន្ថយទោស និងការលើកលែងទោសក៏អាចធ្វើផងដែរក្នុងពិធីបុណ្យ ឬព្រឹត្តិការណ៍ធំៗរបស់ជាតិ។ ការបន្ធូរបន្ថយទោស និងការលើកលែងទោស ក៏អាចធ្វើសម្រាប់ពិធីបុណ្យនីមួយៗខាងលើដាច់ដោយឡែកពីគ្នា ឬ រួមគ្នា[95]។

### ២.៤. នីតិវិធីនៃការស្នើសុំលើកលែងទោស និងបន្ធូរបន្ថយទោស

#### ២.៤.១. គណៈកម្មការដែលរៀបចំដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត

អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវបង្កើតគណៈកម្មការមួយដើម្បីពិនិត្យ និងវាយតម្លៃអំពីកម្រិតកែប្រែរបស់ទណ្ឌិត ក្នុងរយៈពេលជាប់ឃុំនៅក្នុងពន្ធនាគារដែលស្ថិតក្នុងការគ្រប់គ្រងរបស់ខ្លួន។ គណៈកម្មការនេះត្រូវធ្វើបញ្ជីទណ្ឌិតដែលមានលក្ខណៈសម្បត្តិអាចស្នើសុំបន្ធូរបន្ថយទោស និងលើកលែងទោសបញ្ជូនទៅ គណៈកម្មការថ្នាក់ជាតិ តាមរយៈអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារយ៉ាងយឺតបំផុត ៣០ (សាមសិប) ថ្ងៃ មុនថ្ងៃកំណត់នៃពិធីបុណ្យនីមួយៗ។

គណៈកម្មការនេះ មានសមាសភាពដូចខាងក្រោម ៖

- អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ជាប្រធាន
- តំណាងអង្គការអយ្យការអមសាលាដំបូងរាជធានី ខេត្ត ជាអនុប្រធាន
- ប្រធានក្រុមការងារប្រឡងប្រណាំងនៃពន្ធនាគាររាជធានី ខេត្ត ជាអនុប្រធានអចិន្ត្រៃយ៍
- អនុប្រធានពន្ធនាគាររាជធានី ខេត្តទទួលបន្ទុកអប់រំកែប្រែ ជាសមាជិក
- អនុប្រធានពន្ធនាគាររាជធានី ខេត្តទទួលបន្ទុកប្រតិបត្តិ ជាសមាជិក

គណៈកម្មការនេះអាចមានសមាសភាពមួយចំនួនទៀតតាមការចាំបាច់។ ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការនេះ ត្រូវកំណត់ដោយដីការបស់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត[96]។

---

[95] មាត្រា៣ នៃព្រះរាជក្រឹត្យស្តីពីការបន្ធូរបន្ថយទោស និងការលើកលែងទោស ឆ្នាំ២០២១

[96] មាត្រា៧៤ នៃច្បាប់ស្តីពីពន្ធនាគារ ឆ្នាំ២០១១

### ២.៤.២. គណៈកម្មការដែលរៀបចំដោយអគ្គនាយនៃអគ្គនាយកដ្ឋានពន្ធនាគារនៃក្រសួងមហាផ្ទៃ

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវបបង្កើតគណៈកម្មការមួយដើម្បីពិនិត្យ និងវាយតម្លៃអំពីកម្រិតកែប្រែរបស់ទណ្ឌិត ក្នុងរយៈពេលជាប់ឃុំតាមពន្ធនាគារ ឬមណ្ឌលអប់រំកែប្រែដែលស្ថិតក្នុងការគ្រប់គ្រងរបស់ខ្លួន។ គណៈកម្មការនេះត្រូវផ្ញើបញ្ជីឈ្មោះទណ្ឌិតដែលមានលក្ខណសម្បត្តិអាចស្នើសុំបន្ធូរបន្ថយទោស និងលើកលែងទោសបញ្ជូនទៅគណៈកម្មការថ្នាក់ជាតិយ៉ាងយឺតបំផុត ៣០ (សាមសិប) ថ្ងៃ មុនថ្ងៃកំណត់នៃពិធីបុណ្យនីមួយៗ។

គណៈកម្មការនេះ មានសមាសភាពដូចខាងក្រោម៖

- រដ្ឋលេខាធិការក្រសួងមហាផ្ទៃទទួលបន្ទុកពន្ធនាគារ ជាប្រធាន
- តំណាងអង្គការអយ្យការអមសាលាដំបូងដែលមានសមត្ថកិច្ច ជាអនុប្រធាន
- លើមណ្ឌលអប់រំកែប្រែសាមី ជាអនុប្រធាន
- ប្រធានក្រុមប្រឹក្សានីតិកម្មនៃក្រសួងមហាផ្ទៃ ជាអនុប្រធាន
- អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ ជាអនុប្រធានអចិន្ត្រៃយ៍
- ប្រធាននាយកដ្ឋានអប់រំកែប្រែ ជាសមាជិក
- ប្រធាននាយកដ្ឋានប្រតិបត្តិ ជាសមាជិក
- ប្រធានក្រុមការងារប្រឡងប្រណាំងនៃមណ្ឌលអប់រំកែប្រែនីមួយៗ ជាសមាជិក

គណៈកម្មការនេះ អាចមានសមាសភាពមួយចំនួនទៀតតាមការចាំបាច់។ ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មកការនេះត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ[97]។

### ២.៤.៣. គណៈកម្មការថ្នាក់ជាតិរៀបចំដោយរាជរដ្ឋាភិបាល

រាជរដ្ឋាភិបាលត្រូវបង្កើតគណៈកម្មការថ្នាក់ជាតិមួយ ដើម្បីពិនិត្យ និងវាយតម្លៃបញ្ជីឈ្មោះទណ្ឌិតស្នើសុំបន្ធូរបន្ថយទោស និងលើកលែងទោសដែលបានផ្ញើមកពីគណៈកម្មការរាជធានី ខេត្ត និងពីគណៈកម្មការក្រសួងមហាផ្ទៃ។ ក្រោយពីបានពិនិត្យវាយតម្លៃរួចហើយ គណៈកម្មការនេះត្រូវធ្វើបែបបទជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យ និងសម្រេចដើម្បីដាក់សំណើថ្វាយព្រះមហាក្សត្រសុំបន្ធូរបន្ថយទោស និងលើកលែងទោសឱ្យទណ្ឌិត យ៉ាងយឺតបំផុត ១០ (ដប់) ថ្ងៃ មុនថ្ងៃកំណត់នៃពិធីបុណ្យនីមួយៗ។

គណៈកម្មការនេះ មានសមាសភាពដូចខាងក្រោម ៖

- រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ជាប្រធាន
- រដ្ឋលេខាធិការក្រសួងមហាផ្ទៃទទួលបន្ទុកពន្ធនាគារ អនុប្រធានអចិន្ត្រៃយ៍
- អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ជាអនុប្រធាន
- តំណាងក្រុមប្រឹក្សាអ្នកច្បាប់ ចំនួន ០១ រូប ជាសមាជិក

[97] មាត្រា៧៤ នៃច្បាប់ស្តីពីពន្ធនាគារ ឆ្នាំ២០១១

- ប្រធានក្រុមប្រឹក្សានីតិកម្មនៃក្រសួងមហាផ្ទៃ ជាសមាជិក
- តំណាងក្រសួងយុត្តិធម៌ ចំនួន ០១ រូប ជាសមាជិក
- អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ ជាសមាជិក
- ប្រធាននាយកដ្ឋានជំនាញនៃអគ្គនាយកដ្ឋានពន្ធនាគារ ចំនួន ០២ រូប ជាសមាជិក

គណៈកម្មការនេះ អាចមានសមាសភាពមួយចំនួនទៀតតាមការចាំបាច់ ។ ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការនេះត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បន្ទាប់ពីមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌[98]។

### ២.៤.៤. ការលើកលែងទោសដោយបុព្វសិទ្ធិ

ក្នុងករណីចាំបាច់ ប្រមុខរាជរដ្ឋាភិបាលដែលជានាយករដ្ឋមន្ត្រីមានបុព្វសិទ្ធិធ្វើសំណើថ្វាយព្រះមហាក្សត្រសុំលើកលែងទោសឱ្យទណ្ឌិតនៅពេលណាក៏បាន[99]។

## ២.៥. ការអនុវត្តព្រះរាជក្រឹត្យបន្ធូរបន្ថយទោស និងលើកលែងទោស

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវរៀបចំសំណៅចែកផ្សាយជូនក្រសួងយុត្តិធម៌ ដើម្បីចាត់ចែងអនុវត្តក្រោយពីបានទទួលព្រះរាជក្រឹត្យបន្ធូរបន្ថយទោស និងលើកលែងទោស។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ត្រូវចាត់បញ្ជូនព្រះរាជក្រឹត្យបន្ធូរបន្ថយទោស និងលើកលែងទោសទៅព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងរាជធានី ខេត្ត ដែលមានសមត្ថកិច្ចដើម្បីអនុវត្ត។ ចំពោះទណ្ឌិតដែលត្រូវបានលើកលែងទោស ដោយព្រះរាជក្រឹត្យនឹងត្រូវដោះលែងឱ្យមានសេរីភាពភ្លាមដោយប្រធានពន្ធនាគារ បន្ទាប់ពីទទួលបានដីកាបង្គាប់ឱ្យដោះលែងទណ្ឌិតរបស់ព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងរាជធានី ខេត្តដែលមានសមត្ថកិច្ច។

ទណ្ឌិតដែលត្រូវបានបន្ធូរបន្ថយទោសដោយព្រះរាជក្រឹត្យលើកលែងទោសឱ្យទណ្ឌិតនោះរួចផុតពីការអនុវត្តទោសសម្រាប់រយៈពេលដែលត្រូវបានបន្ធូរបន្ថយ។ ព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងរាជធានី ខេត្តដែលមានសមត្ថកិច្ច និងប្រធានពន្ធនាគារ ត្រូវធ្វើការប្រកាសផ្សព្វផ្សាយព្រះរាជក្រឹត្យបន្ធូរបន្ថយទោសដល់ ទណ្ឌិតដែលត្រូវបានបន្ធូរបន្ថយទោស។ ថ្វីត្បិតតែទណ្ឌិតបានទទួលនូវការបន្ធូរបន្ថយទោស និងការលើកលែងទោសក៏ពិតមែន តែមិនមែនជាឧបសគ្គដល់សិទ្ធិរបស់ជនរងគ្រោះក្នុងការទទួលសំណងជួសជុលការខូចខាតទេ លើកលែងតែមានបទប្បញ្ញត្តិផ្ទុយនឹងព្រះរាជក្រឹត្យដែលពាក់ព័ន្ធនឹងការបន្ធូរបន្ថយទោស និងការលើកលែងទោសដែលមានចែងតែប៉ុណ្ណោះ។

[98] មាត្រា៧៥ នៃច្បាប់ស្តីពីពន្ធនាគារ ឆ្នាំ២០១១

[99] មាត្រា៧៧ នៃច្បាប់ស្តីពីពន្ធនាគារ ឆ្នាំ២០១១

# សេចក្ដីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

សរុបមកបន្ទាប់ពីបានសិក្សាស្រាវជ្រាវលើប្រធានបទនេះ យើងឃើញថាទាំងច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងបទដ្ឋានគតិយុត្តិអន្តរជាតិបានកំណត់យ៉ាងជាក់លាក់អំពីសិទ្ធិរបស់ទណ្ឌិតដែលគួរតែទទួលបាននៅពេលដែលជននោះត្រូវបានផ្តន្ទាទោសឱ្យជាប់ក្នុពន្ធនាគារ។ ជនជាទណ្ឌិតត្រូវបានច្បាប់គាំពារឱ្យទទួលបាននូវសិទ្ធិមួយចំនួនដើម្បីការពារខ្លួននៅចំពោះមុខច្បាប់ និងការពារពីការរំលោភបំពានលើសិទ្ធិដោយប្រការណាមួយដែលធ្វើឱ្យប៉ះពាល់ដល់សិទ្ធិសេរីក្នុងអំឡុងពេលនៃការឃុំខ្លួនរបស់ពួកគេ ថ្វីត្បិតតែខ្លួនធ្លាប់បានប្រព្រឹត្តទោសកំហុសយ៉ាងណាក៏ដោយ។ ជនជនទណ្ឌិតក៏ដូចជាបុគ្គលទូទៅដែរសុទ្ធតែទទួលបាននូវការការពារដោយច្បាប់ និងមានសិទ្ធិនៅក្នុងការរស់រានមានជីវិត ប៉ុន្តែពួកគេមិនទទួលបាននូវសិទ្ធិក្នុងការដើរហើរ និងមានសិទ្ធិសេរីភាពដូចបុគ្គលទូទៅទាំងស្រុងនោះទេ ពោលគឺសិទ្ធិមួយចំនួនធំរបស់ពួកគេត្រូវបានហាមឃាត់ដែលក្នុងនោះមានដូចជា សិទ្ធិក្នុងការធ្វើអាជីវកម្ម សិទ្ធិក្នុងការបញ្ចេញមតិ សិទ្ធិក្នុងការចេញដើរហើរនៅក្រៅពន្ធនាគារ និងសិទ្ធិក្នុងការទទួលបានការទំនាក់ទំនងដោយសេរីជាមួយនឹងសមាជិកគ្រួសាររបស់ពួកគេជាដើម។

ជនជាទណ្ឌិតត្រូវរ៉ាប់រងនូវសកម្មភាព និងទង្វើដែលខ្លួនបានប្រព្រឹត្តល្មើសនឹងច្បាប់ហើយត្រូវទទួលរងនូវទោស និងអនុវត្តនូវការផ្តន្ទាទោសដែលខ្លួនបានប្រព្រឹត្តឱ្យស្របតាមសេចក្តីសម្រេចរបស់តុលាការដែលបានកាត់ទោសជនជាទណ្ឌិតរូបនោះ។ ថ្វីត្បិតតែសិទ្ធិរបស់ទណ្ឌិតត្រូវបានច្បាប់ដកហូតមួយចំនួនជាបណ្តោះអាសន្នក៏ដោយ ប៉ុន្តែក្នុងអំឡុងពេលដែលទណ្ឌិតស្ថិតនៅក្នុងពន្ធនាគារក៏ត្រូវទទួលបានការការពារផ្នែកច្បាប់នូវសិទ្ធិរបស់ខ្លួនដែរ។ ជាពិសេស ចំពោះអនីតិជន ស្ត្រីទន់ខ្សោយ ស្ត្រីមានផ្ទៃពោះ ទណ្ឌិតដែលអាយុច្រើន ឬទណ្ឌិតស្ថិតក្នុងជរាភាពដែលមានសុខភាពទន់ខ្សោយ ឬមានជម្ងឺប្រចាំកាយ ជនពិការ និងទណ្ឌិតជាជនបរទេស ជាដើមសុទ្ធតែត្រូវទទួលបានការយកចិត្តទុកដាក់ពីច្បាប់ទៅលើស្ថានភាពជាក់ស្តែងរបស់ពួកគេផងដែរ។ ក្នុងការលើកកម្ពស់ចំពោះសិទ្ធិរបស់ទណ្ឌិតមាននូវយន្តការមួយចំនួនដូចជាការគ្រប់គ្រងសំណុំរឿងជនជាប់ឃុំ ការបែងចែកជនជាប់ឃុំតាមប្រភេទ ទីកន្លែងសម្រាប់ជនជាទណ្ឌិតស្នាក់នៅអានាម័យ ប្រចាំកាយ ការស្លៀកពាក់ និងការដេក ម្ហូបអាហារ ការហាត់ប្រាណ ការលេងកីឡា និងសេវាថែទាំសុខភាព។

ក្រៅពីការទទួលបានសិទ្ធិមួយចំនួនដែលទណ្ឌិតត្រូវទទួលបាននៅអំឡុងពេលនៃការឃុំឃាំងហើយនោះក្នុងនោះដែរទណ្ឌិតត្រូវគោរពឱ្យបានយ៉ាងខ្ជាប់ខ្ជួននូវកាតព្វកិច្ចរបស់ខ្លួនឱ្យស្របតាមច្បាប់ស្តីពីពន្ធនាគារ និងបទបញ្ជាផ្ទៃក្នុងរបស់ពន្ធនាគារដោយគោរពនូវវិធានការមួយចំនួនដែលបានដាក់ជូនដោយមន្ត្រីនៅក្នុងពន្ធនាគារផងដែរ។ កាតព្វកិច្ចមួយខាងលើនេះ ក៏ជាមូលដ្ឋាននៃសិទ្ធិការទទួលបានការដោះលែងដោយមានលក្ខខណ្ឌ និងសិទ្ធិទទួលបានការបន្ធូរបន្ថយទោស និងការលើកលែងទោសផងដែរ ប្រសិនបើទណ្ឌិតរូបនោះបានអនុវត្តបានយ៉ាងល្អនូវកាតព្វកិច្ចទាំងអស់នោះដោយការវិនិច្ឆ័យទៅអាកប្បកិរិយា ចរិតលក្ខណៈ ការចូលរួមសកម្មភាពការងារ វគ្គបណ្តុះបណ្តាលនានាដែលបានចាត់ចែងដោយមន្ត្រីនៅក្នុងពន្ធនាគារ និងតាមលក្ខខណ្ឌរយៈពេលនៃការជាប់ពន្ធនាគាររបស់ពួកគេផងដែរ។

សរុបជារួមមក ចំពោះសិទ្ធិរបស់ជនជាប់ឃុំ ឬទណ្ឌិត ជាផ្នែកមួយដែលសំខាន់របស់ជនដែលត្រូវបានតុលាការចេញសេចក្តីសម្រេចផ្តន្ទាទោសជាប់ពន្ធនាគារជាស្ថាពរដែលអាចជាទណ្ឌិត និងជនជាប់ឃុំដោយមិនទាន់ទទួលបានសេចក្តីសម្រេចជាស្ថាពររបស់តុលាការនៅឡើយ។ ជាជនទណ្ឌិតទាំងអស់ គឺមានសិទ្ធិទទួលបាននូវការការពារសិទ្ធិមនុស្សក្នុងគ្រប់កាលៈទេសៈ និងគ្រប់ពេលវេលាដោយមិនប្រកាន់ភេទ ពណ៌សម្បុរ សាសនា ភាសា ជាតិសាសន៍ និងនិន្នាការចំពោះនយោបាយឡើយ ប្រសិនបើគ្មានច្បាប់សម្រាប់ការពារចំពោះជនទាំងអស់នោះទេ ពួកគេទាំងនោះអាចនឹងត្រូវប្រឈមមុខខ្លាំងទៅនឹងការរំលោភបំពានសិទ្ធិមនុស្សយ៉ាងខ្លាំងដូចកាលពីសម័យកម្ពុជាប្រជាធិបតេយ្យជាដើមដែលយើងសង្កេតឃើញថាមានការរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរ ដោយមិនបានតាក់តែងច្បាប់ក្នុងការការពារជនជាទាំងនោះជាពិសេស គឺទណ្ឌិតដែលជាជនដែលងាយក្នុងការរងគ្រោះជាងគេ ជាពិសេសនៅក្នុងសម័យនោះមិនមានការចងក្រមជាបទដ្ឋានគតិយុត្តិ ឬមានអង្គការសម្រាប់គាំពារទៅលើជនជាទណ្ឌិតទាំងនោះឡើយ។

ក្រោយពីការជួលរលំនូវរបបនោះកម្ពុជានាសម័យក្រោយៗមកទៀតបានយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះសិទ្ធិមនុស្សដែលសិទ្ធិមនុស្សនេះត្រូវបានទទួលបានការគាំពារទាំងពីរមជ្ឈដ្ឋានជាតិ និងមជ្ឈដ្ឋានអន្តរជាតិដែលនៅក្នុងនោះផងដែររួមមានទាំងអង្គការក្រៅរដ្ឋាភិបាលក្នុងការជួយជ្រោមជ្រែងលើកកម្ពស់នូវការគោរពសិទ្ធិរបស់ជនជាជាប់ឃុំក៏ដូចជាជនជាទណ្ឌិតផងដែរឱ្យទទួលបាននូវសិទ្ធិដែលខ្លួនគួរតែទទួលបានឱ្យស្របតាមបទដ្ឋានគតិយុត្តជាតិ និងអន្តរជាតិផងដែរ។ ម្យ៉ាងវិញទៀត ចំពោះជនជាប់ឃុំវិញ មិនថាជនដែលត្រូវបានតុលាការសម្រេចឃុំខ្លួនស្ថាពរ ឬជនដែលឃុំខ្លួនជាបណ្តោះអាសន្ននោះទេ គឺសុទ្ធតែទទួលបានការការពារសិទ្ធិមនុស្សគ្រប់ៗគ្នា។ ចំពោះជនជាទណ្ឌិតមានដូចជាចំពោះទណ្ឌិតជាស្ត្រី ទណ្ឌិតជាអនីតិជន និងទណ្ឌិតជាជនពិការ ប្រសិនបើកមានការរំលោភបំពានទៅជនជាទណ្ឌិតណាមួយនោះ ជននោះមានសិទ្ធិក្នុងការប្តឹងទៅប្រធានពន្ធនាគារបាន ដើម្បីការពារសិទ្ធិរបស់ពួកគេ ។

តួយ៉ាងដើម្បីឱ្យការការពារសិទ្ធិរបស់ជនជាទណ្ឌិតឱ្យកាន់តែទទួលបាននូវប្រសិទ្ធិភាពខ្ពស់ត្រូវតែមានការចូលរួមពីសំណាក់អង្គភាពដែលពាក់ព័ន្ធដូចជា ក្រសួងមហាហាផ្ទៃ ក្រសួងយុត្តិធម៌ និងអង្គការសិទ្ធិមនុស្សជាដើម ដើម្បីការពារសិទ្ធិរបស់ជនជាប់ឃុំ និងទទួលបានការលើកម្ពស់ដល់សិទ្ធិរបស់ជនជាទណ្ឌិតទាំងអស់នោះ។

# អនុសាសន៍

# អនុសាសន៍

បន្ទាប់ពីបានធ្វើការសិក្សា និងស្រាវជ្រាវលើប្រធានបទស្តីពីសិទ្ធិរបស់ទណ្ឌិតនៅក្នុងពន្ធនាគារនៃព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្នកន្លងមក ទោះបីជាមានការលំបាកបន្តិចក៏ដោយតែវាក៏បានធ្វើឱ្យយើងខ្ញុំដែលជាអ្នកសិក្សាស្រាវជ្រាវបានយល់ដឹងកាន់តែច្បាស់ពីសិទ្ធិទាំងឡាយដែល និងត្រូវយកមកអនុវត្តចំពោះជនជាទណ្ឌិត និងការផ្តល់នូវចំណេះដឹងជាច្រើនអំពីផ្នែកមួយនេះ ព្រោះជាផ្នែកមួយដែលបានផ្សារភ្ជាប់ពីការអនុវត្តនៅក្នុងសង្គមដោយស្របទៅនឹងបទដ្ឋានគតិយុត្តជាតិ និងអន្តរជាតិទៅលើជនជាទណ្ឌិត។ ការសិក្សាលើប្រធានបទនេះផងដែរក៏ជាផ្នែកមួយក្នុងជួយទៅការសិក្សាស្រាវជ្រាវរបស់ក្រុមសិស្ស និស្សិត និងអ្នកវិជ្ជាជីវៈមេធាវីច្បាប់ព្រោះប្រធានបទនេះបានផ្តោតសំខាន់ទៅលើជនដែលត្រូវបានចាប់ខ្លួន និងឃុំខ្លួនតាមដីកាសម្រេចរបស់តុលាការ និងសិទ្ធិរបស់ពួកគេនៅពេលដែលជននោះត្រូវបានជាប់ឃុំក្នុងករណីណាមួយតាមរយៈការប្រព្រឹត្តអំពើល្មើសច្បាប់របស់ខ្លួន និងផ្នែកទាំងនោះមានដូចជាការការពារសិទ្ធិជនជាប់ឃុំ និងជនជាទណ្ឌិតទាំងនៅក្នុងច្បាប់ជាតិ សិទ្ធិទទួលបានការថែទាំសុខភាព សិទ្ធិទទួលបានការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការងារ សិទ្ធិរួចផុតពីការធ្វើទារុណកម្ម និងជាពិសេសទទួលបានសិទ្ធិនៅពេលដែលពួកគេទទួលរងភាពអយុត្តិធម៌ ក្នុងនោះដែរ ទណ្ឌិតមានសិទ្ធិក្នុងប្តឹងឧទ្ធរណ៍ស្របទៅតាមបញ្ញត្តិនៃច្បាប់ដែលបានចែងនៅក្នុងច្បាប់ក្នុងគោលបំណងការពារការបំពាននូវសិទ្ធិណាមួយទៅលើជនទាំងនោះ។

ប៉ុន្តែបន្ទាប់ពីការសិក្សាស្រាវជ្រាវទាក់ទងក្នុងប្រធានបទនេះយើងឃើញថាការអនុវត្តសិទ្ធិរបស់ជនជាប់ឃុំ និងជនជាទណ្ឌិតជាក់ស្តែងនៅកម្ពុជាមិនទាន់បានពេញលេញនោះទេ ពោលការអនុវត្តគឺមានការខ្វះចន្លោះដូចជាការអនុវត្តផ្តល់សិទ្ធិដល់ទណ្ឌិតចំពោះការជួបក្រុមគ្រួសារ ឬមិត្តភក្តិការទទួលបានការព្យាបាលនៅពេលដែលមានជម្ងឺ ការប្រើប្រាស់ថ្នាំសង្កូវដែលក្រុមគ្រួសារបានផ្ញើឱ្យក្នុងពេលជាប់ឃុំជាដើម ការអនុវត្តបែបនេះមិនទាន់បានពេញលេញនៅឡើយទេ ដែលធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់ទណ្ឌិត ។

ដូច្នេះដើម្បីទប់ស្កាត់ការរំលោភបំពានសិទ្ធិរបស់ជនជាប់ឃុំ យើងខ្ញុំដែលអ្នកសិក្សាស្រាវជ្រាវយល់ថាកម្ពុជាគួរតែមានវិធានការលើកកម្ពស់ និងលើកតម្កើនដល់សិទ្ធិរបស់ជនជាប់ឃុំ និងជនជាទណ្ឌិតឱ្យកាន់តែប្រសើរជាងនេះ ក្នុងគោលបំណងដើម្បីធានាឱ្យព្រះរាជាណាចក្រកម្ពុជាបានអនុវត្ត និងធានាដល់សិទ្ធិមនុស្ស គ្រប់ទីកន្លែង និងត្រូវបានការពារដោយច្បាប់របស់ជាតិ អន្តរជាតិ និងជួយពង្រឹងការគោរពសិទ្ធិមនុស្សឱ្យបានកាន់តែរឹងមាំ។

# ឯកសារយោង

# ឯកសារយោង

## ❖ លិខិតបទដ្ឋានគតិយុត្តិអន្តរជាតិ

១. អនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ឆ្នាំ១៩៨៧

២. អនុសញ្ញាស្តីពីសិទ្ធិកុមារ ខែមិថុនា ឆ្នាំ២០០៩

២. វិធានអង្គការសហប្រជាជាតិស្តីពីបទដ្ឋានអប្បបរមាសម្រាប់ការប្រព្រឹត្តទៅលើជនជាប់ឃុំ (វិធាននៃលសាន់ម៉ានដឺលា) ឆ្នាំ២០១៥

៣. យុទ្ធសាស្ត្រលេខ១៨ ស្តីពីជនជាប់ឃុំស្ត្រីរបស់អង្គការសហប្រជាជាតិសិទ្ធិមនុស្សការិយាល័យឧត្តមស្នងការកម្ពុជា ឆ្នាំ២០១២ ។

## ❖ លិខិតបទដ្ឋានគតិយុត្តិជាតិ

១. ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

២. ច្បាប់ស្តីពីពន្ធនាគារ ឆ្នាំ២០១១

៣. ច្បាប់ស្តីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

៤. ព្រះរាជក្រឹត្យស្តីពីការបន្ធូរបន្ថយទោស និងការលើកលែងទោស ឆ្នាំ២០២១

៦. ប្រកាសលេខ០៩០កយ.ប្រក/២១ ស្តីពីបែបបទនៃការឃ្លាំមើលតាមដាន ការត្រួតពិនិត្យ និងការបញ្ជូនទៅក្នុងសង្គមវិញនៃទណ្ឌិតដែលត្រូវបានដោះលែងដោយមានលក្ខខណ្ឌ ឆ្នាំ២០២១

៧. សេចក្តីសម្រេចលេខ១៦ កយ សសរ/២១ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០២១ ស្តីពីសមាសភាព និងការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាការជាតិដោះលែងដោយមានលក្ខខណ្ឌ

៨. ប្រកាសលេខ៤០៤ ប្រក ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០០៧ ស្តីពីតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់នាយកដ្ឋានលេខាធិការដ្ឋាន មណ្ឌលអប់រំកែប្រែ និងពន្ធនាគារ ខេត្ត ក្រុង ចំណុះអគ្គនាយកដ្ឋានពន្ធនាគារ ក្រសួងមហាផ្ទៃ

៩. សេចក្តីសម្រេចលេខ០៩ សសរ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៥ ស្តីពីការបង្កើតក្រុមការងារពិនិត្យ ស្រង់ស្ថិតិ និងរៀបចំបែបបទដើម្បីធ្វើការលើកលែងទោសស្ត្រីមានគភ៌ និងមានកូនដែលជាប់ពន្ធនាគារ។

១០. សេចក្តីណែនាំលេខ ០១ កយ.សណន/២០ ស្តីពីគោលការណ៍ដែលត្រូវអនុវត្តនៅក្នុងដំណាក់កាលអយ្យការ ដំណាក់កាលស៊ើបសួរ និងដំណាក់កាលជំនុំជម្រះសម្រាប់យុទ្ធនាគារដោះស្រាយការកកស្ទះសំណុំរឿងនៅតាមសាលាដំបូងរាជធានីខេត្ត។

១១. នីតិវិធីពន្ធនាគារ របស់អគ្គនាយកដ្ឋានពន្ធនាគារ ឆ្នាំ២០០៣ ។

❖ **ឯកសារ និងអត្ថបទផ្សេងទៀត**

១. របាយការណ៍ស្តីពីសិទ្ធិមនុស្សនៅកម្ពុជា ឆ្នាំ២០២១

២. របាយការណ៍ជំរឿនទូទៅប្រជាជនព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩ របស់វិទ្យាស្ថានជាតិស្ថិតិក្រសួងផែនការខែមិថុនា ឆ្នាំ២០១៩

៣. របាយការណ៍អង្គការលីកាដូសិទ្ធិមនុស្សកម្ពុជា ឆ្នាំ២០១២

៤. សេចក្តីថ្លែងការណ៍ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២៣ ស្តីពីសូមបញ្ឈប់ការឃុំខ្លួនដែលមិនចាំបាច់លលើកុមារនៅក្នុងពន្ធនាគារដ៏ចង្អៀតណែនរបស់អង្គការលីកាដូ

៥. របាយការណ៍អង្គការលីកាដូស្តីពីគម្រោងជំនួយដល់កុមាររស់នៅជាមួយម្តាយក្នុងពន្ធនាគារ ខែមិថុនា ឆ្នាំ២០១០

៦. សេចក្តីថ្លែងការណ៍ស្តីពី សូមបញ្ឈប់ការឃុំខ្លួនដែលមិនចាំបាច់លើកុមារនៅក្នុងពន្ធនាគារដ៏ចង្អៀតណែន ចេញផ្សាយថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២៣

៥. ប្រសាសន៍របស់ឯកត្តមអគ្គានុរក្សថ្នាក់លេខ១ ឆែម សារុធ អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារក្នុងសន្និបាតផ្សព្វផ្សាយទិសដៅការងារឆ្នាំ២០២៣ នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៣

៦. ប្រសាសន៍របស់ឯកឧត្តម ឧត្តមអគ្គានុរក្ស ១ នុត សវនា អគ្គនាយករងនៃអគ្គនាយដ្ឋានពន្ធនាគារ លើប្រធានបទស្ថានភាពនៃជនជាប់ឃុំក្នុងពន្ធនាគារ និងការទប់ស្កាត់ជំងឺកូវីដក្នុងពន្ធនាគារ

៧. ប្រសាសន៍របស់ឯកឧត្តម ប៉ាវ ហមផាន ក្នុងកម្មវិធីបើកសន្និបាតផ្សព្វផ្សាយ លទ្ធផលការងារឆ្នាំ២០២១ និងលើកទិសដៅការងារឆ្នាំ២០២២ និងផែនការសកម្មភាពឆ្នាំ២០២២ របស់អគ្គនាយដ្ឋានពន្ធនាគារ ថ្ងៃទី២៥ ខែមិនា ឆ្នាំ២០២២

៨. ប្រសាសន៍របស់លោក ព្រំ សុផល ជាប្រធានការិយាល័យអប់រំកែប្រែមណ្ឌលអប់រំកែប្រែទី២ កាលពីឆ្នាំ២០១២ (សារណាស្តីពីស្ថានភាពជនជាប់ឃុំក្នុងពន្ធនាគារឆ្នាំ២០១២ របស់និស្សិត ស.ភ.វ.ន.ស)

៩. ប្រសាសន៍របស់លោក គង់ សំអុន ជាប្រធានការិយាល័យមធ្យោបាយមណ្ឌលអប់រំកែប្រែទី២ កាលពីឆ្នាំ២០១២ (សារណាស្តីពីស្ថានភាពជនជាប់ឃុំក្នុងពន្ធនាគារឆ្នាំ២០១២ របស់និស្សិត ស.ភ.វ.ន.ស)

១០. ប្រសាសន៍របស់លោក ហេង សំណាង ជាអនុប្រធានការិយាល័យមធ្យោបាយមណ្ឌលអប់រំកែប្រែទី២ កាលពីឆ្នាំ២០១២ (សារណាស្តីពីស្ថានភាពជនជាប់ឃុំក្នុងពន្ធនាគារឆ្នាំ២០១២ របស់និស្សិត ស.ភ.វ.ន.ស)

១១. សារព័ត៌មានហ្វ្រេសញ៉ូកាលពីថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៣ ស្តីពីមេពន្ធនាគារ ឆ្នាំ២០២២ ជនជាប់ឃុំថយចុះ 0.៦ ភាគរយហើយជនជាប់ឃុំភាគច្រើនពាក់ព័ន្ធបទល្មើសគ្រឿងញៀន

១២. សារព័ត៌មានវិទ្យុអាស៊ីសេរីកាលពីថ្ងៃទី០៧ ខែតុលា ឆ្នាំ២០២១ ស្តីពីរដ្ឋាភិបាលបារម្ភពីស្ថានភាពចង្អៀតណែនក្នុងពន្ធនាគារ ដូចអ្នករាយការណ៍ពិសេស UN

១៣. សារព័ត៌មានភ្នំពេញប៉ុស្តិ៍កាលពីថ្ងៃព្រហស្បត្តិ៍ ទី០៣ ខែសីហា ឆ្នាំ២០២៣ ស្តីពី បច្ចុប្បន្នកម្ពុជាមានជនជាប់ឃុំប្រមាណ ៣៨,000 នាក់ ក្នុងនោះមានជនជាប់ឃុំប្រមាណ ៥៤% ជាប់ពាក់ព័ន្ធនឹងគ្រឿងញៀន។

# បញ្ជីឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ

## បញ្ជីរាយនាមឧបសម្ព័ន្ធ

- ឧបសម្ព័ន្ធទី១៖ នីតិវិធីពន្ធនាគារ ឆ្នាំ២០០៣។
- ឧបសម្ព័ន្ធទី២៖ របាយការណ៍ស្តីពីសិទ្ធិមនុស្សនៅកម្ពុជា ឆ្នាំ២០២១។
- ឧបសម្ព័ន្ធទី៣៖ តារាង និងប្លង់ព័ត៌មានស្តីពីបច្ចុប្បន្នភាពទិន្នន័យស្តូលពីភាពចង្អៀតណែនជនជាប់ឃុំឆ្នាំ២០១២
- ឧបសម្ព័ន្ធទី៤៖ ទិន្នន័យជនជាប់ឃុំជាអនីតិជនក្នុងពន្ធនាគារក្នុងឆ្នាំ២០២៣ របស់អង្គការលីកាដូ
- ឧបសម្ព័ន្ធទី៥៖ ព្រះរាជក្រឹត្យស្តីពីការដោះលែងទណ្ឌិត

# ឧបសម្ព័ន្ធទី១

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមហាផ្ទៃ**

**អគ្គនាយកដ្ឋានរដ្ឋបាល**

**នាយកដ្ឋានពន្ធនាគារ**

# នីតិវិធី លេខ ៣

| ចំណងជើង | **ការដាក់អ្នកទោសទៅតាមជំពូក** |
|---|---|
| យោង | ប្រកាស លេខ ២១៧ ប្រ.ក ចុះថ្ងៃទី ៣១ ខែ មិនា ឆ្នាំ ១៩៩៨ ស្តីពីការគ្រប់គ្រងពន្ធនាគារ របស់ក្រសួងមហាផ្ទៃ ប្រការទី៤ ចំណុចទី៣ |
| កាលបរិច្ឆេទចេញឱ្យប្រើប្រាស់ | ភ្នំពេញ, ថ្ងៃទី ..........ខែ ...........ឆ្នាំ ២០០៣ |
| កាលបរិច្ឆេទពិនិត្យឡើងវិញ | ១២ខែ |

**១. គោលបំណង:**

ដើម្បីគូសបញ្ជាក់នូវនីតិវិធីក្នុងការដាក់អ្នកទោសទៅតាមជំពូក នៅក្នុងពន្ធនាគារ ។

**២. វិសាលភាពអនុវត្ត:**

នីតិវិធីនេះ អនុវត្តចំពោះអ្នកទោស និងមន្ត្រីពន្ធនាគារ ។

**៣. លំនាំដើម:**

៣.១ ត្រូវដាក់អ្នកទោសបុរស និងអ្នកទោសស្ត្រីឱ្យនៅដាច់ដោយឡែកពីគ្នា ។

៣.២ អ្នកទោសដែលមានអាយុក្រោម ១៨ឆ្នាំ ដាក់ឱ្យនៅដោយឡែកពីអ្នកទោសពេញវ័យ

៣.៣ ត្រូវដាក់អ្នកទោសឱ្យនៅដោយឡែកពីគ្នាទៅតាមអាគារឃុំឃាំងដែលអាចទទួលបានដូចខាងក្រោម ÷

ក. ពិរុទ្ធជនដាក់ឱ្យនៅដោយឡែកពីទណ្ឌិត

ខ. អ្នកទោសដែលបានរត់គេចពីពន្ធនាគារ ឬបានប្រព្រឹត្តអ្វីមួយផ្ទុយពីសន្តិសុខ និងសណ្តាប់ធ្នាប់ល្អរបស់ពន្ធនាគារ ។

គ. អ្នកទោសកម្រិតធ្ងន់ ដាក់ឱ្យនៅដោយឡែកពីអ្នកទោសកម្រិតស្រាល ឬអ្នកទោសមធ្យម

ឃ. អ្នកទោសដែលមានរោគប្រចាំកាយ ឬមានជម្ងឺសរសៃប្រសាទ មានរបួសធ្ងន់ធ្ងរ ដែលប៉ះពាល់ដល់សុខភាពសាមីខ្លួន និងដល់អ្នកទោសដទៃទៀត ។

ង. ការពារអ្នកទោសពីការវាយប្រហារផ្សេងទៀត

## ៤. នីតិវិធី:

៤.១ បើសិនជាអ្នកទោសត្រូវបានបំបែក ដោយយោងទៅតាមចំណុច ៣.៣ ខ ខាងលើប្រធានពន្ធនាគារត្រូវ ÷

ក. សរសេររបាយការណ៍ជាលាយលក្ខណ៍អក្សរទៅកាន់ប្រធាននាយកដ្ឋានពន្ធនាគារ តាមទម្រង់បែបបទជាប់មកជាមួយ (**៣-I**) ដោយបញ្ជាក់ឈ្មោះអ្នកទោស និងហេតុផលដែលត្រូវបំបែក ។

ខ. ប្រធានពន្ធនាគារ ឬមន្ត្រីដែលអនុញ្ញាតដោយប្រធានពន្ធនាគារ និងមន្ត្រីពេទ្យពន្ធនាគារត្រូវចូលពិនិត្យអ្នកទោសជារៀងរាល់ថ្ងៃ និងធ្វើការបូកសរុបវាយតម្លៃអំពីការបំបែកអ្នកទោសថា តើគួរឈប់ ឬក៏ត្រូវកែប្រែ ពីព្រោះថាការបំបែកនេះអាចបណ្តាលឱ្យមានផលអាក្រក់ទៅលើសុខភាព ផ្នែកស្មារតី និងផ្លូវកាយរបស់អ្នកទោស ។

គ. សរសេររបាយការណ៍ជាលាយលក្ខណ៍អក្សរដោយភ្ជាប់ជាមួយនូវទម្រង់បែបបទ (**៣-II**) ទៅកាន់ ប្រធាននាយកដ្ឋានពន្ធនាគារ នៅពេលដែលអ្នកទោសត្រូវបានគេផ្ទេរត្រឡប់មកពីការបំបែកវិញ ដោយបញ្ជាក់អំពីឈ្មោះ និងមូលហេតុនៃការឈប់បំបែកនេះ ។

៤.២ បន្ថែមពីលើការពិនិត្យប្រចាំថ្ងៃដូចដែលបានចែងក្នុងចំណុច ៤.១ ខាងលើ អនុប្រធានពន្ធនាគារទទួលបន្ទុកផ្នែកអគ្គារនុរក្ស និងមន្ត្រីពេទ្យពន្ធនាគារផ្តល់ការថែទាំសុខភាពនឹងធ្វើការពិនិត្យឡើងវិញជាចាំបាច់នូវការបំបែកនេះ ដោយយោងទៅតាមចំណុច ៣.៣ ខ និង ៣.៣ គ រាល់ ៣០ថ្ងៃម្តង ដើម្បីវាយតម្លៃបូក សរុបលើតម្រូវការបន្ត ក្នុងការបំបែកនេះ ។

៤.៣ នៅពេលបញ្ចប់ការពិនិត្យឡើងវិញនូវការបំបែក ប្រធានពន្ធនាគារត្រូវធ្វើរបាយការណ៍លំអិតអំពីលទ្ធផលក្នុងទម្រង់បែបបទដែលភ្ជាប់មកជាមួយ (**៣-III**) ជូនប្រធាននាយកដ្ឋានពន្ធនាគារ ។

៤.៤ ប្រធានពន្ធនាគារត្រូវធានាថា អ្នកទោសទាំងអស់ដែលបានត្រូវបំបែកឱ្យនៅដោយឡែកដោយយោងទៅលើចំណុច ៣.៣ ខ, ៣.៣ ឃ និង ៣.៣ ង ទទួលបានពេលវេលាធ្វើលំហាត់ប្រាណជាអតិបរិមាមួយម៉ោងក្នុងមួយថ្ងៃ ។

៤.៥ បើសិនជាអ្នកទោសត្រូវបានគេបំបែកឱ្យនៅដាច់ដោយឡែក តាមចំណុច ៣.៣ ឃ ខាងលើ មន្ត្រីពេទ្យពន្ធនាគារត្រូវពិនិត្យ វាយតម្លៃការព្យាបាលរៀងរាល់ថ្ងៃ ដើម្បីកំណត់ថា តើការបំបែកនេះគួរបន្ត ឬយ៉ាងណា ។

៤.៦ ក្នុងករណីដែលអ្នកទោសស្ត្រីដែលមានកូននៅជាមួយ ហើយត្រូវបានបំបែកឱ្យនៅដោយឡែកដោយសារបញ្ហាសុខភាព ប្រធានពន្ធនាគារត្រូវធ្វើការពិគ្រោះយោបល់ជាមួយមន្ត្រីពេទ្យពន្ធនាគារដើម្បីកំណត់រកម្តាយដែលមានលទ្ធភាពថែរក្សាកូននោះ ។

៤.៧ បើសិនជាមន្ត្រីពេទ្យពន្ធនាគារគិតឃើញថា ម្តាយមិនអាចថែទាំកូនបាន ប្រធានពន្ធនាគារ ត្រូវជួយសម្រួល ចាត់ចែងតាមវិធីផ្សេងៗ ប្រគល់កូននោះទៅឱ្យសាច់ញាតិ ឬរកម្តាយចិញ្ចឹមណាមួយដែលស័ក្តិសម នៅក្នុងពន្ធនាគារដើម្បីថែរក្សាកូននោះ ។

៤.៨ ប្រធានពន្ធនាគារត្រូវធានាដល់សិទ្ធិរបស់អ្នកទោសដែលត្រូវបំបែកឱ្យនៅដោយឡែក ដោយអនុលោមទៅតាមប្រកាសលេខ ២១៧ ។

**ប្រធាននាយកដ្ឋានពន្ធនាគារ**

**សំកុល សុខន**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមហាផ្ទៃ**

**អគ្គនាយកដ្ឋានរដ្ឋបាល**

**នាយកដ្ឋានពន្ធនាគារ**

**ទម្រង់បែបបទ ៣.១**

**ពន្ធនាគារ..........................................................**

## ទម្រង់បែបបទដាក់អ្នកទោសឱ្យនៅដាច់ដោយឡែក

**ជូនចំពោះ លោកប្រធាននាយកដ្ឋានពន្ធនាគារ**

ខ្ញុំបាទមានកិត្តិយស សូមគោរព និងជម្រាបថា អ្នកទោស.......................................................... ត្រូវបាន បំបែកចេញពីអ្នកទោសដទៃទៀត នៅថ្ងៃទី............ ខែ............. ឆ្នាំ................. ដោយមូលហេតុ:

........................................................................................................................................................

........................................................................................................................................................

........................................................................................................................................................

........................................................................................................................................................

........................................................................................................................................................

........................................................................................................................................................

........................................................................................................................................................

........................................................................................................................................................

........................................................................................................................................................

ថ្ងៃទី............ ខែ............. ឆ្នាំ..............

**ប្រធានពន្ធនាគារ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមហាផ្ទៃ**
**អគ្គនាយកដ្ឋានរដ្ឋបាល**
**នាយកដ្ឋានពន្ធនាគារ**

**ទម្រង់បែបបទ៣.**

**ពន្ធនាគារ.........................................................................**

## ទម្រង់បែបបទបញ្ឈប់ពីការបំបែកឱ្យនៅដោយឡែក

**ជូនចំពោះ លោកប្រធាននាយកដ្ឋានពន្ធនាគារ**

ខ្ញុំបាទមានកិត្តិយស សូមគោរព និងជម្រាបថា អ្នកទោស............................................................. ត្រូវបាន បញ្ឈប់ពីការបំបែកឱ្យនៅដោយឡែក នៅថ្ងៃទី............ ខែ............. ឆ្នាំ................ ដោយមូលហេតុ:

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

ថ្ងៃទី............ ខែ............ ឆ្នាំ.............

**ប្រធានពន្ធនាគារ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមហាផ្ទៃ**

**អគ្គនាយកដ្ឋានរដ្ឋបាល**

**នាយកដ្ឋានពន្ធនាគារ**

**ទម្រង់បែបបទ៣_III**

**ពន្ធនាគារ.........................................................**

## ទម្រង់បែបបទស្តីពីការពិនិត្យឡើងវិញ
## នូវការបំបែកអ្នកទោសឱ្យនៅដាច់ដោយឡែក

**ជូនចំពោះ លោកប្រធាននាយកដ្ឋានពន្ធនាគារ**

ខ្ញុំបាទមានកិត្តិយស សូមគោរព និងជម្រាបថា អ្នកទោស................................................................. ត្រូវបាន បំបែកឱ្យនៅដាច់ដោយឡែកពីអ្នកទោសដទៃទៀត នៅថ្ងៃទី............ ខែ............ ឆ្នាំ................ ដោយ មូលហេតុ:

.......................................................................................................................................................

.......................................................................................................................................................

.......................................................................................................................................................

.......................................................................................................................................................

ត្រូវបានពិនិត្យពីការបំបែកឱ្យនៅដោយឡែកឡើងវិញ នៅថ្ងៃទី............. ខែ............. ឆ្នាំ.............

ដោយបានកំណត់ថា ការបំបែកនេះនឹងត្រូវបានធ្វើបន្ត/មិនធ្វើបន្តដោយមូលហេតុដូចតទៅ :-

.......................................................................................................................................................

.......................................................................................................................................................

.......................................................................................................................................................

.......................................................................................................................................................

ថ្ងៃទី............ ខែ............ ឆ្នាំ.............

**ប្រធានពន្ធនាគារ**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ

អគ្គនាយកដ្ឋានរដ្ឋបាល

នាយកដ្ឋានពន្ធនាគារ

# នីតិវិធី លេខ ៥

| | |
|---|---|
| ចំណងជើង | **ឯកសណ្ឋានរបស់អ្នកទោស និងសម្ភារៈបរិក្ខារក្នុងបន្ទប់ឃុំឃាំង** |
| យោង | - អនុក្រឹត្យលេខ ១១ អនក្រ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៨៥ ស្តីពីរបបជីវភាព ពិរុទ្ធជន ទណ្ឌិត របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ជំពូក ៣ មាត្រា ១១-១៧<br>- ប្រកាស លេខ២១៧ ប្រ.ក ចុះថ្ងៃទី ៣១ ខែ មិនា ឆ្នាំ ១៩៩៨ ស្តីពីការគ្រប់គ្រង ពន្ធនាគារ របស់ក្រសួងមហាផ្ទៃ ប្រការទី៤ ចំណុចទី៨ |
| កាលបរិច្ឆេទចេញឱ្យប្រើប្រាស់ | ភ្នំពេញ , ថ្ងៃទី..........ខែ...........ឆ្នាំ ២០០៣ |
| កាលបរិច្ឆេទពិនិត្យឡើងវិញ | ១២ខែ |

## ១. គោលបំណង:

ដើម្បីគូសបញ្ជាក់នូវនីតិវិធីក្នុងការផ្តល់ឯកសណ្ឋានសម្រាប់អ្នកទោស និងសម្ភារៈបរិក្ខារប្រើប្រាស់ក្នុងបន្ទប់ឃុំឃាំង ។

## ២. វិសាលភាពអនុវត្ត:

នីតិវិធីនេះ អនុវត្តចំពោះអ្នកទោស និងមន្ត្រីពន្ធនាគារទាំងអស់ ។

## ៣. លំនាំដើម:

៣.១ អ្នកទោសទាំងអស់ត្រូវបានផ្តល់ឱ្យនូវឯកសណ្ឋាន និងសម្ភារៈប្រើប្រាស់ក្នុងបន្ទប់ឃុំឃាំងសមស្របទៅតាមលក្ខខ័ណ្ឌអាកាសធាតុ សម្រាប់ប្រើប្រាស់ក្នុងរយៈពេលជាប់ពន្ធនាគារ ហើយសម្ភារៈទាំងនោះត្រូវថែរក្សាឱ្យនៅក្នុងស្ថានភាពល្អ និងត្រូវផ្លាស់ប្តូរបើសិនជាចាំបាច់ ។

## ៤. នីតិវិធី:

៤.១ មន្ត្រីទទួលបន្ទុកយកអ្នកទោសចូលត្រូវធានាថា នៅពេលទទួលយកអ្នកទោសចូលក្នុងពន្ធនាគារ ត្រូវផ្តល់ឱ្យអ្នកទោសនូវឯកសណ្ឋាន និងសម្ភារៈបរិក្ខារដូចខាងក្រោម ÷

- អាវអំបោះពណ៌ខៀវឆ្នូតស ពីរ
- ខោអំបោះពណ៌ខៀវឆ្នូតស ពីរ
- ស្បែកជើងផ្ទាត់មួយសម្រាប់
- ក្រមា មួយ
- ខោខ្លីអំបោះពណ៌ខៀវ ពីរ
- អ្នកទោសស្ត្រីត្រូវទទួលបានសារុងមួយផងដែរ
- មុង មួយ
- កន្ទេលដេក មួយ
- ភួយ មួយ
- ខ្នើយកើយ មួយ
- កន្ទោរ មួយ បើសិនជាអ្នកទោសគ្មានបង្គន់
- ចានសម្លរ មួយ
- ចានបាយ មួយ
- ដបទឹកប្លាស្ទិច មួយ បើសិនជាអ្នកទោសគ្មានទឹកបរិភោគបានល្អ
- ស្លាបព្រា មួយ
- សាប៊ូ មួយដុំ, ថ្នាំដុសធ្មេញ, ច្រាសដុសធ្មេញ និងក្រាសសិតសក់
- អ្នកទោសស្ត្រីអាចទទួលបានសម្ភារៈអនាម័យផងដែរ
- ក្រណាត់កៅស៊ូភ្លៀង សំរាប់អ្នកទោសធ្វើពលកម្ម ។

៤.២ សម្ភារៈបន្ថែមទាំងឡាយដែលអាចចាំបាច់ ចំពោះលក្ខខ័ណ្ឌអាកាសធាតុ (ភួយ សំលៀកបំពាក់ការពារអាកាសធាតុត្រជាក់ ។ល។) នឹងត្រូវបានផ្តល់ឱ្យបើសិនជាសមស្រប ។

៤.៣ ប្រធានពន្ធនាគារ អាចអនុញ្ញាតឱ្យអ្នកទោសស្លៀកពាក់សំលៀកបំពាក់ផ្ទាល់ខ្លួន បើសិនជាសំលៀកបំពាក់នោះមានលក្ខណៈស្អាតស្អំ ហើយសមរម្យ ព្រមទាំងមិនប៉ះពាល់ដល់សន្តិសុខ និងសណ្តាប់ធ្នាប់ល្អរបស់ពន្ធនាគារ ។ ពិរុទ្ធជនអាចស្លៀកសំលៀកបំពាក់ផ្ទាល់ខ្លួននៅក្នុងពន្ធនាគារ ឬនៅពេលឡើងសវនាការក្នុងតុលាការ ។

៤.៤ នៅពេលអ្នកទោសផ្ទេរពីពន្ធនាគារមួយទៅពន្ធនាគារមួយទៀត ពួកគេអាចយកទៅជាមួយនូវឯកសណ្ឋាន និងសម្ភារៈទាំងអស់ដែលបានចែកឱ្យប្រើប្រាស់ ។

៤.៥ អ្នកទោសត្រូវថែរក្សារាល់ឯកសណ្ឋាន និងសម្ភារៈទាំងអស់ដែលបានចែកឱ្យប្រើប្រាស់ឱ្យបានល្អ ។ ត្រូវរក្សាទុកសម្ភារៈទាំងនោះឱ្យបានល្អ និងមិនត្រូវដោះដូរ ឬធ្វើឱ្យខូចខាតដោយចេតនាឡើយ ។

៤.៦ អ្នកទោសដែលធ្វើការបំផ្លិចបំផ្លាញសម្ភារៈដែលបានចែកឱ្យប្រើប្រាស់ដោយចេតនា នឹងត្រូវបានទទួលវិន័យ យោងទៅតាមនីតិវិធីលេខ៩ ។

៤.៧ ប្រធានពន្ធនាគារត្រូវថែរក្សាទុកបរិមាណឯកសណ្ឋាន និងសម្ភារៈប្រើប្រាស់ក្នុងបន្ទប់ឃុំឃាំងរបស់អ្នកទោសឱ្យបានគ្រប់គ្រាន់នៅក្នុងពន្ធនាគារ ។

៤.៨ អនុប្រធានពន្ធនាគារទទួលបន្ទុកផ្នែកភស្តុភារ ឬផ្នែករដ្ឋបាល ត្រូវធានាក្នុងការផ្លាស់ប្តូរឯកសណ្ឋាន និងសម្ភារៈប្រើប្រាស់ បើសិនជារហែក ឬខូចខាត ឬសត្វចង្រៃស៊ីបំផ្លាញ ។ ឯកសណ្ឋានដែលស៊ីបំផ្លាញដោយសត្វចង្រៃ ត្រូវប្រមូលដុតចោល ។

៤.៩ ឯកសណ្ឋាន សម្ភារៈប្រើប្រាស់ក្នុងបន្ទប់ឃុំឃាំង ឬសម្ភារៈផ្សេងៗទៀតរបស់អ្នកទោស ដែលបានផ្តល់ឱ្យដោយនាយកដ្ឋានពន្ធនាគារ ឬអំណោយពីអង្គការក្រៅរដ្ឋាភិបាល ឬប្រភពផ្សេងទៀត មិនត្រូវបានអនុញ្ញាតឱ្យលក់ដូរ ដោះដូរ ឬឱ្យទៅខាងក្រៅពន្ធនាគារឡើយ ។

៤.១០ អនុប្រធានពន្ធនាគារទទួលបន្ទុកផ្នែកអគ្គានុរក្ស ត្រូវធ្វើការត្រួតពិនិត្យជារៀងរាល់អាទិត្យនូវសម្ភារៈដែលបានចែកឱ្យប្រើប្រាស់ ព្រមទាំងផ្តល់របាយការណ៍ទៅឱ្យប្រធានពន្ធនាគារ ។

**ប្រធាននាយកដ្ឋានពន្ធនាគារ**

**សំគុល សុខន**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមហាផ្ទៃ**

**អគ្គនាយកដ្ឋានរដ្ឋបាល**

**នាយកដ្ឋានពន្ធនាគារ**

# នីតិវិធី លេខ ៦

| | |
|---|---|
| ចំណងជើង | **ការផ្តល់ម្ហូបអាហារសម្រាប់អ្នកទោស** |
| យោង | អនុក្រឹត្យលេខ ១១ អនក្រ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៩៥ ស្តីពីរបបជីវភាពពិរុទ្ធជន ទណ្ឌិត របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ជំពូក ២ មាត្រា ៥-១០<br>ប្រកាស លេខ២១៧ ប្រ.ក ចុះថ្ងៃទី ៣១ ខែ មិនា ឆ្នាំ១៩៩៨ ស្តីពីការគ្រប់គ្រងពន្ធនាគារ របស់ក្រសួងមហាផ្ទៃ ប្រការទី៤ ចំណុចទី៥ |
| កាលបរិច្ឆេទចេញឱ្យប្រើប្រាស់ | ភ្នំពេញ, ថ្ងៃទី............ខែ............ឆ្នាំ ២០០៣ |
| កាលបរិច្ឆេទពិនិត្យឡើងវិញ | ១២ខែ |

## ១. គោលបំណង:

ដើម្បីគូសបញ្ជាក់នូវនីតិវិធីសម្រាប់ផ្តល់អាហារដល់អ្នកទោស ។

## ២. វិសាលភាពអនុវត្ត:

នីតិវិធីនេះ អនុវត្តចំពោះអ្នកទោស និងមន្ត្រីពន្ធនាគារទាំងអស់ ។

## ៣. សេចក្តីផ្តើម:

៣.១ អ្នកទោសទាំងអស់ត្រូវបានផ្តល់ម្ហូបអាហារដែលមានជីវជាតិសមល្មមអាចថែរក្សានូវសុខភាព និងរូបរាងកាយ ។ ប្រធានពន្ធនាគារត្រូវកំណត់ពេលវេលាដែលត្រូវផ្តល់ម្ហូបអាហារ ប៉ុន្តែជាទូទៅគួរផ្តល់ម្ហូបអាហារពេលព្រឹកនៅម៉ោង ១០:៣០នាទី និងពេលល្ងាចនៅម៉ោង ៤:៣០នាទី ជារៀងរាល់ថ្ងៃ ។

៣.២ ត្រូវផ្តល់ទឹកស្អាតសម្រាប់ប្រើប្រាស់នៅគ្រប់ពេលវេលា ។

## ៤. នីតិវិធី:

៤.១ ប្រធានពន្ធនាគារត្រូវផ្តល់អាហារប្រចាំថ្ងៃដល់អ្នកទោសម្នាក់ៗ ដូចខាងក្រោម ÷

- អង្ករ ០.៥៥ គីឡូក្រាម

- ត្រីស្រស់ ឬត្រីងៀត ឬសាច់ ១៥០ ក្រាម
- បន្លែ ១៥០ ក្រាម
- ប្រេងឆា ១០ មីលីលីត្រ
- អំបិល ឬទឹកត្រី ១០ ក្រាម
- គ្រឿងផ្សំ ២០ ក្រាម

៤.២ ប្រធានពន្ធនាគារត្រូវចាត់ចែងឱ្យមានថាមពលចំអិនអាហារឱ្យបានគ្រប់គ្រាន់ចាំបាច់ សំរាប់រៀបចំចំអិនម្ហូបអាហារក្នុងពន្ធនាគារ ។

៤.៣ អ្នកទោសទាំងឡាយដែលចូលរួមក្នុងការងារពលកម្ម ត្រូវបានផ្តល់ឱ្យនូវអាហារបន្ថែមដែលកំណត់ដោយប្រធានពន្ធនាគារ ។

៤.៤ អ្នកទោសទាំងអស់នឹងទទួលបានរបបអាហារបន្ថែមលើសរបបប្រចាំថ្ងៃធម្មតា មួយជាពីរ នៅក្នុងថ្ងៃបុណ្យ ដូចតទៅ ៖

- ថ្ងៃបុណ្យចូលឆ្នាំខ្មែរ
- ថ្ងៃបុណ្យ ៧ មករា
- ថ្ងៃបុណ្យភ្ជុំបិណ្ឌ
- ថ្ងៃបុណ្យចូលឆ្នាំសកល

៤.៥ អ្នកទោសដែលមានកូននៅក្នុងពន្ធនាគារ ត្រូវផ្តល់ម្ហូបអាហារតាមលក្ខណៈសមរម្យសម្រាប់ថែទាំសុខភាព និងរូបកាយរបស់កូន ដូចដែលបានពិពណ៌នានៅក្នុងនីតិវិធីប្រតិបត្តិការសេវាសុខភាពពន្ធនាគារ ។

៤.៦ អ្នកទោសស្ត្រីដែលចិញ្ចឹមថែរក្សាទារក អាចទទួលបានអាហារបន្ថែម បើសិនជាមានការណែនាំដោយមន្ត្រីពេទ្យពន្ធនាគារដូចដែលបានពិពណ៌នានៅក្នុងនីតិវិធីប្រតិបត្តិការសេវាសុខភាពពន្ធនាគារ ។

៤.៧ ប្រធានពន្ធនាគារត្រូវផ្តល់ឱ្យអ្នកទោសនូវសាច់ជ្រូក សាច់គោ សាច់មាន់ ទា ជំនួសឱ្យសាច់ត្រី យ៉ាងហោចណាស់ម្តងក្នុងមួយសប្តាហ៍ ។

៤.៨ ប្រធានពន្ធនាគារត្រូវផ្តល់ឱ្យអ្នកទោសនូវអាហារសមរម្យ ដែលជាតម្រូវការពិសេសក្នុងតំណមអាហារ នៅពេល ៖

ក. មន្ត្រីពេទ្យពន្ធនាគារយល់ឃើញថា ចំណីអាហារបែបនេះគឺចាំបាច់សម្រាប់ហេតុផលសុខភាព ។

ខ. នៅពេលជំនឿសាសនារបស់អ្នកទោសហាមឃាត់ការបរិភោគអាហារប្រភេទនេះ

៤.៩ ប្រធានពន្ធនាគារ ប្រសិនបើមានលទ្ធភាព ត្រូវរៀបចំឱ្យមានដីសំរាប់ធ្វើផលិតកម្មស្បៀងអាហារក្នុងពន្ធនាគារ ។

៤.១០ ផលិតផលដែលបានមកពីការដាំដុះ ឬការចិញ្ចឹមសត្វនៅក្នុងពន្ធនាគារ ត្រូវបានប្រើប្រាស់ជាអាហារបន្ថែមសម្រាប់អ្នកទោស ឬក៏ដោះដូរ ឬលក់ ។ ការលក់ ឬក៏ការដោះដូរស្បៀងអាហារត្រូវកត់បញ្ចូលក្នុងបញ្ជីដោយអនុប្រធានពន្ធនាគារ ទទួលបន្ទុកផ្នែកភស្តុភា ឬរដ្ឋបាល ។

៤.១១ ប្រធានពន្ធនាគារអាចស្នើសុំការជួយឧបត្ថម្ភម្ហូបអាហារសម្រាប់អ្នកទោស ពីអង្គការក្រៅរដ្ឋាភិបាល ឬសប្បុរសជននានា ។

៤.១២ មន្ត្រីពន្ធនាគារអាចអនុញ្ញាតឱ្យអ្នកទោសទទួលម្ហូបអាហារពីខាងក្រៅពន្ធនាគារ អ្នកទោសអាចទិញដោយចំណាយថវិកាផ្ទាល់ខ្លួនរបស់គេ ឬផ្តល់ពីអ្នកមកសួរសុខទុក្ខ តែម្ហូបអាហារទាំងនោះ ត្រូវត្រួតពិនិត្យដោយមន្ត្រីពន្ធនាគារមុនពេលប្រគល់ឱ្យអ្នកទោស ។ ម្ហូបដែលមិនអនុញ្ញាតឱ្យចូលក្នុងពន្ធនាគារ ត្រូវប្រគល់ឱ្យអ្នកដែលផ្តល់ឱ្យនោះវិញ ហើយត្រូវជូនដំណឹងទៅប្រធានពន្ធនាគារអំពីមូលហេតុដែលមិនអនុញ្ញាតឱ្យយកចូលក្នុងពន្ធនាគារ ។

៤.១៣ ប្រធានពន្ធនាគារ ត្រូវស្នើសុំទៅនាយកដ្ឋានពន្ធនាគារឱ្យផ្តល់ថវិកាដើម្បីទិញម្ហូបអាហារសម្រាប់អ្នកទោសជារៀងរាល់ខែ ឱ្យទាន់ពេលវេលា ។

៤.១៤ ប្រធានពន្ធនាគារត្រូវធានាឱ្យមានចានឆ្នាំង និងសម្ភារៈចំអិនអាហារដទៃទៀត ឱ្យបានគ្រប់គ្រាន់ចាំបាច់ សម្រាប់ការរៀបចំចំអិនអាហារក្នុងពន្ធនាគារ ។

**ប្រធាននាយកដ្ឋានពន្ធនាគារ**

**សំគុល សុខន**

ព្រះរាជាណាចក្រកម្ពុជា

ក្រសួងមហាផ្ទៃ ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គនាយកដ្ឋានរដ្ឋបាល

នាយកដ្ឋានពន្ធនាគារ

# នីតិវិធី លេខ ៧

| | |
|---|---|
| ចំណងជើង | **ការគាំទ្រផ្នែកសាសនាសម្រាប់អ្នកទោស** |
| យោង | ប្រកាស លេខ២១៧ ប្រ.ក ចុះថ្ងៃទី៣១ ខែមិនា ឆ្នាំ១៩៩៨ ស្តីពីការគ្រប់គ្រងពន្ធនាគារ របស់ក្រសួងមហាផ្ទៃ ប្រការទី៤ ចំណុចទី១៦ |
| កាលបរិច្ឆេទចេញឱ្យប្រើប្រាស់ | ភ្នំពេញ,ថ្ងៃទី...........ខែ...............ឆ្នាំ ២០០៣ |
| កាលបរិច្ឆេទពិនិត្យឡើងវិញ | ១២ខែ |

## ១. គោលបំណង:

ដើម្បីគូសបញ្ជាក់នូវនីតិវិធីសម្រាប់ផ្តល់នូវការគាំទ្រផ្នែកសាសនាដល់អ្នកទោស ។

## ២. វិសាលភាពអនុវត្ត:

នីតិវិធីនេះ អនុវត្តចំពោះអ្នកទោស និងមន្ត្រីពន្ធនាគារទាំងអស់ ។

## ៣. លំនាំដើម:

៣.១ អ្នកទោសអាចប្រកាន់យកសាសនាតាមផ្លូវជម្រើសរបស់ខ្លួន ហើយពួកគេត្រូវបានផ្តល់ឱ្យនូវសម្ភារៈសមស្រប សម្រាប់ធ្វើសក្ការៈផ្នែកសាសនារបស់ខ្លួន ។

## ៤. នីតិវិធី:

៤.១ មន្ត្រីទទួលបន្ទុកយកអ្នកទោសចូល ត្រូវកត់បញ្ចូលក្នុងបញ្ជីកំណត់ហេតុ និងក្នុងសំណុំឯកសាររបស់អ្នកទោស នូវជំនឿសាសនា ប្រសិនបើមាន នៅពេលទទួលយកអ្នកទោសចូលក្នុងពន្ធនាគារ ។

៤.២ អ្នកទោសអាចប្រកាន់យកសាសនាតាមផ្លូវជម្រើសរបស់ខ្លួន ឬជាក្រុមជាមួយអ្នកទោសដទៃទៀត បើសិនជាប្រធានពន្ធនាគារយល់ឃើញថា វាមិនប៉ះពាល់ដល់សន្តិសុខ និងសណ្តាប់ធ្នាប់ល្អក្នុងពន្ធនាគារ ។

៤.៣ អ្នកទោសត្រូវបានអនុញ្ញាតឱ្យមានជាគម្ពីរ សៀវភៅធម៌ និងគ្រឿងសក្ការៈសាសនាផ្សេងៗ ដែលចាំបាច់ សម្រាប់ការប្រតិបត្តិខាងសាសនារបស់ពួកគេ ហើយដែលវាមិនប៉ះពាល់ដល់សន្តិសុខ និងសណ្តាប់ ធ្នាប់ល្អក្នុងពន្ធនាគារ ។

៤.៤ ត្រូវទទួលស្គាល់នូវតម្រូវការម្ហូបអាហារចាំបាច់របស់អ្នកទោស ដែលមានចែងនៅក្នុងតំណមសាសនារបស់ពួកគេ ( យោងទៅលើនីតិវិធីលេខ ៦) ។

៤.៥ ដោយមានការអនុញ្ញាតយល់ព្រមជាលាយលក្ខណ៍អក្សរពីប្រធាននាយកដ្ឋានពន្ធនាគារ អង្គការក្រៅរដ្ឋាភិបាល អាចចុះទៅពិនិត្យនៅពន្ធនាគារ ដើម្បីផ្តល់ជំនួយទានផ្នែកសាសនា និងឧបត្ថម្ភគាំទ្រដល់អ្នកទោសបាន ។ ពេលវេលា និងគោលបំណងនៃការចុះពិនិត្យនេះ ត្រូវមានការយល់ព្រមជាមុនពីនាយកដ្ឋានពន្ធនាគារ ហើយលិខិតអនុញ្ញាតនេះត្រូវបង្ហាញ និងប្រគល់ជូនទៅប្រធានពន្ធនាគារ ។

៤.៦ ប្រធានពន្ធនាគារត្រូវនិមន្តព្រះសង្ឃ ឬអាចារ្យចូលរួមទេសនាផ្តល់ឱវាទដល់អ្នកទោសក្នុងពន្ធនាគារជាពិសេសនៅថ្ងៃសីល ឬថ្ងៃបុណ្យសាសនារបស់ជាតិ ។

៤.៧ អ្នកទោសមិនត្រូវបានគេបង្ខំឱ្យទទួលនូវការរៀនសូត្រផ្នែកសាសនា ឬទទួលជំនួយទានទោះទេ បើសិនជាផ្ទុយពីឆន្ទៈរបស់ខ្លួន ។

**ប្រធាននាយកដ្ឋានពន្ធនាគារ**

**សំគុល សុខន**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ
អគ្គនាយកដ្ឋានរដ្ឋបាល
នាយកដ្ឋានពន្ធនាគារ

# នីតិវិធី លេខ ៨

| | |
|---|---|
| ចំណងជើង | **ការសួរសុខទុក្ខអ្នកទោស** |
| យោង | ប្រកាស លេខ២១៧ ប្រ.ក ចុះថ្ងៃទី៣១ ខែមិនា ឆ្នាំ ១៩៩៨ ស្ដីពីការគ្រប់គ្រងពន្ធនាគារ របស់ក្រសួងមហាផ្ទៃ ប្រការ៤ ចំណុចទី១០ |
| កាលបរិច្ឆេទចេញឱ្យប្រើប្រាស់ | ភ្នំពេញ, ថ្ងៃទី.............ខែ..............ឆ្នាំ ២០០៣ |
| កាលបរិច្ឆេទពិនិត្យឡើងវិញ | ១២ខែ |

## ១. គោលបំណង :

ដើម្បីគូសបញ្ជាក់នូវនីតិវិធីចូលសួរសុខទុក្ខអ្នកទោសនៅក្នុងពន្ធនាគារ ។

## ២. វិសាលភាពអនុវត្ត :

នីតិវិធីនេះ អនុវត្តចំពោះអ្នកទោស អ្នកមកសួរសុខទុក្ខ និងមន្ត្រីពន្ធនាគារ ។

## ៣. សំនាំដើម :

៣.១ អ្នកទោសទាំងអស់មានសិទ្ធិទទួលការមកសួរសុខទុក្ខពីក្រុមគ្រួសារ ឬមិត្តភក្តិ យ៉ាងតិចបំផុតបាន ១ម៉ោង ក្នុង ១សប្តាហ៍ ទៅតាមពេលវេលាកំណត់នៅក្នុងបទបញ្ជាផ្ទៃក្នុង ដែលរៀបចំដោយប្រធានពន្ធនាគារ ។

៣.២ អ្នកតំណាងស្ថានទូត ឬស្ថានកុងស៊ុលត្រូវបានផ្តល់សិទ្ធិឱ្យចូលសួរសុខទុក្ខអ្នកទោស ជាជនជាតិបរទេសរបស់ខ្លួន ដោយមានការយល់ព្រមជាមុនពីនាយកដ្ឋានពន្ធនាគារ នៅក្នុងម៉ោងធ្វើការ ។

៣.៣ អ្នកទោសជាជនភៀសខ្លួន ឬអ្នកទោសដែលគ្មានប្រទេសច្បាស់លាស់ អាចត្រូវបានទទួលការមកសួរសុខទុក្ខពីអ្នកតំណាងស្ថានទូតរបស់ប្រទេស ដែលមានការទទួលខុសត្រូវចំពោះផល

ប្រយោជន៍របស់ពួកគេ ឬពីអ្នកតំណាងអង្គការជាតិ ឬអន្តរជាតិណាមួយ ដែលមានភារកិច្ចការពារអ្នកទោសទាំងនោះ ។

៣.៤ អ្នកទោសមានសិទ្ធិទទួលការមកសួរសុខទុក្ខពីមេធាវីរបស់ខ្លួន ក្នុងនាមអ្នកតំណាងស្របច្បាប់តាមផ្លូវការ ក្នុងពេលម៉ោងធ្វើការ ។ ប្រធានពន្ធនាគារត្រូវធានាថា ការពិគ្រោះយោបល់រវាងមេធាវីជាមួយអ្នកទោស ត្រូវធ្វើឡើងដោយរក្សាការសំងាត់ ។ ការទំនាក់ទំនង និងពិគ្រោះយោបល់ ត្រូវធ្វើក្នុងលក្ខខណ្ឌសមហេតុផល ដើម្បីការពារសន្តិសុខ និងសណ្តាប់ធ្នាប់ល្អក្នុងពន្ធនាគារ ។

៣.៥ ជនដែលមានអាយុក្រោម ១៨ឆ្នាំ មិនអាចអនុញ្ញាតឱ្យចូលសួរសុខទុក្ខអ្នកទោសបានទេ លុះត្រាតែ ÷

ក- មកជាមួយមនុស្សពេញវ័យ

ខ- ក្នុងកាលៈទេសៈពិសេសដែលមានការឯកភាពដោយប្រធានពន្ធនាគារ

៣.៦ រាល់ការមកសួរសុខទុក្ខទាំងអស់ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់មន្ត្រីអនុរក្សពន្ធនាគារ ។

## ៤. នីតិវិធី :

៤.១ ការមកសួរសុខទុក្ខពីក្រុមគ្រួសារ :

ក- ប្រធានពន្ធនាគារត្រូវ ÷

- កំណត់ថ្ងៃ ម៉ោង និងរយៈពេលនៃការមកសួរសុខទុក្ខ
- ចាត់តាំងមន្ត្រីពន្ធនាគារត្រួតពិនិត្យការសួរសុខទុក្ខ
- កំណត់ចំនួនមនុស្សដែលអាចចូលសួរសុខទុក្ខក្នុងពេលនីមួយៗ
- ធ្វើតារាងពតិមាន អំពីពេលវេលា ទីកន្លែង និងបទបញ្ជាផ្ទៃក្នុង

ខ- អ្នកមកសួរសុខទុក្ខទាំងអស់ត្រូវបំពេញក្នុងពាក្យសុំចូលសួរសុខទុក្ខ ( ដែលមានភ្ជាប់នៅក្នុងទំរង់បែបបទ ៨-I ) នៅពេលដែលមកដល់ពន្ធនាគារ ។

គ- ពាក្យសុំនីមួយៗត្រូវបញ្ជូនទៅឱ្យអនុប្រធានពន្ធនាគារទទួលបន្ទុកផ្នែករដ្ឋបាល ដើម្បីជាដំណឹង ហើយសុំការយល់ព្រមពីប្រធានពន្ធនាគារ ។

ឃ-ត្រូវកត់ត្រាចូលទៅក្នុងសៀវភៅបញ្ជីនូវការមកសួរសុខទុក្ខ (ដែលមានភ្ជាប់នៅក្នុងទំរង់បែបបទ ៨-II ) ។

ង- អ្នកទោសអាចទទួលការសួរសុខទុក្ខជួបដោយផ្ទាល់បើសិនជាមានការអនុញ្ញាត ។

ច- ដោយសារកង្វល់ខាងសន្តិសុខ ឬមានសកម្មភាពដាក់វិន័យ ប្រធានពន្ធនាគារអាចបញ្ជាឱ្យមានតែការសួរសុខទុក្ខមិនផ្ទាល់ ហើយរយៈពេលនៃការសួរសុខទុក្ខមិនផ្ទាល់នេះ ត្រូវកំណត់ដោយប្រធានពន្ធនាគារ ។ សេចក្តីលំអិតនៃហេតុផលទាំងនេះត្រូវបានកត់បញ្ចូលទៅក្នុងសំណុំឯកសាររបស់អ្នកទោស និងសៀវភៅបញ្ជីនៃការមកសួរសុខទុក្ខ ។

ឆ- ការបន្ថែមពេល ឬការពន្យារពេលចំពោះការសួរសុខទុក្ខ អាចត្រូវបានឯកភាពដោយប្រធានពន្ធនាគារ បើសិនជា ÷

- មានការអាណិតអាសូរ
- អ្នកទោសមានវិបត្តិនៅក្នុងគ្រួសាររបស់ខ្លួន
- អ្នកមកសួរសុខទុក្ខធ្វើដំណើរមកពីឆ្ងាយ

ជ- អ្នកមកសួរសុខទុក្ខអាចសុំការអនុញ្ញាតពីប្រធានពន្ធនាគារ ឬមន្ត្រីដែលចាត់តាំងដោយប្រធានពន្ធនាគារ ដើម្បីយកចូលទៅក្នុងពន្ធនាគារ នូវវត្ថុទាំងឡាយដែលបានឯកភាពដោយយោងតាមនីតិវិធីលេខ១៤ ។ បើសិនជាការអនុញ្ញាតត្រូវបានផ្តល់ឱ្យ វត្ថុទាំងនោះត្រូវបានឆែកឆេរ និងកត់ចូលទៅក្នុងសៀវភៅបញ្ជីសួរសុខទុក្ខ មុនពេលប្រគល់ទៅឱ្យអ្នកទោស ហើយបន្ទាប់មកទៀត កត់ចូលក្នុងសៀវភៅបញ្ជីទ្រព្យសម្បត្តិរបស់ អ្នកទោសដោយយោងទៅតាមនីតិវិធីលេខ ១៤ ។

ឈ-មន្ត្រីទទួលបន្ទុកក្នុងការមកសួរសុខទុក្ខ អាចបដិសេធមិនអនុញ្ញាតឱ្យចូលក្នុងពន្ធនាគាររាល់អ្នកមកសួរសុខទុក្ខទាំងឡាយណាដែលស្រវឹងស្រា ឬសង្ស័យថាមានជាតិស្រា ឬក៏អ្នកដែលស្ថិតនៅក្រោមឥទ្ធិពលណាមួយដែលយើងមិនអាចដឹងបាន ឬក៏មានអាកប្បកិរិយាដែលស្តែងឡើងនូវលក្ខណៈមិនគោរពបទវិន័យ ។

ញ- ប្រធានពន្ធនាគារអាចហាមឃាត់មិនឱ្យសួរសុខទុក្ខអ្នកទោស បើសិនជាប្រធានពន្ធនាគារយល់ឃើញថា អ្នកសួរសុខទុក្ខនោះគំរាមកំហែងដល់សន្តិសុខ និងសណ្តាប់ធ្នាប់ល្អរបស់ពន្ធនាគារ ។ រយៈពេលហាមឃាត់នេះត្រូវកំណត់ដោយប្រធានពន្ធនាគារ ហើយរាយការណ៍ទៅកាន់ប្រធាននាយកដ្ឋានពន្ធនាគារដោយបញ្ជាក់អំពី ឈ្មោះអ្នកមកសួរសុខទុក្ខ ឈ្មោះអ្នកទោស ហេតុផលនៃការហាមឃាត់ និងថេរៈវេលានៃការហាមឃាត់

ហើយធ្វើកំណត់ហេតុអំពីពតិមាននេះ រក្សាទុកនៅក្នុងពន្ធនាគារ (ទំរង់បែបបទជាប់មកជាមួយ ៨-III) ។

ង- ប្រធានពន្ធនាគារអាចអនុញ្ញាតឱ្យចូលសួរសុខទុក្ខអ្នកទោស ដែលអនុញ្ញាតឱ្យសំរាកព្យាបាលនៅមន្ទីរពេទ្យ ។ ការសួរសុខទុក្ខនេះ ត្រូវគោរពទៅតាមម៉ោងពេលធ្វើការធម្មតារបស់មន្ទីរពេទ្យ ហើយត្រូវធ្វើកំណត់ហេតុ កត់បញ្ចូលទៅក្នុងសៀវភៅបញ្ជីសួរសុខទុក្ខគ្រួសារ ។

ច- រាល់អ្នកមកសួរសុខទុក្ខទាំងអស់ត្រូវបានឆែកឆេរ បើសិនជាប្រធានពន្ធនាគារយល់ឃើញថា ជាការចាំបាច់សំរាប់សន្តិសុខ និងសណ្តាប់ធ្នាប់ល្អរបស់ពន្ធនាគារ ។ ការឆែកឆេរអ្នកមកសួរសុខទុក្ខ ត្រូវបានធ្វើដោយអនុលោមតាមនីតិវិធីលេខ ១៧ ។

ឆ- អ្នកទោសទាំងអស់ត្រូវបានឆែកឆេរ មុន និង ក្រោយ ពេលឱ្យជួបសួរសុខទុក្ខគ្រួសារដោយអនុលោមតាមនីតិវិធីលេខ ១៧ ។

ឈ- មន្ត្រីពន្ធនាគារមិនត្រូវយកប្រាក់កាស ឬរបស់របរអ្វីពីអ្នកមកសួរសុខទុក្ខឡើយ ។ មន្ត្រីពន្ធនាគារណាម្នាក់ដែលបានដឹងថាអនុវត្តរបៀបនេះ នឹងត្រូវបានដាក់វិន័យដោយអនុលោមទៅតាមច្បាប់ស្តីពីសហលក្ខន្តិកៈរបស់មន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ជំពូកទី ៥ ។

៤.២ អ្នកមកសួរសុខទុក្ខជាមន្ត្រីផ្លូវការ :

ក- ជនទាំងឡាយដូចខាងក្រោម ត្រូវបានចាត់ទុកអ្នកមកសួរសុខទុក្ខជាមន្ត្រីផ្លូវការ ÷

- តំណាងព្រះមហាក្សត្រ
- សមាជិកព្រឹទ្ធសភា
- សមាជិករដ្ឋសភា
- រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
- ព្រះរាជអាជ្ញា
- ចៅក្រម
- អភិបាលខេត្ត ក្រុង
- ជនទាំងឡាយដែលមានការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- ជនណាម្នាក់ ឬអង្គការណាមួយ ដែលបានទទួលការអនុញ្ញាតជាលាយលក្ខណ៍អក្សរ ពីប្រធាននាយកដ្ឋានពន្ធនាគារ ។

ខ- ដើម្បីជាប្រយោជន៍ដល់ការរៀបចំពិធីការ សុវត្ថិភាព និងសន្តិសុខ មន្ត្រីផ្លូវការ គួរជូនដំណឹងជាមុនទៅកាន់ប្រធាននាយកដ្ឋានពន្ធនាគារ អំពីបំណងធ្វើទស្សនកិច្ចពន្ធនាគារណាមួយ ដើម្បីផ្តល់ឱកាសក្នុងការរៀបចំទទួលឱ្យបានសមរម្យ ។

គ- ត្រូវកត់បញ្ចូលទៅក្នុងសៀវភៅបញ្ជីអ្នកមកសួរសុខទុក្ខដែលជាមន្ត្រីផ្លូវការ ហើយសៀវភៅបញ្ជីនេះត្រូវរក្សាទុកនៅក្នុងពន្ធនាគារ (ទំរង់បែបបទភ្ជាប់មកជាមួយ៨-IV) ។

ឃ- អ្នកមកសួរសុខទុក្ខដែលជាមន្ត្រីផ្លូវការ ត្រូវផ្តល់ពត៌មានដោយផ្ទាល់មាត់ ឬដោយលាយលក្ខណ៍អក្សរអំពីលទ្ធផលនៃការមកសួរសុខទុក្ខ មកឱ្យប្រធានពន្ធនាគារ នៅពេលបញ្ចប់ការធ្វើទស្សនកិច្ចនីមួយៗ និងមុនពេលចាកចេញ ពីពន្ធនាគារ ។

ង- ប្រធានពន្ធនាគារត្រូវធ្វើរបាយការណ៍ អំពីលទ្ធផលនៃការសួរសុខទុក្ខរបស់មន្ត្រីផ្លូវការ ដោយភ្ជាប់មកជាមួយនូវរបាយការណ៍របស់មន្ត្រីផ្លូវការនោះ មកប្រធាននាយកដ្ឋានពន្ធនាគារ ។

**ប្រធាននាយកដ្ឋានពន្ធនាគារ**

**សំកុល សុខន**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមហាផ្ទៃ**

**អគ្គនាយកដ្ឋានរដ្ឋបាល**

**នាយកដ្ឋានពន្ធនាគារ**

# នីតិវិធី លេខ ១១

| | |
|---|---|
| ចំណងជើង | **ការងារសំរាប់អ្នកទោស ការអប់រំ និងការបណ្តុះបណ្តាលវិជ្ជាជីវៈ** |
| យោង | - ប្រកាសលេខ២១៧ ប្រ.ក ចុះថ្ងៃទី ៣១ ខែ មិនា ឆ្នាំ១៩៩៨ ស្តីពីគ្រប់គ្រងពន្ធនាគាររបស់ក្រសួងមហាផ្ទៃ ប្រការទី៤ ចំណុចទី១៥ ( ក ) ៥៧ ( ជ ) ។<br>- នីតិវិធីលេខ ២ ( ចំណាត់ថ្នាក់សន្តិសុខអ្នកទោស ) សៀវភៅក្បួនធ្វើចំណាត់ថ្នាក់សន្តិសុខ អ្នកទោស ។ |
| កាលបរិច្ឆេទចេញឱ្យប្រើប្រាស់ | ភ្នំពេញ, ថ្ងៃទី............ខែ..............ឆ្នាំ ២០០៣ |
| កាលបរិច្ឆេទពិនិត្យឡើងវិញ | ១២ខែ |

## ១. គោលបំណង:

ដើម្បីគូសបញ្ជាក់នូវនីតិវិធីដែលទាក់ទងដល់ការងារការអប់រំ និងការបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់អ្នកទោស ។

## ២. វិសាលភាពអនុវត្តៈ

នីតិវិធីនេះ អនុវត្តចំពោះអ្នកទោស និងមន្ត្រីពន្ធនាគារទាំងអស់ ។

## ៣. លំនាំដើម:

៣.១ អ្នកទោសត្រូវបានផ្តល់អោយនូវកម្មវិធីការងារ ការអប់រំ និងការបណ្តុះបណ្តាលវិជ្ជាជីវៈដែលមានប្រយោជន៍នៅក្នុងពន្ធនាគារដើម្បីផ្តល់ និងកែលំអ នូវជំនាញ និងលើកស្ទួយជីវភាពរស់នៅ និងការស្តារនីតិសម្បទារ ក្នុងការរៀបចំសំរាប់អោយពួកគេវិលត្រឡប់ចូលទៅរស់នៅក្នុងសហគមន៍វិញ ។

៣.២ មិនត្រូវដឹកនាំអោយធ្វើការនូវអ្នកទោសដូចខាងក្រោម ÷

- ពិរុទ្ធជន.
- ស្ត្រីមានផ្ទៃពោះ ៩០ ថ្ងៃ មុនពេលសំរាលទារក
- អ្នកទោសស្ត្រីសំរាលទារកបានក្រោយរយៈពេល ៩០ ថ្ងៃ
- អ្នកទោសដែលមានភាពពិការខាងស្មារតី ឬរាងកាយធ្ងន់ធ្ងរ

- អ្នកទោសដែលមានរបួស ឬជំងឺ
- អ្នកទោសដែលមានវ័យចាស់ជរា

៣.៣ ប្រធានពន្ធនាគារត្រូវធានាអោយអ្នកទោសសំរាកបានមួយថ្ងៃក្នុងមួយសប្តាហ៍ ។

៣.៤ អ្នកទោសមិនត្រូវបានគេដឹកនាំអោយធ្វើការដើម្បីបំរើផលប្រយោជន៍ឯកជនផ្ទាល់ណាមួយ ។

## ៤. នីតិវិធី :

៤.១ **ការងារសំរាប់អ្នកទោស** .

ក- ទណ្ឌិតទាំងអស់ នឹងត្រូវបានវាយតំលៃសំរាប់អោយធ្វើការដោយគណៈកម្មការធ្វើចំណាត់ថ្នាក់សន្តិសុខអ្នកទោស ក្នុងរយៈពេលពាអាទិត្យ បន្ទាប់ពីការផ្តន្ទាទោសរួចដូចដែលបានពិពណ៌នានៅក្នុងនិតិវិធីលេខ ២ ។

ខ- អ្នកទោសដែលមានជំនាញ ឬសមត្ថភាពដោយឡែកត្រូវបានចាត់អោយទៅធ្វើការនៅក្នុងផ្នែកទាំងឡាយណាដែលពួកគេអាចប្រើប្រាស់ជំនាញរបស់គេ ។

គ- អ្នកទោសដែលមានការធ្វើត្រូវទទួលផលប្រយោជន៍បន្ថែម ដូចដែលមានចែងដោយប្រធាននាយកដ្ឋានពន្ធនាគារ ។

ឃ- អនុប្រធានពន្ធនាគារទទួលបន្ទុកផ្នែកអគ្គានុរក្ស ត្រូវកត់បញ្ចូលពត៌មានស្តីពីការងាររបស់អ្នកទោសម្នាក់ៗ ទៅក្នុងសំណុំឯកសាររបស់អ្នកទោសជារៀងរាល់ខែ ធ្វើដូចនេះដើម្បីអាចធ្វើការពិចារណានៅពេលធ្វើចំណាត់ថ្នាក់សន្តិសុខអ្នកទោស ឬធ្វើសំណើដាក់ជូនសំរាប់ការបន្ធូរបន្ថយទោស និងការលើកលែងទោស ។

ង- បើសិនជាអាចមានលទ្ធភាព ប្រធានពន្ធនាគារត្រូវផ្តល់ឱកាសអោយអ្នកទោសដាំដុះផលិតផលដើម្បី ផ្គត់ផ្គង់បន្ថែមទៅលើអាហារប្រចាំថ្ងៃ ។

ច- ទីតាំង និងប្រភេទការងារត្រូវអោយមានលក្ខណៈសមស្រប ទៅនឹងចំណាត់ថ្នាក់សន្តិសុខរបស់អ្នកទោស អ្នកទោសដែលត្រូវបានធ្វើចំណាត់ថ្នាក់សន្តិសុខខ្ពស់ មិនត្រូវដឹកនាំអោយធ្វើការនៅខាងក្រៅបរិវេណពន្ធនាគារទេ ដូចដែលបានចែងនៅក្នុងសៀវភៅក្បួនធ្វើចំណាត់ថ្នាក់សន្តិសុខអ្នកទោស ។

ឆ- អ្នកទោសណាដែលបដិសេធមិនព្រមធ្វើការ ត្រូវដាក់វិន័យដោយអនុលោមទៅតាមនីតិវិធីលេខ៩ ។

) **ការអប់រំ និងការបណ្តុះបណ្តាលវិជ្ជាជីវៈ**

ក- ប្រធានពន្ធនាគារត្រូវផ្តល់ការបណ្តុះបណ្តាលលេខនព្វន្ត និងអក្សរសាស្ត្រ សំរាប់អ្នកទោសទាំងអស់ ដោយផ្តោតជាពិសេសទៅលើអ្នកទោសក្រោម ១៨ ឆ្នាំ ។

ខ- ប្រធានពន្ធនាគារត្រូវប្រើប្រាស់អ្នកទោស ដែលត្រូវបានកត់សំគាល់ឃើញថា មានជំនាញសមស្រប ដើម្បីផ្តល់នូវកម្មវិធីអប់រំ និង ឬ កម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ ។

គ- ប្រធានពន្ធនាគារត្រូវបង្កើតទំនាក់ទំនង ជាមួយបណ្តាក្រុមអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក ដើម្បីលើកទឹកចិត្តអោយពួកគេផ្តល់នូវកម្មវិធីអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈដល់ពន្ធនាគារ ។

ឃ- នៅពេលក្រុមអង្គការក្រៅរដ្ឋាភិបាលមានបំណងចង់ផ្តល់នូវកម្មវិធីនានា ប្រធានពន្ធនាគារត្រូវធ្វើពាក្យសុំទៅប្រធាននាយកដ្ឋានពន្ធនាគារហើយពាក្យស្នើសុំនេះត្រូវមានពតិមានដូចតទៅ ÷

- ឈ្មោះរបស់បុគ្គលដែលធ្វើការផ្តល់នូវកម្មវិធី
- សមត្ថភាព និងលក្ខណៈសម្បត្តិរបស់បុគ្គលដែលផ្តល់កម្មវិធី .
- ការបរិច្ឆេទ ពេលវេលា រយៈពេល និងគោលបំណងរបស់កម្មវិធី .

ង- នៅពេលដែលមានការឯកភាពអោយក្រុមអង្គការក្រៅរដ្ឋាភិបាលផ្តល់នូវកម្មវិធីអប់រំ ឬបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវធ្វើការខិតខំប្រឹងប្រែងដើម្បីធានាអោយកម្មវិធីទទួលបានជោគជ័យដោយធ្វើការសហការជាមួយក្រុមអង្គការក្រៅរដ្ឋាភិបាល ក្នុងការផ្តល់អោយអ្នកទោសចូលរួមយ៉ាងពេញលេញ ។

ឆ- ប្រធានពន្ធនាគារត្រូវធានាអោយអ្នកទោសទាំងអស់ចូលរួមនៅ ក្នុងកម្មវិធីអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ហើយត្រូវធ្វើកំណត់ហេតុកត់ចូលក្នុងសំណុំឯកសារ របស់អ្នកទោស ។

**ប្រធាននាយកដ្ឋានពន្ធនាគារ**

**សំកុល សុខន**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ

អគ្គនាយកដ្ឋានរដ្ឋបាល

នាយកដ្ឋានពន្ធនាគារ

# នីតិវិធី លេខ ៣៤

| | |
|---|---|
| ចំណងជើង | **កូនរបស់អ្នកទោសស្ត្រី និងអ្នកទោសស្ត្រីមានផ្ទៃពោះនៅក្នុងពន្ធនាគារ** |
| យោង | - អនុក្រិត្យលេខ ១១ មាត្រាទី៦ ៩ ១០ និង ១៣<br>- ប្រកាសលេខ២១៧ ប្រ.ក ចុះថ្ងៃទី៣១ ខែមិនា ឆ្នាំ១៩៩៨ ស្តីពីការគ្រប់គ្រងពន្ធនាគារ របស់ក្រសួងមហាផ្ទៃ ប្រការ ៤ ចំណុចទី១៨ ពី (ក) ដល់ (ត) ។<br>- នីតិវិធីប្រតិបត្តិការសេវាសុខភាពពន្ធនាគារ ។ |
| កាលបរិច្ឆេទចេញឱ្យប្រើប្រាស់ | ភ្នំពេញ, ថ្ងៃទី ..........ខែ ...........ឆ្នាំ ២០០៣ |
| កាលបរិច្ឆេទពិនិត្យឡើងវិញ | ១២ខែ |

## ១. គោលបំណង :

ដើម្បីគូសបញ្ជាក់នូវនីតិវិធីសំរាប់គ្រប់គ្រង និងថែទាំអ្នកទោសស្ត្រីដែលមានផ្ទៃពោះ និងកូនអ្នកទោសស្ត្រីនៅក្នុងពន្ធនាគារ ។

## ២. វិសាលភាពអនុវត្ត :

នីតិវិធីនេះ អនុវត្តចំពោះមន្ត្រីពន្ធនាគារទាំងអស់ ។

## ៣. លំនាំដើម :

៣.១ ម្តាយត្រូវបានផ្តល់ឱ្យនូវឱកាសជាច្រើនដើម្បីអនុវត្ត និងអភិវឌ្ឍន៍នូវការទទួលខុសត្រូវជាមាតា ព្រមទាំងភារកិច្ច និងជំនាញដើម្បីបង្កើននូវសក្តានុពលសម្រាប់ការអភិវឌ្ឍន៍ដ៏ត្រឹមត្រូវរបស់កូន និងកាត់បន្ថយនូវការប្រព្រឹត្តិបទល្មើសជាថ្មីឡើងវិញរបស់ម្តាយ ។

៣.២ កូនអាចរស់នៅជាមួយម្តាយក្នុងពន្ធនាគាររហូតដល់អាយុ ៦ឆ្នាំ ប្រសិនបើមានប្រយោជន៍ដ៏ល្អដល់ក្មេងនេះ ។

## ៤ នីតិវិធី :

៤.១ ប្រធានពន្ធនាគារត្រូវធ្វើយ៉ាងណាឱ្យមានវិធានការសមស្រប ដើម្បីធានាដល់សុខភាព និងសុខុមាលភាពរបស់អ្នកទោស និងទារកក្នុងអំឡុងពេលមានផ្ទៃពោះ និងក្រោយពេលសំរាលទារក ។ វិធានការទាំងនេះរួមមាន :

- ផ្តល់អាហារឱ្យមានតុល្យភាព (រួមមាន នៅពេលបំបៅកូនដោយទឹកដោះម្តាយ) ។
- ជួយផ្តល់សេវាពិនិត្យសុខភាព
- ឱ្យម្តាយសំរាលទារកក្នុងមន្ទីរពេទ្យខាងក្រៅ
- ផ្តល់សំលៀកបំពាក់បានសមស្របសម្រាប់ទារក

៤.២ មន្ត្រីពេទ្យពន្ធនាគារត្រូវពិនិត្យតាមដានសុខភាពរបស់អ្នកទោសដែលមានផ្ទៃពោះជាប្រចាំខែ ក្នុងអំឡុងពេល៣ខែដំបូង ២អាទិត្យម្តង ក្នុងអំឡុងពេលត្រីមាសទី២ ហើយជាប្រចាំសប្តាហ៍ ក្នុងអំឡុងពេលត្រីមាសទី៣ ។ ក្នុងករណីមានការព្រួយបារម្ភដល់បញ្ហាសុខភាពធ្ងន់ធ្ងរណាមួយ ត្រូវរាយការណ៍ជូនប្រធានពន្ធនាគារដើម្បីធានាផ្តល់ការព្យាបាលសុខភាពនៅពេលចាំបាច់ ។

៤.៣ អ្នកទោសស្ត្រីដែលមានផ្ទៃពោះ មិនត្រូវឱ្យធ្វើការក្នុងរយៈពេល ២ខែ មុនពេលសំរាលកូន និងរយៈ ពេល ៣ខែ ក្រោយពេលសំរាលកូន ។

៤.៤ នៅពេលអ្នកទោសស្ត្រីសំរាលទារកក្នុងពន្ធនាគារ មន្ត្រីពេទ្យពន្ធនាគារត្រូវចូលរួមជួយក្នុងការសំរាលទារក ។

៤.៥ បើសិនជាអ្នកទោសស្ត្រីសំរាលទារកក្នុងពន្ធនាគារ មិនត្រូវចុះទីកន្លែងកំណើតនៅក្នុងពន្ធនាគារទៅក្នុងបញ្ជីកំណើតរបស់ទារកនោះទេ ។

៤.៦ នៅពេលកូនស្នាក់នៅជាមួយម្តាយក្នុងពន្ធនាគារ ម្តាយត្រូវទទួលខុសត្រូវចំពោះការថែទាំ និងសុវត្ថិភាពរបស់កូន ។

៤.៧ នៅពេលមានការបែងចែកការងារឱ្យអ្នកទោសស្ត្រីធ្វើ ប្រធានពន្ធនាគារត្រូវធានាថា ម្តាយរបស់កូនមានពេលវេលាគ្រប់គ្រាន់ ដើម្បីផ្តល់ការថែទាំ និងសុវត្ថិភាពសម្រាប់កូនរបស់គេ ។

៤.៨ ប្រធានពន្ធនាគារត្រូវធានាថា កូនដែលស្នាក់នៅក្នុងពន្ធនាគារជាមួយម្តាយ ត្រូវផ្តល់ឱ្យដូចជា :

- ការថែទាំសុខភាព ដោយយោងទៅតាមនីតិវិធីប្រតិបត្តិការសេវាសុខភាពពន្ធនាគារ ។
- សំលៀកបំពាក់សមរម្យ
- ផ្តល់ម្ហូបអាហារឱ្យមានតុល្យភាព
- ផ្តល់ឱ្យមានការអភិវឌ្ឍន៍ខាងកាយសម្បទា និងចំណេះដឹង

៤.៩ ប្រធានពន្ធនាគារត្រូវធ្វើការទំនាក់ទំនងជាមួយបណ្តាអង្គការក្រៅរដ្ឋាភិបាល និងបណ្តាក្រសួងដែលមានការពាក់ព័ន្ធទាំងឡាយ ដើម្បីជួយសម្រួលនូវតម្រូវការផ្សេងៗក្នុងចំណុច ៤.៨ ខាងលើ ។

៤.១០ នៅពេលដែលអ្នកទោសស្ត្រីមិនមានលទ្ធភាពគ្រប់គ្រាន់ ក្នុងការថែទាំកូនរបស់ខ្លួននៅក្នុងពន្ធនាគារ ដោយហេតុផលណាមួយ ប្រធានពន្ធនាគារបន្ទាប់ពីខិតខំប្រឹងប្រែងជួយដល់អ្នកទោសនោះ ក្នុងការផ្តល់ការថែទាំឱ្យបានគ្រប់គ្រាន់ ត្រូវរៀបចំការទាក់ទងជាមួយក្រសួង ឬក៏សមាជិកគ្រួសារសាច់ញាតិរបស់អ្នកទោស ដើម្បីមើលថែទាំទារកនោះនៅខាងក្រៅពន្ធនាគារ ។

៤.១១ ក្នុងករណីដែលកូនអ្នកទោសត្រូវបានយកចេញពីពន្ធនាគារ ប្រធានពន្ធនាគារត្រូវផ្តល់របាយការណ៍ជាលាយលក្ខណ៍អក្សរទៅឱ្យប្រធាននាយកដ្ឋានពន្ធនាគារ ។

៤.១២ កូនរបស់អ្នកទោស ដែលស្នាក់នៅក្នុងពន្ធនាគារ អាចចេញ-ចូលពន្ធនាគារបានដោយមានការឯកភាពយល់ព្រមពីប្រធានពន្ធនាគារ និងដោយមានអ្នកទៅជាមួយ ។ ត្រូវខិតខំប្រឹងប្រែងយ៉ាងណាដើម្បីធានាឱ្យកូនរបស់អ្នកទោសបានទទួលការជួបយ៉ាងទៀងទាត់ជាមួយសមាជិកគ្រួសារ ឬសាច់ញាតិ ។

៤.១៣ កូនអ្នកទោសអាចត្រូវបានឆែកឆេរដោយមន្ត្រីពន្ធនាគារភេទស្រី ឬមន្ត្រីពេទ្យពន្ធនាគារដោយមានម្តាយនៅជាមួយផង ។

៤.១៤ នៅពេលកូនរបស់អ្នកទោសមានអាយុ ៦ឆ្នាំ ប្រធានពន្ធនាគារត្រូវជួយសម្រួលយកកូននេះចេញពីពន្ធនាគារ ដោយធ្វើការពិគ្រោះយោបល់ជាមួយម្តាយ សមាជិកគ្រួសារ និងបណ្តាអ្នកតំណាងក្រសួងដែលពាក់ព័ន្ធ ដើម្បីជ្រើសរើសអ្នកថែទាំកូននេះឱ្យបានសមស្រប ។

៥ ក្នុងករណីដែលកូនស្លាប់នៅពេលស្នាក់នៅក្នុងពន្ធនាគារជាមួយម្តាយ ប្រធានពន្ធនាគារត្រូវចាត់ការជាបន្ទាន់ទៅតាមនីតិវិធីលេខ ២០ ។

**ប្រធាននាយកដ្ឋានពន្ធនាគារ**

**សំគុណ សុខន**

# ឧបសម្ព័ន្ធទី២

# របាយការណ៍ស្តីពីសិទ្ធិមនុស្ស នៅកម្ពុជា ឆ្នាំ ២០២១

## សេចក្តីសង្ខេបរួម

## ស្ថានភាពពន្ធនាគារ និងមណ្ឌលឃុំខ្លួន

ស្ថានភាពពន្ធនាគារមានសភាពយ៉ាប់ខ្លាំង ហើយក្នុងករណីជាច្រើន គំរាមកំហែងដល់អាយុជីវិតថែមទៀតផង ។

**ទិដ្ឋភាពទីកន្លែង៖** ការមានអ្នកទោសកកកុញច្រើនគឺជាបញ្ហាមួយ។ យោងតាមក្រសួងមហាផ្ទៃ គិតត្រឹមខែកក្កដា មានអ្នកទោស និងអ្នកជាប់ពន្ធនាគារ ចំនួនប្រមាណជាង ៣៩ ០០០ នាក់ ដោយមាន ២ ៥៧១ នាក់ជានារី នៅក្នុងពន្ធនាគារចំនួន ២៩ ដែលត្រូវបានបង្កើតឡើងសម្រាប់ដាក់អ្នកជាប់ពន្ធនាគារ និងអ្នកជាប់ឃុំត្រឹមតែចំនួន ១១ ០០០ នាក់ប៉ុណ្ណោះ ។ ក្រសួងបាននិយាយថា «សង្គ្រាមប្រឆាំងនឹងគ្រឿងញៀន» របស់រដ្ឋាភិបាលបានធ្វើឱ្យពន្ធនាគារកាន់តែចង្អៀតខ្លាំងឡើង ដោយមានអ្នកទោសគ្រឿងញៀនប្រមាណ ២២ ០០០ នាក់។

នៅក្នុងពន្ធនាគារភាគច្រើន គ្មានការដាក់នៅដាច់ពីគ្នាទេ រវាងអ្នកទោសជាមនុស្សពេញវ័យ និងអ្នកទោសជាកុមារ (រួមទាំងកុមារដែលរស់នៅជាមួយម្តាយជាអ្នកទោស) រវាងអ្នកទោសធ្ងន់ និងអ្នកទោសស្រាល ឬអ្នកឃុំមុនសវនាការទេ។ បើយោងតាម អង្គការក្រៅរដ្ឋាភិបាល ដោយគិតមកត្រឹមខែកក្កដា មានអ្នកទោសជាស្ត្រីមានផ្ទៃពោះចំនួន ២៥ នាក់ ហើយមានកូនចំនួន ៧៤ នាក់រស់នៅជាមួយម្តាយ។ នៅចន្លោះពីខែមករាដល់ខែកក្កដា នាយកដ្ឋានពន្ធនាគារបានរាយការណ៍ពីចំនួនអ្នកទោសស្លាប់ ក្នុងពន្ធនាគារចំនួនយ៉ាងតិច ១២០ នាក់។

របបអាហារសម្រាប់អ្នកជាប់ពន្ធនាគារ និងរបស់ចាំបាច់ផ្សេងៗទៀត តែនៅតែមិនគ្រប់គ្រាន់ទេ នៅក្នុងករណីជាច្រើន។ ជាញឹកញាប់ សមាជិកគ្រួសារធ្វើការសូកប៉ាន់ខ្លះ ដើម្បីផ្តល់បន្ថែមដល់អ្នកទោស។ អ្នកសង្កេតការណ៍បានបន្តរាយការណ៍ថា របបសម្រាប់ទិញអាហារអ្នកទោស ពេលខ្លះ ត្រូវបានកឹបកេងយកដោយអាជ្ញាធរ ដែលជាការធ្វើឱ្យមានកង្វះអាហារូបត្ថម្ភកាន់តែខ្លាំង និងជំងឺអ្នកទោសមានកាន់តែច្រើន។ អាជ្ញាធរមិនបានផ្តល់តួលេខចុងក្រោយស្តីពីចំនួនពន្ធនាគារដែលក្នុងនោះអ្នកទោសមានទឹកស្អាតប្រើប្រាស់ទេ ថ្វីបើ គិតមកដល់ឆ្នាំ ២០១៦ មានពន្ធនាគារតែចំនួន ១៨ ទេ ក្នុងចំណោមពន្ធនាគារចំនួន ២៩ មានផ្តល់ទឹកស្អាត។ ពន្ធនាគារគ្មានកន្លែងគ្រប់គ្រាន់សម្រាប់អ្នកទោសពិការរាងកាយ ឬមានបញ្ហាខួរក្បាលទេ។ អង្គការមិនមែនរដ្ឋាភិបាល បានចោទប្រកាន់ថា អ្នកគ្រប់គ្រងពន្ធនាគារប្រព្រឹត្តមិនស្មើគ្នាលើអ្នកទោស ដូចជាករណីផ្តល់ការអនុញ្ញាតឱ្យអ្នកចូលសួរសុខទុក្ខ ការប្តូរទៅបន្ទប់ល្អ និងឱកាសចេញពីបន្ទប់ នៅពេលថ្ងៃ ចំពោះអ្នកទោសដែលគ្រួសាររបស់គេមានលុយសូក ហើយមានការរឹតត្បិតច្រើនលើអ្នកទោសការពារសិទ្ធិមនុស្ស និងអ្នកទោសនយោបាយ។ អង្គការក្រៅរដ្ឋាភិបាល បានរាយការណ៍ថា មានការប្រើប្រាស់គ្រឿងញៀននៅក្នុងពន្ធនាគារយ៉ាងច្រើន ដែលគេអាចធ្វើទៅបានដោយសូកប៉ាន់មន្ត្រីពន្ធនាគារ។

កម្ពុជាមានមជ្ឈមណ្ឌលបន្សាបថ្នាំញៀនរបស់រដ្ឋាភិបាលចំនួន ១១ មាន ៣ ទៀតជារបស់ឯកជន និង ៤ ជារបស់អង្គការក្រៅរដ្ឋាភិបាល ។ អ្នកសង្កេតការណ៍ ភាគច្រើនបានយល់ស្របថា ភាគច្រើននៃអ្នកដែលត្រូវបានយកមកឃុំនៅទីនេះ គឺត្រូវបានឃុំដោយបង្ខំ ឬផ្ញើនៅមណ្ឌលដោយសមត្ថកិច្ច ឬសមាជិកគ្រួសារ ដោយគ្មានឆ្លងកាត់ដំណើរការក្តីត្រឹមត្រូវទេ។ យោងតាមអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន គ្មានអ្នកដែលជាប់នៅក្នុងមណ្ឌលមានអាយុក្រោម ១៨ ឆ្នាំទេ។ អាជ្ញាធរបាននិយាយថា គិតពីខែមករាដល់ខែមិនា អ្នកញៀនថ្នាំចំនួន ៩ ២៦៧ នាក់បានទទួលការព្យាបាលនៅក្នុងមជ្ឈមណ្ឌលទាំងនេះ។ អ្នកសង្កេតការណ៍ បានកត់សំគាល់ឃើញថា បុគ្គលិកក្នុងមណ្ឌល ជាញឹកញាប់ ប្រើវិធីបង្ខំ ដើម្បី «គ្រប់គ្រង» ទៅលើអ្នកជាប់ក្នុងនោះ និងឱ្យហាត់ប្រាណយ៉ាងខ្លាំង ។ ជាញឹកញាប់ អ្នកញៀនថ្នាំផ្សេងទៀតបានប្រើហិង្សា។ ឈ្មោះ មួយ សំណាង បានស្លាប់នៅមន្ទីរពេទ្យបន្ទាប់ពីរងការវាយដំដោយអ្នកញៀនថ្នាំងទៀត។ មន្ត្រីនគរបាលម្នាក់បាននិយាយថា «មេ» នៃបណ្តាញជនល្មើសនៅកន្លែងនោះ បានបញ្ជាកូនចៅឱ្យវាយ និងធ្វើទារុណកម្មលើ មួយ បន្ទាប់ពីគាត់បានទៅដល់មជ្ឈមណ្ឌលភ្លាម។

បន្ទាប់ពីជំងឺកូវីដ ១៩ រាលដាលនៅទូទាំងប្រទេស បន្ទាប់ពីផ្ទុះនៅខែកុម្ភៈ គេបានដាក់ការរឹតត្បិតខ្លាំងលើការចេញចូលពន្ធនាគារដល់សមាជិកគ្រួសារ មេធាវី មន្ត្រីកុងស៊ុល និងតំណាងមកពីខាងក្រៅផ្សេងទៀត។ មេធាវីការពារមេដឹកនាំសហជីព លោក រ៉ុង ឈុន មិនអាចទាក់ទងបានជាមួយកូនក្តីរបស់គាត់ទេ ហើយមិនដឹងថា លោក ឈុន មានជំងឺ ឬក៏បានចាក់វ៉ាក់សាំងទេ រហូតទាល់តែព្រះរាជអាជ្ញាប្រាប់ទៅអ្នកចូលរួមក្នុងសវនាការបើកចំហក្នុងតុលាការ នៅថ្ងៃទី ៨ មិថុនា ។ មានសេចក្តីរាយការណ៍ថា មានការឆ្លងកូវីដច្រើនក្នុងចំណោមអ្នកទោស មុនពេលអាជ្ញាធរធ្វើការចាក់វ៉ាក់សាំងការពារជូន ។ គិតមកត្រឹមខែវិច្ឆិកា អាជ្ញាធរបានរឹតត្បិតខ្លាំងលើការចេញចូលរបស់អ្នកខាងក្រៅ។ បើតាមមន្ត្រីធនាគារ គិតមកត្រឹមខែកញ្ញា រដ្ឋបានចាក់វ៉ាក់សាំងកូវីដ ១៩ ដល់អ្នកទោសចំនួន ៩០% នៅទូទាំងប្រទេស។

<u>រដ្ឋបាល</u>៖ អាជ្ញាធរមិនបានប្រើវិធីផ្សេងក្រៅពីការដាក់គុកទេ។ អ្នកទោសអាចដាក់បណ្តឹងស្តីពីការរំលោភបំពានទៅតុលាការ តាមរយៈមេធាវី តែអ្នកទោសមួយចំនួនធំគ្មានលទ្ធភាពរកមេធាវីតំណាងផ្លូវច្បាប់ឡើយ។ រដ្ឋាភិបាលបាននិយាយថា ខ្លួនបានស៊ើបអង្កេតលើពាក្យបណ្តឹង ហើយតាមមើលស្ថានភាពពន្ធនាគារ និងមជ្ឈមណ្ឌលឃុំឃាំងតាមរយៈអគ្គនាយកដ្ឋានពន្ធនាគាររបស់ក្រសួងមហាផ្ទៃ ដែលធ្វើរបាយការណ៍ប្រចាំឆមាសស្តីពីការគ្រប់គ្រងពន្ធនាគារ។ អគ្គនាយកដ្ឋានពន្ធនាគារ មិនបញ្ចេញរបាយការណ៍នេះទេ ទោះបីជាអង្គការសង្គមស៊ីវិលបានធ្វើការស្នើសុំជាញឹកញាប់ក្តី។

មុនពេលមានវិធានការកូវីដ ១៩ នៅខែកុម្ភៈ អាជ្ញាធរតែងតែអនុញ្ញាតឲ្យអ្នកទោសជួបអ្នកចូលជួប តែអង្គការផ្នែកសិទ្ធិមនុស្សបានបញ្ជាក់ថា ពេលខ្លះ គ្រួសារត្រូវសូកមន្ត្រីដើម្បីអាចចូលជួបបាន។ មានរបាយការណ៍គួរឱ្យជឿទុកចិត្តបានថា ជាញឹកញាប់ មន្ត្រីបានទាមទារប្រាក់សំណូក មុននឹងអនុញ្ញាតអ្នកជាប់ពន្ធនាគារ ចូលរួមការជំនុំជម្រះក្តី ឬសវនាការឧទ្ធរណ៍ និងមុនពេលដោះលែងអ្នកជាប់ពន្ធនាគារ ដែលបានអនុវត្តទោសជាប់ពន្ធនាគាររបស់ខ្លួនពេញលេញហើយនោះ ឬមុនពេលអនុញ្ញាតឱ្យគេចេញពីមន្ទីរឃុំឃាំងរបស់គេ ។

ការតាមដានដោយឯករាជ្យ៖ ដោយមានលក្ខខណ្ឌជាមុន និងការដាក់កំហិត ជាទូទៅ រដ្ឋាភិបាលបន្តអនុញ្ញាតក្រុមសិទ្ធិមនុស្សអន្តរជាតិ និងក្រុមសិទ្ធិមនុស្សក្នុងស្រុក ដូចជាគណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ និងការិយាល័យឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (UNHCHR) ចូលមើលពន្ធនាគារ និងផ្តល់ការបណ្តុះបណ្តាលសិទ្ធិមនុស្សដល់ឆ្មាំពន្ធនាគារ ថ្វីបើវិធានការកូវីដប៉ះពាល់ដល់ដំណើរការនេះ។ ។ អង្គការមិនមែនរដ្ឋាភិបាលមួយចំនួន បានរាយការណ៍ថា ជួនកាល ការសហការពីអាជ្ញាធរដែនដីនៅមានកម្រិត ដែលជាការធ្វើឱ្យមានការលំបាកសម្រាប់ចូលជួបអ្នកជាប់ឃុំដែលមិនទាន់ទទួលការជំនុំជម្រះក្តី ។

ក្រសួងមហាផ្ទៃតម្រូវឱ្យមេធាវី អ្នកត្រួតពិនិត្យសិទ្ធិមនុស្ស និងអ្នកសួរសុខទុក្ខដទៃទៀតសុំការអនុញ្ញាតមុននឹងចូលជួបអ្នកជាប់ពន្ធនាគារ ដោយច្រើនតែតម្រូវឱ្យសុំពីអង្គភាពច្រើនកន្លែង អាស្រ័យលើករណីមួយៗ ហើយក្នុងករណីខ្លះ រដ្ឋាភិបាលតំរូវអោយអង្គការមិនមែនរដ្ឋាភិបាលចុះហត្ថលេខាលើអនុស្សារណៈនៃការយោគយល់ ជាផ្លូវការ ដោយបញ្ជាក់ពី «តួនាទី» របស់គេ ក្នុងពេលទៅមើលអ្នកទោស។ ជារួម អាជ្ញាធរបញ្ឈប់ការសួរសុខទុក្ខអ្នកទោស បន្ទាប់ពីជំងឺកូវីដបានរាលដាលទូទាំងប្រទេស នៅខែកុម្ភៈ។ ថ្វីបើអង្គការក្នុងស្រុកដែលធ្វើការតាមដានដោយឯករាជ្យ អាចជួបជាលក្ខណៈឯកជនជាមួយអ្នកទោសក្តី តែអ្នកខ្លះក៏មិនអាចជួបបានទេ។ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកផ្នែកសិទ្ធិមនុស្សមួយដែលជាធម្មតា ផ្តល់ការថែទាំសុខភាពដល់អ្នកទោស បាននិយាយថា ពេលខ្លះ រដ្ឋាភិបាលមិនអនុញ្ញាតឱ្យគេចូលមើលអ្នកទោសដែលកាត់ក្តីហើយ និងជាសមាជិកនៃគណបក្សប្រឆាំងឡើយ។ អង្គការមួយទៀតបាននិយាយថា រដ្ឋាភិបាលបានចោទខ្លួនថា មានគំនិតលំអៀងនយោបាយ ហើយប្រើការទៅមើលអ្នកទោស ដើម្បីជំរុញអ្នកទោសនយោបាយឱ្យកាន់តែផ្តើនខ្លាំងឡើង។ តំណាងនៃការិយាល័យស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សបាននិយាយថា ធម្មតា ខ្លួនអាចជួបជាលក្ខណៈឯកជននៅពេលសម្ភាសន៍អ្នកជាប់ពន្ធនាគារពិសេសណាម្នាក់។

# ឧបសម្ព័ន្ធទី៣



# ទំហំដែលផ្ទុកអ្នកទោសបាន ឆ្នាំ២០១២: ការវិវឌ្ឍន៍នៃរបាយកា
# ស្តីពីភាពចង្អៀតណែនរបស់អ្នកទោស នៅក

របាយការណ៍ លីកាដូ
ខែកក្កដា ឆ្នាំ២០១២

សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ
LICADHO
Cambodian League for the
Promotion and Defense of Human Rights

# ទំហំដែលផ្ទុកអ្នកទោសបាន ឆ្នាំ២០១២: ការវិវឌ្ឍន៍ នៃរបាយការណ៍ស្តីពីភាពចង្អៀតណែនរបស់អ្នក ទោស នៅកម្ពុជា

---

របាយការណ៍ លីកាដូ

ខែកក្កដា ឆ្នាំ២០១២


សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស លីកាដូ

**LICADHO**

CAMBODIAN LEAGUE FOR THE PROMOTION
AND DEFENSE OF HUMAN RIGHTS

# សេចក្ដីផ្ដើម

នេះគឺជារបាយការណ៍ភាគទីបី នៃរបាយការណ៍ប្រចាំឆ្នាំរបស់អង្គការលីកាដូ ស្ដីពីភាពចង្អៀតណែននៅពន្ធនាគារក្នុងប្រទេសកម្ពុជា[១]។

អង្គការលីកាដូដំបូងបានរាយការណ៍អំពីកំណើនជនជាប់ឃុំឆាប់រហ័ស នៅក្នុងប្រព័ន្ធគ្រប់គ្រងពន្ធនាគារក្នុងឆ្នាំ២០១០ នៅពេលពន្ធនាគាររបស់ជាតិបានផ្ទុកជនជាប់ឃុំពេញទំហំផ្ទុករបស់ខ្លួនស្មើនឹង ១៦៧% ហើយចំនួនជនជាប់ឃុំមានការកើនឡើងប្រហែល ១៤% ជារៀងរាល់ឆ្នាំ។

នៅខែឧសភា ឆ្នាំ២០១១ អត្រាអ្នកជាប់ឃុំនៅតាមពន្ធនាគារទូទាំងប្រទេស មានចំនួនកើនឡើងរហូតដល់ ១៧៩% ចំណែកពន្ធនាគារចំនួន ១៨ ដែលអង្គការលីកាដូ[២] បានឃ្លាំមើលបានផ្ទុកជនជាប់ឃុំពេញទំហំផ្ទុករបស់ខ្លួនស្មើនឹង ១៨១%។ កំណើនជនជាប់ឃុំនៅតាមពន្ធនាគារ ដែលអង្គការលីកាដូ បានឃ្លាំមើលបានកើនឡើងជាមធ្យមប្រហែល ១៣% ក្នុងមួយឆ្នាំៗ ហើយប្រព័ន្ធគ្រប់គ្រងពន្ធនាគារកំពុងរំកិលទៅរកភាពចង្អៀតណែនបំផុតនៅលើពិភពលោកនៅឆ្នាំ២០១៩ ខាងមុខនេះ។ ជាមួយគ្នានេះ មានភស្ដុតាងបង្ហាញថា អាជ្ញាធរមិនទាន់បានចាត់វិធានការជាក់ស្ដែង ដើម្បីកាត់បន្ថយការពឹងពាក់ហួសហេតុទៅលើពន្ធនាគារ ដែលជាការដាក់ទណ្ឌកម្មតាមផ្លូវតុលាការមួយបែប ក្នុងដំណាក់កាលបឋម។ ឧទាហរណ៍ ពន្ធនាគារទាំងឡាយនៅតែកំពុងត្រូវបានប្រើប្រាស់ជាឃ្លាំងសម្រាប់ផ្ទុកអ្នកប្រើប្រាស់គ្រឿងញៀន ពិរុទ្ធជនដែលបានប្រព្រឹត្តបទល្មើសតូចតាច និងជនក្រីក្រដែលគ្មានលទ្ធភាពបង់ប្រាក់ពិន័យក្នុងរឿងព្រហ្មទណ្ឌ។

---

[១] សូមមើល គុកធំ-ចង្អៀតខ្លាំង: ភាពចង្អៀតណែនរបស់អ្នកទោសនៅកម្ពុជា និងក្ដីស្រមៃនៃមណ្ឌលអប់រំកែប្រែទី៤ របាយការណ៍លីកាដូ ខែកក្កដា ឆ្នាំ២០១០ និង 'ទំហំដែលផ្ទុកអ្នកទោសបានឆ្នាំ២០១១: របាយការណ៍ថ្មីៗ ស្ដីពីភាពចង្អៀតណែនរបស់អ្នកទោសនៅកម្ពុជា' របាយការណ៍លីកាដូ ខែកក្កដា ឆ្នាំ២០១១។

[២] ពន្ធនាគារទាំងនេះ: មានមណ្ឌលអប់រំកែប្រែទី១ មណ្ឌលអប់រំកែប្រែទី២ មណ្ឌលអប់រំកែប្រែទី៣ មណ្ឌលអប់រំកែប្រែទី៤ ពន្ធនាគារប៉េ ហ្ស៊ី ពន្ធនាគារនៅតាខ្មៅ ពន្ធនាគារនៅព្រះសីហនុ ពន្ធនាគារនៅកំពង់ស្ពឺ ពន្ធនាគារនៅកំពត ពន្ធនាគារនៅកំពង់ឆ្នាំង ពន្ធនាគារនៅកំពង់ចាម ពន្ធនាគារនៅកំពង់ធំ ពន្ធនាគារនៅកោះកុង ពន្ធនាគារនៅពោធិ៍សាត់ ពន្ធនាគារនៅបាត់ដំបង ពន្ធនាគារនៅបន្ទាយមានជ័យ ពន្ធនាគារនៅសៀមរាប និងពន្ធនាគារនៅស្វាយរៀង។

នៅឆ្នាំ២០១២ ទីបំផុតមានការវិវឌ្ឍន៍មួយចំនួន ដែលគួរឲ្យលើកទឹកចិត្ត ថ្វីបើការវិវឌ្ឍន៍នេះមិនទាន់ឈានដល់ពេលវេលា ដែលត្រូវប្រារព្ធពិធីអបអរសាទរនៃជ័យជំនះក៏ដោយ។

ចាប់តាំងពីខែឧសភា ឆ្នាំ២០១១មក តាមស្ថិតិជនជាប់ឃុំនៅក្នុងពន្ធនាគារចំនួន ១៨ ដែលអង្គការលីកាដូបានឃ្លាំមើល មានចំនួនថេរដដែល។ គិតមកត្រឹមថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១២ ពន្ធនាគារទាំង ១៨ នេះ បានផ្ទុកជនជាប់ឃុំចំនួន ១៣.៤៦៨ នាក់ ដែលចំនួននេះ បានថយចុះ ១.៦% យ៉ាងពិតប្រាកដ បើប្រៀបធៀបនឹងខែឧសភា ឆ្នាំ២០១១។

ទោះបីយ៉ាងណាក៏ដោយ ជនជាប់ឃុំសរុបនៅទូទាំងប្រទេស មានចំនួនកើនឡើងដល់ ១៥.៣៥១ នាក់ ដែលជាចំនួនកើនតិចតួច - ចំនួនកើនស្មើនឹង ២.៣% - នៅក្នុងរយៈពេលដូចគ្នា[៣]។ អត្រាឃុំខ្លួននៅតាមពន្ធនាគារទូទាំងប្រទេសមានចំនួន ១៧០.៦% ជាការកែលំអមួយ ទៅលើតួលេខកាលពីឆ្នាំមុន ដែលមានចំនួន ១៧៩% ដោយសារមានចំនួនកន្លែងបន្ថែម។ ចំនួនកន្លែងនៅក្នុងប្រព័ន្ធពន្ធនាគាររបស់ប្រទេសកម្ពុជាយើងបានធ្វើអោយកម្ពុជាស្ថិតនៅលំដាប់លេខ ៣៥ ក្នុងចំណោមប្រទេសដែលមានភាពចង្អៀតណែន ក្នុងពិភពលោក ប៉ុន្តែលំដាប់លេខនេះមានភាពប្រសើរបន្តិច បើប្រៀបធៀបនឹងឆ្នាំកន្លងទៅ ដែលកម្ពុជាស្ថិតនៅលំដាប់លេខ ២៥[៤]។

ប៉ុន្តែនៅតែមានសញ្ញាគួរឲ្យព្រួយបារម្ភ។

ទោះបីមានតួលេខកើនឡើងតិចតួចសម្រាប់ឆ្នាំ២០១១ - ២០១២ ក៏ដោយ ក៏ចំនួនជនជាប់ឃុំនៅតាមពន្ធនាគារទូទាំងប្រទេស នៅតែកើនឡើងយ៉ាងច្រើនស្មើនឹង ១៥.២% ចាប់តាំងតែពីខែមីនា ឆ្នាំ ២០១០[៥]មក។ ទោះជាអត្រាឃុំខ្លួនមានការធ្លាក់ចុះក៏ដោយក៏អត្រាទាំងនេះ ទំនងជាដោយសាតែការប៉ាន់ប្រមាណស្មើរនូវភាពចង្អៀតណែន។ អាជ្ញាធរ

---

[៣] អគ្គនាយកដ្ឋានពន្ធនាគារមិនបានផ្តល់ព័ត៌មានបច្ចុប្បន្នភាពជាសាធារណៈទៀងទាត់ឡើយ ស្តីពីចំនួនជនជាប់ឃុំនៅតាមពន្ធនាគារនៅទូទាំងប្រទេស។ ហេតុដូច្នេះ តួលេខទាំងនេះត្រូវបានធ្វើការប្រៀបធៀបពីខែមេសា ឆ្នាំ២០១១ និងខែកុម្ភៈ ឆ្នាំ២០១២ - ជាតួលេខដែលមានស្រាប់ និងល្អបំផុតសម្រាប់បង្ហាញពីកំណើនជនជាប់ឃុំសម្រាប់រយៈពេលមួយឆ្នាំ។

[៤] ដោយយោងតាមទិន្នន័យបច្ចុប្បន្នប្រហែលអាចស្ថិតនៅលំដាប់លេខ៣៤ ក្នុងចំណោម ១៩៦នៃឋានានុក្រមដែលបានស្ទង់។ សូមពិនិត្យមើលមជ្ឈមណ្ឌលសម្រាប់ការសិក្សាពន្ធនាគារ "Entire World-Occupancy Rates" សូមចូលមើលក្នុងវេបសាយ http://prisonstudies.org/info/worldbrief/wpb_stats.php?area =all&category=wb_occupancy

[៥] អគ្គនាយកដ្ឋានពន្ធនាគារបានរាយការណ៍អំពីចំនួនជនជាប់ឃុំទូទាំងប្រទេសស្មើនឹង ១៣.៣២៥ នាក់នៅក្នុងខែមីនា ឆ្នាំ២០១០។

ពន្ធនាគារបានទទួលស្គាល់ថា តួលេខទំហំផ្ទុកមិនត្រូវបានគេគណនាជាទម្រង់តែមួយ ដូចគ្នាជាចាំបាច់នៅទូទាំងប្រព័ន្ធគ្រប់គ្រងពន្ធនាគារឡើយ។

លក្ខណៈធ្ងន់ធ្ងរបំផុតនោះ គឺបុព្វហេតុជាមូលដ្ឋាននៃវិបត្តិចង្អៀតណែននៅតែមិនទាន់ត្រូវបានគេលើកយកមកដោះស្រាយនៅឡើយ។ ការចាប់ខ្លួនក្នុងបទល្មើសគ្រឿងញៀន ស្ទើរតែកើនឡើងបួនដងក្នុងឆ្នាំ២០១១ ហើយចំនួនជនជាប់ឃុំដែលត្រូវចោទពីបទល្មើសគ្រឿងញៀន ស្ទើរតែកើនឡើងបីដងក្នុងឆ្នាំ២០១១។ នៅតែមិនទាន់មានប្រព័ន្ធដោះលែង ដោយមានលក្ខខណ្ឌ។ ជនជាប់ឃុំប្រមាណ ៣.០០០ នាក់ ជាប់ត្រាំត្រែងក្នុងពន្ធនាគារ ដោយគ្មានសាលក្រម/សាលដីកាស្ថាពរឡើយ ទុកឲ្យពួកគេប្រឈមនឹងការឃុំខ្លួនហួសការកំណត់ទោស។ ការកាត់ទោសដោយមិនឃុំខ្លួន ដូចជាទោសការងារសហគមន៍មិនទាន់ត្រូវបានអនុវត្តជាលក្ខណៈប្រព័ន្ធឡើយ។

សរុបសេចក្តីមកមានការវិវឌ្ឍន៍បន្តិចបន្តួច ចំពោះការដោះស្រាយវិបត្តិចង្អៀតណែនកាលពីឆ្នាំមុន ប៉ុន្តែនៅតែមានការងារច្រើនទៀតត្រូវបំពេញបន្ត។

## អំពីរបាយការណ៍នេះ

របាយការណ៍មុនៗរបស់អង្គការលីកាដូ ស្តីពីភាពចង្អៀតណែននៅតាមពន្ធនាគារ បានផ្តល់នូវទិដ្ឋភាពរួមនៃវិបត្តិចង្អៀតណែននៅតាមពន្ធនាគារក្នុងប្រទេសកម្ពុជា លក្ខណៈស្ថិតិ និងបែបអត្ថាធិប្បាយ។ របាយការណ៍នេះ គឺជារបាយការណ៍មួយ បែបអត្ថាធិប្បាយបន្ត មានន័យថា ត្រូវយកទៅអានក្នុងបរិបទនៃរបាយការណ៍មុនៗរបស់អង្គការលីកាដូ។

ដើម្បីសម្រេចគោលដៅនេះផ្នែកទី១ នៃរបាយការណ៍នេះ មានបច្ចុប្បន្នភាពទិន្នន័យស្ថិតិស្នូលដោយផ្អែកលើតារាងនានា រាប់ទាំងរបាយការណ៍លើកទីមួយចំនួនពីររបស់អង្គការលីកាដូផង។

ផ្នែកទី២ នៃរបាយការណ៍នេះ គឺជាសេចក្តីសង្ខេប និងការធ្វើវិភាគទៅលើគន្លឹះនៃការវិវឌ្ឍន៍ទាំងឡាយ ដែលបានកើតឡើងចាប់តាំងពីមានរបាយការណ៍ចុងក្រោយរបស់អង្គការលីកាដូ ក្នុងខែកក្កដា ឆ្នាំ២០១១ ស្តីពីភាពចង្អៀតណែននៅតាមពន្ធនាគារ។ ផ្នែក

នេះមានស្ថិតិ គួសពន្យល់ពីនិន្នាការនានាផងដែរ ដែលមិនបានធ្វើវិភាគឲ្យបានពេញលេ
នៅក្នុងរបាយការណ៍មុនៗ របស់អង្គការលីកាដូ។

នៅក្នុងផ្នែកចុងក្រោយនៃរបាយការណ៍នេះ យើងខ្ញុំពិនិត្យឡើងវិញនូវអនុសាស សំខាន់ៗទាំងឡាយ ដែលបានធ្វើនៅក្នុងរបាយការណ៍របស់យើងក្នុងឆ្នាំ២០១០ និងឆ្ន ២០១១ ហើយនឹងតាមដានមើលភាពរីកចំរើន ដែលបានធ្វើឡើងឆ្ពោះទៅរកការបំពេ បាននូវអនុសាសន៍ទាំងនេះ។



*អគារនៅសម័យអាណានិគមស្ថិតក្នុងស្ថានភាពចាស់ទ្រុឌទ្រោមនៅក្នុងបរិវេណ នៃពន្ធនាគារខេត្ត កំពត។ ពន្ធនាគារនេះ បានកសាងឡើងនៅក្នុងឆ្នាំ១៩៣៦ ដោយគិតត្រឹមខែឧសភា ឆ្នាំ២០១២ ពន្ធនាគារនេះ មានផ្ទុកអ្នកទោសចំនួន ៥៥៥ នាក់ ដែលចំនួននេះលើសពីទំហំ ដែលអាចផ្ទុកបាន ២៨០%។*

# ១. ភាពចង្អៀតណែន: បច្ចុប្បន្នភាពទិន្នន័យស្នូល

តារាង និងប្លង់ព័ត៌មាននានាខាងក្រោមនេះ ផ្តល់នូវព័ត៌មានស្តីពីចំនួនជនជាប់ឃុំនៅតាមពន្ធនាគារក្នុងប្រទេសកម្ពុជា។ ស្ថិតិទាំងឡាយត្រូវបានដកស្រង់ចេញពីប្រភពផ្សេងៗគ្នារាប់ទាំងការសិក្សាស្រាវជ្រាវដោយអង្គការលីកាដូ ឯកសារអគ្គនាយកដ្ឋានពន្ធនាគារ និងរបាយការណ៍នានា ចេញផ្សាយដោយប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន។

ក្រាហ្វិកទី១ រៀបរាប់ពិស្តារអំពីចំនួនជនជាប់ឃុំនៅតាមពន្ធនាគារទូទាំងប្រទេសកម្ពុជា និងអត្រាជាប់ឃុំសរុបពីខែធ្នូ ឆ្នាំ២០០៧ ដល់ខែកុម្ភៈ ឆ្នាំ២០១២ នៅចន្លោះពេលតាមកាលកំណត់ (អគ្គនាយកដ្ឋានពន្ធនាគារមិនបានផ្សព្វផ្សាយជាសាធារណៈនូវចំនួនអ្នកជាប់ឃុំជាទៀងទាត់តាមរយៈពេលកំណត់ទេ)។ បន្ទាប់ពីចំនួនជនជាប់ឃុំកើនឡើងមិនប្រែប្រួលជាច្រើនឆ្នាំ ទីបំផុតអត្រាឃុំខ្លួនបានចាប់ផ្តើមថយចុះនៅចុងឆ្នាំ២០១១ និងដើមឆ្នាំ២០១២។ ការថយចុះកើតមានឡើងដោយសារការកើនឡើងនូវទំហំផ្ទុកនៃពន្ធនាគារ និងការថយចុះនូវអត្រាកំណើន:

**ទិន្នន័យជនជាប់ឃុំ និងការឃុំខ្លួននៅទូទាំងប្រទេស (គ្រប់ពន្ធនាគារ)**




**កំណត់សម្គាល់:**

- ទិន្នន័យនេះ ដកស្រង់ពី: ខែធ្នូ ឆ្នាំ២០០៧ ខែធ្នូ ឆ្នាំ២០០៨ ខែសីហា ឆ្នាំ២០០៩ ខែធ្នូ ឆ្នាំ២០០៩ ខែមិថុនា ឆ្នាំ២០០៩ ខែមិថុនា ឆ្នាំ២០១០ ខែធ្នូ ឆ្នាំ២០១០ ខែមេសា ឆ្នាំ២០១១ ខែវិច្ឆិកា ឆ្នាំ២០១១ និងខែកុម្ភៈ ឆ្នាំ២០១២ ។
- អគ្គនាយកដ្ឋានពន្ធនាគារបានរាយការណ៍ថា ថ្មីៗទំហំផ្ទុកអ្នកទោសនៃប្រព័ន្ធពន្ធនាគារគឺ ៩០០០ នាក់ តួលេខនេះគឺបានថ្មីតាំងពីចុងឆ្នាំ២០១១ ។ នៅដើមឆ្នាំ២០១១ ទំហំផ្ទុកអ្នកទោស ត្រូវបានរាយការណ៍ថា មានចំនួនប្រហែល ៨៣៦០នាក់។ នៅឆ្នាំ២០១០ ទំហំផ្ទុកអ្នកទោសត្រូវបានរាយការណ៍ថា មានចំនួន ៨០០០នាក់។ ទិន្នន័យទំហំផ្ទុកអ្នកទោសសម្រាប់ឆ្នាំ២០០៩ គឺជាការវាយតំលៃតាមរយៈការប្រើប្រាស់តំនូស បន្ទាត់ដូចគ្នានឹងឆ្នាំ២០១០។
- ប្រភព: របាយការណ៍ផ្លូវការណ៍របស់អគ្គនាយកដ្ឋានពន្ធនាគារ បានរាយការណ៍តាមប្រព័ន្ធ ផ្សព្វផ្សាយព័ត៌មាន និងទិន្នន័យផ្សេងទៀតរបស់អគ្គនាយកដ្ឋានពន្ធនាគារ។

តារាងខាងក្រោមនេះ គូសពន្យល់អំពីចំនួនជនជាប់ឃុំតាមពន្ធនាគារចំនួន១៨ ដែល អង្គការលីកាដូបានឃ្លាំមើលសម្រាប់ឆ្នាំ២០១០ ឆ្នាំ២០១១ និងឆ្នាំ២០១២។ អត្រាឃុំខ្លួនឆ្នាំ ២០១២ សម្រាប់ពន្ធនាគារនិមួយៗត្រូវបានរៀបរាប់នៅក្នុងក្រឡោនចុងក្រោយ។ សូមកត់សម្គាល់ថា ទំហំផ្ទុកនៃពន្ធនាគារជាច្រើន បានប្រែប្រួលចាប់តាំងពីឆ្នាំ២០១០ និងឆ្នាំ២០១១:

| ពន្ធនាគារ | ចំនួនជនជាប់ឃុំ(ខែមិថុនា ឆ្នាំ ២០១០) | ចំនួនជនជាប់ឃុំ(ខែឧសភា ឆ្នាំ២០១១) | ចំនួនជនជាប់ឃុំ (ខែឧសភា ឆ្នាំ ២០១២) | ទំហំផ្ទុក (ខែឧសភា ឆ្នាំ ២០១២) | ភាគរយសមត្ថភាពផ្ទុក (ខែឧសភា ឆ្នាំ ២០១២) |
|---|---|---|---|---|---|
| ប៉ៃលិន | ១៦៧ | ១៩២ | ១៦៨ | ២០០ | ៨៤% |
| មណ្ឌលអប់រំកែប្រែទី១ | ២,៦៤៤ | ២,៨៤៨ | ២,៨៦០ | ១,៦០០ | ១៧៨.៨% |
| មណ្ឌលអប់រំកែប្រែទី២ | ៧៧៧ | ៨១១ | ៧៣៣ | ៣០០ | ២៤៤.៣% |
| មណ្ឌលអប់រំកែប្រែទី៣ | ១,៥២៩ | ១,៥០២ | ១,៤៧៣ | ៨១០ | ១៨១.៩% |
| មណ្ឌលអប់រំកែប្រែទី៤ | ១៥៤ | ១៩៦ | ១៧៦ | ២១០ | ៨៣.៨% |
| តាខ្មៅ | ១,០៤២ | ១,០៩០ | ៩២៦ | ៣១៤ | ២៩៤.៩% |
| ព្រះសីហនុ | ៣៣២ | ៤៣៥ | ៣៦៥ | ១៥០ | ២៤៣.៣% |
| កំពង់ស្ពឺ | ៣១៣ | ៣៣៨ | ៣៥២ | ១៨០ | ១៩៥.៦% |
| កំពត | ៣៤៥ | ៤២៨ | ៤៥៤ | ១៦០ | ២៨៣.៨% |
| កំពង់ឆ្នាំង | ២៧១ | ៣៣៦ | ៤៣៦ | ១៥០ | ២៩០.៧% |
| កំពង់ចាម | ៧៩៨ | ៨៣៩ | ៨៥០ | ៦០០[៦] | ១៤១.៧% |
| កំពង់ធំ | ២០៨ | ២៧១ | ៤៣២ | ៣០០[៧] | ១៤៤% |
| កោះកុង | ២១៨ | ២៣៧ | ២៣៣ | ១៥០ | ១៥៥.៣% |
| ពោធិ៍សាត់ | ២២៩ | ២៣៣ | ២០៣ | ១២០ | ១៦៩.២% |
| បាត់ដំបង | ១,១៧៤ | ១,១៩១ | ១,២០៧ | ៦៥០ | ១៨៥.៧% |
| បន្ទាយមានជ័យ | ៨១៦ | ១,០៨៥ | ១,០៦០ | ៧០០ | ១៥១.៤% |
| សៀមរាប | ១,៣៦១ | ១,៤៨២ | ១,២៣៦ | ១,០០០ | ១២៣.៦% |
| ស្វាយរៀង | ២៦៦ | ៣១៧ | ៣០៤ | ១៦០ | ១៩០% |
| **សរុប** | **១២,៦៤៦** | **១៣,៦៨១** | **១៣,៤៦៨** | **៧,៧៥៤** | **១៧៣.៧%** |

[៦] ចំនួននេះឆ្លុះបញ្ចាំងកន្លែងបន្ថែមចំនួន ១០០ ចាប់តាំងពីខែកក្កដា ឆ្នាំ២០១១ តាមរយៈការបញ្ចប់ការសាងសង់អគារឃុំខ្លួនថ្មីមួយ។

[៧] ចំនួននេះឆ្លុះបញ្ចាំងកន្លែងបន្ថែមចំនួន ១០០ ចាប់តាំងពីខែកក្កដា ឆ្នាំ២០១១ តាមរយៈការបញ្ចប់ការសាងសង់អគារឃុំខ្លួនថ្មីមួយ។

តារាងចុងក្រោយនេះ ពិពណ៌នាអំពីអត្រាឃុំខ្លួននៅទូទាំងប្រទេសកម្ពុជា ដែលត្រូវបានកំណត់ជាចំនួនជនជាប់ឃុំក្នុងចំណោមមនុស្ស ១០០.០០០ នាក់ នៅទូទាំងប្រទេស។ ជាការលំបាកក្នុងការចង្អុលបង្ហាញឲ្យបានជាក់លាក់នូវអត្រាឃុំខ្លួន "ធម្មតា" - តួលេខទាំងឡាយ មានការប្រែប្រួលច្រើននៅជុំវិញពិភពលោក[៨] - ប៉ុន្តែអត្រាកម្ពុជាបន្តកើនឡើងជាលំដាប់ ដែលនៅតែជាបុព្វហេតុនៃកង្វល់:

**អត្រាឃុំខ្លួនទូទាំងប្រទេសកម្ពុជាចាប់តាំងពីឆ្នាំ២០០៦**

| ឆ្នាំ | ចំនួនប្រជាពលរដ្ឋទូទាំងប្រទស[៩] | ចំនួនជនជាប់ឃុំ | ជនជាប់ឃុំក្នុងចំណោមមនុស្ស ១០០,០០ នាក់ |
|---|---|---|---|
| ២០០៦ | ១៣,៥១៥,៨៨៤ | ១០,៣៣៨ | ៧៦.៥ |
| ២០០៧ | ១៣,៦៦៩,៨៥៧ | ១០,៩០២ | ៧៩.៨ |
| ២០០៨ | ១៣,៨២២,៦៤៤ | ១១,៦៨៨ | ៨៤.៦ |
| ២០០៩ | ១៣,៩៧៧,៩០៣ | ១៣,៣៤៥ | ៩៥.៥ |
| ២០១០ | ១៤,១៣៩,០០០ | ១៤,០៤៣ | ៩៩.៣ |
| ២០១១ | ១៤,៣៦៥,២២៤ | ១៥,៤០៤ | ១០៧.២ |
| ២០១២ | (ទិន្នន័យមិនទាន់ពេញលេញ) | | |

*(ទិន្នន័យជនជាប់ឃុំនៅពន្ធនាគារ ដែលបង្ហាញនូវតួលេខទូទាំងប្រទេសនៅបំណាច់ឆ្នាំប្រតិទិននីមួយៗ)*

[៨] កាសិក្សាស្រាវជ្រាវមួយដាក់អត្រាឃុំខ្លួនប្រទេសកម្ពុជា ប្រហែលនៅលំដាប់ខ្ពស់បំផុតទី២១ ក្នុងចំណោម ៣១ ប្រទេសនៅអាស៊ី។ សូមមើលមជ្ឈមណ្ឌលអន្តរជាតិសម្រាប់សិក្សាស្រាវជ្រាវកិច្ចការពន្ធនាគារ "អាស៊ី - អត្រាជនជាប់ឃុំនៅពន្ធនាគារក្នុងចំណោមមនុស្ស ១០០.០០០ នាក់នៅទូទាំងប្រទេស" មាននៅក្នុងគេហទំព័រ: http://prisonstudies.org/info/worldbrief/wpb_stats.php?area =contasia&category=wb_poprate។

[៩] ទិន្នន័យស្រង់ចេញពីគេហទំព័រ: http://data.worldbank.org/indicator/SP.POP.TOTL។ សូមកត់សម្គាល់ថា តួលេខចំនួនប្រជាពលរដ្ឋទូទាំងប្រទេសត្រូវបានកែប្រែយ៉ាងច្រើនតាមរបាយការណ៍មុនៗរបស់អង្គការលីកាដូ ដើម្បីឆ្លុះបញ្ចាំងទិន្នន័យឲ្យកាន់តែមានភាពត្រឹមត្រូវ។ ការកែសម្រួលនេះ បានកែប្រែអត្រាឃុំខ្លួនដែលបានប៉ាន់ប្រមាណកាលពីពេលមុនផងដែរ។ តួលេខសម្រាប់ឆ្នាំ២០១១ គឺជាការប៉ាន់ប្រមាណមួយផ្អែកលើតួលេខឆ្នាំ២០១០ បូកបញ្ចូលអត្រាកំណើន ១.៦%។

តារាងខាងក្រោមធ្វើការប្រៀបធៀបចំនួនជនជាប់ឃុំ - ទាំងពិរុទ្ធជន និងទណ្ឌិត - ដែលត្រូវបានឃុំខ្លួនតាមការចោទប្រកាន់ទាក់ទងនឹងគ្រឿងញៀន នៅក្នុងខែមករា ឆ្នាំ ២០១១ និងខែកុម្ភៈ ឆ្នាំ២០១២។ តារាងនេះ ពិពណ៌នាអំពីទិន្នន័យក្នុងពន្ធនាគារចំនួន ១៣ ដោយសារតែអគ្គនាយកដ្ឋានពន្ធនាគារមិនបានផ្តល់ជូនអង្គការលីកាដូ នូវស្ថិតិពេញលេញស្របគ្នាស្តីពីបទល្មើសដែលត្រូវបានចោទប្រកាន់ទៅលើជនជាប់ឃុំ។[១៤]

**ការប្រៀបធៀបស្ថិតិបទល្មើសគ្រឿងញៀនក្នុងពន្ធនាគារចំនួន១៣**
**(ខែមករា ឆ្នាំ២០១១ ប្រៀបធៀបនឹងខែកុម្ភៈ ឆ្នាំ២០១២)**

| ពន្ធនាគារ | ខែមករា ឆ្នាំ២០១១ | | | ខែកុម្ភៈ ឆ្នាំ២០១២ | | | កំណើន |
|---|---|---|---|---|---|---|---|
| | ជួញដូរ | ប្រើប្រាស់ | សរុប | ជួញដូរ | ប្រើប្រាស់ | សរុប | |
| ព្រះសីហនុ | ០ | ០ | ០ | ៨០ | ០ | ៨០ | ∞ |
| កំពង់ស្ពឺ | ៩ | ០ | ៩ | ២១ | ១០ | ៣១ | ២៤៤% |
| កំពត | ២០ | ០ | ២០ | ២៤ | ០ | ២៤ | ២០% |
| កំពង់ចាម | ៤៦ | ៣២ | ៧៨ | ៩៧ | ៧៨ | ១៧៥ | ១២៤% |
| កំពង់ឆ្នាំង | ៥ | ០ | ៥ | ១៤ | ០ | ១៤ | ១៨០% |
| កំពង់ធំ | ៨ | ០ | ៨ | ៣៣ | ២ | ៣៥ | ៣៣៨% |
| ពោធិ៍សាត់ | ២ | ០ | ២ | ៩ | ០ | ៩ | ៣៥០% |
| បាត់ដំបង | ៨៥ | ០ | ៨៥ | ៧៩ | ១១២ | ១៩១ | ១២៥% |
| បន្ទាយមានជ័យ | ១១៨ | ១៤ | ១៣២ | ៣៣២ | ១៣១ | ៤៦៣ | ២៥១% |
| សៀមរាប | ៧១ | ៧៩ | ១៥០ | ៩២ | ១១៥ | ២០៧ | ៣៨% |
| ស្វាយរៀង | ៦ | ០ | ៦ | ៩ | ០ | ៩ | ៥០% |
| កោះកុង | ៣ | ០ | ៣ | ២១ | ០ | ២១ | ៦០០% |
| មណ្ឌលអប់រំកែប្រែទី៣ | ៦៨ | ០ | ៦៨ | ៦៨ | ០ | ៦៨ | -- |
| **សរុប** | **៤៤១** | **១២៥** | **៥៦៦** | **៨៧៩(៩៩% ↑)** | **៤៤៨(២៥៨% ↑)** | **១,៣២៧** | **១៣៤%** |

---

[១៤] ទិន្នន័យទៀងទាត់ដែលអគ្គនាយកដ្ឋានពន្ធនាគារផ្តល់ទៅឲ្យអង្គការលីកាដូ កំណត់យ៉ាងច្បាស់លាស់អំពី "ការជួញដូរគ្រឿងញៀន" និង "ការប្រើប្រាស់ថ្នាំញៀន" ដែលជាប្រភេទទាក់ទងនឹងថ្នាំញៀនពីរបែប។ ទិន្នន័យបទល្មើសព្រហ្មទណ្ឌមិនបានយោងទៅតេបទបញ្ញត្តិជាក់លាក់ក្នុងច្បាប់ព្រហ្មទណ្ឌឡើយ។ តួលេខសម្រាប់ប្រភេទបទល្មើសព្រហ្មទណ្ឌទាំងពីរបែបក្នុងតារាងនេះ គឺដាក់បញ្ចូលពិរុទ្ធជនជាមួយទណ្ឌិត។ សូមកត់សម្គាល់ផងដែរថា ភាពខុសគ្នារវាង "ការប្រើប្រាស់" និង "ការជួញដូរ" តែងតែមិនត្រូវបានគាំទ្រដោយអង្គហេតុនៃករណីឡើយ។ តាមការសិក្សាស្រាវជ្រាវពីអង្គការលីកាដូ បង្ហាញឲ្យឃើញថា ករណី "ប្រើប្រាស់" ជាក់ស្តែងជាញឹកញាប់បានក្លាយទៅជាកម្មវត្ថុនៃការចោទប្រកាន់ពីបទជួញដូរ ផ្អែកលើភស្តុតាងមិនគ្រប់គ្រាន់ ឬគ្មានភស្តុតាងសោះ។ ការឧទាហរណ៍មួយ គឺមានករណីប្រឆាំងនឹងសួស ចន្ថា ជាប្រធានសហជីពដែលត្រូវបានកាត់ទោសពីបទជួញដូរគ្រឿងញៀន (ក្រោយមកបញ្ចុះទោសនៅត្រឹមបទចែកចាយទៅវិញ) នៅពេលដែលគាត់កាន់ថ្នាំញៀនចំនួនដ៏តិចតួច (សូមមើល សួស ចន្ថា ត្រូវបានដោះលែង ប៉ុន្តែដំកល់ការចោទប្រកាន់ខាងព្រហ្មទណ្ឌ ដែលមិនត្រឹមត្រូវ" យុទ្ធនាការសំលៀកបំពាក់ស្អាតស្អំនៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ មានក្នុងគេហទំព័រ: http://www. cleanclothes .org/news/sous-chantha-released-but-contrived-criminal-charges-upheld ហើយ "អ្នកគាំទ្រប្រមូលផ្តុំគ្នានៅខាងក្រៅពន្ធនាគារជាតិកម្ពុជា ដើម្បីស្វែងរកការដោះលែងប្រធានសហជីពដែលត្រូវជាប់ពន្ធនាគារ" សេចក្តីប្រកាសព័ត៌មានពីអង្គការលីកាដូនៅថ្ងៃទី២១ ខែមករា ឆ្នាំ២០១១ មានក្នុងគេហទំព័រ: http://www.licadho-cambodia.org/articles/20110121/130/index.html)។

## ការប្រៀបធៀបស្ថិតិបទល្មើសគ្រឿងញៀនទូទាំងប្រទេស
## (ខែវិច្ឆិកា ឆ្នាំ២០១០ ប្រៀបធៀបនឹងខែវិច្ឆិកា ឆ្នាំ២០១១)[១៦]

| បទល្មើស | ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ ២០១០ | ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ ២០១១ | ភាពខុសគ្នា |
|---|---|---|---|
| ចែកចាយគ្រឿងញៀន | ២៩២ | ៥៤១ | កំណើន ៨៥% |
| ជួញដូរគ្រឿងញៀន | ៦៨៨ | ១,៩៧៤ | កំណើន ១៨៧% |
| ប្រើប្រាស់គ្រឿងញៀន | ៥៥ | ២២៧ | កំណើន ៣១៣% |
| ផលិតគ្រឿងញៀន | ២ | ២ | -- |
| ជម្រុញនិងជួយសម្រួលក្នុងការផលិត ឬចែកចាយ | ៩ | ៣ | (ថយចុះ ២០០%) |
| **សរុប** | **១,០៤៦** | **២,៧៤៧** | **កំណើន ១៦៣%** |

តាមពិតមិនគួរឲ្យភ្ញាក់ផ្អើលទេដែលថា ការចាប់ខ្លួនទាក់ទងនឹងគ្រឿងញៀនកំពុងតែជម្រុញចំនួនជនជាប់ឃុំនៅពន្ធនាគារឲ្យកាន់តែកើនឡើងយ៉ាងឆាប់រហ័ស។ កាលពីឆ្នាំកន្លងទៅ គេបានឃើញការបង្ក្រាបយ៉ាងធំមួយទៅលើបទល្មើសគ្រឿងញៀន ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានជារឿយៗ បានពិពណ៌នាអំពីរឿងរ៉ាវរបស់អាជ្ញាធរ ដែលអះអាងពីចំនួនចាប់ខ្លួន។[១៧]

យោងតាមកាសែត *Phnom Penh Post*[១៨] ពួកគេទាំងអស់បានប្រាប់ឲ្យដឹងថាចំនួនការកាត់ឲ្យជាប់ទោស ទាក់ទងនឹងថ្នាំញៀនបានកើនឡើងជិត ៤ ដងនៅអំឡុងឆ្នាំ២០១១ គឺកើនពី ២៤៨ ក្នុងឆ្នាំ២០១០ រហូតដល់ ៩៥១ ក្នុងឆ្នាំ២០១១។ ការចាប់ខ្លួនមានសន្ទុះពី ៨៦៤ រហូតឡើងដល់ ១,៣០០។

---

[១៦] សូមមើលអគ្គនាយកដ្ឋានពន្ធនាគារ "របាយការណ៍ស្តីពីសមិទ្ធិផលការងារក្នុងឆ្នាំ២០១១ និងគោលដៅសម្រាប់ឆ្នាំ២០១២" ចេញផ្សាយ នៅខែកុម្ភៈ ឆ្នាំ២០១២ (បកប្រែក្រៅផ្លូវការជាភាសាអង់គ្លេស)។

[១៧] សូមមើលឧទាហរណ៍ បុត្រពស្មិតង្កា "ករណីគ្រឿងញៀនបង្កើនល្បឿន" កាសែត Phnom Penh Post ចេញផ្សាយថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១១ (កត់សម្គាល់ឃើញថានៅក្នុងខែកញ្ញា ឆ្នាំ២០១១ ការចាប់ខ្លួនទាក់ទងនឹងគ្រឿងញៀនបានកើនឡើងបីដង បើប្រៀបធៀបទៅនឹងរយៈពេលដូចគ្នានៅឆ្នាំ២០១០។ ឧត្តមសេនីយ៍ទោ ឌៀវ សាម៉ន អគ្គលេខាធិការស្តីទីនៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនក្រសួងមហាផ្ទៃបានមានប្រសាសន៍ថា ការចាប់ខ្លួនបានបង្ហាញពី "ការប្តេជ្ញាចិត្តយ៉ាងខ្លាំងដើម្បី [បង្ក្រាបគ្រឿងញៀន]" និងប្រយុទ្ធប្រឆាំងនឹង "ការជួញដូរ និងប្រើប្រាស់ថ្នាំញៀន")។

[១៨] បុត្រពស្មិតង្កា និងKristin Lynch "ការកាត់ទោសក្នុងរឿងគ្រឿងញៀនមានសន្ទុះកើនឡើងយ៉ាងឆាប់រហ័ស" កាសែត Phnom Penh Post ចេញផ្សាយថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១២។

## ម្ដាយជាប់ពន្ធនាគារ[២១] ពីបទល្មើសគ្រឿងញៀន
## (ខែមីនា ឆ្នាំ២០១១ ប្រៀបធៀបនឹងខែឧសភា ឆ្នាំ២០១២)

| ពន្ធនាគារ | ម្ដាយជាប់ឃុំក្នុងពន្ធនាគារ (ខែមីនា ឆ្នាំ២០១១) | | ម្ដាយជាប់ឃុំក្នុងពន្ធនាគារ (ខែឧសភា ឆ្នាំ២០១២) | |
|---|---|---|---|---|
| | ចំនួនសរុប | ចំនួនបទល្មើសគ្រឿងញៀន | ចំនួនសរុប | ចំនួនបទល្មើសគ្រឿងញៀន |
| មណ្ឌលអប់រំកែប្រែទី២ | ១៦ | ៩ | ១៥ | ៩ |
| តាខ្មៅ | ២ | ១ | ១ | ០ |
| កោះកុង | ១ | ១ | ១ | ១ |
| ពោធិ៍សាត់ | ៣ | ០ | ១ | ០ |
| បាត់ដំបង | ៥ | ២ | ១៦ | ១១ |
| បន្ទាយមានជ័យ | ៨ | ២ | ២៥ | ២១ |
| សៀមរាប | ៤ | ២ | ១១ | ៧ |
| ព្រះសីហនុ | ០ | ០ | ៧ | ៦ |
| កំពត | ១ | ០ | ១ | ០ |
| កំពង់ឆ្នាំង | ២ | ០ | ០ | ០ |
| កំពង់ចាម | ២ | ០ | ០ | ០ |
| **សរុប** | **៤៤** | **១៧(៣៩%)** | **៧៨** | **៥៥(៧១%)** |

[២១] ត្រូវបានកំណត់ថាជាស្ត្រីមានផ្ទៃពោះ និងស្ត្រីកំពុងរស់នៅក្នុងពន្ធនាគារជាមួយកូនរបស់ពួកគេ។ យោងតាមច្បាប់កូនក្មេងត្រូវបានអនុញ្ញាតឲ្យស្នាក់នៅជាមួយម្ដាយរបស់ខ្លួនក្នុងពន្ធនាគាររហូតដល់មានអាយុ ៣ ឆ្នាំ (សូមមើលច្បាប់ពន្ធនាគារត្រង់មាត្រា ៤១) តាមការអនុវត្តជាក់ស្តែងកូនក្មេងជាញឹកញាប់ត្រូវបានអនុញ្ញាតឲ្យស្នាក់នៅជាមួយម្ដាយក្នុងពន្ធនាគាររហូតដល់ពួកគេមានអាយុ ៦ ឆ្នាំ។

មិនទាន់ច្បាស់នៅឡើយថា តើរដ្ឋាភិបាលមានបានលៃលកមូលនិធិសម្រាប់គម្រោងនេះ ឬយ៉ាងណាទេ។

## ការគណនាទំហំផ្ទុក

កម្មវត្ថុមួយ ដែលមិនបានលើកក្នុងរបាយការណ៍ប្រចាំឆ្នាំ២០១២ របស់អគ្គនាយកដ្ឋានពន្ធនាគារនោះ គឺការសិក្សាស្រាវជ្រាវដ៏ទូលំទូលាយមួយ ស្តីពីទំហំផ្ទុកចំនួនជនជាប់ឃុំនៅតាមពន្ធនាគារបច្ចុប្បន្ន។ សូម្បីតែរបាយការណ៍នេះ ក៏មិនមានផ្តល់តួលេខអំពីទំហំផ្ទុក (ថ្វីបើតួលេខនេះ ត្រូវបានប្រព័ន្ធផ្សព្វផ្សាយព័ត៌មានធ្វើការផ្សព្វផ្សាយថាមានចំនួន ៩,០០០នាក់ក៏ដោយ)[៣១]។

អគ្គនាយកដ្ឋានពន្ធនាគារមិនដែលបានអនុម័តជាសារធារណៈនូវបទដ្ឋានទំហំផ្ទៃដីសម្រាប់ជនជាប់ឃុំម្នាក់ៗឡើយ ហើយក៏មិនដែលបានធ្វើការសិក្សាស្រាវជ្រាវសមស្របទូទាំងប្រទេស ស្តីអំពីទំហំផ្ទុកចំនួនជនជាប់ឃុំនៅតាមពន្ធនាគារ ដោយផ្អែកលើបទដ្ឋានបែបនេះឡើយ។ អាស្រ័យហេតុនេះ ទើបភាពត្រឹមត្រូវនៃតួលេខផ្ទុកនៅតាមពន្ធនាគារកម្ពុជាមានភាពខុសគ្នាយ៉ាងខ្លាំង។

ថ្វីបើមិនទាន់មានបទដ្ឋានអន្តរជាតិ សម្រាប់គ្រប់គ្រងទំហំផ្ទៃដីឲ្យបានសមស្របដែលត្រូវផ្តល់ឲ្យជនជាប់ឃុំម្នាក់ៗក៏ដោយ ក៏គណៈកម្មាធិការអឺរ៉ុប ដើម្បីទប់ស្កាត់អំពើទារុណកម្មបានលើកអនុសាសន៍ថា យ៉ាងតិចណាស់ជនជាប់ឃុំម្នាក់ៗត្រូវទទួលបានទំហំផ្ទៃដី ៤ ម៉ែត្រការ៉េសម្រាប់បន្ទប់ឃុំខ្លួនដែលមានជនជាប់ឃុំច្រើន[៣២]។ គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិបានបញ្ជាក់ថា "ទោះស្ថិតក្នុងស្ថានភាពមានវិបត្តិពិសេសក៏ដោយ ក៏ផ្ទៃក្រឡាផ្ទៃក្នុងបន្ទប់ឃុំខ្លួន និងអគារច្រើនជាន់មិនត្រូវឲ្យមានទំហំតូចជាង ២ ម៉ែត្រការ៉េឡើយសម្រាប់ជនជាប់ឃុំម្នាក់ៗ"[៣៣]។

---

[៣១] KuchNaren and Kate Bartlett, "ពន្ធនាគារកម្ពុជាមានសមត្ថភាពផ្ទុក ១៧១% នៅឆ្នាំ ២០១១" កាសែត The Cambodia Daily ចេញផ្សាយនៅថ្ងៃទី២២ ខែមីនា ឆ្នាំ២០១២។

[៣២] គេហទំព័រ: http://www.coe.int/t/commissioner/Viewpoints/070305_en.asp។

[៣៣] គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ "ទឹក អនាម័យ និងការរស់នៅក្នុងពន្ធនាគារ" ខែសីហា ឆ្នាំ២០០៥ ត្រង់ទំព័រ២១ (មានក្នុងគេហទំព័រ: http://www.icrc.org/eng/resources/documents/publication/p0823.htm)។

# ឧបសម្ព័ន្ធទី៤

សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស  លីកាដូ

LICADHO

CAMBODIAN LEAGUE FOR THE PROMOTION AND DEFENSE OF HUMAN RIGHTS

ផ្ទះលេខ១៦ ផ្លូវលេខ៩៩ ប្រអប់សំបុត្រលេខ៤៩៩ រាជធានីភ្នំពេញ កម្ពុជ
ទូរស័ព្ទលេខ៖ (+៨៥៥) ២៣ ៧២៧ ១០២/២១៦ ៦០២ អ៊ីម៉ែល៖ licacambodia14@gmail.com

# សេចក្តីថ្លែងការណ៍

## សូមបញ្ឈប់ការឃុំខ្លួនដែលមិនចាំបាច់ លើកុមារនៅក្នុងពន្ធនាគារដ៏ចង្អៀតណែន

រាជធានីភ្នំពេញ ថ្ងៃព្រហស្បតិ៍ ទី ០១ ខែមិថុនា ឆ្នាំ២០២៣

នៅក្នុងឱកាសនៃការប្រារព្ធទិវាអន្តរជាតិនៃសិទ្ធិកុមារ ឆ្នាំ២០២៣ នេះ និងនៅខណៈដែលកំណើននៃការឃុំខ្លួនអនីតិជននៅក្នុងពន្ធនាគារមានការកើនឡើងខ្ពស់គួរឱ្យកត់សម្គាល់ អង្គការ លីកាដូ សូមអំពាវនាវដល់រាជរដ្ឋាភិបាលកម្ពុជា ដែលក្នុងនោះរួមមាន ក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃ និងស្ថាប័នតុលាការ សូមមេត្តាធ្វើការដោះស្រាយជាបន្ទាន់ចំពោះវិបត្តិដែលកុមារជាច្រើននាក់កំពុងជាប់ និងចម្រើនវ័យនៅក្នុងពន្ធនាគារដ៏ចង្អៀតណែន ហើយដែលការឃុំខ្លួនលើកុមារទាំងនោះ គឺមិនមានភាពចាំបាច់ទាល់តែសោះ ។

ចំនួនអនីតិជន ដែលកំពុងជាប់ឃុំនៅក្នុងពន្ធនាគារទាំង ១៩ កន្លែង ដែលអង្គការ លីកាដូ បានឃ្លាំមើល មានការកើនឡើងជាង ៣០% ដែលជាចំនួនលើសពីចំនួននៅក្នុងឆ្នាំមុន ។ នេះបើយោងទៅតាមព័ត៌មានដែលទទួលបានពីមន្ត្រីរដ្ឋបាលពន្ធនាគារជាច្រើន ។ ចំនួនអនីតិជននៅក្នុងពន្ធនាគារមានរហូតដល់ទៅ ១.៦៥៨ នាក់ ក្នុងខែមេសា ឆ្នាំ ២០២៣ ។ ប្រហែល ៩៦% នៃអនីតិជនទាំងនោះជាកុមារា ៥២% នៃកុមារទាំងនោះ គឺកំពុងតែជាប់ឃុំជាបណ្តោះអាសន្នរង់ចាំសវនាការ និង ៣៧% ផ្សេងទៀតកំពុងរង់ចាំសាលក្រមស្ថាពរ ។

ច្បាប់ជាតិទទួលស្គាល់ថា ពន្ធនាគារមិនមែនជាកន្លែងសម្រាប់អនីតិជននោះទេ ហើយច្បាប់ទាំងនោះផ្តល់ឱ្យអាជ្ញាធរនូវជម្រើសផ្សេងៗជាច្រើនទៀតក្រៅពីការឃុំខ្លួនកុមារ ។ លើសពីនេះ ច្បាប់បានកំណត់នូវអនីតិជនដែលអាចទទួលខុសត្រូវ និងទទួលរងទោសទណ្ឌ គឺមានអាយុចន្លោះពី ១៤ ទៅ ១៧ ឆ្នាំ នៅពេលពួកគេបានប្រព្រឹត្តនូវបទល្មើសដែលច្បាប់កំណត់ ។ ច្បាប់ស្តីពីយុត្តិធម៌អនីតិជនបានចែងថា ការឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការ គឺជាជម្រើសចុងក្រោយសម្រាប់កុមារ ដោយយោងទៅតាមគោលការណ៍នៃការសន្មត់ជាមុនថាគ្មានទោស និងដើម្បីលើកកំពស់ការប្រើប្រាស់នូវប្រភេទទោសផ្សេងៗទៀត ក៏ដូចជាទោសសហគមន៍ ។ ដូចគ្នានេះដែរ ការប្រើប្រាស់ការព្យួរទោស ឬការដោះលែងដោយមានលក្ខខណ្ឌ គួរត្រូវបានប្រើប្រាស់ជំនួសឱ្យការដាក់ទោសពន្ធនាគារមកលើកុមារ ។

ក៏ប៉ុន្តែមកដល់បច្ចុប្បន្ននេះ ជម្រើសផ្សេងៗទាំងនេះ នៅមិនទាន់បានតុលាការយកមកប្រើប្រាស់នៅឡើយទេ ហើយចំនួនអនីតិជនដែលជាប់ឃុំ នៅតែបន្តហក់ឡើងយ៉ាងខ្ពស់ ដែលជាសញ្ញាមួយគួរឱ្យព្រួយបារម្ភ ។

អំឡុងពេលដែលកម្ពុជាកំពុងបន្តនូវយុទ្ធនាការបង្ក្រាបគ្រឿងញៀននោះ ការចាប់ខ្លួនក្នុងករណីពាក់ព័ន្ធ នឹងគ្រឿងញៀនមានការកើនឡើងក្នុងឆ្នាំ ២០២២ ។ ដូចនេះវាអាចធ្វើឱ្យចំនួនអនីតិជននៅក្នុងពន្ធនាគារភាគច្រើន គឺត្រូវបានចាប់ខ្លួនដោយសារបទល្មើសគ្រឿងញៀនតូចតាច ដែលក្នុងករណីនេះ ជម្រើសនៅដាក់ឱ្យនៅក្រៅឃុំបណ្ដោះអាសន្ន ឬជម្រើសផ្សេងទៀតដែលអាច គួរត្រូវបានតុលាការប្រើប្រាស់ ដើម្បីធានាថាកុមារមិនត្រូវបានបញ្ជូនទៅកាន់ពន្ធនាគារដោយមិន ចាំបាច់នោះទេ ។

ការការពារសិទ្ធិចំពោះមុខនីតិវិធីច្បាប់ គឺចាំបាច់ត្រូវតែមានសម្រាប់អនីតិជនដែលត្រូវបានសង្ស័យថាបានប្រព្រឹត្តនូវបទល្មើសព្រហ្មទណ្ឌ ក៏ប៉ុន្តែកុមារជាច្រើនបានរាយការណ៍ថាពួកគេមិនដែលបាននិយាយជាមួយនឹងមេធាវី ឬក៏មានឱកាសស្នើសុំនៅក្រៅឃុំបណ្ដោះអាសន្ននោះឡើយ ។ ការប្រើវិធានការនៃការឃុំខ្លួនបណ្ដោះអាសន្នច្រើនហួសហេតុ តែងតែត្រូវបានតុលាការសម្រេចប្រើប្រាស់ដោយផ្អែកលើទ្រឹស្ដី "ឆន្ទានុសិទ្ធិ" របស់ចៅក្រម ហើយជម្រើសផ្សេងទៀតក្រៅពីការឃុំខ្លួនមិនត្រូវបានតុលាការប្រើប្រាស់ឡើយ ដែលនេះធ្វើឱ្យសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងសុខមាលភាពរបស់អនីតិជន មិនត្រូវបានតុលាការយកចិត្តទុកដាក់ឡើយ ។

យ៉ាងតិចណាស់ មានកុមារ ៨២ នាក់ កំពុងតែរស់នៅក្នុងពន្ធនាគារ ជាមួយម្ដាយដែលជាប់ទោស ហើយនិងមានស្ត្រី និងក្មេងស្រី ៣០ នាក់ ផ្សេងទៀត កំពុងតែមានផ្ទៃពោះ នៅក្នុងពន្ធនាគារគិតត្រឹមខែមេសា ឆ្នាំ២០២៣ នេះ ។ ការដាក់ឱ្យនៅក្រៅឃុំបណ្ដោះអាសន្ន គួរត្រូវបានផ្ដល់ឱ្យដូចគ្នាដល់ម្ដាយរបស់ក្មេងៗ និងស្ត្រី/ក្មេងស្រីដែលកំពុងមានផ្ទៃពោះទាំងនោះ ដូចនេះពួកគេអាចថែរក្សាទំនាក់ទំនងរវាងម្ដាយ និងកូននៅឯផ្ទះ ។

ផលប៉ះពាល់ចំពោះការឃុំខ្លួនលើកុមារគឺ មានភាពធ្ងន់ធ្ងរ ហើយអាចកាន់តែអាក្រក់ខ្លាំងទៅៗនៅពេលដែលនៅក្នុងពន្ធនាគារមានភាពចង្អៀតណែន និងកង្វះនូវអនាម័យ ដែលស្ថានភាពនេះបានកើតមានឡើងនៅក្នុងប្រព័ន្ធពន្ធនាគារនៅក្នុងប្រទេសទាំងមូល ។ ពន្ធនាគារជាច្រើន ដែលអង្គការលីកាដូ បានធ្វើការងារជាមួយ គឺមានអនីតិជនជាច្រើនតែងតែមិនត្រូវបានដាក់ឱ្យនៅដាច់ដោយឡែកពីពន្ធនាគារសម្រាប់មនុស្សពេញវ័យនោះទេ ហើយពន្ធនាគារទាំងនោះមានអត្រាផ្ទុកមនុស្សជាមធ្យម ២៥០% នៃសមត្ថភាពស្ដង់ដាដែលពន្ធនាគារទាំងនោះអាចដាក់បាន ដោយគិតត្រឹមខែមេសានេះ ។ លើសពីនេះ មានពន្ធនាគារចំនួន ៣ កន្លែង មានអត្រាផ្ទុកមនុស្សរហូតដល់ទៅជាង ៤៥០% នៃ

សមត្ថភាពដែលអាចដាក់បានទៅទៀត ។ អ្នកដែលត្រូវជាប់ឃុំ រួមទាំងកុមារផងដែរ តែងតែរាយការណ៍ពីកង្វះខាតនូវអាហារ ទឹក កន្លែងគេងសមរម្យ និងទំនាក់ទំនងជាមួយក្រុមគ្រួសារ ហើយអ្នកទាំងនោះត្រូវចំណាយថវិកាបន្ថែមដើម្បីបំពេញតម្រូវការទាំងនោះ ។ រីឯ ការទទួលបាននូវការថែទាំសុខភាព និងជំនួយរូបបត្ថម្ភវិញ គឺមិនគ្រប់គ្រាន់ស្មើភាពគ្នានោះទេ ដែលនេះនឹងបង្កគ្រោះថ្នាក់ដល់ជីវិតទាំងម្តាយ និងកូនរបស់ពួកគេផងដែរ ។

ការព្យាយាមដែលមានពីមុនមួយចំនួន ដើម្បីដោះស្រាយនូវវិបត្តិនេះ មិនដែលទទួលបានជោគជ័យនោះឡើយ ។ ជំនួសឱ្យការកម្រិតចំនួនកុមារដែលត្រូវជាប់ឃុំ រាជរដ្ឋាភិបាលបែរជាធ្វើការសាងសង់នូវពន្ធនាគារថ្មីបន្ថែម ដោយគ្រាន់តែដាក់ឈ្មោះថាជាមណ្ឌលស្តារយុវនីតិសម្បទាទៅវិញ ។ មណ្ឌលនេះបានបើកឱ្យដំណើរការនៅក្នុងខេត្តកណ្តាល កាលពីខែធ្នូ ឆ្នាំ ២០២១ ហើយមណ្ឌលនេះត្រូវបានបង្កើតឡើងក្នុងគោលបំណង ធ្វើជាមជ្ឈមណ្ឌលឃុំខ្លួនអនីតិជនដែលមានទោសមកពីគ្រប់ខេត្ត និងអាចឃុំខ្លួនអនីតិជនដែលមានអាយុរហូតដល់ ២៤ ឆ្នាំ ។ យ៉ាងតិចណាស់ មានក្មេងប្រុស ១៣០ នាក់ ដែលត្រូវបានផ្តន្ទាទោសរួច ត្រូវបានបញ្ជូនចូលទៅក្នុងមណ្ឌលនេះ ដែលក្នុងនោះមានក្មេងប្រុសមួយចំនួនត្រូវបាននគរបាលដឹកពីពន្ធនាគារខេត្តនៅតំបន់ឆ្ងាយ ដូចជាបន្ទាយមានជ័យ ។ ដោយនេះជាមណ្ឌលតែមួយសម្រាប់អនីតិជនដែលមកពីគ្រប់ពន្ធនាគារនៅទូទាំងប្រទេស វាធ្វើឱ្យសមាជិកគ្រួសារដែលរស់នៅឆ្ងាយប្រឈមនឹងកង្វះលទ្ធភាពក្នុងការមកសួរសុខទុក្ខ ក៏ដូចជាលទ្ធភាពក្នុងការផ្គត់ផ្គង់ជំនួយចាំបាច់ដល់កូនៗរបស់ពួកគេបាន ។

យើងខ្ញុំសូមទាមទារឱ្យបញ្ឈប់ការឃុំខ្លួន សម្រាប់ករណីមួយចំនួនដែលមិនចាំបាច់មកលើកុមារដែលនេះជារំលោភសិទ្ធិអនីតិជន និងអត្ថប្រយោជន៍របស់កុមារយ៉ាងខ្លាំង ទាំងការដាក់នៅក្នុងពន្ធនាគារដែលមានស្រាប់ ឬពន្ធនាគាថ្មីដែលហៅថា មណ្ឌលស្តារយុវនីតិសម្បទា ។ ការប្រើប្រាស់នូវការឃុំខ្លួនហួសប្រមាណនេះ ធ្វើឱ្យកុមារបាត់បង់សេរីភាព ទំនាក់ទំនងគ្រួសារ និងសុខមាលភាព ។ អាជ្ញាធរត្រូវតែដោះស្រាយនូវបញ្ហាដែលកំពុងតែកើតឡើងនេះជាបន្ទាន់ និង៖

- អនុវត្តវិធានការដាក់ឱ្យក្រៅឃុំបណ្តោះអាសន្នលើគ្រប់អនីតិជន ស្ត្រី/ក្មេងស្រីមានផ្ទៃពោះ និងម្តាយដែលមានកូនតូច និងអនុវត្តជម្រើសទោសដទៃទៀតជំនួសឱ្យការឃុំឃាំង ។ ក៏ដូចគ្នាដែរ គឺការអនុវត្តវិធានការខាងលើនេះចំពោះអ្នកដែលប្រព្រឹត្តបទល្មើសគ្រឿងញៀនតូចតាច ។ សូមមេត្តាប្រើប្រាស់នូវវិធានការទាំងនេះសម្រាប់ករណីក្រោយៗផ្សេងទៀត ដោយកម្រិតការប្រើប្រាស់ការឃុំខ្លួនបណ្តោះអាសន្នតែក្នុងករណីចាំបាច់ ឬជម្រើសចុងក្រោយដូចមានចែងនៅក្នុងច្បាប់ ។

- ធានាថាគ្រប់អនីតិជនទាំងអស់ ដែលត្រូវបានតុលាការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ ទទួលបានមេធាវីការពារ និងត្រូវទទួលបានការជូនដំណឹងអំពីសិទ្ធិស្នើសុំនៅក្រៅឃុំបណ្តោះអាសន្ន ។
- ធ្វើឱ្យកាន់តែប្រសើរឡើងនូវលក្ខខណ្ឌនៅក្នុងពន្ធនាគារ ដើម្បីធានាថាអ្នកជាប់ឃុំម្នាក់ៗ រួមទាំងអនីតិជន ទទួលបាននូវអាហារូបត្ថម្ភសមរម្យ ការថែទាំសុខភាព ការសួរសុខទុក្ខពីក្រុមគ្រួសារ និងមានឱកាសក្នុងការអភិវឌ្ឍខ្លួន និងជាពិសេសការកាត់បន្ថយនូវចំនួនអ្នកជាប់ឃុំនៅក្នុងពន្ធនាគារ ៕




*នៅក្នុងពន្ធនាគារចំនួន ១៩ កន្លែង នៃចំនួនពន្ធនាគារទាំង ៣០កន្លែង ដែលអង្គការ លីកាដូ ឃ្លាំមើល

# ឧបសម្ព័ន្ធទី៥

ច្បាប់ចម្លង

# ព្រះរាជក្រឹត្យ

នស/រកត/០៤២៣/២០១

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានតួមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២១១/០២១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីពន្ធនាគារ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០១២១/០៣០ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២១ ស្តីពីការបន្ធូរបន្ថយទោស និងការលើកលែងទោស
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** : លើកលែងទោសឱ្យទណ្ឌិតឈ្មោះ [redacted] ភេទប្រុស កើតឆ្នាំ១៩៧៣ ដែលត្រូវបានតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៣ឆ្នាំ តាមអំណាចសាលដីកាព្រហ្មទណ្ឌស្ថាពរលេខ ៤៤៥ VI ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២១ របស់តុលាការកំពូល។

**មាត្រា២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

[illegible]

**បានប្រទាប់ព្រះរាជលញ្ឆករហើយ**

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៦ ខែមេសា ឆ្នាំ២០២៣

**នរោត្តម សីហមុនី**